ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥

## ការទទួលខុសត្រូវ ប្រសិទ្ធភាព គុណភាព សមធម៌

ក្រសួងសុខាភិបាល

មេសា ២០០៨

# ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨_២០១៥

## ការទទួលខុសត្រូវ ប្រសិទ្ធភាព គុណភាព សមធម៌

ក្រសួងសុខាភិបាល

មេសា ២០០៨

# អារម្ភកថា

ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៣-២០០៧ ត្រូវបានប្រកាសឱយប្រើប្រាស់ជាផ្លូវការ នៅខែសីហា ឆ្នាំ២០០២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា។

មន្ត្រី-បុគ្គលិកសុខាភិបាលទាំងអស់នៅគ្រប់ថ្នាក់នៃប្រពន្ធ័សុខាភិបាល រួមជាមួយដៃគូពាក់ពន្ធ័ជាតិ អន្តរជាតិ និងសហគមន៍ បានអនុវត្តផែនការនេះដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីឈានឆ្ពោះទៅសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជាផ្នែកសុខភាពនៅជំណាច់ឆ្នាំ២០១៥។

ការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០០៥ បានបង្ហាញថាប្រទេសកម្ពុជាកំពុងស្ថិតនៅលើមាគ៌ានៃវឌ្ឍនភាព ឆ្ពោះទៅសំរេចដោយជោគជយ័គោលដៅអភិវឌ្ឍន៍សហសវត្សទី៤ (បន្ថយការស្លាប់របស់កុមារ) និងគោលដៅទី៦ (ប្រយុទ្ធនឹងជំងឺឆ្លងចំបងៗ: ជំងឺអេដស៍ របេង និងគ្រុនចាញ់)។ លើកលែងតែគោលដៅទី៥ (លើកកំពស់សុខភាពមាតា) ការកាត់បន្ថយអត្រាស្លាប់របស់មាតានៅខ្ពស់នឹងបន្តនៅជាបញ្ហាប្រឈមមុខដ៏ស្រួចស្រាវបំផុតដែលតំរូវឱយមានការវិនិយោគធនធានកាន់តែច្រើនថែមទៀតទន្ទឹមគ្នានឹងការពង្រឹងអន្តរាគមន៍ ការបន្តអភិវឌ្ឍន៍ស្ថាប័ននិងការកសាងសមត្ថភាព ព្រមទាំងកិច្ចដំណើរការមុខងារនៃប្រពន្ធ័សុខាភិបាល ការសំរបសំរួល និងកិច្ចសហការពហុវិស័យឱយកាន់តែមានប្រសិទ្ធភាព ។

ផែនការយុទ្ធសាស្ត្រសុខាភិបាលលើកទី២ (២០០៨-២០១៥) ត្រូវបានអភិវឌ្ឍន៍ដោយឈរលើទីតាំងដ៏រឹងមាំនៃបទពិសោធន៍ ទាំងចំនុចខ្លាំង និងចំនុចខ្សោយនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ២០០៣-២០០៧ និងមានគោលដៅដោះស្រាយបញ្ហាសុខភាពជាអាទិភាពរបស់ប្រជាជនកម្ពុជា នៅក្នុងរយៈពេលប្រាំបីឆ្នាំខាងមុខ ដោយប្រើប្រាស់ឱយអស់លទ្ធភាពនូវកាលានុវត្តភាពជាសក្តានុពល ដែលរាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការលើកស្ទួយសុខភាពប្រជាជនកម្ពុជាគ្រប់រូបជាវិស័យអាទិភាពមួយនៅក្នុងការវិនិយោគធនធានរដ្ឋសំរាប់វិស័យសង្គម។ ឆន្ទៈនយោបាយដ៏មោះមុតនេះ ត្រូវបានសបញ្ជាក់តាមរយៈកំណើនការវិភាជន៍ថវិកាជាតិប្រចាំឆ្នាំ សំរាប់វិស័យសុខាភិបាល ការប្រើប្រាស់ថវិកាជាតិ ទ្រទ្រង់ដល់កម្មវិធីមូលនិធិសមធម៌ ដើម្បីដកចេញនូវរបាំងហិរញ្ញវត្ថុក្នុងការមកទទួលយកសេវាអប់រំសុខភាពបង្ការ ពិនិត្យ-ថែទាំនិងព្យាបាល ដោយប្រជាជនក្រីក្រនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ព្រមទាំងការផ្តល់ប្រពន្ធ័លាភការនៅក្នុងក្របខណ្ឌ័នៃកំណែទំរង់បៀវត្សរបស់រាជរដ្ឋាភិបាល ដើម្បីលើកទឹកចិត្តដល់បុគ្គលិកសុខាភិបាល ឱយបំពេញការងារផ្តល់សេវាជូនប្រជាជនកាន់តែមានប្រសិទ្ធភាព និងសមធម៌ពិសេសនៅតំបន់ជនបទដាច់ស្រយាល តាមរយៈកម្មវិធីកន្សោមអាទិភាព និងការផ្តល់ប្រាក់ឧបត្ថម្ភដល់ឆ្មបទូទាំងប្រទេស សំរាប់ជួយឱយមានការសំរាលកូនប្រកបដោយសុវត្ថិភាពនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ។ កាលានុវត្តភាពដ៏សំខាន់ពីរ ដែលនឹងជួយសំរិតសំរាំងតួនាទី និងមុខងារស្នូលនៃប្រពន្ធ័សុខាភិបាលឱយកាន់តែឆ្លើយតបទៅនឹងតំរូវការផ្នែកសុខភាពរបស់ប្រជាជននិងមានការទទួលខុសត្រូវខ្ពស់នោះ គឺការអនុវត្តន៍បែបបទនៃ

គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល។ អភិក្រមយុទ្ធសាស្ត្រសុខាភិបាល២០០៨–២០១៥ បានឆ្លុះបញ្ចាំងពីកត្តាបរិបទទាំងអស់ខាងលើនេះ។

ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨–២០១៥ បានកំណត់ច្បាស់លាស់នូវកម្មវិធីគោលនយោបាយសុខាភិបាលចំនួន១៥ចំណុច ដែលនឹងត្រូវយកមកអនុវត្តដោយអង្គភាពសុខាភិបាលគ្រប់ថ្នាក់ ដើម្បីឈានទៅសំរេចគោលបំណងចំបង៣របស់ផែនការ៖ បន្ថយការឈឺនិងស្លាប់របស់មាតា–ទារកនិងកុមារ និងការលើកកំពស់សេវាសុខភាពបន្តពូជ បន្ថយអត្រាឈឺនិងអត្រាស្លាប់ដោយសារជំងឺអេដស៍–របេង–គ្រុនចាញ់និងជំងឺឆ្លងដទៃទៀត និងបន្ថយបន្ទុកជំងឺមិនឆ្លង និងបញ្ហាសុខភាពដទៃទៀត។

ក្នុងការឈានទៅសំរេចគោលបំណងខាងលើនេះយុទ្ធសាស្ត្រសុខាភិបាលត្រូវបានអភិវឌ្ឍន៍ ដោយផ្តោតលើផ្នែកជាយុទ្ធសាស្ត្រចំបង៥៖ ការផ្តល់សេវាថែទាំសុខភាព ហិរញ្ញប្បទានសុខាភិបាល ធនធានមនុស្សសុខាភិបាល ប្រពន្ធ័ពត៌មានសុខាភិបាល និងអភិបាលកិច្ចប្រពន្ធ័សុខាភិបាល ដើម្បីតំរង់ទិសអន្តរាគមន៍ទូទាំងវិស័យសុខាភិបាលស្របតាម “ យុទ្ធសាស្ត្រចតុកោណ ” និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍនជាតិរបស់រាជរដ្ឋាភិបាល។

ការអនុវត្តន៏ដោយជោគជយ័នៃផែនការយុទ្ធសាស្ត្រសុខាភិបាល២០០៨–២០១៥ នឹងបង្កើនតំរូវការផ្នែកសុខភាព និងលទ្ធភាពទទួលយកសេវាថែទាំមានគុណភាពប្រកបដោយសមធម៌ ដើម្បីឱយប្រជាជនកម្ពុជាទាំងអស់មានលទ្ធភាពទទួលបានអត្ថប្រយោជន៏ផ្នែកសុខភាព និងសុខុមាលភាពក្នុងកំរិតអតិប្បរមា ដែលនឹងរួមចំណែកដ៏សំខាន់ ដល់ដំណើរការយូរអង្វែងនៃការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ទន្ទឹមគ្នាដែលការអភិវឌ្ឍន៏ផ្នែកសេដ្ឋកិច្ចនិងសង្គមដែលកំពុងលូតលាស់យ៉ាងឆាប់រហាស់។

ក្រសួងសុខាភិបាលមានជំនឿយ៉ាងមុតមាំថា ផែនការយុទ្ធសាស្ត្រនេះនឹងផ្តល់នូវក្របខណ្ឌ័ការងាររឹងមាំឈរលើចក្ខុវិស័យរួមសំរាប់ថ្នាក់ដឹកនាំ មន្ត្រីរាជការ–បុគ្គលិកសុខាភិបាលទូទាំងប្រទេស ក្រសួង–ស្ថាបន័ពាក់ពន្ធ័ ដៃគូអភិវឌ្ឍន៏ និងអង្គការជាតិ–អន្តរជាតិ ធ្វើសកម្មភាពរួមគ្នាដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ចំពោះការលើកស្ទួយសុខភាពនិងសុខុមាលភាពប្រជាជនកម្ពុជាទាំងអស់។

ភ្នំពេញ ថ្ងៃទី១១ ខែមេសា ឆ្នាំ ២០០៨

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ក្រសួងសុខាភិបាល

វេជ្ជ. នុត–សុខុម

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមវាយតំលៃខ្ពស់ចំពោះមន្ត្រីដឹកនាំជាន់ខ្ពស់ក្រសួងសុខាភិបាលដែលបានផ្តល់នូវការគាំទ្រ និងមគ្គុទេសភាពក្នុងការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រសុខាភិបាលលើកទី២ ២០០៨-២០១៥ (ផ.យ.ស.២)។

ឯកសារដ៏មានសារៈសំខាន់នេះនឹងយកទៅប្រើប្រាស់ដើម្បី តំរង់ទិសការងារក្នុងវិស័យសុខាភិបាលទាំងមូលសំរាប់អំលុងពេលខាងមុខ និងដើម្បីត្រួសត្រាយការខិតខំប្រឹងប្រែងរបស់យើង ក្នុងការដោះស្រាយអាទិភាពនិងតំរូវការផ្នែកសុខភាពរបស់ប្រជាជន។ ឯកសារនេះនឹងមិនអាចកើតចេញជារូបរាងបានទេ បើសិនជាគ្មានការខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់ក្រុមការងារអភិវឌ្ឍន៍ ផ.យ.ស.២ ដឹកនាំដោយ ឯ.ឧ សាស្ត្រាចារ្យ កើត មៀច អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ និង ឯ.ឧ វេជ្ជ. ទេព លន់ អគ្គនាយកបច្ចេកទេសសុខាភិបាល។

បែបបទនៃការពិគ្រោះយោបល់ដែលបានប្រព្រឹត្តទៅ គឺមានការចូលរួមយ៉ាងសកម្ម និងការផ្តល់យោបល់ចូលដ៏មានតំលៃពី ៖

- អនុក្រុមការងារផ្នែកអភិវឌ្ឍន៍ស្ថាប័ន ក្រោមការដឹកនាំរបស់ ឯ.ឧ សាស្ត្រាចារ្យ កើត មៀច
- អនុក្រុមការងារផ្នែកសុខភាពមាតា-កុមារក្រោមការដឹកនាំរបស់លោកសាស្ត្រាចារ្យសាន់ចន្ទ័ សឿន អគ្គនាយករងបច្ចេកទេសសុខាភិបាល
- អនុក្រុមការងារផ្នែកជំងឺឆ្លងនិងជំងឺមិនឆ្លង ក្រោមការដឹកនាំរបស់លោក ឯ.ឧ វេជ្ជ. ទេព លន់

សូមថ្លែងអំណរគុណចំពោះលេខាធិការដ្ឋានក្រុមការងារ ក្រោមការដឹកនាំរបស់ លោកវេជ្ជ. ច ម៉េងចូ អគ្គនាយករងបច្ចេកទេសសុខាភិបាល។

ខ្ញុំសូមកោតសរសើរ ចំពោះការខិតខំប្រឹងប្រែងអស់កំលាំងកាយចិត្ត របស់មន្ត្រី-បុគ្គលិកនៃនាយកដ្ឋានផែនការនិងពត៌មានសុខាភិបាល ក្នុងដំណើរការនៃការអភិវឌ្ឍន៍ ផ.យ.ស.២។ សូមថ្លែងអំណរជាពិសេសចំពោះលោកវេជ្ជបណ្ឌិត. ឡូ វាសនាគីរី ប្រធាននាយកដ្ឋានផែនការ ដែលបានដឹកនាំការសំរបសំរួល រៀបចំនិងចាត់ចែងការអភិវឌ្ឍន៍ផែនការ ការពិគ្រោះយោបល់ និងសរសេរ-ចងក្រងឯកសារផែនការ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ អង្គការក្រៅរដ្ឋាភិបាល និងលោក-លោកស្រីទាំងអស់ដែលបានរួមវិភាគទាន និងផ្តល់ការគាំទ្រដល់ការងារដ៏សំខាន់នេះ ពិសេសគំរោងទ្រទ្រង់វិស័យសុខាភិបាល អង្គការ URC ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (USAID) និងអង្គការសុខភាពពិភពលោក។

**វេជ្ជ. នុត សុខុម**
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

# មាតិកា


អារម្ភកថា i
សេចក្តីថ្លែងអំណរគុណ iii
មាតិកា iv
ក្រុមការងារនិងអ្នកចូលរួមកសាងផែនការ vi
បែបបទនៃការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រសុខាភិបាល viii
អក្សរកាត់ ix
សេចក្តីសង្ខេប x
**ជំពូក ១: ទិសដៅគោលនយោបាយសុខាភិបាល** ១
១. ចក្ខុវិស័យ ២
២. បេសកកម្ម ២
៣. គុណតំលៃនិងគោលការណ៍ ៣
៤. ទិសដៅគោលនយោបាយសុខាភិបាល ៤
**ជំពូក ២: ទិដ្ឋភាពរួមវិស័យសុខាភិបាល** ៧
១. ការរៀបចំប្រពន្ធ័សុខាភិបាល ៨
២. ផែនការគ្របដណ្តប់សុខាភិបាល ១០
៣. អភិបាលកិច្ចជំនួយ ការអភិវឌ្ឍន៍ស្ថាប័ន វិមជ្ឈការនិងវិសហមជ្ឈការ ១២
៤. ការពិនិត្យវាយតំលៃវិស័យសុខាភិបាលឆ្នាំ២០០៧ ១៣
**ជំពូក ៣: អតិក្រមផែនការយុទ្ធសាស្ត្រសុខាភិបាល** ២៦
១. តួនាទីនៃផែនការយុទ្ធសាស្ត្រ ២៧
២. អាទិភាពជាយុទ្ធសាស្ត្រ ២៨
៣. គោលបំណង និងគោលដៅនៃ ផ.យ.ស ២ ៣១
៤. គោលដៅចំណុច និងសូចនាករ ៣៣
**ជំពូក ៤: យុទ្ធសាស្ត្រសុខាភិបាល** ៣៧
១. ក្របខ័ណ្ឌយុទ្ធសាស្ត្រ ៣៨
២. ក្របខ័ណ្ឌប្រតិបត្តិ ៣៩
៣. អភិក្រមយុទ្ធសាស្ត្រសុខាភិបាល ៤០
៤. ផ្នែកជាយុទ្ធសាស្ត្រ ៤០
- យុទ្ធសាស្ត្រនៃការផ្តល់សេវាសុខាភិបាល ៤២
- យុទ្ធសាស្ត្រហិរញ្ញប្បទានការថែទាំសុខភាព ៤៨
- យុទ្ធសាស្ត្រធនធានមនុស្សសុខាភិបាល ៥២
- យុទ្ធសាស្ត្រប្រព័ន្ធពត៌មានសុខាភិបាល ៥៦
- យុទ្ធសាស្ត្រអភិបាលកិច្ចប្រពន្ធ័សុខាភិបាល ៦០

**ជំពូក ៥: ការអនុវត្តន៍យុទ្ធសាស្ត្រសុខាភិបាលតាមរយៈផ្នែកកម្មវិធីសុខភាព** ៦៨
១. អភិក្រមផ្នែកកម្មវិធីសុខភាព ៦៩
២. ផ្នែកកម្មវិធីសុខភាពបន្តពូជ–មាតា–ទារកនិងកុមារ ៧២
៣. ផ្នែកកម្មវិធីជំងឺឆ្លង ៧៨
៤. ផ្នែកកម្មវិធីជំងឺមិនឆ្លងនិងបញ្ហាសុខភាពដទៃទៀត ៨៩
**ជំពូក ៦: ក្របខណ្ឌអនុវត្តន៍ ត្រួតពិនិត្យតាមដាន ក្របខណ្ឌវាយតំលៃ** ៩៧
១. អភិក្រមជំហាន៧ក្នុងការអនុវត្តន៍ ផ.យ.ស.២ ៩៨
២. ក្របខណ្ឌអនុវត្ត ១០២
៣. ក្របខណ្ឌត្រួតពិនិត្យតាមដាននិងវាយតំលៃ ១០៨
៤. ក្របខណ្ឌសូចនាករសំរាប់ការត្រួតពិនិត្យតាមដាននិងវាយតំលៃ ១១១
**ជំពូក ៧: ថ្លៃចំណាយ និងមូលនិធិសំរាប់អន្តរាគមន៍ជាយុទ្ធសាស្ត្រ** ១១៥
១. សេចក្តីផ្តើម ១១៦
២. សមាសភាគថ្លៃចំណាយនិងសម្មតិកម្ម ១១៦
៣. ថ្លៃចំណាយលើការពង្រីកអន្តរាគមន៍ ១១៩
- ថ្លៃចំណាយលើការបង្កើនការប្រើប្រាស់សេវា ១១៩
- ថ្លៃចំណាយលើការពង្រីកកិច្ចសន្យា ១១៩
- ថ្លៃចំណាយសំរាប់ការពង្រីកមូលនិធិសមធម៌ ១១៩
- ថ្លៃចំណាយលើអន្តរាគមន៍សុខភាពបន្តពូជ ១២០
- ថ្លៃចំណាយលើអន្តរាគមន៍នៃការរស់រានរបស់កុមារ ១២២
- ប្រាក់លាភការបន្ថែមផ្អែកលើស្នាដៃការងារ ១២៣

៤. ថ្លៃចំណាយសរុប លទ្ធភាពផ្តល់ថវិកាបាននិងលំហសារពើពន្ធ ១២៣
**ឧបសម្ព័ន្ធ** ១២៦
**សន្ទានុក្រម** ១៣៣

# ក្រុមការងារនិងអ្នកចូលរួមរៀបចំផែនការ

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តមសាស្ត្រាចារ្យ | កើត | មៀច | អគ្គនាយករដ្ឋបាល–ហិរញ្ញវត្ថុ |
| ២. | ឯកឧត្តមវេជ្ជ. | ទេព | លន់ | អគ្គនាយកបច្ចេកទេសសុខាភិបាល |
| ៣. | លោកសាស្ត្រាចារ្យ | សាន់ | ចន្ទ័សឿន | អគ្គនាយករងបច្ចេកទេសសុខាភិបាល |
| ៤. | លោកវេជ្ជ. | ជី | មានហៀ | អគ្គនាយករងបច្ចេកទេសសុខាភិបាល |
| ៥. | លោកវេជ្ជ. | សុខ | ទូច | ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| ៦. | លោកស្រីឱសថការី | គាត | ភួង | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស |
| ៧. | លោកស្រីវេជ្ជ. | ប្រាក់ | ពិសិដ្ឋរង្សី | ប្រធាននាយកដ្ឋានការពារសុខភាព |
| ៨. | លោកស្រីឱសថការី | ទា | គីមឆាយ | ប្រធាននាយកដ្ឋានឱសថ |
| ៩. | លោក | ឡាយ | ហួន | ប្រធាននាយកដ្ឋានថវិកា–ហិរញ្ញវត្ថុ |
| ១០. | លោកវេជ្ជ. | មុី | សំបូរ | ប្រធាននាយកដ្ឋានបុគ្គលិក |
| ១១. | លោកវេជ្ជ. | សាន់ | សារី | ប្រធាននាយកដ្ឋានមន្ទីរពេទ្យ |
| ១២. | លោក | អុំ | វិចិត្រ | ប្រធាននាយកដ្ឋានរដ្ឋបាល |
| ១៣. | លោកស្រីវេជ្ជ. | ឱ | វណ្ណឌីន | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ១៤. | លោកសាស្ត្រាចារ្យ | គុំ | កាណាល់ | ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក |
| ១៥. | លោកវេជ្ជ. | លឹម | ថៃភាង | ប្រធានមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព |
| ១៦. | លោកសាស្ត្រាចារ្យ | ឈូ | អុីម៉េង | ប្រធានមន្ទីរពេទ្យកុមារជាតិ |
| ១៧. | លោកសាស្ត្រាចារ្យ | កា | ស៊ុនបូណាត | ព្រឹទ្ធបុរសសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ១៨. | លោកវេជ្ជ. | ឌួង | សុជាតិ | ប្រធានមជ្ឈមណ្ឌលជាតិកំចាត់ជំងឺគ្រុនចាញ់ |
| ១៩. | លោកវេជ្ជ. | មាន | ឈីវុន | ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ |
| ២០. | លោកវេជ្ជ. | ម៉ៅ | តាន់អ៊ាង | ប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង–ហង់សិន |
| ២១. | លោកវេជ្ជ. | អ៊ុង | សំអាន | ប្រធានវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ |
| ២២. | លោកវេជ្ជ. | តូ | ឈុនសេង | អនុប្រធានមន្ទីរពេទ្យអង្គឌួង |
| ២៣. | លោកវេជ្ជ. | ឃូ | អាំងអូ | អនុប្រធាននាយកដ្ឋានផែនការនិងពត៌មានសុខាភិបាល |
| ២៤. | លោកវេជ្ជ. | អុំ | ធន | ប្រធានមន្ទីរសុខាភិបាលខេត្ត កណ្តាល |
| ២៥. | លោកវេជ្ជ. | ងួន | ស៊ឹមអាន | ប្រធានមន្ទីរសុខាភិបាលខេត្ត កំពង់ចាម |
| ២៦. | លោកវេជ្ជ. | ហួត | ថន | ប្រធានមន្ទីរសុខាភិបាលខេត្ត កំពង់ស្ពឺ |
| ២៧. | លោកវេជ្ជ. | ហុង | រត្នមុនី | អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| ២៨. | លោកស្រីវេជ្ជ. | ទុង | រដ្ឋាវី | អនុប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| ២៩. | លោកស្រីវេជ្ជ. | ឃួន | អេងមុនី | អនុប្រធាននាយកដ្ឋានការពារសុខភាព |
| ៣០. | លោកវេជ្ជ. | កុល | ហេរ៉ូ | អនុប្រធាននាយកដ្ឋានការពារសុខភាព |
| ៣១. | លោកវេជ្ជ. | ហែម | មុនីរិទ្ធ | អនុប្រធាននាយកដ្ឋានរដ្ឋបាល |
| ៣២. | លោកស្រី | ឃុត | ថាវារី | អនុប្រធាននាយកដ្ឋានថវិកា–ហិរញ្ញវត្ថុ |
| ៣៣. | លោកវេជ្ជ. | លី | ពេញស៊ុន | អនុប្រធានមជ្ឈមណ្ឌលប្រយុទ្ធជំងឺអេដស៍ |
| ៣៤. | លោកវេជ្ជ. | លឹម | ឃី | អនុប្រធានមជ្ឈមណ្ឌលប្រយុទ្ធជំងឺអេដស៍ |
| ៣៥. | លោក | រស់ | ឈុនអៀង | ប្រធានការិយាល័យសេដ្ឋកិច្ច–ហិរញ្ញប្បទានសុខាភិបាល |

| | | | |
|---|---|---|---|
| ៣៦. លោកវេជ្ជ. | លន់ | ចាន់រស្មី | អនុប្រធានមន្ទីរសុខាភិបាលខេត្ត កំពង់ចាម |
| ៣៧. លោកវេជ្ជ. | ស៊ិន | សុវណ្ណ | ប្រធានការិ.បច្ចេកទេស មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព |
| ៣៨. លោកវេជ្ជ. | ទៀង | ស៊ីវណ្ណា | អនុប្រធានការិ.បច្ចេកទេស មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង-ហង់សិន |
| ៣៩. លោកស្រី | Alice | Levissay | UNFPA |
| ៤០. លោកវេជ្ជ. | សុខ | សុគន្ធ | UNFPA |
| ៤១. លោក | Toomas | Palu | World Bank |
| ៤២. លោកស្រីនិសថការី | លី | ណារ៉េត | World Bank |
| ៤៣. អ្នកស្រី | Thazin | Oo | UNICEF |
| ៤៤. លោកវេជ្ជ. | ថៅ | រ៉ាសូកា | UNICEF |
| ៤៥. លោកស្រី | Masayo | Terakado | JICA |
| ៤៦. លោកស្រី | Shoko | Sato | JICA |
| ៤៧. លោកវេជ្ជ. | ឆោម | រ៉ាដា | GTZ |
| ៤៨. លោកវេជ្ជ. | ចក | ចន្ថា | USAID |
| ៤៩. លោកស្រី | Peggy | Cook | URC |
| ៥០. លោកវេជ្ជ. | Claes | Ortendahl | HLSP |
| ៥១. លោក | Mark | Pearson | HLSP |

**លេខាធិការដ្ឋាន**

| | | | |
|---|---|---|---|
| ១. លោកវេជ្ជ. | ច | ម៉េងចូ | អគ្គនាយករងបច្ចេកទេសសុខាភិបាល |
| ២. លោកវេជ្ជ. | ឡូ | វ៉ាសនាគីរី | ប្រធាននាយកដ្ឋានផែនការនិងពត៌មានសុខាភិបាល |
| ៣. លោកវេជ្ជ. | សៅ | សុវណ្ណរតនៈ | អនុប្រធាននាយកដ្ឋានផែនការនិងពត៌មានសុខាភិបាល |
| ៤. លោកស្រីវេជ្ជ. | សុខ | កញ្ញា | អនុប្រធាននាយកដ្ឋានផែនការនិងពត៌មានសុខាភិបាល |
| ៥. លោកវេជ្ជ. | ប៊ុន | សំណាង | នាយកដ្ឋានផែនការនិងពត៌មានសុខាភិបាល |
| ៦. លោកស្រីវេជ្ជ. | ងិន | ស៊ីលាផ្ទង់ | នាយកដ្ឋានផែនការនិងពត៌មានសុខាភិបាល |
| ៧. លោកស្រី | សេង | អ៊ីដែត | នាយកដ្ឋានផែនការនិងពត៌មានសុខាភិបាល |
| ៨. លោក | សេក | សុខណា | នាយកដ្ឋានផែនការនិងពត៌មានសុខាភិបាល |
| ៩. លោកវេជ្ជ. | អ៊ុយ | វេងគី | គំរោងទ្រទ្រង់វិស័យសុខាភិបាល |
| ១០. លោក | គីវ | សុនិស្ស័យ | លេខាធិការដ្ឋានក្រុមការងារបច្ចេកទេសសុខាភិបាល |
| ១១. លោកវេជ្ជ. | ស៊ិន | សុមុនី | នាយកប្រតិបត្តិអង្គការ MEDICAM |
| ១២. លោក | Paul | Weelen | ទីប្រឹក្សាអង្គការសុខភាពពិភពលោក |
| ១៣. លោកស្រី | Anne | Erpelding | GTZ |
| ១៤. លោកស្រី | Katherine | Crawford | USAID |
| ១៥. លោកវេជ្ជ. | Vijay | Rao | ទីប្រឹក្សាគំរោងទ្រទ្រង់វិស័យសុខាភិបាល |

**ក្រុមចងក្រងឯកសារ**

| | | | |
|---|---|---|---|
| ១. លោកវេជ្ជ. | ឡូ | វ៉ាសនាគីរី | ប្រធាននាយកដ្ឋានផែនការនិងពត៌មានសុខាភិបាល |
| ២. លោក | Benjamin | D. Lane | ទីប្រឹក្សាអង្គការសុខភាពពិភពលោក |
| ៣. លោកស្រី | Maryam | Bigdeli | ទីប្រឹក្សាអង្គការសុខភាពពិភពលោក |

# បែបបទនៃការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រសុខាភិបាល២០០៨-២០១៥ ត្រូវបានអភិវឌ្ឍន៍ដោយ "ក្រុមការងារអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រសុខាភិបាល២០០៨-២០១៥" ក្រោមការណែនាំជាយុទ្ធសាស្ត្រពីថ្នាក់ដឹកនាំជាន់ខ្ពស់ក្រសួងសុខាភិបាល។

ការកសាងផែនការយុទ្ធសាស្ត្រនេះមានរយៈពេល៦ខែ ដោយចាប់ពីផ្តើមនៅខែតុលាឆ្នាំ២០០៧បន្ទាប់ពីបញ្ចប់ការពិនិត្យវាយតំលៃលទ្ធផលនៃការអនុវត្តន៍ផែនការការយុទ្ធសាស្ត្រ ២០០៣-២០០៧ នៅខែកញ្ញា ២០០៧ និងបានឆ្លងកាត់ការពិគ្រោះយោបល់យ៉ាងទូលំទូលាយតាមយន្តការខាងក្រោមនេះ:

- ការពិគ្រោះយោបល់កំរិតតំបន់លើសេចក្តីព្រាងលើកទី១ ជាមួយមន្ត្រីសុខាភិបាលថ្នាក់ខេត្ត-ក្រុង ស្រុកប្រតិបត្តិ មណ្ឌលសុខភាព ក្នុងខេត្ត-ក្រុងទាំង២៤។
- ការពិគ្រោះយោល់លើសេចក្តីព្រាងលើកទី១ ជាមួយក្រុមការងារបច្ចេកទេសសុខាភិបាលផ្អែកលើលទ្ធផលនៃការពិគ្រោះយោបល់ដោយឡែក២: មួយក្នុងចំណោមដៃគូអភិវឌ្ឍន៍និងមួយទៀតក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាលដែលសកម្មក្នុងវិស័យសុខាភិបាល។
- ការពិគ្រោះយោបល់កំរិតជាតិលើកសេចក្តីព្រាងលើកទី២ ដោយមានការចូលរួមពីមន្ទីរសុខាភិបាលខេត្ត-ក្រុង ទាំង២៤ ស្ថាប័ន-ក្រសួងពាក់ពន្ធ័ និងតំណាងដៃគូអភិវឌ្ឍន៍និងអង្គការក្រៅរដ្ឋាភិបាលនិងសមាគមវិជ្ជាជីវៈ។
- ការពិនិត្យដោយថ្នាក់ដឹកនាំជាន់ខ្ពស់ក្រសួងសុខាភិបាល ដើម្បីសំរេចលើសេចក្តីព្រាងចុងក្រោយនៃផែនការ។

ការអភិវឌ្ឍន៍ផែនការនេះបានទទួលការឧបត្ថម្ភបច្ចេកទេស ពីសំណាក់អង្គការសុខភាពពិភពលោកនិងជំនាញការរយៈពេលខ្លី(HLSP) ឧបត្ថម្ភថវិកាដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក(USAID) និងថវិកាពីគំរោងទ្រទ្រង់វិស័យសុខាភិបាល (ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិចក្រភពអង់គ្លេស(DFID) អង្គការ UNFPA និងអង្គការសុខភាពពិភពលោក។

# អក្សរកាត់

| | |
|---|---|
| គ.អ.ស | គោលដៅអភិវឌ្ឍន៍សហសវត្ស |
| ជ.ឆ | ជំងឺឆ្លង |
| ជ.ម.ឆំ | ជំងឺមិនឆ្លងនិងបញ្ហាសុខភាពដទៃទៀត |
| ធ.ម.ស | ធនធានមនុស្សសុខាភិបាល |
| ប.ព.ស | ប្រព័ន្ធព័ត៌មានសុខាភិបាល |
| ផ.គ្រ.ស | ផែនការគ្រប់ដណ្តប់សុខាភិបាល |
| ផ.យ.អ.ជ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ផ.យ.ស.២ | ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥ |
| ផ.យ.ស.១ | ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៣-២០០៧ |
| ផ.ស.ស | ការផ្តល់សេវាសុខភាព |
| ព.ស.ឆ | ការពិនិត្យរួមគ្នាសមិទ្ធផលសុខាភិបាលប្រចាំឆ្នាំ |
| ស.ប.ម.ទ.ក | សុខភាពបន្តពូជ-មាតា-ទារក-កុមារ |
| ស.ស.អ | សំណុំសកម្មភាពអប្បបរមា |
| ស.ស.ប | សំណុំសកម្មភាពអតិបរមា |
| ហ.ថ.ស | ហិរញ្ញប្បទានការថែទាំសុខភាព |
| អ.ប្រ.ស | ការអង្កេតប្រជាសាស្ត្រនិងសុខភាព |
| អ.ប.ស | អភិបាលកិច្ចប្រព័ន្ធសុខាភិបាល |

# សេចក្តីសង្ខេប

**ចក្ខុវិស័យ** ដែលលើកឡើងដោយផែនការយុទ្ធសាស្រ្តសុខាភិបាល ២០០៨-២០១៥(ផ.យ.ស.២) គឺ: "លើកកំពស់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពនៃវិស័យសុខាភិបាល ដើម្បីភាពកាន់តែប្រសើរឡើងនៃសុខភាព និងសុខុមាលភាពរបស់ប្រជាជនទាំងអស់ ពិសេសប្រជាជនក្រីក្រ ស្រ្តីនិងកុមារ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចនិងសង្គមកិច្ចនិងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។"

នៅក្នុងវិស័យសុខាភិបាល **បេសកកម្ម** របស់ក្រសួងសុខាភិបាលគឺ **"ផ្តល់មគ្គុទេសភាពសំរាប់វិស័យសុខាភិបាលទាំងមូលនិងធានាអោយមានបរិយាកាសគាំទ្រ ដល់ការបង្កើនតំរូវការផ្នែកសុខភាពនិងលទ្ធភាពទទួលយកសេវាថែទាំមានគុណភាព ប្រកបដោយសមធម៌ ដើម្បីឱយប្រជាជនកម្ពុជាទាំងអស់មានលទ្ធភាពទទួលបាននូវកំរិតអតិបរមាលើផ្នែកសុខភាពនិងសុខុមាលភាព។"**

**គុណតំលៃ** ដែលឈរលើមូលដ្ឋាននៃការប្តេជ្ញាចិត្តខាងលើរបស់ក្រសួងសុខាភិបាល គឺ **សមធម៌** និង **សិទ្ធសុខភាព** សំរាប់ប្រជាជនកម្ពុជាទាំងអស់។

សកម្មភាពបំពេញការងារប្រចាំថ្ងៃរបស់មន្រ្តីគ្រប់គ្រង និងបុគ្គលិកសុខាភិបាលនៅគ្រប់ផ្នែកទាំងអស់ទូទាំងអង្គភាពគ្រប់ថ្នាក់គប្បីគោរពតាម **គោលការណ៍៥** យ៉ាង:(១)ការគាំពារសុខភាពសង្គម ពិសេសប្រជាជនក្រីក្រ និងក្រុមប្រជាជនដែលងាយរងគ្រោះ (២)វិធីសាស្រ្តផ្តោតការយកចិត្តទុកដាក់លើអតិថិជន ក្នុងការផ្តល់សេវាសុខភាព (៣)វិធីសាស្រ្តសមាហរណកម្មក្នុងការផ្តល់សេវាសុខភាព និងអន្តរាគមន៍សុខភាពសាធារណៈមានគុណភាពខ្ពស់(៤)ការគ្រប់គ្រងធនធានមនុស្ស គឺជាសសរទ្រូងនៃប្រព័ន្ធសុខាភិបាលទាំងមូលនិង (៥)អភិបាលកិច្ចល្អ និងការទទួលខុសត្រូវ។

សំរាប់ប្រទេសកម្ពុជានាដំណាក់កាលបច្ចុប្បន្ននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម ចក្ខុវិស័យនិងបេសកកម្ម គុណតំលៃនិងគោលការណ៍ខាងលើតំរូវឱយមាន **ទិសដៅគោលនយោបាយ** មួយយ៉ាងច្បាស់លាស់សំរាប់វិស័យសុខាភិបាលនៅកម្ពុជាក្នុងបណ្តាឆ្នាំខាងមុខ។ ទិសដៅគោលនយោបាយសុខាភិបាល២០០៨-២០១៥ត្រូវបានកំណត់ដោយផ្អែកលើលទ្ធផលនៃការពិនិត្យវាយតំលៃផែនការយុទ្ធសាស្រ្តសុខាភិបាល២០០៣-២០០៧និងផ្តោតជាចំបងលើ:

---

១. អនុវត្តវិមជ្ឈការលើមុខងារផ្តល់សេវានិងមុខងារគ្រប់គ្រង

២. ពង្រឹងអភិបាលកិច្ចទូទាំងវិស័យសុខាភិបាល

៣. ពង្រីកលទ្ធភាពមកទទួលយកសេវានិងការគ្របដណ្តប់សេវាសុខភាព

៤. អនុវត្តប្រព័ន្ធហិរញ្ញប្បទានសុខាភិបាលគាំទ្រដល់ជនក្រីក្រ

---

៥. ពង្រឹងការអនុវត្តន៍និតិក្រមសុខាភិបាល ក្រមសីលធម៌វិជ្ជាជីវៈ និងលក្ខន្តិកៈនិងពង្រឹងយន្តការនិយត័កម្ម
៦. លើកកំពស់គុណភាពក្នុងការផ្តល់សេវាសុខភាពនិងការគ្រប់គ្រង
៧. បង្កើនសមត្ថភាពជំនាញរបស់បុគ្គលិកសុខាភិបាល និងបច្ចេកទេសជំនាញពាក់ព័ន្ធ
៨. ពង្រឹងនិងវិនិយោគលើប្រព័ន្ធព័ត៌មានសុខាភិបាលនិងលើកកំពស់ការស្រាវជ្រាវសុខភាព
៩. បង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឧបករណ៍-បរិក្ខាពេទ្យ និងបច្ចេកវិទ្យាទំនើបនិងការលើកកំពស់សេវាគាំទ្រមិនមែនវេជ្ជសាស្ត្រ
១០. លើកកំពស់គុណភាពនិងរបៀបរបបរស់នៅប្រកបដោយសុខភាពល្អរបស់ប្រជាជន
១១. បង្ការនិងទប់ស្កាត់ជំងឺឆ្លង ជំងឺរ៉ាំរ៉ៃនិងជំងឺមិនឆ្លង ព្រមទាំងពង្រឹងប្រព័ន្ធតាមដានជំងឺ
១២. ពង្រឹងអន្តរាគមន៍សុខភាពសាធារណៈដើម្បីដោះស្រាយបញ្ហាប្រឈមមុខប្រទាក់ក្រឡា
១៣. លើកកំពស់ភាពជាដៃគូមានប្រសិទ្ធភាពរវាងវិស័យសាធារណៈនិងឯកជនក្នុងការផ្តល់សេវា
១៤. លើកទឹកចិត្តការចូលរួមរបស់សហគមន៍ក្នុងសកម្មភាពផ្តល់សេវានិងលើកកំពស់គុណភាព
១៥. ពង្រឹងស្ថាប័នសុខាភិបាលមានលក្ខណៈជាប្រព័ន្ធគ្រប់ថ្នាក់នៅក្នុងប្រព័ន្ធសុខាភិបាល

**ការពិនិត្យវាយតំលៃផែនការ** យុទ្ធសាស្ត្រសុខាភិបាល ២០០៣-២០០៧ បានបង្ហាញថាៈ

- រង្វាស់ទូទៅពីរ ដែលយកមកប្រើប្រាស់ដើម្បីកំណត់គុណភាពប្រព័ន្ធសុខាភិបាល គឺអត្រាស្លាប់របស់កុមារអាយុក្រោម១ឆ្នាំ និងក្រោម៥ឆ្នាំ ត្រូវបានកាត់បន្ថយយ៉ាងខ្លាំងបើទុកណាជាសូចនករសុខភាពកុមារត្រូវការកែលំអថែមទៀត ដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជាក៏ដោយ ។
- សូចនាករលទ្ធផលសុខភាពទី៣របស់ប្រព័ន្ធសុខាភិបាល គឺអត្រាស្លាប់របស់មាតាមិនមានវឌ្ឍនភាពហើយស្ថិតនៅជាបញ្ហាព្រួយបារម្ភយ៉ាងខ្លាំង បើទុកណាជាមានវឌ្ឍនភាពនៅក្នុងផ្នែកសុខភាពមាតាកុមារនិងសុខភាពបន្តពូជ ។
- ប្រទេសកម្ពុជាកំពុងស្ថិតក្នុងអន្តរកាល (អេពីដេមីញ៉ូសាស្ត្រ)ឆ្ពោះទៅកាន់បន្ទុកធ្ងន់នៃជំងឺមិនឆ្លងការពិនិត្យវាយតំលៃផែនការយុទ្ធសាស្ត្រសុខាភិបាល២០០៣-២០០៧ បានផ្តល់អនុសាសន៍ដូចខាងក្រោមនេះ

១- ត្រូវធ្វើការសំរេចចិត្តជាបន្ទាន់ លើគោលនយោបាយនៅលើផ្នែកនានា ដែលការអនុវត្តន៍សាកល្បងកំពុងដំណើរការជឿនលឿនទៅមុខ ។ ការសំរេចចិត្តលើគោលនយោបាយនេះ ត្រូវបញ្ចូលកំណែទំរង់កិច្ចសន្យាផ្តល់សេវា ពង្រីកមូលនិធិសមធម៌ និងលើកកំពស់ប្រព័ន្ធលាភការសំរាប់បុគ្គលិក ។

២- ពង្រឹងបន្ថែមតួនាទីនិងមុខងារស្ថាប័នទូទាំងប្រព័ន្ធសុខាភិបាល ជាមួយនឹងការកសាងសមត្ថភាពព្រមទាំងលើកស្ទួយការផ្សារភ្ជាប់រវាងយុទ្ធសាស្ត្រនៃ ផ.យ.ស.២ ជាមួយប្រព័ន្ធត្រួតពិនិត្យតាមដាន ។

៣- ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងជំនួយដើម្បីដោះស្រាយស្ថានភាពបែកខ្ញែកបច្ចុប្បន្ននៃហិរញ្ញប្បទាន ពីដៃគូសុខាភិបាលតាមរយៈការខិតខំប្រឹងប្រែងប្រាកដប្រជានៃសុខដុមនីយកម្ម ដើម្បីអនុញ្ញាតិឱយមានការបន្តពង្រីកធនធាន។

ក្នុងការកំណត់អភិក្រមជាយុទ្ធសាស្រ្ត ផ.យ.ស.២កំណត់ **អាទិភាពជាយុទ្ធសាស្រ្ត** សំរាប់វិសយ័សុខាភិបាលជាពីរផ្នែកទូលំទូលាយនិងទាក់ទងគ្នាទៅវិញទៅមក ហើយដែលក្រសួងសុខាភិបាលនិងដៃគូទាំងអស់ត្រូវយកចិត្តទុកដាក់ជាពិសេស សំរាប់អន្តរាគមន៍ក្នុងរយៈពេលមធ្យមទៅរយៈពេលវែង នៅក្នុងអំលុងពេលនៃការអនុវត្តន៍ ផ.យ.ស.២។ អាទិភាពទាំងពីរផ្នែកនេះគឺ:

**ក. អាទិភាពសុខភាពរបស់ប្រជាជននិងសេវាសុខភាពជាសារវន្ត័**

**(១) បន្ថយការឈឺនិងស្លាប់របស់មាតា ទារកនិងកុមារ និងការលើកកំពស់សេវាសុខភាពបន្តពូជ**

**គោលដៅ** ១ លើកកំពស់ស្ថានភាពអាហារូបត្ថម្ភរបស់មាតានិងកុមារ

២ លើកកំពស់លទ្ធភាពមកទទួលយកពត៏មាននិងសេវាសុខភាពបន្តពូជមានគុណភាព

៣ លើកកំពស់លទ្ធភាពមកទទួលយកសេវាសុខភាពសារវ័ន្តសំរាប់មាតានិងទារក និងការប្រព្រឹត្ត ការថែទាំសុខភាព តាមគ្រួសារបានល្អប្រសើរ

៤ ធានានូវលទ្ធភាពមកទទួលយកសេវាសុខភាពសារវ័ន្តសំរាប់កុមារនិងការប្រព្រឹត្តការថែទាំសុខភាពតាមគ្រួសារបានល្អប្រសើរ

**(២) បន្ថយការឈឺនិងស្លាប់ដោយសារជំងឺអេដស៍ របេង គ្រុនចាញ់ និងជំងឺឆ្លងដទៃទៀត**

**គោលដៅ** ៥ កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍

៦ បង្កើនការរស់រានមានជីវិតរបស់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍

៧ សំរេចបានអត្រាស្រាវជ្រាវជំងឺរបេងខ្ពស់ និងរក្សាអត្រាជាសះស្បើយកំរិតខ្ពស់នៃករណីជំងឺរបេងស្ទួតបេកាវិជ្ជមាន។

៨ កាត់បន្ថយការស្លាប់ដោយជំងឺគ្រុនចាញ់ និងអត្រាឈឺក្នុងចំណោមប្រជាជនទូទៅ

៩ កាត់បន្ថយបន្ទុកនៃជំងឺឆ្លងដទៃទៀត

**(៣) បន្ថយបន្ទុកជំងឺមិនឆ្លង និងបញ្ហាសុខភាពដទៃទៀត**

**គោលដៅ** ១០ កាត់បន្ថយឥរិយាបទគ្រោះថ្នាក់នាំទៅរកជំងឺមិនឆ្លង (ការយល់ដឹង ទំលាប់ ការអនុវត្តន៍) :ជំងឺទឹកនោមផ្អែម ជំងឺបេះដូង-សរសៃរឈាម ជំងឺមហារីក ជំងឺផ្លូវចិត្ត ការប្រើប្រាស់គ្រឿងញៀន គ្រោះថ្នាក់និងរបួស ការថែទាំភ្នែក សុខភាពមាត់ធ្មេញ ។ល។

១១ លើកកំពស់លទ្ធភាពមកទទួលយកសេវាព្យាបាល និងការស្តារនិតិសម្បទាបង្ករឡើងដោយជំងឺមិនឆ្លង: ជំងឺទឹកនោមផ្អែម ជំងឺបេះដូង-សរសៃរឈាម ជំងឺមហារីក

ជំងឺផ្លូវចិត្ត ការប្រើប្រាស់គ្រឿងញៀន គ្រោះថ្នាក់និងរបួស ការថែទាំភ្នែក សុខភាពមាត់ធ្មេញ ។ល។

១២ ធានាដំណើរការមុខងារសារវ័ន្ត នៃសុខភាពសាធារណៈ សុខភាពបរិស្ថាន សុវត្ថិភាព ចំណីអាហារ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការត្រៀមលក្ខណៈ (សំរាប់គ្រោះអាសន្ន)។

---

ខ. **បញ្ហាប្រឈមមុខដែលមានទាក់ទងនឹងដំណើរការមុខងាររបស់ប្រព័ន្ធសុខាភិបាល** ទាំងបញ្ហាប្រឈមមុខនៅ "ផ្នែកផ្តល់សេវា" និងបញ្ហាប្រឈមមុខនៅ "ផ្នែកទទួលសេវា" ។

**ក្របខណ្ឌ័យុទ្ធសាស្ត្រនៃផ.យ.ស ២ មានចរិតលក្ខណៈ ៥ យ៉ាងដូចតទៅៈ**

- ជាក្របខ័ណ្ឌការងារដែលដាក់ "ការទទួលខុសត្រូវ ប្រសិទ្ធភាព គុណភាព និងសមធម៌" នៅចំកណ្តាលនៃយុទ្ធសាស្ត្រប្រទាក់ក្រឡាទាំង៥ ដែលគាំទ្រដល់អន្តរាគមន៍នៃកម្មវិធីសុខភាពចំនួន៣ ដើម្បីផ្តល់នូវលទ្ធផលសុខភាពដែលប្រសើរជាងមុន។
- ជាក្របខ័ណ្ឌការងារដែលប្រែក្លាយ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ទៅជាសកម្មភាពដើម្បីរួមចំណែកដល់ដំណើរការរយៈពេលវែងនៃការកាត់បន្ថយភាពក្រីក្រ។
- ជាក្របខ័ណ្ឌការងារដែលផ្តល់ពត៌មាននិងបច្ចុប្បន្នភាពគោលដៅចំណុចនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ លើមូលដ្ឋានទៀងទាត់ប្រចាំឆ្នាំ។
- ជាក្របខ័ណ្ឌការងារដែលមានពេលវេលាកំណត់និងយកគោលដៅអភិវឌ្ឍន៍សហសវត្ស ជាគោល។
- ជាក្របខ័ណ្ឌការងារដែលឆ្លុះបញ្ចាំងពី គោលការណ៍នៃសេចក្តីប្រកាសក្រុងប៉ារីស (ភាពម្ចាស់ការ ការតំរៀបតំរង់ សុខដុមនីយកម្ម ការគ្រប់គ្រង ដើម្បីសំរេចលទ្ធផលនិងការទទួលខុសត្រូវទៅវិញទៅមក) និងផែនការសកម្មភាពស្តីពីការតំរៀបតំរង់និងសុខដុមនីយកម្មដើម្បីសំរេចលទ្ធផល របស់រាជរដ្ឋាភិបាល។

**សំណាង់ក្របខ័ណ្ឌយុទ្ធសាស្ត្រ**នៃផ.យ.ស.២ រួមមានផ្នែកកម្មវិធីសុខភាពចំបងចំនួន៣ ដែលអនុវត្តសំណុំយុទ្ធសាស្ត្រប្រទាក់ក្រឡាចំនួន៥។ យុទ្ធសាស្ត្រនិមួយៗនៃយុទ្ធសាស្ត្រទាំង៥គឺ: **ការផ្តល់សេវាសុខភាព ហិរញ្ញប្បទាន ការថែទាំសុខភាព ធនធានមនុស្សសុខាភិបាល ប្រព័ន្ធពត៌មានសុខាភិបាល** និង**អភិបាលកិច្ចប្រព័ន្ធសុខាភិបាល** ត្រូវយកទៅអនុវត្តនៅក្នុងកម្មវិធីនីមួយៗ។ ការណ៍នេះនឹងធានាការផ្តល់សេវានិងត្រួតពិនិត្យតាមដានលទ្ធផលប្រកបដោយប្រសិទ្ធភាពនិងសង្គតភាពទូទាំងវិស័យសុខាភិបាល។

- **ការផ្តល់សេវាសុខភាព** រួមមានវិធានការសុខភាពសាធារណៈដើម្បីប្រយុទ្ធនិងជំងឺ–ដូចជាការរៀបចំចាត់ចែងការលើកកំពស់សុខភាព ដើម្បីកាត់បន្ថយឥរិយាបទគ្រោះថ្នាក់និងគាំពារដល់ផ្នែកសុខភាព ព្រមទាំងពង្រឹងជាទូទៅការផ្តល់សេវាថែទាំសុខភាព តាមរយៈគោលនយោបាយ និងផែនការដោយឡែកនិងទូទៅនៃជំងឺចាំបាច់នានា ដោយផ្តោតជាចំបងទៅលើការលើកកំពស់គុណភាពសេវា។ ការ

បង្កើនតំរូវការផ្នែកសុខភាព និងសិទ្ធអំណាចរបស់អ្នកជំងឺ គឺជាមធ្យោបាយចំពោះមុខដ៏សំខាន់សំរាប់បង្កើនគុណភាពសេវានិងការទទួលខុសត្រូវក្នុងការផ្តល់សេវា។

- **ហិរញ្ញប្បទានការថែទាំសុខភាព** ដោះស្រាយការបង្កើនវិនិយោគលើសុខភាពនិងការប្រឹងប្រែង ដើម្បីបំបាត់របាំងហិរញ្ញវត្ថុក្នុងការទទួលយកសេវាមានគុណភាព។ ការវិភាជន៍ធនធានរបស់រដ្ឋាភិបាលដល់វិស័យសុខាភិបាលគ្រាន់តែជាផ្នែកមួយតែប៉ុណ្ណោះ។ ដូច្នេះត្រូវគូសបញ្ជាក់អំពីបញ្ហានានា ជុំវិញតុល្យភាពនៃហិរញ្ញប្បទានរវាងរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ក៏ដូចជាការផ្តល់មូលនិធិឱយបានគ្រប់គ្រាន់ដល់ថ្នាក់ផ្តល់សេវា។ពង្រឹងយន្តការគាំពារសុខភាពសង្គមដោយរាប់បញ្ចូលទាំងមូលនិធិសមធម៌ ការធានារ៉ាប់រងសុខភាពតាមសហគមន៍ ការធានារ៉ាប់រងសុខភាពសង្គម និងរួមចំណែកដល់ការកាត់បន្ថយរបាំងហិរញ្ញវត្ថុ ក្នុងការមកទទួលយកសេវា និងគ្រោះថ្នាក់នៃការចំណាយដ៏មហន្តរាយដោយសារសុខភាព។
- **ធនធានមនុស្សសុខាភិបាល** គ្របដណ្តប់លំដាប់លំដោយលើអន្តរាគមន៍គ្រប់ជ្រុងជ្រោយមួយ។១)ធានាកំរិតបរិមាណបុគ្គលិកគ្រប់គ្រាន់ ហើយមានប្រវត្តិវិជ្ជាជីវៈនិងសមត្ថភាពសមស្រប។ ២)ការពិនិត្យសារឡើងវិញកម្មវិធីនៃការបណ្តុះបណ្តាល។ ៣)បង្កើនចំនួនសិស្ស–និស្សិត ដែលត្រូវជ្រើសរើសឱយចូលរៀនតាមសាលានិងសកលវិទ្យាល័យនិង ៤)ពង្រឹងវិធានការនានាដើម្បីការពារគុណភាពបណ្តុះបណ្តាលនិងគ្រូបណ្តុះបណ្តាល។ ឆ្មបត្រូវបានជ្រើសរើសជាពិសេសថាជាក្រុមចំណុច ដោយសារតែតួនាទីដ៏សំខាន់របស់ពួកគេក្នុងការសំរេចគោលបំណងទូទៅនៃផ.យ.ស.២។ ការរៀបចំកម្មវិធីធនធានមនុស្ស ត្រូវរាប់បញ្ចូលផងដែរការគោរពក្រមសីលធម៌វិជ្ជាជីវៈ។ តំរូវការចាំបាច់និងជាបន្ទាន់គឺការផ្សារភ្ជាប់ទៅនឹងការអនុវត្តន៍កំណែទំរង់បៀវត្សរ៍សំរាប់សេវាសុខភាព។
- **ប្រព័ន្ធពត៌មានសុខាភិបាល** ដោះស្រាយអំពីតំរូវការទិន្នន័យមានគុណភាពខ្ពស់ ត្រឹមត្រូវគ្រប់ជ្រុងជ្រោយនិងទាន់ពេលវេលាដើម្បីជាមូលដ្ឋានដល់ការតាក់តែងគោលនយោបាយផ្អែកលើភស្តុតាង ការធ្វើផែនការ ការត្រួតពិនិត្យតាមដានស្នាដៃការងារនិងការវាយតំលៃ។ ចំណុចផ្តោតជាចំបងគឺលើកស្ទួយការសំរបសំរួលនិងកិច្ចសហការ ទាំងក្នុងនិងក្រៅវិស័យសុខាភិបាល តាមរយៈការចែករំលែកទិន្នន័យ ការគ្រប់គ្រង ការវិភាគ ការផ្សព្វផ្សាយនិងប្រើប្រាស់ ព្រមទាំងការដាក់បញ្ចូលពត៌មានពីវិស័យឯកជន និងការតាមដានថវិកានិងការចំណាយ និងពង្រីកការបណ្តុះបណ្តាល ដើម្បីកសាងសមត្ថភាពប្រព័ន្ធពត៌មានសុខាភិបាល។
- **អភិបាលកិច្ចវិស័យសុខាភិបាល**ទស្សនៈវិស័យស្តីអំពីអភិបាលកិច្ចនៅក្នុងផ.អ.យ.ជ ផ្តោតលើវិមជ្ឈការនិងវិសហមជ្ឈការ។ **"ថវិកាកញ្ចប់"**ពីថ្នាក់ជាតិនិងការកៀងគរធនធាននៅនឹងមូលដ្ឋាននឹងគ្របដណ្តប់លើសេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុតាមគោលនយោបាយនេះ។ សុខដុមនីយកម្មនិងការតំរៀបតំរង់ ដើម្បីលទ្ធផលត្រូវបានបញ្ជាក់ច្បាស់ ដើម្បីឈានទៅសំរេចក្របខណ្ឌ័គោលនយោបាយរួមមួយរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍សំរាប់ការអភិវឌ្ឍន៍វិស័យសុខាភិបាល។ យុទ្ធសាស្ត្រនឹងលើកកំពស់ឱយកាន់

តែប្រសើរឡើងនូវរូបភាពគ្រប់ជ្រុងជ្រោយ នៃការផ្តល់មូលនិធិរបស់រដ្ឋាភិបាលនិងប្រទេសផ្តល់ជំនួយ ព្រមទាំងពង្រឹង**សុខដុមនីយកម្ម** (សំរបសំរួលជំនួយក្រៅប្រទេសស្របតាមនិតិវិធី រចនាសម្ព័ន្ធនិងប្រពន្ធ័ជាតិនៅកន្លែងណាដែលអាចប្រព្រឹត្តទៅបាន)និង**តំរៀបតំរង់** (ធានាថាអាទិភាពដែលបានកំណត់ដោយប្រទេសកម្ពុជាក៏ជាអាទិភាពរបស់ប្រទេសផ្តល់ជំនួយ) ស្ថាបត្យកម្មជំនួយឱយស្របតាមបន្ទាត់គោលនយោបាយរបស់រដ្ឋាភិបាលស្តីអំពីវិមជ្ឈការនិងវិសហមជ្ឈការនិងអាទិភាពរបស់ផ.យ.ស.២។

មានកត្តាបរិបទមួយចំនួនដែលតំរូវឱយការអនុវត្តន៍ផ.យ.ស.២ ប្រព្រឹត្តទៅតាម**លំដាប់លំដោយនៃពេលវេលា** ក្នុងការឈានឆ្ពោះទៅសំរេចគោលបំណងរបស់ ផ.យ.ស.២:

- **ទីមួយ-បរិបទគោលនយោបាយ:** ក្រសួងសុខាភិបាលនឹងធ្វើការសំរេចចិត្តអំពីគោលនយោបាយសំខាន់ៗ ដែលទាក់ទងនិងតំរូវការផ្នែកហិរញ្ញប្បទាននិងអភិបាលកិច្ចប្រពន្ធ័សុខាភិបាល នៅក្នុងក្របខណ្ឌ័នៃការអនុវត្តន៍កម្មវិធីវិមជ្ឈការនិងវិសហវិមជ្ឈការ។ ឆ្នាំ២០០៨ត្រូវបានចាត់ទុកថាជាឆ្នាំនៃការត្រៀមរៀបចំ ដែលក្នុងរយៈពេលនេះបែបបទនៃការសំរេចចិត្តនឹងបញ្ចប់ហើយប្រព្រឹត្តទៅស្របគ្នាជាមួយនឹងដំណាក់កាលបន្តបន្ទាប់នៃការពង្រឹងនិងការអនុវត្តន៍។
- **ទីពីរ-បរិបទស្ថាបន័:** ការចាត់ចែងរៀបចំរចនាសម្ព័ន្ធស្ថាបន័សុខាភិបាល និងការកសាងសមត្ថភាពស្ថាបន័ នឹងប្រព្រឹត្តទៅនៅគ្រប់ថ្នាក់ នៅក្នុងប្រពន្ធ័សុខាភិបាល-ថ្នាក់កណ្តាល ខេត្ត-ក្រុង ស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាលដោយរាប់បញ្ចូលទាំងសហគមន៍។
- **ទីបី-បរិបទសេដ្ឋកិច្ច:** ធនធាននឹងត្រូវពង្រីកតាមសង្វាក់ ដែលរាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយទទួលយកបាន។ ក្របខណ្ឌ័ហិរញ្ញប្បទានវិសយ័សុខាភិបាល សំរាប់រយៈមធ្យមទៅរយៈពេលវែងចាំបាច់ត្រូវផ្សារភ្ជាប់ទៅក្នុងក្របខណ្ឌ័ម៉ាក្រូសេដ្ឋកិច្ចប្រទេសកម្ពុជា ដែលនឹងតំរូវឱយមានដាក់ចេញយុទ្ធសាស្រ្តតាមលំដាប់លំដោយ។

ជាផលបច្ចយ័ការអនុវត្តន៍ផ.យ.ស.២ នឹងប្រព្រឹត្តទៅតាមពីរដំណាក់កាល:

- ដំណាក់កាលពង្រឹងដែលចាប់ផ្តើមពីឆ្នាំ២០០៨–២០១០
- ដំណាក់កាលពង្រីកចាប់ផ្តើមពីឆ្នាំ២០១១ ដល់ពេលបញ្ចប់ផែនការឆ្នាំ២០១៥

**ក្របខណ្ឌ័អនុវត្តផែនការ** ត្រូវបានកំណត់ច្បាស់លាស់ និងពង្រឹងតួនាទីស្នូលនៃឧបករណ៍ផែនការចំបង ២ ដែលមានរួចមកហើយនៅប្រទេសកម្ពុជា:

- ផែនការរំកិល៣ឆ្នាំផ្សារភ្ជាប់ទៅនឹងក្របខណ្ឌ័ថវិកាយុទ្ធសាស្រ្ត និងកម្មវិធីវិនិយោគសាធារណ:
- ផែនការប្រតិបត្តិប្រចាំឆ្នាំនិងការកសាងថវិកាតាមកម្មវិធី

វឌ្ឍនភាពក្នុងការអនុវត្តន៍ផ.យ.ស.២ នឹងត្រូវបានត្រួតពិនិត្យតាមដាន តាមរយៈការពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំនិងការពិនិត្យពាក់កណ្តាលអណត្តិនៃផែនការ និងបន្តដោយការវាយតំលៃនៅវគ្គបញ្ចប់នៃផែនការ ដើម្បីបញ្ជាក់អំពីផលប៉ះពាល់របស់ផែនការទៅលើការធ្វើឱយស្ថានភាពសុខភាពប្រសើរឡើង។

ក្របខណ្ឌត្រួតពិនិត្យតាមដានខាងក្រោមគឺជាឧបករណ៍សំរាប់ក្រសួងសុខាភិបាលត្រួតពិនិតតាមដាន និងវាយតំលៃឈរលើមូលដ្ឋានទៀងទាត់ដើម្បីទទួលបានពត៌មានសំរាប់ធ្វើការសំរេចចិត្តផ្នែកគោលនយោបាយ។

មានការគិតទុកថាដៃគូសុខាភិបាលទាំងអស់នឹងប្រើប្រាស់ក្របខណ្ឌសូចនាករនេះ (ដោយរាប់បញ្ចូលទាំងសំណុំសូចនាករដែលបានឯកភាពគ្នា) ដើម្បីពិនិត្យវឌ្ឍនភាពនៃកម្មវិធី/គំរោងរបស់ខ្លួនក្នុងវិស័យសុខាភិបាល។




គោលបំណងនៃ **ក្របខណ្ឌសូចនាករ** មាន ៣យ៉ាងដូចខាងក្រោមនេះ :

- ត្រួតពិនិត្យតាមដាននិងវាយតំលៃស្នាដៃវិស័យសុខាភិបាលក្នុងការលើកស្ទួយលទ្ធផលសុខភាពតាមរយៈការអនុវត្តន៍ ផ.យ.ស.២
- បន្សុទ្ធគោលនយោបាយសុខាភិបាលដែលមាន ដោយពិចារណាទៅលើវឌ្ឍនភាពដែលបានកើតមាននៅក្នុងអំលុងពេលនៃការអនុវត្តន៍ ផ.យ.ស.២ និង
- ជួយឱយមន្ត្រីតាក់តែងគោលនយោបាយសំរេចចិត្តលើប្រសិទ្ធភាពនៃអន្តរាគមន៍ផ្សេងៗគ្នា និងជំរើសគោលនយោបាយ

ក្របខណ្ឌសូចនាករនេះរួមមានសូចនាករស្នូល ចំនួន២៨ ដែលនឹងត្រូវយកមកពិនិត្យវាយតំលៃតាមរយៈការពិនិត្យរួមគ្នាសមិទ្ធផលសុខាភិបាលប្រចាំឆ្នាំ។សំរាប់ការត្រួតពិនិត្យតាមដានផែនការប្រតិបត្តិប្រចាំឆ្នាំនៅថ្នាក់អនុវិស័យ គឺនៅមានសូចនាករបន្ថែមមួយចំនួនទៀត។

## ជំពូក ១

# ទិសដៅគោលនយោបាយសុខាភិបាល

- ចក្ខុវិស័យ
- បេសសកកម្ម
- គុណតំលៃ
- គោលការណ៍
- ទិសដៅគោលនយោបាយ

# ១ ទិសដៅគោលនយោបាយសុខាភិបាល

## ១. ចក្ខុវិស័យ

ចក្ខុវិស័យយូរអង្វែងដ៏ទូលំទូលាយរបស់ក្រសួងសុខាភិបាលគឺ **“លើកកំពស់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពនៃវិស័យសុខាភិបាល ដើម្បីភាពកាន់តែប្រសើរឡើងនៃសុខភាព និងសុខុមាលភាពរបស់ប្រជាជនទាំងអស់ពិសេសប្រជាជនក្រីក្រ ស្ត្រី និងកុមារ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចនិងសង្គមកិច្ចនិងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។”**

## ២. បេសកកម្ម

សេចក្តីថ្លែងអំពីបេសកកម្មគូសបញ្ជាក់ អំពីការប្តេជ្ញារបស់ក្រសួងសុខាភិបាល ដែលផ្តោតទៅលើការអនុវត្តន៍ **“មគ្គុទេសភាព”** សំរាប់ការផ្តល់សេវាកម្មលើគ្រប់ផ្នែកទាំងអស់ទូទាំងវិស័យសុខាភិបាល។ បេសកកម្មនេះ បានរំលេចឱយឃើញផងដែរអំពី **កំរិតអតិប្បរមានៃស្ថានភាពសុខភាព និងសុខុមាលភាពរបស់ប្រជាជន** ដែលប្រពន្ធ័សុខាភិបាលខិតខំប្រយុទ្ធដើម្បីលើកស្ទួយ នោះគឺប្រពន្ធ័សុខាភិបាលដែលបានដាក់ **“បង្កើនតំរូវការផ្នែកសុខភាព គុណភាពកាន់តែប្រសើរ និងលើកស្ទួយលទ្ធភាពមកទទួលយកសេវា”** នៅចំកណ្តាលបេះដូងនៃការផ្តល់សេវាថែទាំសុខភាព។

> **“ ផ្តល់មគ្គុទេសភាពសំរាប់វិស័យសុខាភិបាលទាំងមូល និងធានាអោយមានបរិយាកាសគាំទ្រដល់ការបង្កើនតំរូវការផ្នែកសុខភាពនិងលទ្ធភាពទទួលយកសេវាថែទាំមានគុណភាព ប្រកបដោយសមធម៌ ដើម្បីឱយប្រជាជនកម្ពុជាទាំងអស់មានលទ្ធភាពទទួលបាននូវកំរិតអតិបរមាលើផ្នែកសុខភាពនិងសុខុមាលភាព។ ”**

## ៣. គុណតំលៃនិងគោលការណ៍

- **គុណតំលៃ**

គុណតំលៃដែលឈរលើមូលដ្ឋាននៃការប្តេជ្ញាចិត្តខាងលើរបស់ក្រសួងសុខាភិបាលគឺ **សមធម៌** និង **សិទ្ធិសុខភាព** សំរាប់ប្រជាជនកម្ពុជាទាំងអស់ ។

- **គោលការណ៍**

បង្កើនប្រសិទ្ធភាព ការទទួលខុសត្រូវ គុណភាព និងសមធម៌ ទូទាំងប្រពន្ធ័សុខាភិបាលអាច និង សំរេចបានតាមរយៈការប្រព្រឹត្តវិធានសីលធម៌ ជំនឿដ៏រឹងមាំ និងការប្តេជ្ញាចំពោះគោលបំណងរួម របស់បុគ្គលទាំងអស់ដែលកំពុងបំពេញការងារក្នុងការថែទាំសុខភាព ។ ដូច្នេះសកម្មភាពពីមួយថ្ងៃមួយទៅមួយថ្ងៃរបស់មន្ត្រីគ្រប់គ្រងនិងបុគ្គលិក នៅគ្រប់ផ្នែកទាំងអស់ទូទាំងអង្គភាពគ្រប់ថ្នាក់ គប្បីត្រូវបានណែនាំដោយគោលការណ៍ ៥ យ៉ាងដូចតទៅ:

| | |
|---|---|
| **១. ការគាំពារសុខភាពសង្គមពិសេស ប្រជាជនក្រីក្រនិងក្រុមប្រជាជនដែលងាយរងគ្រោះ** | លើកស្ទួយវិធីសាស្រ្តគាំទ្រជនក្រីក្រផ្តោតលើការតំរង់ធនធានទៅកាន់ជនក្រីក្រ និងក្រុមប្រជាជនដែលមានតំរូវការចាំបាច់ និងទៅកាន់កន្លែងដែលត្រូវការបំផុត ពិសេសតំបន់ជនបទដាច់ស្រយាលនិងទីប្រជុំជនក្រីក្រ ។ |
| **២. វិធីសាស្រ្តផ្តោតការយកចិត្តទុកដាក់លើអតិថិជនក្នុងការផ្តល់សេវាសុខភាព** | ផ្តល់សេវាសុខភាព ដោយផ្តោតលើលទ្ធភាពអាចបង់ថ្លៃបាន និង ការទទួលយកបាននៃសេវា សិទ្ធិអតិថិជន ការចូលរួមរបស់សហគមន៍ និងភាពជាដៃគូជាមួយផ្នែកឯកជន ។ |
| **៣. វិធីសាស្រ្តសមាហរណកម្មក្នុងការផ្តល់សេវាសុខភាពនិងអន្តរាគមន៍សុខភាពសាធារណៈមានគុណភាពខ្ពស់** | ផ្តល់សេវាថែទាំសុខភាពគ្រប់ជ្រុងជ្រោយរួមមានសេវាបង្កា ព្យាបាលនិងលើកកំពស់សុខភាព ស្របតាមគោលការណ៍ស្តង់ដារ និងមគ្គុទេសន៍គ្លីនិកជាតិ ដែលអាចទទួលយកបានតាមរយៈសំណុំសកម្មភាពអប្បបរមា និងសំណុំសកម្មភាពបង្គ្រប់ និងភាពជាដៃគូជាមួយវិស័យឯកជន ។ |
| **៤. ការគ្រប់គ្រងធនធានមនុស្សគឺជាសសរទ្រូងនៃប្រព័ន្ធសុខាភិបាលទាំងមូល** | មានចរិតប្រតិបត្តិនិងផលិតភាពដែលស្តែងចេញពីសមត្ថភាព ក្រមសីលធម៌ ការបំពេញការងារជាក្រុម ការលើកទឹកចិត្ត បរិយាកាសបំពេញការងារល្អនិងបែបបទរៀនហើយរៀនទៀត |
| **៥. អភិបាលកិច្ចល្អនិងការទទួលខុសត្រូវ** | ផ្តល់មគ្គុទេសភាព ដល់វិស័យសាធារណៈនិងឯកជនដោយផ្តោតលើអភិក្រមគ្រប់គ្រងបើកទូលាយទូទាំងវិស័យផែនការនីយកម្មមានប្រសិទ្ធភាព ការត្រួតពិនិត្យតាមដានស្នាដៃការងារនិងការសំរបសំរួល ។ |

## ៤. ទិសដៅគោលនយោបាយសុខាភិបាល

សំរាប់ប្រទេសកម្ពុជានៅដំណាក់កាលបច្ចុប្បន្ននៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ចក្ខុវិស័យ បេសកកម្ម គុណតំលៃ និងគោលការណ៍របស់ក្រសួងសុខាភិបាល តំរូវឱយមានទិសដៅគោលនយោបាយច្បាស់លាស់មួយសំរាប់បណ្តាឆ្នាំខាងមុខ។ ចាត់ទុកជាជំហានដំបូងនៃការអនុវត្តន៍ផែនការយុទ្ធសាស្រ្តដូច្នេះ ទិសដៅគោលនយោបាយខាងក្រោមនេះ ត្រូវតែអនុមត័តាមរយៈគោលនយោបាយដែលបានកំណត់យល់ព្រម និងប្រកាសឱយប្រើប្រាស់ទូទាំងវិស័យសុខាភិបាល។ គោលនយោបាយទាំងអស់នេះគឺត្រូវការជាមុន សំរាប់ការពង្រឹងនិងពង្រីកជោគជយ័នៃបណ្តាឆ្នាំមុនៗ ហើយនឹងស្ថាបនាគ្រឹះសំរាប់យុទ្ធសាស្រ្តដែលនឹងត្រូវប្រកាន់យកក្នុងរយៈពេលនៃផែនការយុទ្ធសាស្រ្តនេះ។

### ទិសដៅគោលនយោបាយសុខាភិបាល ២០០៨-២០១៥

១. ធ្វើអោយសេវាកាន់តែឆ្លើយតប និងខិតកាន់តែជិតសាធារណៈជន តាមរយៈការអនុវត្តន៍វិមជ្ឈការលើមុខងារផ្តល់សេវានិងមុខងារគ្រប់គ្រង ដែលណែនាំដោយ“គោលនយោបាយជាតិស្តីពីការផ្តល់សេវាសាធារណៈ” និង“គោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ”។

២. ពង្រឹងអភិបាលកិច្ចទូទាំងវិស័យសុខាភិបាល តាមរយៈការអនុវត្តន៍នូវអភិក្រមគ្រប់គ្រងបើកទូលាយទូទាំងវិស័យ ដោយផ្តោតលើការបង្កើនភាពម្ចាស់ការនិងការទទួលខុសត្រូវ ដើម្បីលើកកំពស់លទ្ធផលសុខភាព សុខដុមនីយកម្មនិងការតំរៀបតំរង់ ការសំរបសំរួលកាន់តែប្រសើរ និងភាពជាដៃគូប្រកបដោយប្រសិទ្ធភាពនៅក្នុងចំណោមដៃគូទាំងអស់ ។

៣. ពង្រីកលទ្ធភាពមកទទួលយកសេវានិងការគ្របដណ្តប់សេវា ពិសេសសេវាគ្រប់ជ្រុងជ្រោយនៃសុខភាពបន្តពូជ មាតា ទារកនិងកុមារ តាមរយៈយន្តការនានាដូចជា ស្ថាបនីយកម្មការពង្រីកកិច្ចសន្យាផ្តល់សេវាតាមរយៈ ទីភ្នាក់ងារប្រតិបត្តិការពិសេស ការលើកលែងការបង់ថ្លៃសេវាចំពោះអ្នកក្រីក្រ មូលនិធិសមធម៌ និងការធានារ៉ាប់រងសុខភាព។

៤. អនុវត្តប្រព័ន្ធហិរញ្ញប្បទានសុខាភិបាលគាំទ្រដល់ជនក្រីក្រ តាមរយៈការលើកលែងការបង់ថ្លៃ ការពង្រីកមូលនិធិសមធម៌ រួមជាមួយនឹងយន្តការជំនួយសង្គមដទៃទៀត។

៥. ពង្រឹងការអនុវត្តន៍និតិក្រមសុខាភិបាល ក្រមសីលធម៌វិជ្ជាជីវៈ និងលក្ខន្តិកៈ ព្រមទាំងពង្រឹងយន្តការនិយតកម្ម ដោយរាប់បញ្ចូលការផលិត ការចែកចាយ ការគ្រប់គ្រងគុណភាពឱសថ គ្រឿងសំអាង អនាមយ័ និងសុវត្ថិភាពចំណីអាហារ ដើម្បីការពារសិទ្ធិនិងសុខភាពរបស់អ្នកផ្តល់សេវានិងអតិថិជន។

៦. លើកកំពស់គុណភាពក្នុងការផ្តល់សេវាសុខភាពនិងការគ្រប់គ្រង តាមរយៈការបង្កើតនិងការគោរពតាមពិធីសារ សេចក្តីណែនាំវេជ្ជសាស្ត្រនិងបទដ្ឋានគុណភាព ពិសេសការបង្កើតប្រពន្ធ័ទទួលស្គាល់គុណភាព ។

៧. បង្កើនសមត្ថភាពជំនាញរបស់បុគ្គលិកសុខាភិបាល ដើម្បីឆ្លើយតបនឹងកំណើននៃតំរូវការឱយមានការទទួលខុសត្រូវ និងការថែទាំសុខភាពមានគុណភាពខ្ពស់ ដោយរាប់បញ្ចូលការពង្រឹងជំនាញ បច្ចេកទេសពាក់ពន្ធ័ បច្ចេកវិទ្យាទំនើប តាមរយៈការអនុវត្តន៍ការកែលំអគុណភាពក្នុងការបណ្តុះបណ្តាល ការអភិវឌ្ឍន៍អាជីព ការលើកទឹកចិត្តត្រឹមត្រូវ និងបរិយាកាសបំពេញការងារល្អ ។

៨. ពង្រឹងនិងវិនិយោគលើប្រពន្ធ័ពត៌មានសុខាភិបាល និងលើកកំពស់ការស្រាវជ្រាវសុខភាពសំរាប់ការកសាងគោលនយោបាយ ផែនការនីយកម្ម ការត្រួតពិនិត្យតាមដានស្នាដៃនិងការវាយតំលៃដោយផ្អែកទៅលើមូលដ្ឋានទិន្នន័យជាក់ស្តែង ។

៩. បង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឧបករណ៍-បរិក្ខាពេទ្យ និងបច្ចេកវិទ្យាទំនើប ជាមួយនឹងការលើកកំពស់សេវាគាំទ្រមិនមែនវេជ្ជសាស្ត្រ ដោយរាប់បញ្ចូលទាំងសុវត្ថិភាពឈាម ការគ្រប់គ្រង-ថែទាំជួសជុល និងប្រព័ន្ធផ្គត់ផ្គង់ឱសថ- ឧបករណ៍-បរិក្ខាដទៃទៀត ។

១០. លើកកំពស់គុណភាពនិងរបៀបរបប នៃការរស់នៅប្រកបដោយសុខភាពល្អរបស់ប្រជាជន តាមរយៈការបង្កើនការយល់ដឹងអំពីសុខភាពរបស់ប្រជាជន និងបង្កើតបរិយាកាសគាំទ្រ ដោយរាប់បញ្ចូលទាំងការពង្រឹងរចនាសម្ពន្ធ័ ធនធានមនុស្សនិងហិរញ្ញវត្ថុ សំភារៈសំរាប់ការផ្តល់ពត៌មាន-ការអប់រំ-ការប្រាស្រយ័ទាក់ទងដើម្បីលើកកំពស់សុខភាពសំដៅធ្វើអោយមានការផ្លាស់ប្តូរឥរិយាបទផ្នែកសុខភាព និងការប្រព្រឹត្តត្រឹមត្រូវក្នុងការស្វែងរកការថែទាំសុខភាព ។

១១. បង្ការនិងទប់ស្កាត់ជំងឺឆ្លង ជំងឺរ៉ាំរ៉ៃនិងជំងឺមិនឆ្លង ព្រមទាំងពង្រឹងប្រព័ន្ធតាមដានជំងឺដើម្បីឆ្លើយតបមានប្រសិទ្ធភាពទៅនឹងជំងឺរាតត្បាតដែលលេចឡើង និងលេចឡើងសារជាថ្មី ។

១២. ពង្រឹងអន្តរាគមន៍សុខភាពសាធារណៈ ដើម្បីដោះស្រាយបញ្ហាប្រឈមមុខប្រទាក់ក្រឡាពិសេស ផ្នែកយែនឌ័រ សុខភាពជនជាតិភាគតិច អនាម័យ-ភាពស្អាត សុខភាពនៅតាមសាលារៀន ហានិភយ័សុខភាពបរិស្ថាន ការប្រើប្រាស់គ្រឿងញៀន/សុខភាពផ្លូវចិត្ត របួស សុខភាពការងារ គ្រោះមហន្តរាយ តាមរយៈការឆ្លើយតបទាន់ពេលវេលា កិច្ចសហការ និង ការសំរបសំរួលដ៏មានប្រសិទ្ធភាពជាមួយវិស័យដទៃទៀត ។

១៣. លើកកំពស់ភាពជាដៃគូមានប្រសិទ្ធភាព រវាងវិស័យសាធារណៈ និងឯកជនក្នុងការផ្តល់សេវា ដោយផ្អែកទៅលើគោលនយោបាយ បទបញ្ញត្តិច្បាប់ និងបទដ្ឋានបច្ចេកទេស។

១៤. លើកទឹកចិត្តការចូលរួមរបស់សហគមន៍ នៅក្នុងសកម្មភាពផ្តល់សេវាសុខភាព និងការគ្រប់គ្រងមូលដ្ឋានសុខាភិបាល ដោយរាប់បញ្ចូលទាំងការតស៊ូមតិ ដើម្បីការលើកកំពស់គុណភាពសេវាជាប្រចាំ។

១៥. ពង្រឹងស្ថាប័នសុខាភិបាលគ្រប់ថ្នាក់ នៅក្នុងប្រព័ន្ធសុខាភិបាល ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពនូវទិសដៅគោលនយោបាយដែលបានលើកឡើងក្នុងចំណុចទាំង ១៤ខាងលើ។

# ជំពូក ២

# ទិដ្ឋភាពរួមវិស័យសុខាភិបាល

- ការរៀបចំប្រពន្ធ័សុខាភិបាល
- ផែនការគ្របដណ្តប់សុខាភិបាល
- អភិបាលកិច្ចជំនួយ
- ការអភិវឌ្ឍន៍ស្ថាបន័
- វិមជ្ឈការនិងវិសហវិមជ្ឈការ
- ការពិនិត្យវាយតំលៃវិស័យសុខាភិបាលឆ្នាំ២០០៧

# ២ ទិដ្ឋភាពរួមវិស័យសុខាភិបាល

## ១. ការរៀបចំប្រព័ន្ធសុខាភិបាល

ចាប់ពីឆ្នាំ១៩៩៤ មកក្រសួងសុខាភិបាលបានប្តេជ្ញាក្នុងការរៀបចំឡើងវិញ នូវប្រព័ន្ធសុខាភិបាល ដោយផ្តោតជាចំបងទៅលើថ្នាក់ស្រុក។ កំណែទំរង់ប្រព័ន្ធសុខាភិបាល គឺជាផ្នែកមួយនៃកំណែទំរង់រដ្ឋបាលសាធារណៈជាតិទូលំទូលាយ។ កំណែទំរង់នេះបង្ហាញអំពីឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹង និងលើកស្ទួយឱយ កាន់តែប្រសើរឡើងប្រសិទ្ធភាព និងប្រសិទ្ធផលនៃវិសយ័សាធារណៈ។ គោលដៅចំបងនៃកំណែទំរង់ប្រព័ន្ធសុខាភិបាលគឺដើម្បី **លើកកំពស់និងពង្រីកការថែទាំសុខភាពបឋម តាមរយៈការអនុវត្តន៍ប្រព័ន្ធសុខាភិបាលស្រុក** (ផែនការមេក្រសួងសុខាភិបាល ១៩៩៤-១៩៩៦)។

ក្រសួងសុខាភិបាលអនុវត្តកំណែទំរង់ ដើម្បីឆ្លើយតបនឹងតំរូវការផ្នែកសុខភាពជាសារវន្ត របស់ប្រជាជនតាមរយៈ

- លើកកំពស់ជំនឿទុកចិត្តរបស់ប្រជាជនមកលើសេវាសុខភាពសាធារណៈ
- បញ្ជាក់និងពង្រឹងតួនាទីរបស់មន្ទីរពេទ្យនិងមណ្ឌលសុខភាព
- បង្កើតតំបន់ទទួលខុសត្រូវសំរាប់មូលដ្ឋានសុខាភិបាលនិមួយៗ ដើម្បីធានាដល់ការគ្របដណ្តប់លើប្រជាជន
- សនិទានកម្មលើការវិភាជន៍និងការប្រើប្រាស់ធនធាន

កំណែទំរង់វិស័យសុខាភិបាលទាមទារឱយមានរូបបរិវត្តន៍ ទាំងផ្នែកហិរញ្ញប្បទាន និងរចនាសម្ព័ន្ធស្ថាប័នដូចជា៖

- ការបែងចែកធនធាន ប្រកបដោយសនិទានកម្មដោយផ្អែកលើផែនការគ្រប់ដណ្តប់សុខាភិបាល៖ ហិរញ្ញវត្ថុ ហេដ្ឋារចនាសម្ព័ន្ធ ឱសថ សំភារៈបរិក្ខារ និងធនធានមនុស្ស
- រៀបចំឡើងវិញនូវក្របខណ្ឌស្ថាប័ននៅថ្នាក់កណ្តាល ខេត្ត-ក្រុងនិងស្រុក
- កំណែទំរង់ថវិកា ដូចជាផ្លាស់ប្តូរវិធីសាស្ត្រទៅរកការវិភាជន៍ថវិកាតាមរូបមន្ត
- កំណត់និយមន័យថ្មីសំរាប់ប្រពន្ធ័សុខាភិបាល និងប្រភេទសេវាដែលរំពឹងទុក នៅថ្នាក់និមួយៗនៃប្រពន្ធ័សុខាភិបាល (រូបភាព១)
- បែងចែកឡើងវិញ និងបណ្តុះបណ្តាលឡើងវិញបុគ្គលិកសុខាភិបាល
- ដាក់ចេញមធ្យោបាយថ្មីនានាដើម្បីហិរញ្ញប្បទានសេវាសុខភាព

**រូបភាព ១: ការរៀបចំប្រពន្ធ័សុខាភិបាល**




(**ស.ស.ប៖** សំណុំសកម្មភាពបង្គ្រប់- **ស.ស.អ៖** សំណុំសកម្មភាពអប្បបរមា)

### ថ្នាក់ស្រុកប្រតិបត្តិ

ស្រុកប្រតិបត្តិ គឺជាអនុប្រពន្ធ័បរិមណ្ឌលនៅក្នុងប្រពន្ធ័សុខាភិបាល ហើយស្ថិតនៅជិតបំផុតនឹងប្រជាជន។ នៅពេលដែលស្រុកប្រតិបត្តិត្រូវបានតំរៀបតំរង់ទៅតាមថ្នាក់រដ្ឋបាលដូចជាខណ្ឌ-ស្រុករដ្ឋបាល និងឃុំ-សង្កាត់ ការកំណត់ទំហំ និងការគ្របដណ្តប់របស់ស្រុកប្រតិបត្តិត្រូវតែពិចារណាដល់កត្តាសេដ្ឋកិច្ច និងសុខភាពសាធារណៈ ដើម្បីបន្ថយជាអប្បបរមានូវការត្រួតជាន់គ្នានៃសកម្មភាពនិងការខ្ជះខ្ជាយធនធានសាធារណៈ។ ស្រុកប្រតិបត្តិផ្សំឡើងដោយមណ្ឌលសុខភាពជាច្រើននិងមន្ទីរពេទ្យបង្អែកមួយ។ តួនាទីចំបងរបស់ស្រុកប្រតិបត្តិ គឺអនុវត្តគោលដៅសុខភាពរបស់ស្រុកប្រតិបត្តិតាមរយៈ

- បកស្រាយផ្សព្វផ្សាយ និងអនុវត្តគោលនយោបាយសុខាភិបាលជាតិ និងយុទ្ធសាស្ត្ររបស់ខេត្ត-ក្រុង
- ប្រកាន់ភ្ជាប់នូវសេវាមានប្រសិទ្ធភាព ប្រសិទ្ធផល និងគ្រប់ជ្រុងជ្រោយ (លើកកំពស់សុខភាព បង្ការព្យាបាលនិងស្តារនិតិសម្បទា) យោងតាមតំរូវការរបស់សហគមន៍
- ធានាការចែកចាយធនធានមានសមធម៌ និងប្រើប្រាស់ធនធានទាំងអស់នោះមានប្រសិទ្ធផល
- កៀងគរធនធានបន្ថែមសំរាប់សេវាសុខភាពក្នុងស្រុក ឧ. ការទ្រទ្រង់ពីអង្គការក្រៅរដ្ឋាភិបាល
- សហការជាមួយឃុំ-សង្កាត់និងអាជ្ញាធររដ្ឋបាលមូលដ្ឋាន

## ២. ផែនការគ្របដណ្តប់សុខាភិបាល

ផែនការគ្របដណ្តប់សុខាភិបាល គឺជាក្របខណ្ឌ័សំរាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធ័ប្រពន្ធ័សុខាភិបាល ដោយឈរលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យទំហំប្រជាជន និងលទ្ធភាពភូមិសាស្ត្រក្នុងការមកទទួលយកសេវា។ គោលការណ៍អនុវត្តក្នុងការជ្រើសរើសយកលក្ខណៈវិនិច្ឆ័យនេះគឺ៖

- គ្របដណ្តប់ប្រជាជនទាំងមូល ដោយមិនទុកឱយមានចន្លោះប្រហោងឬត្រួតជាន់គ្នា
- តំរូវការផ្នែកសុខភាពជាមូលដ្ឋានរបស់ប្រជាជនភាគច្រើនលើសលប់
- គុណភាពសេវាថែទាំ-សមារណកម្មការថែទាំ
- ធនធានដែលអាចរកបាន

**តារាង ១: លក្ខណៈវិនិច្ឆ័យនៃផែនការគ្របដណ្តប់សុខាភិបាល**

| លក្ខណៈវិនិច្ឆ័យ | (១)ចំនួនប្រជាជន | (២)លទ្ធភាពភូមិសាស្ត្រ |
|---|---|---|
| មណ្ឌលសុខភាព (ស.ស.អ) | គោលការណ៍៖ ១០.០០០ នាក់<br>ប្រែប្រួលពី ៨.០០០-១២.០០០នាក់ | រង្វង់ចំងាយ ១០គ.ម ឬ<br>ធ្វើដំណើរអតិបរមា ២ ម៉ោង ដោយថ្មើរជើង |
| មន្ទីរពេទ្យបង្អែក (ស.ស.ប) | គោលការណ៍៖១០០.០០០-២០០.០០០<br>ប្រែប្រួលពី៦០.០០០-២០០.០០០នាក់ | ២០-៣០គ.ម រវាងមន្ទីរពេទ្យបង្អែក២<br>ឬធ្វើដំណើរ ៣ម៉ោង ដោយរថយន្តឬកាណូត |

ផែនការគ្រប់ដណ្តប់សុខាភិបាលដែលដាក់ឱយអនុវត្តនៅឆ្នាំ ១៩៩៥ មានបំណង:

- អភិវឌ្ឍសេវាសុខភាពទៅតាមលក្ខណៈវិនិច្ឆ័យ សំរាប់ទីតាំងមូលដ្ឋានសុខាភិបាលនិងតំបន់ទទួលខុសត្រូវរបស់ខ្លួន
- បែងចែកធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស
- ធានាឆ្លើយតបតំរូវការផ្នែកសុខភាពរបស់ប្រជាជនប្រកបដោយសមធម៌តាមរយៈការគ្របដណ្តប់ពេញលេញ

ការចំណោលប៉ាន់ស្មាននៃផែនការគ្របដណ្តប់សុខាភិបាលដែលបង្ហាញនៅក្នុងតារាង១ខាងក្រោមគឺផ្អែកលើ:

- ចំណោលប៉ាន់ស្មាននៃចំនួនប្រជាជនកម្ពុជា (Population Projection for Cambodia 1998-2020, June 2004 វិទ្យាស្ថានស្ថិតិនៃក្រសួងផែនការ )
- លក្ខណៈវិនិច្ឆយ័: ចំនួនប្រជាជន ១០.០០០នាក់ សំរាប់មណ្ឌលសុខភាពមួយ និង ២០០.០០០នាក់ សំរាប់ស្រុកប្រតិបត្តិ/មន្ទីរពេទ្យបង្អែកមួយ។

**តារាង ២: ផែនការគ្របដណ្តប់សុខាភិបាល**

| កូដខេត្ត | ខេត្ត | ស្រុកប្រតិបត្តិ | | | មន្ទីរពេទ្យបង្អែក | | | មណ្ឌលសុខភាព | | | ប៉ុស្តិ៍សុខភាព | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឆ្នាំ | ៩៥ | ០៧ | ១៥ | ៩៥ | ០៧ | ១៥ | ៩៥ | ០៧ | ១៥ | ៩៥ | ០៧ | ១៥ |
| ១ | បន្ទាយមានជ័យ | ៣ | ៤ | ៥ | ៣ | ៥ | ៥ | ៤៥ | ៥៥ | ១០១ | | ៨ | |
| ២ | បាត់ដំបង | ៣ | ៥ | ៦ | ៣ | ៤ | ៦ | ៥៩ | ៧៥ | ១២២ | | ៣ | |
| ៣ | កំពង់ចាម | ១០ | ១០ | ១១ | ១០ | ១០ | ១១ | ១២៨ | ១៣៥ | ២១៨ | | ០ | |
| ៤ | កំពង់ឆ្នាំង | ២ | ៣ | ៣ | ២ | ២ | ៣ | ៣៤ | ៣៤ | ៦៦ | | ៣ | |
| ៥ | កំពង់ស្ពឺ | ៣ | ៣ | ៥ | ៣ | ៣ | ៥ | ៥០ | ៥០ | ៩២ | | ០ | |
| ៦ | កំពង់ធំ | ៣ | ៣ | ៤ | ៣ | ៣ | ៤ | ៥០ | ៥០ | ៨៣ | | ០ | |
| ៧ | កំពត | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ៤៦ | ៤៧ | ៧០ | | ១ | |
| ៨ | កណ្តាល | ៨ | ៨ | ៨ | ៥ | ៥ | ៧ | ៨៨ | ៩១ | ១៤៦ | | ៣ | |
| ៩ | កោះកុង | ២ | ២ | ២ | ២ | ២ | ១ | ១២ | ១៣ | ២៨ | | ២ | |
| ១០ | ក្រចេះ | ២ | ២ | ២ | ២ | ២ | ២ | ២២ | ២៣ | ៤៣ | | ៩ | |
| ១១ | មណ្ឌលគិរី | ១ | ១ | ១ | ១ | ១ | ១ | ៦ | ៧ | ៧ | | ១៧ | |
| ១២ | រាជធានីភ្នំពេញ | ៤ | ៤ | ៩ | ១ | ៥ | ៩ | ៣៧ | ១៧ | ១៧៥ | | ២ | |
| ១៣ | ព្រះវិហារ | ១ | ១ | ១ | ១ | ១ | ១ | ១២ | ១៤ | ២០ | | ១៩ | |
| ១៤ | ព្រៃវែង | ៧ | ៧ | ៧ | ៧ | ៧ | ៧ | ៩០ | ៩០ | ១១៦ | | ០ | |
| ១៥ | ពោធិសាត់ | ២ | ២ | ៣ | ២ | ២ | ៣ | ៣០ | ៣២ | ៥២ | | ៤ | |
| ១៦ | រតនៈគិរី | ១ | ១ | ១ | ១ | ១ | ១ | ១៥ | ១១ | ១៦ | | ១៨ | |
| ១៧ | សៀមរាប | ៤ | ៤ | ៥ | ៤ | ៤ | ៥ | ៥៧ | ៦០ | ១០៩ | | ០ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១៨ | ក្រុងព្រះសីហនុ | ១ | ១ | ១ | ១ | ១ | ១ | ១១ | ១១ | ២៩ | ១ |
| ១៩ | ស្ទឹងត្រែង | ១ | ១ | ១ | ១ | ១ | ១ | ១០ | ១០ | ១៤ | ៣ |
| ២០ | ស្វាយរៀង | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣៧ | ៣៧ | ៦១ | ០ |
| ២១ | តាកែវ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៧០ | ៧២ | ១០៤ | ២ |
| ២២ | ឧត្តរមានជ័យ | ០ | ១ | ១ | ០ | ១ | ២ | ០ | ១៤ | ១៥ | ០ |
| ២៣ | ក្រុងកែប | ១ | ១ | ១ | ១ | ១ | ១ | ៤ | ៤ | ៥ | ០ |
| ២៤ | ក្រុងប៉ៃលិន | ០ | ១ | ១ | ០ | ១ | ១ | ០ | ៥ | ៥ | ០ |
| | **សរុប** | **៧១** | **៧៧** | **៩០** | **៦៥** | **៧៤** | **៨៩** | **៩១៣** | **៩៥៧** | **១.៦៩៧** | **៩៥** |

## ៣. អភិបាលកិច្ចជំនួយ ការអភិវឌ្ឍន៍ស្ថាប័ន វិមជ្ឈការនិងវិសហមជ្ឈការ

សេចក្តីប្រកាសក្រុងប៉ារីស **ស្តីអំពីប្រសិទ្ធភាពនៃជំនួយ** ត្រូវបានអនុវត្តតាមរយៈ **ផែនការសុខដុមនីយកម្ម ការតំរៀបតំរង់ដើម្បីលទ្ធផល**របស់រាជរដ្ឋាភិបាល។ ផែនការនេះបានចាត់ទុកភាពម្ចាស់ការជាសសរទ្រូងនៃការគ្រប់គ្រងជំនួយមានប្រសិទ្ធភាព។ វឌ្ឍនភាពក្នុងការពង្រឹងដៃគូអភិវឌ្ឍន៍នៅឆ្នាំ២០០៦និងដើមឆ្នាំ២០០៧ អំពាវនាវឱយមានសកម្មភាពច្បាស់លាស់ សំរាប់ពង្រឹងការផ្សារភ្ជាប់គ្នារវាងការខិតខំប្រឹងប្រែងដើម្បីប្រសិទ្ធភាពនៃជំនួយ ទៅនឹងសមិទ្ធផលដែលជាលទ្ធផលនៃការអភិវឌ្ឍន៍។

ដៃគូអភិវឌ្ឍន៍បច្ចុប្បន្នកំពុងគាំទ្រក្រសួងសុខាភិបាល ក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្រ្តសុខាភិបាលក្នុងក្របខណ្ឌនៃអភិក្រមគ្រប់គ្រងបើកទូលាយទូទាំងវិស័យដែលបានប្រកាន់យកដោយក្រសួងសុខាភិបាលកាលពីឆ្នាំ២០០០។ មានការអះអាងថា អភិក្រមគ្រប់គ្រងបើកទូលាយទូទាំង វិស័យបានទទួលជោគជ័យនៅក្នុងការស្ថាបនាគ្រឹះ សំរាប់ការសំរបសំរួលមានប្រសិទ្ធភាពនៅ

រូបភាព ២: វិធីសាស្រ្តហិរញ្ញប្បទានដល់វិស័យសុខាភិបាល




ក្នុងវិស័យទោះបីជាបែបបទនៃការប្រព្រឹត្តទៅមានសភាពយឺតយ៉ាវជាងការរំពឹងទុកក៏ដោយ។ ក្នុងបរិបទខាងលើនេះ ក្រសួងសុខាភិបាលទទួលស្គាល់ពីសារៈសំខាន់នៃការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូក្រៅប្រទេស ហើយឆ្លុះបញ្ចាំងនៅក្នុងសកម្មភាពរបស់ ផ.យ.ស.២ តាមរយៈសមាសភាគយុទ្ធសាស្រ្តមួយ ដើម្បីទ្រទ្រង់ដល់សុខដុមនីយកម្មនិងការតំរៀបតំរង់ដើម្បីលទ្ធផល។ រូបភាព២ បង្ហាញអំពីទិដ្ឋភាពរួមនៃយន្តការផ្តល់មូលនិធិពីគ្រប់ប្រភពទាំងអស់ដល់អាចមានដល់វិស័យសុខាភិបាល ហើយដែលបានប្រកាន់ដោយក្រសួងសុខាភិបាល (លិខិតផ្លូវការរបស់ក្រសួងសុខាភិបាលជូនដៃគូសុខាភិបាល: **ការសំរេចចិត្ត**

**អំពីជំរើសសំរាប់ដំណើរឆ្ពោះទៅកាន់អភិក្រមបើកទូលាយទូទាំងវិស័យនៅក្នុងវិសយ័សុខាភិបាល២៣មិនា ២០០៧)។**

ការអនុវត្តន៍ ផ.យ.ស.២ ផ្តល់កាលានុវត្តភាពដ៏ធំធេង ដើម្បីលើកតំកើងភាពម្ចាស់ការរបស់រាជរដ្ឋាភិបាលកម្ពុជាលើវិសយ័សុខាភិបាល ប៉ុន្តែក៏នាំមកនូវបញ្ហាប្រឈមមុខដល់ប្រពន្ធ័សុខាភិបាលក្នុងការអភិវឌ្ឍន៍ស្ថាប័នបន្តទៅមុខទៀត។ បើសិនសេវាសុខភាពដែលផ្តល់ត្រូវតែមានគុណភាពខ្ពស់នៅចំពោះមុខឧបសគ្គ័ផ្នែកថវិកា នោះទាមទារឱយមានសមត្ថភាពគ្លីនិក និងសមត្ថភាពគ្រប់គ្រងកាន់តែល្អប្រសើរឡើង រួមទាំងប្រពន្ធ័ទានាផងដែរដើម្បីគ្រប់គ្រងថវិកានិងបុគ្គលិក។ លើសពីនេះទៀត សមត្ថភាពថ្មីរបស់ស្ថាប័ននឹងតំរូវឱយមាន ដែលជាលទ្ធផលនៃការផ្លាស់ប្តូរសំខាន់ៗនៃតួនាទី និងមុខងាររបស់នាយកដ្ឋានអង្គភាពថ្នាក់កណ្តាល មន្ទីរសុខាភិបាល ខេត្ត-ក្រុង ស្រុក និងសហគមន៍ នៅក្រោមកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ។ មានការឯកភាព ជាទូទៅថាការផ្លាស់ប្តូររចនាសម្ពន្ធ័ស្ថាប័ននឹងមិនអាចកើតចេញជារូបរៀងបានឡើយ ដរាបណាគ្មានការរៀបចំនិងចាត់ចែងគ្រឿងលើកទឹកចិត្តត្រឹមត្រូវ។ បញ្ហាប្រឈមមុខទាំងអស់នេះផ្តល់បរិបទសំរាប់ការតាំងចិត្តដ៏មោះមុតនៅក្នុងអំលុងពេល ផ.យ.ស.២ ដើម្បីការវិនិយោគលើការគ្រប់គ្រងឱយល្អប្រសើរនិងក្នុងការអភិវឌ្ឍន៍ប្រពន្ធ័ស្ថាបន័រយៈពេលយូរអង្វែង។

សារៈសំខាន់នៃការពង្រឹងស្ថាបន័នឹងអាចសំរេចបាន តាមរយៈការបង្កើនចំនួនអង្គភាពក្នុងវិសយ័សុខាភិបាលដែលដំណើរការប្រពន្ធ័មានប្រសិទ្ធភាព (ដោយរាប់បញ្ចូលទាំងការគ្រប់គ្រងប្រពន្ធ័ពត៌មាន) ដើម្បីទ្រទ្រង់ដល់មុខងារៈ កសាងផែនការយុទ្ធសាស្រ្ត ផែនការប្រតិបត្តិ ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងផលិតកម្មសេវា (ដោយរាប់បញ្ចូលទាំងការគ្រប់គ្រងគុណភាពនិងការគ្រប់គ្រងកិច្ចសន្យា (នៅកន្លែងណាដែលមាន) ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អង្គភាព។

## ៤. ការពិនិត្យវាយតំលៃវិសយ័សុខាភិបាលឆ្នាំ២០០៧

ការពិនិត្យឡើងវិញវិសយ័សុខាភិបាលនៅឆ្នាំ២០០៧ បញ្ជាក់ចរិតលក្ខណៈនៃផែនការយុទ្ធសាស្រ្តសុខាភិបាល២០០៣-២០០៧ (ផ.យ.ស.១) ថាជាព្រឹត្តការណ៍ដ៏គួរឱយកត់សំគាល់សំរាប់វិសយ័សុខាភិបាលនៅកម្ពុជា។ ការពិនិត្យឡើងវិញនេះរួមបញ្ចូលនូវកំរងនៃការពិនិត្យវាយតំលៃមួយចំនួន ដូចជាការពិនិត្យវាយតំលៃៈបច្ចេកវិទ្យាឆ្អប ការគ្រប់គ្រងបើកទូលាយទូទាំងវិសយ័ កិច្ចសន្យាសេវា និងការពិនិត្យពាក់កណ្តាលអណត្តិនៃគំរោងទ្រទ្រង់វិសយ័សុខាភិបាល។ ការពិនិត្យឡើងវិញវិសយ័សុខាភិបាលនេះមានបំណងវាស់វែងវឌ្ឍនភាព ក្នុងការឆ្ពោះទៅសំរេចគោលបំណង និងគោលដៅនៃផ.យ.ស.១ និងគំរោងទ្រទ្រង់វិសយ័សុខាភិបាលដកស្រង់មេរៀន និងបទពិសោធន៍ចេញពីការអនុវត្តន៍ក្នុងអំលុងពេល៥ឆ្នាំ ដើម្បីអភិវឌ្ឍជំរើសគោលនយោបាយ និងយុទ្ធសាស្រ្តសំរាប់ការដាក់ចេញនូវផែនការយុទ្ធសាស្រ្តសុខាភិបាល ២០០៨-២០១៥ (ផ.យ.ស.២)។

លទ្ធផលនៃការពិនិត្យវាយតំលៃនេះ និងបន្តសារជាថ្មីនូវចក្ខុវិសយ័នៃវិសយ័សុខាភិបាល និងការអភិវឌ្ឍន៍ ផ.យ.ស.២ ស្របតាមចក្ខុវិស័យនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ)។

## ៩.១ លទ្ធផលសុខភាពនិងការប្រើប្រាស់សេវា

ការប្រើប្រាស់សេវាសុខភាពមានការរីកចំរើនក្នុងអំលុងពេលនៃផ.យ.ស.១ វឌ្ឍនភាពនេះឈានចេញពីកំរិតទាបនៃខ្សែបន្ទាត់គ្រាដើម (តារាង៣និងរូបភាព៣) ថ្វីត្បិតតែមានភាពប្រសើរជាងពេលមុន ក៏កំរិតនៃការប្រើប្រាស់សេវាសាធារណៈស្ថិតនៅឆ្ងាយពីអ្វី ដែលជាតំរូវការចាំបាច់ ដើម្បីសំរេចបានលទ្ធផលសុខភាពល្អ។ មានសញ្ញានៃអតុល្យភាពតាមតំបន់ក្នុងការប្រើប្រាស់សេវា និងរវាងទីប្រជុំជនធំៗនិងតំបន់ជនបទ។

**តារាង៣: ការពិគ្រោះជំងឺនៅមូលដ្ឋានសុខាភិបាលសាធារណៈ**

| ឆ្នាំ | ថ្នាក់ខេត្ត | មន្ទីរពេទ្យជាតិ | ចំនួនពិនិត្យក្នុងម្នាក់ |
|---|---|---|---|
| ២០០២ | ៤.៥៩៥.៩៣៩ | ២៣៣.៦៥០ | ០,៤០ |
| ២០០៣ | ៤.៥៩៧.៨៧៦ | ៣៦៨.៥១៧ | ០,៣៩ |
| ២០០៤ | ៥.៣៨៨.៨៨៥ | ៥២៦.៣០៣ | ០,៤០ |
| ២០០៥ | ៦.២៥៤.៧២៦ | ៦៩៧.៦៤៦ | ០,៥០ |
| ២០០៦ | ៧.៥១០.៥៥៨ | ៨៨៦.៨៩៥ | ០,៦០ |
| **២០០៧** | **៧,៣៦១.៣៩៤** | **៩៧៨.៥២៤** | ០,៥១ |

ប្រភព : ប្រពន្ធ័ពត៌មានសុខាភិបាល ២០០៧

នៅក្រោមផ.យ.ស.១ បញ្ហាសុខាភិបាលចំបងៗដូចជា សមធម៌និងតួនាទីនៃវិសយ័ឯកជននៅមិនទាន់បញ្រ្ជាបឱយបានគ្រប់គ្រាន់ ទៅក្នុងបែបបទផែនការនីយកម្មនិងការត្រួតពិនិត្យតាមដាន។

**រូបភាព៣:អត្រាប្រើប្រាស់គ្រែតាមប្រភេទមន្ទីរពេទ្យ ២០០៦**




ប្រភព : ប្រពន្ធ័ពត៌មានសុខាភិបាល ២០០៧

ការអង្កេតប្រជាសាស្ត្រ និងសុខភាព២០០៥ (អ.ប្រ.ស.០៥) បានបង្ហាញអំពីភាពប្រសើរឡើងនៃការគ្របដណ្តប់នៃសេវាសុខភាពមាតានិងកុមារ (តារាង៤) វឌ្ឍនភាពបានកើតមានលើផ្នែកសុខភាពមាតា ទោះជាដូច្នេះក្តីអត្រាស្លាប់របស់មាតានៅមានកំរិតខ្ពស់មិនអាចទទួលយកបានដោយសារតែការប្រើប្រាស់សេវាសំខាន់ៗនៅទាប ពិសេសនៅតំបន់ជនបទ។

ការស្លាប់នៃមាតាគឺជាបញ្ហាអន្តរវិសយ័ដែលរងឥទ្ធិពលពីកំរិតនៃការអប់រំអនក្ខរកម្ម ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធ័ និងកំរិតនៃការចូលរួមរបស់ស្ត្រីព្រមទាំងបញ្ហាសមធម៌ផ្នែកយែនឌរ័។ មរណៈភាពមាតាត្រូវបានទទួលស្គាល់ជាទូទៅថាជាប្រភេទសូចនាករមួយ នៃប្រពន្ធ័

**តារាងទី៤: សេវាសុខភាពបន្តពូជ និងសុខភាពមាតា_ទារក**

| សូជូនាករសំខាន់ | ២០០០ | ២០០៥ | ២០០៧ |
|---|---|---|---|
| ការសំរាលកូននៅមូលដ្ឋានសុខាភិបាល | ១០% | ២២% | |
| ការសំរាលកូនដោយបុគ្គលិកបានទទួលការបណ្តុះបណ្តាល | ៣២% | ៤៤% | ៤៦% |
| ការពិនិត្យផ្ទៃពោះមុនសំរាល ២ ដង | ៣៨% | ៦៩% | ៦៨% |
| ការចាក់ថ្នាំបង្ការតេតាណូសលើស្ត្រីមានផ្ទៃពោះ | ៤៥% | ៧៧% | ៥០% |
| ស្ត្រីរៀបការកំពុងប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប | ១៨,៥% | ២៧,២% | ២៧% |
| **អត្រាមរណៈរបស់មាតា** | **៤៣៧** | **៤៧២** | |

ប្រភព :២០០០និង២០០៥ :អ.ប្រ.ស. ២០០២/០៧ : ប្រពន្ធ័ពត៌មានសុខាភិបាល

សុខាភិបាល ហើយតំរូវឱយបន្តការ យកចិត្តទុកដាក់ និងធ្វើសកម្មភាព នៅក្នុងផ.យ.ស.២។ ការពិនិត្យវាយតំលៃបានកត់សំគាល់អំពីឆន្ទៈនយោបាយដ៏រឹងមាំក្នុងការដោះស្រាយ បញ្ហាមរណៈភាពមាតា ហើយថែមទាំងបានកត់សំគាល់ថា អន្តរាគមន៍ជាក់ស្តែងល្អប្រសើរនានាកំពុងត្រូវបានអនុវត្ត ហើយការសាកល្បងកំពុងតែប្រព្រឹត្តទៅ។ ទោះជាដូច្នេះក្តី ភាពឈ្នះនឹងមិនអាចទទួលបានទេ បើគ្មានការកើនឡើងជាអតិប្បរមានៃការប្រើប្រាស់សេវាទាំងអស់។

មានវឌ្ឍនភាពធំធេងក្នុង ការលើកស្ទួយស្ថានភាពសុខភាពកុមារ (តារាងទី ៥)។ អ.ប្រ.ស.០៥ បានបង្ហាញពីការថយចុះយ៉ាងខ្លាំងនៃអត្រាស្លាប់របស់កុមារអាយុក្រោម១ឆ្នាំនិងក្រោម៥ឆ្នាំ។ ទោះជាដូច្នេះក្តី ប្រទេសកម្ពុជាចាំបាច់ត្រូវប្តេជ្ញាបន្តការខិតខំប្រឹងប្រែងខ្លាំងក្លាថែមទៀតដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍសហសវត្សទី ៤ នៅដំណាច់ឆ្នាំ២០១៥។

**តារាងទី៥:សេវាសុខភាពកុមារ**

| **សូចនាករសំខាន់** | **២០០០** | **២០០៥** | **២០០៧** |
|---|---|---|---|
| កុមារអាយុក្រោម១ឆ្នាំទទួលថ្នាំបង្ការពេញលេញ | ៣១,៣% | ៦០% | ៧២% |
| ចំនួនមណ្ឌលសុខភាពអនុវត្តយុទ្ធសាស្រ្តសមាហរណកម្មការគ្រប់គ្រងជម្ងឺកុមារ | | ៤៥ (២០០២) | ៥៣៣ |
| ស្ថានភាពអាហារូបត្ថម្ភកុមារអាយុក្រោម៥ឆ្នាំ | | | |
| ក្រិនស្គមស្គាំងកំរិតរ៉ាំរ៉ៃ | ១៥% | ៧% | |
| ក្រិនស្គមស្គាំងកំរិតមធ្យម | ៤៥% | ៣៧% | |
| កង្វះទំងន់ | ៤៥% | ៣៦% | |
| អត្រាស្លាប់ទារកនៅពេលកើត | ៣៦ | ២៨ | |
| អត្រាស្លាប់ទារកនៅក្រោយពេលកើត | ៥៨ | ៣៧ | |
| **អត្រាស្លាប់កុមារអាយុក្រោម ១ ឆ្នាំ** | **៩៥** | **៦៦** | |
| **អត្រាស្លាប់កុមារអាយុក្រោម ៥ ឆ្នាំ** | **១២៤** | **៨៣** | |

ប្រភព :២០០០និង២០០៥ :អ.ប្រ.ស. ២០០២/២០០៧ : ប្រពន្ធ័ពត៌មានសុខាភិបាល

សមធម៌ផ្នែកសុខភាព និងសុខភាពមាតានិងកុមារ ជាចំណុចស្នូលនៃផ.យ.ស.១។ វឌ្ឍនភាពបាននិងកំពុងកើតមាន ប៉ុន្តែស្ថិតនៅកំរិតមួយដែលមិនអាចទទួលយកបាន។ គោលដៅអភិវឌ្ឍសហសវត្សត្រូវតែសំរេចឱយបាននៅក្នុងអំលុងពេលនៃផ.យ.ស.២។ បញ្ហាជាមូលដ្ឋាន គឺកំរិតទាបនៃការប្រើប្រាស់សេវាសុខភាពទាំងសេវាមូលដ្ឋាន និងសេវាបង្គ្រប់ដែលផ្តល់ដោយមូលដ្ឋានសុខាភិបាល តាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក។ម្យ៉ាងវិញទៀត កំរិតបច្ចុប្បន្ននៃការផ្តល់សេវាសុខភាព គឺនៅទាបជាងកំរិតដែលពណ៌នាដោយផែនការគ្របដណ្តប់សុខាភិបាល។

ការបង្កើនតំរូវប្រើប្រាស់សេវាគឺជាអាទិភាពមួយ និងបន្ទាន់បំផុតសំរាប់កម្មវិធីសុខភាពមាតា-កុមារ។ បើសិនតំរូវការត្រូវបានបង្កើនឡើងយ៉ាងខ្លាំងតាមកម្មវិធីនេះ ការរំពឹងទុកគឺថាកំណើនតំរូវការនេះនឹងបន្ត **រាលដាល** ទៅកាន់កម្មវិធីសុខភាពដទៃទៀត ដែលនឹងបង្កើតឱយមានវឌ្ឍនភាពនៅគ្រប់កម្មវិធីសុខភាពទាំងអស់ ហើយបើសិនជាឥរិយាបទនៃការស្វែងរកការថែទាំសុខភាពដែលជាបញ្ហាកង្វល់ត្រូវបានដោះស្រាយនិងបញ្ច្រាបទៅក្នុងគុណភាពសេវាពិសេសសេវាសុខភាពមាតាកុមារ មធ្យោបាយនេះអាចធ្វើឱយសំរេចបានលទ្ធផលសេវាដ៏ល្អប្រសើរក្នុងការប្រយុទ្ធនឹងជំងឺឆ្លងនិងជំងឺមិនឆ្លង។ ទោះជាដូច្នេះក្តី ការពង្រីកសេវានឹងនៅតែជួបឧបសគ្គ ដរាបណាបញ្ហាហិរញ្ញប្បទានវិស័យសុខាភិបាលនៅតែមិនត្រូវបានដោះ

ស្រោយ។ វឌ្ឍនភាពក្នុងផ្នែកនេះទាមទារឱយមានការរៀបចំរចនាសម្ព័ន្ធរឹងមាំ ដោយរាប់បញ្ចូលទាំងកម្មវិធីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ ព្រមទាំងការលើកស្ទួយការចូលរួមនិងការសំរបសំរួលការងាររបស់ដៃគូទាំងអស់។

អ.ប្រ.ស.០៥ បានបង្ហាញពីការថយចុះប្រេវ៉ាឡង់HIV មកនៅត្រឹម ០.៦% គឺប្រមាណ ១/៣ នៃការប៉ាន់ស្មានដំបូងសំរាប់ឆ្នាំ២០០៥។ លទ្ធផលនេះបានដាក់ប្រទេសកម្ពុជាក្នុងចំណោមប្រទេសមួយចំនួនតូចក្នុងពិភពលោកដែលសំរេចបានគោលដៅចំណុចឆ្នាំ២០០៥។ អន្តរាគមន៍នៃកម្មវិធីប្រយុទ្ធនឹងជំងឺរបេងដ៏រឹងមាំបាន នាំឱយអត្រាព្យាបាលជាសះស្បើយមានកំរិតខ្ពស់បំផុត តាមរយៈវិធីសាស្ត្រព្យាបាលដោយពិនិត្យផ្ទាល់ (Directly Observed Treatments) ត្រូវបានពង្រីកទៅកាន់មណ្ឌលសុខភាពទូទាំងប្រទេស (តារាង៦)។

មានពត៌មានមិនគ្រប់គ្រាន់ស្តីអំពីស្ថានភាពបច្ចុប្បន្ននៃជំងឺមិនឆ្លងទាក់ទងទៅនឹងការប្រើប្រាស់សេវានិងការប្រែប្រួលទៅតាមពេលវេលា។ មានការរំពឹងគិតថាកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនិងការផ្លាស់ប្តូរអំពីរបៀបនៃការរស់នៅនឹងនាំមកនូវ បន្ទុកធ្ងន់ធ្ងរនៃជំងឺមិនឆ្លង ដោយរាប់បញ្ចូលទាំង អត្រាស្លាប់ខ្ពស់ដោយសារគ្រោះថ្នាក់ចរាចរ និងជំងឺលេចឡើងថ្មីៗ ដែលបណ្តាលមកពីភាពបំពុលបរិដ្ឋានអនាម័យខ្វះខាតខ្សោយនិងកង្វះទឹកស្អាតប្រើប្រាស់។ ការប្រឹងប្រែងបានកើតមានរួចមកហើយ ដើម្បីបង្កើនការយកចិត្តទុកដាក់លើជំងឺមិនឆ្លង ហើយការខិតខំប្រឹងប្រែងបន្តទៅមុខទៀតនឹងកំណត់បានកាន់តែច្បាស់អំពីតំរូវការនាពេលអនាគតនិងផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ។

**តារាងទី៦: សេវាប្រយុទ្ធជំងឺឆ្លង**

| សូចនាករសំខាន់ៗ | ២០០៣ | ២០០៥ | ២០០៧ |
|---|---|---|---|
| ប្រេវ៉ាឡង់មេរោគអេដស៍លើមនុស្សអាយុ១៥-៤៩ឆ្នាំ | | ០,៦% | |
| អ្នកផ្ទុកមេរោគអេដស៍ប្រើប្រាស់ឱសថពន្យាជីវិត | ៣៩២ | | ២៥៥.៣៥៣ |
| អត្រាជាសះស្បើយនៃការព្យាបាលជំងឺរបេង | >៨៥% | | >៨៥% |
| អត្រាស្រាវជ្រាវករណីរបេង បេកា វិជ្ជមាន | ៦០% | | ៦៥.៤% |
| អាំងស៊ីដង់ជម្ងឺគ្រុនចាញ់ក្នុងប្រជាជន១០០០នាក់ រាយការណ៍ដោយមូលដ្ឋានសុខាភិបាល | ៩,៦% | | ៤,២% |
| ករណីស្លាប់ដោយគ្រុនចាញ់ក្នុងប្រជាជន១០០នាក់ | ៩,៩៦% | | ៧,៩% |
| មណ្ឌលប្រឹក្សា ពិនិត្យឈាម ដោយស្ម័គ្រចិត្ត រក្សាការសំងាត់ | ៣៧ | | ១៩៧ |

ប្រភព:២០០៥:អ.ប្រ.ស. ២០០៣/២០០៧:ប្រពន្ធ័ពត៌មានសុខាភិបាល

## ៩.២ ហិរញ្ញប្បទានសុខាភិបាល

ដូចជាបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតដែរហិរញ្ញប្បទានសុខាភិបាលនៅកម្ពុជាគឺគ្របដណ្តប់ដោយការចំណាយប្រាក់ហោប៉ៅផ្ទាល់។ ប្រៀបធៀបនឹងប្រទេសជិតខាងសមាមាត្រដ៏ធំនៃការចំណាយលើសុខភាពនៅកម្ពុជាស្ថិតជាបន្ទុកគ្រួសារផ្ទាល់។ ការចំណាយសរុបលើសុខភាពសំរាប់ប្រជាជនម្នាក់ក្នុងមួយឆ្នាំនៅឆ្នាំ២០០៥ គឺ៣៧ដុល្លារ ក្នុងនេះ៦៨%(២៥ដុល្លារ)គឺប្រាក់ហោប៉ៅ ខណៈពេលដែល ២២% ផ្តល់ដោយម្ចាស់ជំនួយ និង១០%ពីក្រសួងសុខាភិបាលដែលតំណាងឱយ(១០-១២%)នៃការបែងចែកថវិកាខ្ពស់ពីរដ្ឋាភិបាល។

ប្រាក់ចំណូលប្រចាំឆ្នាំសំរាប់ប្រជាជនម្នាក់គឺ ៤៣០ដុល្លារ ក្នុងឆ្នាំ២០០៥ ហើយបានកើនឡើងយ៉ាងឆាប់រហ័សក្នុងឆ្នាំកន្លងទៅនេះ ។ អត្រាកំណើនសេដ្ឋកិច្ចគួរស្ញប់ស្ញែងជាមធ្យម ៨% ក្នុងមួយឆ្នាំក្នុងអំលុងពេលទសវត្សចុងក្រោយនេះ ដែលនាំទៅសំរេចបានការកាត់បន្ថយក្រីក្រជាមធ្យម១,៥%ក្នុងមួយឆ្នាំ ។ ទោះជាដូច្នេះក្តី ៣៤,៧១% នៃប្រជាជនរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ គឺចំណូលប្រចាំថ្ងៃពី ០,៤៦-០,៦៣ដុល្លារ ។ ការប៉ាន់ស្មានថ្មីៗបង្ហាញថា កំរិតមធ្យមនៃភាពក្រីក្រ គឺចុះទាបជាងពីពេលមុន ប៉ុន្តែគំលាតកាន់តែខ្លាំងរវាងអ្នកមាននិងអ្នកក្រ (World Bank recent poverty assessment) ។ គ្រួសារក្រីក្រមិនអាចទ្រាំទ្របាននឹងការចំណាយលើសុខភាពហើយគ្រួសារជាច្រើនទៀតដែលជាផ្លូវការមិនស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រ ក៏នៅតែខ្វះសាច់ប្រាក់ ។ ការចំណាយលើសុខភាពអាចជំរុញឱយគ្រួសារទាំងនេះធ្លាក់ចូលទៅក្នុងភាពក្រីក្រ ។ ផ.យ.ស.១ បានបង្ហាញពីវឌ្ឍនភាពគួរឱយចាប់អារម្មណ៍ គឺជាការថយចុះថ្លៃក្នុងមួយឯកតា ក្នុងការប្រើប្រាស់សេវាសុខភាព ជាមួយនឹងការកើនឡើងនៃប្រាក់ចំណូលធ្វើឱយសេវាថែទាំសុខភាពកាន់តែអាចបង់ថ្លៃបាន ហើយមិនទំនងជាមូលហេតុនាំទៅរកភាពក្រីក្រទុរគតិ ។ ទន្ទឹមពេលជាមួយគ្នានេះ ការអនុវត្តន៍សាកល្បងទំរង់ធានារ៉ាប់រងសង្គមនាដំណាក់កាលដំបូងបង្ហាញលទ្ធផលដូចដែលចង់បានសំរាប់ការអភិវឌ្ឍន៍ទំរង់បុរេបង់ថ្លៃ ។ ផ្លូវដើរដ៏ទូលំទូលាយឆ្ពោះទៅកាន់ការគ្របដណ្តប់ជាសកល តាមរយៈការធានារ៉ាប់រងសុខភាពសង្គម ត្រូវបានកំណត់ច្បាស់នៅក្នុងផែនការមេនៃការធានារ៉ាប់រងសុខភាពសង្គម ។

ថវិកាជាតិចំណាយចរន្តត្រូវបាន បង្កើនឡើងរហូតដល់ ៦៧% នៅឆ្នាំ២០០៧ បើប្រៀបធៀបនិងថវិកាឆ្នាំ២០០៣ (រូបភាព៤) ។កំណើននេះបានប្រព្រឹត្តទៅនៅក្នុងកំណើននៃការចំណាយសាធារណៈទាំងមូល ។ការវិភាជន៍ថវិកាមាននិន្នាការឈរលើមូលដ្ឋាននៃតំរូវការជាទូទៅខេត្តដែលក្រទទួលបានវិភាជន៍ថវិកាខ្ពស់សំរាប់ប្រជាជនម្នាក់ ។ ជាក់ស្តែងចំនែកថវិកាដែលធ្លាក់ទៅដល់មូលដ្ឋានសុខាភិបាលនៅមានកំរិតទាបនៅឡើយ មួយផ្នែកដោយសារតែឧបសគ្គ ផ្នែកការគ្រប់គ្រងហិរញ្ញវត្ថុ ។ និន្នាការក្នុងទិសដៅផ្ទេរអំណាចឱយទៅខេត្ត- ក្រុងក្នុងការត្រួតត្រា និងការគ្រប់គ្រងថវិកានិងបង្កើនវិភាជន៍ធនធាននឹងពង្រឹងដល់ទិសដៅហិរញ្ញប្បទានសុខាភិបាលគាំទ្រដល់ជនក្រីក្រ ។

**រូបភាព ៤:ថវិកាជាតិសំរាប់វិស័យសុខាភិបាល ២០០៣-២០០៧**




លំដាប់នៃកំណែទំរង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគប្បីរួមចំណែកដល់ការគ្រប់គ្រងការចំណាយសាធារណៈឱយកាន់តែមានប្រសិទ្ធភាពថែមទៀត ។ការប្រតិបត្តិថវិកាមានភាពជឿនលឿនជាលំដាប់ដោយបញ្ចេញបរិមាណសាច់ប្រាក់ខ្ពស់និងទាន់ពេលវេលា ។ ទោះជាដូច្នេះក្តីក៏នៅមានវិសាលភាពសំរាប់ការកែលំអឱយកាន់តែប្រសើរបន្ថែមទៀត ។ បរិមាណសរុបនៃការចំណាយរបស់រដ្ឋលើសុខភាពនិងធនធានដែល

អាចរកបានគឺមានល្មមគ្រប់គ្រាន់ដើម្បីសំរេចបានគោលដៅអភិវឌ្ឍន៍សហសវត្ស។ទោះជាដូច្នេះក្តីការវិភាជន៍សេដ្ឋកិច្ចនៃធនធានទាំងអស់នេះអាចងាករេ ជាមួយនឹងការពឹងផ្អែកហួសហេតុពីប្រភពឯកជន និងពីសេវា និងការរួមវិភាគទានតិចតួចពីវិស័យសាធារណៈ។ សេចក្តីត្រូវការដែលជាបច្ច័យសំខាន់ គឺការពារជនក្រីក្រ និងបង្វែរទិសដៅចេញពីការចំណាយដោយប្រាក់ហោប៉ៅផ្ទាល់ទៅរកយន្តការបុរេបង់ថ្លៃ និងយន្តការវិស័យសង្គម។

## ៤.៣ ភាពក្រីក្រនិងសមធម៌

សុខភាពទន់ខ្សោយនិងភាពក្រីក្រមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធនៅកម្ពុជា។ មានករណីជាច្រើនដែលគ្រួសារក្រីក្រមិនអាចទ្រាំទ្របាន ក្នុងការចំណាយលើការថែទាំសុខភាពដែលមានគុណសម្បត្តិគ្រប់គ្រាន់ ហើយងាកទៅពឹងផ្អែកលើ គ្រូបុរាណ និងអ្នកផ្តល់សេវាឯកជន ដែលគ្មានគុណសម្បត្តិគ្រប់គ្រាន់ (ជារឿយៗតែងមានគ្រោះថ្នាក់)។ អត្រានៃការព្យាបាលមានភាពប្រែប្រួលយ៉ាងខ្លាំង អាស្រ័យលើទីកន្លែងរស់នៅ និងស្ថានភាពសេដ្ឋកិច្ច-សង្គមរបស់អ្នកជំងឺ។ ដោយប្រមាណមួយភាគបីនៃប្រជាជនសរុបក្រពេកមិនអាចបង់ថ្លៃសេវាបានក្នុងវិស័យសាធារណៈ ព្រមទាំងក្នុងវិស័យឯកជន ដូច្នេះផែនការហិរញ្ញប្បទានសុខាភិបាលជាតិត្រូវតែផ្តល់វិធានការគាំពារសង្គមឱយបានសមស្របនិងគួរជាទីពេញចិត្ត រួមទាំងសំណាញ់សុវត្ថិភាពសង្គមដទៃទៀត។ បច្ចុប្បន្នការគាំពារនេះត្រូវបានផ្តល់ តាមរយៈប្រពន្ធ័លើកលែងការបង់ថ្លៃ និងមូលនិធិសមធម៌។ តំរូវការចាំបាច់ គឺដាក់បញ្ចូលនិងពង្រីកយន្តការទាំងអស់នេះទៅក្នុងក្របខណ្ឌជាតិ ហើយអភិវឌ្ឍមធ្យោបាយថ្មីនានាដើម្បីគាំពារអ្នកក្រ។ បទពិសោធន៍អំពីមូលនិធិសមធម៌ និងការធានារ៉ាប់រងសុខភាពតាមសហគមន៍ នៅដំណាក់កាលដំបូងបានបង្ហាញពីការប្រឹងប្រែង ដើម្បីបន្ថយជាអប្បបរមានូវឧបសគ្គហិរញ្ញវត្ថុដែលអ្នកជំងឺជួបប្រទះ។ មូលនិធិសមធម៌បច្ចុប្បន្នភាគច្រើន ផ្តល់មូលនិធិដោយប្រទេសផ្តល់ជំនួយ ទោះជាដូច្នេះក្តីរាជរដ្ឋាភិបាលបានវិភាជន៍ថវិកាជាតិ ដើម្បីទ្រទ្រង់ដល់កម្មវិធីមូលនិធិសមធម៌។

**តារាងទី៧: ការគ្របដណ្តប់នៃយន្តការហិរញ្ញប្បទាន**

| | | ២០០៧ |
|---|---|---|
| ចំនួនកម្មវិធីមូលនិធិសមធម៌កំពុងអនុវត្តន៍ | | ៤៥ |
| | នៅស្រុកប្រតិបត្តិ | ៣៩ |
| | នៅមន្ទីរពេទ្យជាតិ | ៦ |
| ចំនួនករណីគ្របដណ្តប់ដោយមូលនិធិសមធម៌ | | **២៤៦.៥៩៤** |
| ចំនួនករណីលើកលែងការបង់ថ្លៃ | | **១.៣០០.០២៥** |
| ចំនួនគម្រោងធានារ៉ាប់រងសុខភាពតាម សហគមន៍ | | **៩ ក្នុង ៩ ស្រុកប្រតិបត្តិ** |
| ចំនួនអ្នកទទួលផលពីគម្រោងធានារ៉ាប់រងសុខភាពតាមសហគមន៍ | | **៤៥.២៨២** |

ប្រភព: របាយការណ៍ហិរញ្ញប្បទានសុខាភិបាលឆ្នាំ ២០០៧

## ៤.៤ ធនធានមនុស្សវិស័យសុខាភិបាល

ទោះជាបានអនុវត្តសកម្មភាពមួយចំនួន ដើម្បីដោះស្រាយបញ្ហាជ្រើសរើសការរក្សាទុកឆ្មប និងបញ្ហាប្រឈមមុខក្នុងការពង្រាយបុគ្គលិករវាងទីប្រជុំជននិងជនបទក្តី ក៏កង្វះឆ្មបនិងការពង្រាយឆ្មបនៅតែជាបញ្ហា លើកលែងតែការជ្រើសរើសនិងសមត្ថភាពនៃការបណ្តុះបណ្តាលត្រូវបានបង្កើនខ្លាំងឡើង ពីឆ្នាំ ២០០៨-២០១៥ ដែលកង្វះបុគ្គលិកអាចកើតមានកាន់តែធ្ងន់ធ្ងរ ក្នុងពេលជាមួយគ្នានេះចាំបាច់ត្រូវកែលំអគុណភាពនៃការបណ្តុះបណ្តាលឱយកាន់តែប្រសើរឡើងថែមទៀត។

ការពិនិត្យវាយតំលៃបច្ចេកវិទ្យាឆ្មបបង្ហាញ ពីកំរិតសមត្ថភាពមិនគ្រប់គ្រាន់ក្នុងចំណោមឆ្មបបឋម។ លើសពីនេះការពង្រាយឆ្មបបឋមនៅតាមតំបន់ជនបទ គឺមិនអាចឆ្លើយតបទៅនិងតំរូវការផ្នែកសុខភាពទូទៅឡើយ ពិសេសសុខភាពកុមារ។ តំបន់ជនបទត្រូវការឱយមានប្រភេទបុគ្គលិកពហុជំនាញ ដូចជាឆ្មបគិលានុបដ្ឋាក-យិកាមធ្យមជាដើម រីឯបុគ្គលិកពហុជំនាញដែលមានចាំបាច់ត្រូវទទួលភារៈកិច្ចពហុជំនាញធំទូលាយ។

ការផ្តល់និយមនយ័ដ៏ចង្អៀតដល់អ្នកជួយសំរាលកូនមានជំនាញថាជាឆ្មប គឺមិនបានគិតដល់ឱកាសនៃការប្រើប្រាស់ជំនាញរបស់វេជ្ជបណ្ឌិត និងគិលានុបដ្ឋាកមានជំនាញផ្នែកសម្ភព ដើម្បីសេវាសំរាលកូនទេ។ ឆ្មបជាច្រើននិងបុគ្គលិកវិជ្ជាជីវៈដទៃទៀតដែលបំរើការទាំងក្នុងផ្នែកសាធារណៈ ព្រមទាំងឯកជនមិនបានកត់ត្រាគ្រប់គ្រាន់។

ទំនាក់ទំនងរវាងការផ្តល់សេវាក្នុងវិសយ័សាធារណៈនិងឯកជន ចាំបាច់ត្រូវតែបន្តដោះស្រាយនៅក្នុង ផ.យ.ស.២ ពិសេសបញ្ហាអតុល្យភាពនៃប្រពន្ធ័លាភការរវាងវិសយ័ទាំងពីរនេះ។ លទ្ធផលពីការសិក្សាលើកិច្ចសន្យាផ្តល់សេវាបានបង្ហាញថា ការកែលំអអាចរឹងមាំនៅពេលដែលអភិក្រមមានលក្ខណៈស្ថាបនាមួយសំរាប់ប្រពន្ធ័លាភការរបស់បុគ្គលិកត្រូវបានកំណត់ហើយយកទៅអនុវត្ត។

បទពិសោធន៍នៃកិច្ចសន្យាផ្តល់សេវា និងការគ្រប់គ្រងបានបង្ហាញទៀតថា ការផ្តល់ប្រាក់ចំណូលខ្ពស់ ដល់បុគ្គលិកផ្អែកលើស្នាដៃការងារគឺផ្តល់នូវមធ្យោបាយសំរាប់ការលើកកំពស់ឱយកាន់តែប្រសើរឡើងដល់រចនាសម្ពន្ធ័គ្រប់គ្រងនិងការផ្តល់សេវានៅមូលដ្ឋានសុខាភិបាលនិងស្រុកប្រតិបត្តិ។ ដូច្នេះចាំបាច់ត្រូវអនុវត្តយុទ្ធសាស្រ្ត គ្រប់គ្រងធនធានមនុស្សដែលមានសមាសភាគបង្កើនបៀវត្ស នៅក្នុងសំណុំក្របខណ្ឌ័នៃការពង្រឹងប្រពន្ធ័សុខាភិបាល។ យុទ្ធសាស្រ្តនេះនិងបញ្ចូលការកែលំអផែនការនីយកម្មធនធានមនុស្ស ការលើកទឹកចិត្ត ពិសេសសំរាប់ការផ្តល់សេវានៅក្នុងតំបន់ដែលពិបាកទៅដល់ និងប្រពន្ធ័បណ្តុះបណ្តាលក្នុងពេលបំរើការងារមានប្រសិទ្ធភាពហើយប្រការនេះតំរូវឱយមានការរួមវិភាគទានពីដៃគូសុខាភិបាលទាំងអស់ដើម្បីចៀសវាងការបែកខ្ញែក។

ការពិនិត្យឡើងវិញវិស័យសុខាភិបាលផ្តល់អនុសាសន៍ថា កំណែទំរង់កិច្ចសន្យាផ្ទៃក្នុងត្រូវតែយកមកអនុវត្តតាមវិធីជំហានឆ្លៀសវៃ។វិធីសាស្រ្តនេះនឹងបង្កើនការទទួលខុសត្រូវសំរាប់ការអនុវត្តន៍ផ.យ.ស.២ ដោយប្រើប្រាស់វិធីសាស្រ្តលើកទឹកចិត្តតាមស្នាដៃការងារ។

## ៩.៥ សុខភាពនិងប្រជាសាស្ត្រក្នុងអន្តរកាល

ការអភិវឌ្ឍន៍ និងការផ្លាស់ប្តូរផ្នែកប្រជាសាស្ត្រយ៉ាងឆាប់រហ័សត្រូវបានរំពឹងទុកថានាំមកនូវការវិវត្តន៍នៅក្នុងស្ថានភាពនៃជម្ងឺចេញពីជំងឺឆ្លងឆ្ពោះទៅកាន់ការកើនឡើងនៃប្រេវ៉ាឡង់នៃជំងឺមិនឆ្លង។ប្រេវ៉ាឡង់នៃជំងឺលើសឈាមនិងជំងឺទឹកនោមផ្អែម បាននឹងកំពុងកើនឡើងយ៉ាងឆាប់រហ័សជាងការកើនឡើងនៃអាយុកាលដែលបានរំពឹងទុក។ ជំណាក់ផ្តើមដំបូងនៃជំងឺរ៉ាំរ៉ៃហាក់ដូចជានៅទាបនៅឡើយ។ ចំនួននៃការស្លាប់និងរបួសដោយសារគ្រោះថ្នាក់ចរាចរបានកើនឡើង៥០% រវាងឆ្នាំ២០០០និង២០០៥។ មានការចាប់អារម្មណ៍ដល់បន្ទុកនៃជំងឺដែលទាក់ទងទៅនឹងភាពបំពុលបរិដ្ឋាន អនាមយ័ខ្វះខាតខ្សោយនិងកង្វះទឹកស្អាតប្រើប្រាស់។ ទន្ទឹមនឹងនេះ ការលេចឡើងនូវការរាតត្បាតនៃការប្រើប្រាស់គ្រឿងញៀនបានក្លាយទៅជាបញ្ហាប្រឈមមុខថ្មីមួយទៀតដល់រាជរដ្ឋាភិបាល ពីព្រោះវាបានជះឥទ្ធិពលដល់បញ្ហាសុខភាពផ្លូវចិត្ត ការឆ្លងមេរោគអេដស៍ និងបញ្ហាសង្គម។

ដូច្នេះផលវិបាកចំពោះមុខគឺការលេចឡើងបញ្ហាសុខភាពទាំងក្នុងផ្នែកបង្ការ ការព្យាបាលបន្ទាន់និងការស្តារនិតិសម្បទាដែលនឹងទាមទារការវិភាជន៍ធនធានបន្ថែមសំរាប់ការធ្វើអន្តរាគមន៍មានប្រសិទ្ធភាព។

**រូបភាព ៥: រចនាសម្ពន្ធ័ប្រជាសាស្ត្រ**







## ៩.៦ ការវិវត្តន៍នៃផែនការគ្រប់ដណ្តប់សុខាភិបាល

ដូចបានអធិប្បាយនៅក្នុងជំពូក២ ផ.គ្រ.ស ជាឧបករណ៍ផែនការ ដើម្បីត្រួសត្រាយការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល។ លក្ខណៈពិសេសរបស់ផ.គ្រ.សគឺការផ្លាស់ប្តូរការរៀបចំប្រព័ន្ធសុខាភិបាល ពីផ្អែកលើចរិតលក្ខណៈរដ្ឋបាលទៅឈរលើលក្ខណៈវិនិច្ឆ័យចំនួនប្រជាជន ការវិវត្តន៍នៃផ.គ្រ.ស ក្នុងអំលុងពេលជាង១២ឆ្នាំកន្លងមកនេះ គឺជាលទ្ធផលនៃកត្តាបរិបទមួយចំនួន

**តារាងទី៨: ការអភិវឌ្ឍន៍មូលដ្ឋានសុខាភិបាល**

| | ៩៥_២០០៣ | ២០០៧ |
|---|---|---|
| ចំនួនមណ្ឌលសុខភាពសង់ថ្មី | ៦៩៤ | ១៣៤ |
| ចំនួនមណ្ឌលសុខភាពទទួលឱសថស.ស.អ | ៨១២ | ៦៨ |
| ចំនួនអាគារសង់ថ្មីក្នុងមន្ទីរពេទ្យបង្អែក | ៣៤ | ៣ |

ប្រភព:ការពិនិត្យសមិទ្ធផលសុខាភិបាល២០០៧

ដូចខាងក្រោមនេះ ៖

- កំណើនប្រជាជនទៅតាមពេលវេលា នាំឱ្យមានការកើនឡើងតំរូវការសេវាសុខភាពរួចបង្កើនបន្ទុកការងារនៅតាមមូលដ្ឋានសុខាភិបាល។
- ស្ថេរភាពនយោបាយ និងសន្តិសុខទូទាំងប្រទេស បង្កើតទីតាំងយ៉ាងរឹងប៉ឹងដល់កំណើនការវិនិយោគនិងសកម្មភាពល្អលាស់ផ្នែកសេដ្ឋកិច្ច ជំរុញដល់ចំណាកស្រុកពីតំបន់ជនបទទៅកាន់ទីក្រុង-ប្រជុំជននិងទៅកាន់តំបន់អភិវឌ្ឍន៍ ក៏ដូចជាទៅដល់តំបន់ភូមិសាស្ត្រដែលមិនអាចទៅដល់បាននៅពេលអភិវឌ្ឍ ផ.គ្រ.ស ដំបូងនៅឆ្នាំ ១៩៩៥។
- ការរីកចំរើនដ៏ខ្លាំងក្លានៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍ ផ្តល់លទ្ធភាពងាយស្រួលក្នុងការមកទទួលយកសេវារបស់ប្រជាជននៅមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក។
- បច្ចុប្បន្ននេះមានប្រភេទអ្នកផ្តល់សេវាក្នុងវិស័យឯកជនដ៏សំបូរបែបពិសេសក្នុងរដ្ឋធានីនិងទីប្រជុំជនខេត្ត-ក្រុងធំៗ។

**ជាផលបច្ច័យ:**

- ចំនួនមណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពតាមខេត្តមួយចំនួន ត្រូវបានបន្ថែមនិងបញ្ចូលទៅក្នុងប្រពន្ធ័ពត៌មានវិទ្យា ផ.គ្រ.ស ដែលត្រូវធ្វើបច្ចុប្បន្នភាពរវាង២ ឆ្នាំម្តង។
- កំណត់ឡើងវិញតួនាទី និងមុខងាររបស់មន្ទីរពេទ្យបង្អែក ៖ មន្ទីរពេទ្យបង្អែកត្រូវបានរៀបចំជា ៣ ចំណាត់ថ្នាក់ ៖ ស.ស.ប.កំរិត១ ស.ស.ប.កំរិត២ និងស.ស.ប.កំរិត៣ (អធិប្បាយលំអិតក្នុងសេចក្តីណែនាំអំពីសំណុំសកម្មភាពបង្គ្រប់ឆ្នាំ២០០៦)។
- មណ្ឌលសុខភាពមានគ្រែ (អតីតពេទ្យស្រុកចាស់) ខ្លះត្រូវតំឡើងតួនាទីជាមន្ទីរពេទ្យបង្អែក ស.ស.ប.កំរិត១ ទន្ទឹមគ្នានឹងការលប់មណ្ឌលសុខភាពមួយចំនួនដែលបានគ្រោង ចេញពី ផ.គ្រ.ស ពិសេសនៅរាជធានីភ្នំពេញនិងទីរួមខេត្តធំៗ។
- ប៉ុស្តិ៍សុខភាពមួយចំនួនត្រូវបានតំឡើងជាមណ្ឌលសុខភាព ស.ស.អ។

ការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាលនឹងជាបញ្ហាប្រឈមមុខដ៏ស្រួចស្រាវបំផុត។ តារាង១ (សង្ខេបផ.គ្រ.ស) បង្ហាញថាចំនួនមណ្ឌលសុខភាពនឹងកើនឡើងប្រមាណពី៩៥៧ នៅឆ្នាំ២០០៧ ទៅ១.៦៩៧ នៅឆ្នាំ២០១៥ រីឯមន្ទីរពេទ្យបង្អែកនឹងកើនឡើងប្រមាណពី ៧៤ ទៅ៨៩ ក្នុងរយៈពេលដូចគ្នានេះ។ បើសិនអនុវត្តលក្ខណៈវិនិច្ឆ័យប្រជាជន១០.០០០នាក់ សំរាប់មណ្ឌលសុខភាពមួយ និង១០០.០០០-២០០.០០០នាក់ សំរាប់មន្ទីរពេទ្យបង្អែកមួយករណីនេះថ្លៃចំណាយលើការវិនិយោគគឺត្រូវការយ៉ាងច្រើនសន្ធឹកសន្ធាប់ (ដោយរាប់បញ្ចូលទាំងការបំពាក់គ្រឿងឧបករណ៍ពេទ្យ)។ដោយសន្មតថាឃុំ/សង្កាត់មួយត្រូវមានមណ្ឌលសុខភាពមួយ (ឃុំ/សង្កាត់រដ្ឋបាលសរុបទូទាំងប្រទេសគឺ១.៦២១) ដូច្នេះមណ្ឌលសុខភាពថ្មី ចំនួន៦៦៤ ត្រូវការសង់ថ្មី ក្នុងអំលុងពេលពីឆ្នាំ២០០៨-២០១៥ (ជាមធ្យមត្រូវសង់មណ្ឌលសុខភាព ៨៣ ក្នុងមួយឆ្នាំៗ) ហើយផលវិបាកបន្តទៀត គឺនៅលើការផលិតចេញធនធានមនុស្ស

សុខាភិបាល។ ផ្អែកតាមលំហាត់សម្មតិកម្មខាងលើ គឺត្រូវការបុគ្គលិកចំនួន៦.៦៤០នាក់ ដើម្បីឆ្លើយតបទៅនឹងកំរិតចំនួនបុគ្គលិកនៃមណ្ឌលសុខភាពថ្មីទាំងអស់នេះ (យោងតាមសេចក្តីណែនាំអំពី ស.ស.អ ឆ្នាំ ២០០៨ ដែលតំរូវឱយមានបុគ្គលិក១០នាក់ក្នុងមណ្ឌលសុខភាពមួយ) ក្នុងរយៈពេលដូចគ្នា ដោយមិនរាប់បញ្ចូលចំនួនបុគ្គលិកនៅខ្វះបច្ចុប្បន្ន ជំនួសបុគ្គលិកដែលត្រូវចូលនិវត្តន៍ បុគ្គលិកទទួលមរណៈភាព និងបុគ្គលិកជំនាញផ្សេងទៀត ដូចជាបុគ្គលិករដ្ឋបាល គណនេយ្យ។ល។ ជារួមការចំណាយចរន្ត(ឱសថ បរិក្ខានិងសំភារៈដ៏ទៃទៀត ដើម្បីទ្រទ្រង់ដល់ដំណើរការមុខងារមូលដ្ឋានសុខាភិបាលទាំងនេះ)នឹងកើនឡើងជាមួយនឹងការវិនិយោគមូលធននេះទៅតាមពេលវេលា។

ដូច្នេះដើម្បីទទួលបានរូបភាពច្បាស់លាស់សំរាប់ការវិនិយោគ ចាំបាច់ត្រូវធ្វើការពិនិត្យមើលសារឡើងវិញក្នុងពេលឆាប់ៗនៃផ.គ្រ.សទូទាំងប្រទេស។ ចាំបាច់ត្រូវពិនិត្យមើលលក្ខណៈវិនិច្ឆ័យឡើងវិញហើយការអនុវត្តន៍លក្ខណៈវិនិច្ឆ័យនេះត្រូវតែយកចិត្តទុកដាក់ខ្ពស់ដល់ទិដ្ឋភាពសំខាន់៣ៈ**ទីមួយ** រវាងតំបន់ទីក្រុង/ប្រជុំជនធំៗ(ដូចជារាជធានីភ្នំពេញ)និងតំបន់ជនបទ/ដាច់ស្រយាល **ទីពីរ** សក្តានុពលនៃអ្នកផ្តល់សេវាឯកជននិង **ទីបី** ផ.គ្រ.ស ត្រូវតំរៀបតំរង់តាមតំរូវការនៃវិមជ្ឈការនិងវិសហមជ្ឈការ។

## ៤.៧ ប្រសិទ្ធភាពនៃជំនួយ និងអភិបាលកិច្ច

រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍មានជំនឿទុកចិត្តយ៉ាងរឹងមាំលើគោលការណ៍នៃ **សេចក្តីប្រកាសក្រុងប៉ារីសស្តីអំពីប្រសិទ្ធភាពនៃជំនួយៈ** ភាពម្ចាស់ការដ៏រឹងមាំរបស់ប្រទេសយុទ្ធសាស្ត្រដែលបានតំរៀបតំរង់ត្រូវដាក់អនុវត្តសុខដុមនីយកម្មជំនួយក្រៅប្រទេសទៅតាមនិតិវិធី និងប្រព័ន្ធជាតិការគ្រប់គ្រងស្តែងចេញជាលទ្ធផល តាមរយៈប្រព័ន្ធដែលបញ្ជាក់ច្បាស់ពីគោលដៅនិងសូចនាករសំរាប់ត្រួតពិនិត្យតាមដាននិងអភិវឌ្ឍគោលនយោបាយឈរលើមេរៀននៃវឌ្ឍនភាព និងការទទួលខុសត្រូវទាំងសងខាងឈរលើការគ្រប់គ្រងស្តែងចេញជាលទ្ធផលនៅក្នុងប្រព័ន្ធមួយទទួលខុសត្រូវរួមគ្នា។

ខណៈពេលដែល ផ.យ.ស.១ ព្យាយាមវិភាជន៍មូលនិធិដោយសនិទានកម្ម ភាពស្មុគ្រស្មាញនៃស្ថាបត្យកម្មហិរញ្ញវត្ថុនៅតែមាន ក្នុងនេះអ្នកផ្តល់ជំនួយដើរតួនាទីរឹងមាំ តាមរយៈគំរោងហិរញ្ញប្បទានទន្ទឹមគ្នានឹងភាពទន់ខ្សោយ ជាទូទៅនៃយន្តការនិយតកម្មវិស័យឯកជនក្នុងទីផ្សារសុខភាព។ ប្រការទាំងពីរយ៉ាងនេះ គឺជាកត្តានាំមុខយ៉ាងសំខាន់ ប៉ុន្តែប្រហែលជាមិនបានពង្រឹងគ្នា និងប្រព្រឹត្តនៅក្នុងលក្ខណៈសុខដុមនីយកម្មឡើយ។ មូលនិធិដែលផ្តល់ដោយដៃគូរមែងនៅតែបែកខ្ញែកគ្នា ហើយក៏មិនបានតំរៀបតំរង់ត្រឹមត្រូវទៅតាមអាទិភាពជាតិដែលបានកំណត់ ទោះជាមានការខិតខំប្រឹងប្រែង តាមរយៈបែបបទនៃការប្រព្រឹត្តទៅនៃអភិក្រមគ្រប់គ្រងបើកទូលាយទូទាំងវិស័យក្តី។ លំហូរហិរញ្ញវត្ថុពីដៃគូដែលមិនបានតំរៀបតំរង់ ធ្វើឱយរអាក់រអួលដល់ទំរង់គំរូអភិបាលកិច្ចវិស័យសុខាភិបាល។

វិស័យសុខាភិបាលនឹងបន្តពឹងផ្អែកលើដៃគូសុខាភិបាលនៅក្នុងអនាគតដែលអាចដឹងបាន។ ដូច្នេះចាំបាច់ត្រូវពង្រឹងសុខដុមនីយកម្មមូលនិធិដៃគូ ដើម្បីទ្រទ្រង់ដល់ការអនុវត្តន៍ ផ.យ.ស.២។ ការពិនិត្យវាយតំលៃអភិក្រមគ្រប់គ្រងបើកទូលាយទូទាំងវិស័យផ្តល់អនុសាសន៍ សំរាប់ជំរុញបែបបទនេះទៅមុខទៀត។

យន្តការថ្នាក់ជាតិនិងថ្នាក់អន្តរជាតិមួយចំនួន (ដូចជា “**ភាពជាដៃគូអន្តរជាតិក្នុងផ្នែកសុខភាព**” ដែលបានប្រកាសកាលពីខែកញ្ញាឆ្នាំ២០០៦នៅទីក្រុងឡុងដ៏ក្នុងនេះ ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសជំហានដំបូងនៃភាពជាដៃគូនេះ) បាននឹងកំពុងដាក់ឱយដំណើរការដែលនឹងលើកកំពស់សុខដុមនីយកម្មនៅក្នុងអំលុងពេលនៃការអនុវត្តន៍ផ.យ.ស.២។សហប្រតិបត្តិការល្អប្រសើរដែលមានរួចមកហើយរវាងរដ្ឋាភិបាលនិងដៃគូសុខាភិបាលកំណត់ពីដំណាក់កាលសំរាប់ការធ្វើឱយកាន់តែមានប្រសិទ្ធភាពថែមទៀតនៃសុខដុមនីយកម្មលើសពីនេះការសន្ទនាដែលកំពុងមានរវាងរដ្ឋាភិបាលនិងវិសយ័ឯកជនបានផ្តល់ច្រកសំរាប់ភាពចំណេញនៃសមាហរណកម្ម និងក្នុងវិធានការការត្រួតពិនិត្យគុណភាពនៃការផ្តល់សេវាថែទាំសុខភាព។

“ច្បាប់សំរាប់ការរៀបចំអង្គការ” (Organic Laws) គ្របដណ្តប់លើតួនាទីនៃរចនាសម្ពន្ធ័វិមជ្ឈការនិងទំនាក់ទំនងនៃរចនាសម្ពន្ធ័នេះទៅនឹងថ្នាក់ជាតិ។ ច្បាប់នេះនឹងមានអនុភាព លើអភិបាលកិច្ចក្នុងវិសយ័សុខាភិបាល នៅក្នុងអំឡុងពេលផែនការនីយកម្មរបស់ផ.យ.ស.២ ពិសេសមានហេតុបច្ចយ័ដល់តួនាទីនិងវិធីសាស្រ្តធ្វើការងាររបស់ក្រសួងសុខាភិបាល ជំហរទីតាំង និងតួនាទីរបស់ខេត្ត-ក្រុង ដោយរាប់បញ្ចូលទាំងតួនាទីនៃការធ្វើផែនការនិងការវិភាជន៍ធនធានសំរាប់វិសយ័សុខាភិបាលនៅក្នុងក្របខណ្ឌ័ហិរញ្ញប្បទានជាកញ្ចប់សំរាប់ផ្នែកចំបង៧នៃការអភិវឌ្ឍន៍និងជំហរទីតាំងនិងតួនាទីរបស់ស្រុកប្រតិបត្តិព្រមទាំងទំនាក់ទំនងជាមួយអង្គភាពមូលដ្ឋានសំរាប់សកម្មភាពប្រជាធិបតេយ្យវិមជ្ឈការដូចជាឃុំ-សង្កាត់ជាដើម។

វិធីសាស្រ្តមានលក្ខណៈជាប្រពន្ធ័និងលំអិតស្តីអំពីវិមជ្ឈការ និងវិសហមជ្ឈការក្នុងវិសយ័សុខាភិបាលនឹងជួយដល់ការអនុវត្តន៍អភិក្រមមានស្ថេរភាពមួយសំរាប់អភិបាលកិច្ចក្នុងប្រពន្ធ័សុខាភិបាល។អភិក្រមនេះនឹងកសាងឡើងនៅលើបទពិសោធន៍រួមដែលប្រមូលផ្តុំបានពីការសាកល្បងនានា ដែលបានប្រព្រឹត្តទៅក្នុងអំលុងពេលនៃ ផ.យ.ស.១ ទន្ទឹមពេលគ្នាដែលផែនការអភិវឌ្ឍន៍ស្ថាប័ននឹងសំរួចតួនាទី និងមុខងារនៃវិសយ័សុខាភិបាលឱយកាន់តែមានលក្ខណៈយុទ្ធសាស្រ្ត ឆ្លើយតបនិងទទួលខុសត្រូវកាន់តែខ្លាំងឡើង។

## ៤.៨ សេចក្តីសន្និដ្ឋាន

ការពិនិត្យវាយតំលៃវិសយ័សុខាភិបាលបានសន្និដ្ឋានថា ស្ថានភាពទូទៅនៃសុខភាពប្រជាជនកម្ពុជាត្រូវបានលើកស្ទួយចេញពីកំរិតដ៏ទាបមួយនៅក្រោយស្ថានភាពនៃជំលោះជាង៣ទសវត្សមុន។ ស្ថានភាពសុខភាពដែលបានរៀបរាប់ក្នុង អ.ប.ស.០៥ គឺមានសង្គតភាពទៅនឹងស្ថានភាពនៃប្រទេសដែលកំពុងស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍន៍សេដ្ឋកិច្ច។

- រង្វាស់ទូទៅពីរដែលយកមកប្រើប្រាស់ ដើម្បីកំណត់គុណភាពប្រពន្ធ័សុខាភិបាល គឺអត្រាស្លាប់របស់កុមារអាយុក្រោម១ឆ្នាំនិងក្រោម៥ឆ្នាំត្រូវបានកាត់បន្ថយយ៉ាងខ្លាំងបើទុកណាជាត្រូវការកែលំអថែមទៀតដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍន៍សហសវត្ស។
- សូចនាករលទ្ធផលសុខភាពទី៣របស់ប្រពន្ធ័សុខាភិបាលគឺអត្រាស្លាប់របស់មាតាមិនមានវឌ្ឍនភាពហើយស្ថិតនៅជាបញ្ហាប្រឈមមុខដ៏ស្រួចស្រាវដដែល។

- អត្រាអ្នកផ្ទុកមេរោគអេដស៍ត្រូវបានកាត់បន្ថយគួរឱយកត់សំគាល់ រីឯអត្រាជាសះស្បើយនៃការព្យាបាលជំងឺរបេងនៅរក្សាបានក្នុងកំរិតខ្ពស់បំផុត។
- ដោយសារកំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សភាពបំពុលនៃបរិស្ថាននិងការផ្លាស់ប្តូររបៀបរបបរស់នៅធ្វើឱយកើនឡើងនូវការព្រួយបារម្ភអំពីបន្ទុកនៃជំងឺមិនឆ្លង ដោយរាប់បញ្ចូលទាំងអត្រាស្លាប់ដ៏ខ្ពស់ដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរ។
- ការប្រើប្រាស់សេវាសាធារណៈមានការកើនឡើង ប៉ុន្តែស្ថិតនៅកំរិតទាប បើប្រៀបធៀបជាមួយបណ្តាប្រទេសដទៃមួយផ្នែកដោយសារប្រជាជនមួយភាគធំប្រើប្រាស់សេវាវិស័យឯកជន។
- ថវិកាជាតិត្រូវបានបង្កើនឡើងស្របតាមគោលដៅជាយុទ្ធសាស្ត្រ ទោះជាដូច្នេះក្តីក៏នៅមានវិសាលភាព សំរាប់ការកែលំអឱយកាន់តែប្រសើរបន្ថែមទៀត ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនិងការប្រតិបត្តិថវិកា។
- ការគ្រប់គ្រងធនធានមនុស្សនៅតែជាសម្ពាធនៃបញ្ហាប្រឈមមុខពិសេសទាក់ទងទៅនឹងការលើកទឹកចិត្ត និងការផ្តល់ឆ្មបមានជំនាញគ្រប់គ្រាន់នៅតាមមណ្ឌលសុខភាព។
- ការវាយតំលៃស្នាដៃការងារវិស័យសុខាភិបាលជួបឧបសគ្គដោយសារសូចនាករច្រើនពេក និងមិនមានពត៌មានដើមគ្រាគ្រប់គ្រាន់ហើយគោលដៅចំណុច និងសូចនាករត្រូវបានផ្លាស់ប្តូរតាមពេលវេលា។ ការផ្លាស់ប្តូរពហុភាពបែបនេះ បានធ្វើឱយប៉ះពាល់ដល់ដំណើរសិក្សារៀនសូត្រពីរូបធាតុនៃប្រពន្ធ័យុទ្ធសាស្ត្រ។
- ដៃគូអភិវឌ្ឍបានធ្វើឱយមានធនធានកាន់តែច្រើនសំរាប់វិស័យសុខាភិបាល។ ត្រូវការវឌ្ឍនភាពច្រើនថែមទៀត នៅក្នុងការសំរបសំរួលការជួយឧបត្ថម្ភពីដៃគូអភិវឌ្ឍទាំងនោះ ការប្តេជ្ញាជួយសំរាប់រយៈពេលវែង និងការធានាថាការរួមចំណែករបស់ពួកគេស្របតាមអាទិភាពជាតិ។
- លក្ខណៈពិសេសមួយទៀត នៃការអភិវឌ្ឍន៍វិស័យសុខាភិបាលនៅកម្ពុជា គឺភាពខុសគ្នាយ៉ាងខ្លាំងនៃស្ថានភាពសុខភាពរវាងក្រុមប្រជាជន ដែលមានស្ថានភាពសេដ្ឋកិច្ចខុសៗគ្នា។ ស្ថានភាពសុខភាពប្រជារាស្ត្ររបស់នៅតំបន់ជនបទ គឺទាបខ្លាំងជាងប្រជាជនរស់នៅតំបន់ទីប្រជុំជន។ខណៈពេលដែលគ្រួសារមានការសិក្សាអប់រំខ្ពស់មានវឌ្ឍនភាពល្អផ្នែកសុខភាព ការអភិវឌ្ឍន៍សុខភាពក្នុងចំណោមគ្រួសារដែលគ្មានការសិក្សាអប់រំ គឺមានភាពទន់ខ្សោយ ជួនកាលមានលក្ខណៈអវិជ្ជមាន។ ភាពខុសគ្នារវាងខេត្តមួយទៅខេត្តមួយទៀតមានជាទូទៅ។

## ៤.៩ អនុសាសន៍សំខាន់ៗផ្នែកគោលនយោបាយសំរាប់ផែនការយុទ្ធសាស្ត្រ ២០០៨-២០១៥

១- ត្រូវធ្វើការសំរេចចិត្តជាបន្ទាន់ លើគោលនយោបាយនៅលើផ្នែកនានាដែលការអនុវត្តន៍សាកល្បងកំពុងតែដំណើរការជឿនលឿនទៅមុខ។ ការសំរេចចិត្តលើគោលនយោបាយនេះត្រូវបញ្ចូលកំណែទំរង់ឱយមានសង្គតភាពជាមួយបរិបទស្ថាប័នទូលំទូលាយនៃវិស័យសាធារណៈ: នៅកម្ពុជា កិច្ចសន្យាផ្តល់សេវា មូលនិធិសមធម៌ និងប្រពន្ធ័លាភការសំរាប់បុគ្គលិក។

២- បន្តពង្រឹងតួនាទីនិងមុខងារស្ថាបន័ទូទាំងប្រពន្ធ័សុខាភិបាល ជាមួយនឹងការកសាងសមត្ថភាព ព្រមទាំងលើកស្ទួយការផ្សារភ្ជាប់រវាងយុទ្ធសាស្ត្រនៃផ.យ.ស.២ ជាមួយប្រពន្ធ័ត្រួតពិនិត្យតាមដាន។

៣- ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងជំនួយ ដើម្បីដោះស្រាយស្ថានភាពបែកខ្ញែកបច្ចុប្បន្ន នៃហិរញ្ញប្បទានពីដៃគូសុខាភិបាលតាមរយៈការខិតខំប្រឹងប្រែងប្រាកដប្រជានៃសុខដុមនីយកម្ម ដើម្បីអនុញ្ញាតិឱយមានការបន្តពង្រីកធនធាន។

# ជំពូក ៣

# អភិក្រមយុទ្ធសាស្ត្រសុខាភិបាល

- តួនាទីនៃផែនការយុទ្ធសាស្ត្រ
- អាទិភាពជាយុទ្ធសាស្ត្រ
- គោលបំណង និង គោលដៅ
- គោលដៅចំណុច និង សូចនាករ

# ៣ អភិក្រមផែនការយុទ្ធសាស្ត្រសុខាភិបាល

## ១. តួនាទីនៃផែនការយុទ្ធសាស្ត្រ

ផ.យ.ស.២ ត្រូវបានកសាងឡើងលើការខិតខំប្រឹងប្រែងរបស់ផ.យ.ស.១ ដំបូងគឺការពង្រឹងសមិទ្ធផលសំខាន់ៗ ដែលមានទូទាំងប្រព័ន្ធសុខាភិបាល បន្ទាប់មកគឺការពង្រីកអន្តរាគមន៍នានាដែលបានបង្ហាញឱយឃើញអំពីជោគជ័យទៅទូទាំងប្រទេស ដើម្បីអត្ថប្រយោជន៍សុខភាពរបស់ប្រជាជនកម្ពុជាទាំងអស់។

យុទ្ធសាស្ត្រនៃ ផ.យ.ស.២ ផ្តោតជាចំបងទៅលើបញ្ហាប្រឈមមុខនានា និងផ្តល់ភាពកាន់តែប្រសើរឡើងនៅក្នុងអន្តរាគមន៍ជាយុទ្ធសាស្ត្រលើផ្នែកសុខភាព នៅក្នុងប្រតិបត្តិការនៃប្រព័ន្ធសុខាភិបាល។ ផែនការនេះនឹងសមាហរណកម្មកំណែទំរង់វិស័យសុខាភិបាល ទៅក្នុងបរិបទដ៏ទូលំទូលាយនៃកំណែទំរង់របស់ប្រទេសកម្ពុជា។

- ផ្តល់នូវចក្ខុវិស័យទូលំទូលាយ និងយូរអង្វែងដើម្បីត្រួសត្រាយការអភិវឌ្ឍន៍វិស័យសុខាភិបាលកម្ពុជា ដោយរាប់បញ្ចូលទាំងការអភិវឌ្ឍន៍សមត្ថភាពនិងការវិភាជន៍ធនធាន។
- អនុវត្តជាក់ស្តែងតាមរយៈផែនការគ្របដណ្តប់សុខាភិបាល ផែនការរំកិល៣ឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ។
- តំរៀបតំរង់ជាមួយអាទិភាពនិងបែបបទផែនការនីយកម្មជាតិ–ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។

ផ.យ.ស.២កំណត់ផ្នែកយុទ្ធសាស្ត្ររបស់ខ្លួនចេញពី ផ.យ.អ.ជ ដែលបានបញ្ជាក់ពីការពង្រឹងគោលបំណងជាអាទិភាពផ្នែកសុខភាពនៅកម្ពុជា គឺការលើកស្ទួយសុខភាពមាតានិងកុមារ ការប្រយុទ្ធនឹងជំងឺឆ្លង និងការពង្រឹងការផ្តល់សេវាថែទាំសុខភាពសំរាប់ប្រជាជនកម្ពុជាទាំងអស់។ ផ.យ.អ.ជ បញ្ជាក់ច្បាស់អំពីគោលដៅចំបង និងទូលំទូលាយដែលមានឥទ្ធិពលលើផ.យ.ស.២ គឺការរួមចំណែកបន្ទាប់សន្ទុះទស្សន៍នៃភាពក្រីក្រ ឱយមកនៅត្រឹម ២៥% ចាប់ពីឆ្នាំ២០១០ និងតំរង់ទិសដៅទៅកាន់ទីកន្លែងដែលប្រេវ៉ាឡង់នៃភាពក្រីក្រមានកំរិតខ្ពស់។

ផ.យ.ស.២ ឆ្លុះបញ្ចាំងពីគោលនយោបាយជាតិទូទៅ និងមានបំណងជះឥទ្ធិពលទៅលើគោលនយោបាយសុខាភិបាល តាមរយៈបែបបទជាច្រើនដែលមាននៅក្រសួងសុខាភិបាល ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងមូលដ្ឋានទាំងនាដែលពាក់ព័ន្ធ។ គោលនយោបាយដ៏មានសារៈសំខាន់ជាពិសេសនោះគឺ:

- ការអភិវឌ្ឍន៍ចាំបាច់ក្នុងវិស័យសុខាភិបាលស្តីអំពីអភិបាលកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុ
- កិច្ចការកំណែទំរង់ដើម្បីអភិវឌ្ឍបន្ថែមទៀតនូវទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍
- ប្រពន្ធ័លាភការ និងផែនការនីយកម្មសំរាប់ធនធានមនុស្ស
- គុណភាពក្នុងវិស័យសុខាភិបាល និងសេចក្តីណែនាំគ្លីនិកសំរាប់មូលដ្ឋានសុខាភិបាល
- ការត្រួតពិនិត្យតាមដាន និងវាយតំលៃវិស័យសុខាភិបាល
- ពង្រឹងតួនាទីរបស់មូលដ្ឋានសុខាភិបាល ស.ស.អ និង ស.ស.ប

គោលនយោបាយនិងយុទ្ធសាស្ត្ររបស់ ផ.យ.ស.២ នឹងត្រូវបានត្រួតពិនិត្យតាមដាននិងវាយតំលៃជាបន្តបន្ទាប់។ ការពិនិត្យរួមគ្នាសមិទ្ធផលសុខាភិបាលប្រចាំឆ្នាំ និងសន្និបាទសុខាភិបាលប្រចាំឆ្នាំនឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងការសំរេចចិត្តលើការពិនិត្យកែសំរួលអន្តរាគមន៍ជាបន្តបន្ទាប់ និងធ្វើបច្ចុប្បន្នភាពគោលដៅចំនុចប្រតិបត្តិប្រចាំឆ្នាំ និងដើម្បីធ្វើឱយ ផ.យ.ស.២ ក្លាយជា "**ឯកសាររស់**"។

## ២. អាទិភាពជាយុទ្ធសាស្ត្រ

ផ.យ.ស.២ កំណត់អាទិភាពជាយុទ្ធសាស្ត្រសំរាប់វិស័យសុខាភិបាលជាពីរផ្នែកទូលំទូលាយនិងទាក់ទងគ្នាទៅវិញទៅមក ហើយដែលក្រសួងសុខាភិបាលនិងដៃគូទាំងអស់ត្រូវយកចិត្តទុកដាក់ជាពិសេសសំរាប់អន្តរាគមន៍ក្នុងរយៈពេលមធ្យមទៅរយៈពេលវែងក្នុងអំលុងពេលនៃការអនុវត្តន៍ ផ.យ.ស.២។

អាទិភាពទាំងពីរផ្នែកនេះគឺ: ១)អាទិភាពសុខភាពរបស់ប្រជាជន និងសេវាសុខភាពជាសារវន្ត័ (តារាង៩) និង ២)បញ្ហាប្រឈមមុខដែលមានទាក់ទងនឹងដំណើរការមុខងាររបស់ប្រព័ន្ធសុខាភិបាល ។

តារាង ៩: កម្មវិធីសុខភាពអាទិភាពនិងសេវាសារវ័ន្ត

| សុខភាពបន្តពូជ-មាតា-ទារកនិងកុមារ | ជំងឺឆ្លង | ជំងឺមិនឆ្លងនិងបញ្ហាសុខភាពផ្សេងទៀត |
|---|---|---|
| ផែនការគ្រួសារនិងការពន្យារកំណើត<br>ការពន្លូតកូនមានសុវត្ថិភាព<br>សុខភាពមាតានិងកុមារ<br>អាហារូបត្ថម្ភ<br>ការថែទាំគភ៌មុនសំរាល<br>ការទប់ស្កាត់ការចំលង HIV ពីម្តាយទៅទារក<br>ការថែទាំករណីសម្ភពបន្ទាន់<br>សមាហរណកម្មការថែទាំក្រោយសំរាលលើមាតានិងទារក<br>ចាក់ផ្តល់ថ្នាំបង្ការ<br>ដោយរាប់បញ្ចូលការលប់បំបាត់ជំងឺកញ្ជ្រិលនិងតេតាណូស<br>ការបញ្ចូលវ៉ាក់សាំងថ្មី<br>សមាហរណកម្មការគ្រប់គ្រងជំងឺកុមារ<br>ការថែទាំសារវ័ន្តដល់កុមារ<br>ការស្លាប់ទារក និងកុមារ<br>សុខភាពវ័យជំទង់/យុវវ័យ<br>ការអនុវត្តន៍តាមគ្រួសារ | ជំងឺឆ្លងប្រដាប់បន្តពូជ<br>HIVជំងឺអេដស៍ ជំងឺកាមរោគ<br>របេង ឃ្លង់<br>គ្រុនចាញ់ គ្រុនឈាម<br>រោគបណ្តាលមកពីព្រូន<br>helminthiasis<br>schistomosiasis<br>ជំងឺដែលទើបនិងលេចឡើង<br>ឬលេចឡើងសារជាថ្មី<br>ការអនុវត្តន៍និតិក្រមសុខភាពអន្តរជាតិ (International Health Regulations) | ជំងឺទឹកនោមផ្អែម<br>ជំងឺមហារីក<br>ជំងឺសរសៃឈាមនិងបេះដូង<br>ជំងឺផ្លូវចិត្ត រួមទាំងការប្រើប្រាស់គ្រឿងញៀន<br>ការបង្ការជំងឺខ្វាក់-ថ្លង់<br>សុខភាពមាត់ធ្មេញ<br>ហានិភយ័សុខភាពបរិស្ថាន<br>របួស គ្រោះថ្នាក់<br>សុខភាពការងារ<br>ការស្តារនីតិសម្បទា<br>រោគមនុស្សចាស់<br>សុវត្ថិភាពចំណីអាហារ<br>ថ្នាំជក់ |

កំរិតនៃបញ្ហាប្រឈមមុខក្នុងប្រពន្ធ័សុខាភិបាល ទាំងនៅផ្នែកផ្តល់សេវា និងផ្នែកតំរូវការសេវា មានបង្ហាញនៅក្នុង ប្រអប់១ និង ប្រអប់២ ខាងក្រោមនេះ:

**ប្រអប់១: បញ្ហាប្រឈមមុខនៅ "ផ្នែកផ្តល់សេវា"**

- មូលដ្ឋានសុខាភិបាលជាច្រើននៅតំបន់ជនបទដាច់ស្រយាល មានបុគ្គលិកបំរើការផ្តល់សេវាមិនគ្រប់គ្រាន់ ដោយសារបញ្ហានៃការពង្រាយបុគ្គលិក ហើយពាក់ពន្ធ័នឹងកំរិតសមត្ថភាព និងការលើកទឹកចិត្តមានកំរិត។
- ការផ្តល់សេវាជួបឧបសគ្គ បណ្តាលមកពីលំហូរធនធានហិរញ្ញវត្ថុនិងការទ្រទ្រង់-ផ្គត់ផ្គង់ឱសថ-បរិក្ខារ មិនគ្រប់គ្រាន់។
- ធនធានមិនគ្រប់គ្រាន់សំរាប់ដំណើរការនិងពង្រីកសេវានិងការគ្របដណ្តប់នៃមូលនិធិសមធម៌ និងការធានារ៉ាប់រងសុខភាពសង្គម។
- បញ្ហានៃគុណភាពសេវាថែទាំនៅមូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជនទៅតាមបទដ្ឋានស្តង់ដារនៃការថែទាំវេជ្ជសាស្ត្រ ការរៀបចំចាត់ចែង និងការផ្តល់សេវា។
- អភិបាលកិច្ចប្រពន្ធ័សុខាភិបាលនៅថ្នាក់ខេត្ត-ក្រុង និងសមត្ថភាពគ្រប់គ្រងនៅថ្នាក់ស្រុក និងមូលដ្ឋានសុខាភិបាលមានកំរិត។ ប្រការនេះទាមទារឱយមានការពង្រឹងខ្លាំងក្លាប្រពន្ធ័សុខាភិបាល និងការខិតខំប្រឹងប្រែងកសាងសមត្ថភាព។
- ភាពទន់ខ្សោយនៃការពង្រឹងការអនុវត្តន៏និតិក្រមសុខាភិបាល និងការគោរពតាមសេចក្តីណែនាំស្តង់ដារ ការអនុវត្តន៍ និងការធានាគុណភាព (មន្ទីរពិសោធន៍ ការត្រួតពិនិត្យគុណភាពឱសថ....)។
- កង្វះទិន្នន័យដែលគួរឱយទុកចិត្តបាននៃប្រពន្ធ័ពត៌មាន និងប្រពន្ធ័រាយការណ៍ ផែនការត្រៀមគ្រប់ជ្រុងជ្រោយ ប្រពន្ធ័ឆ្លើយតបគ្រាអាសន្ន និងទិន្នន័យអេពីដេមីញូសាស្ត្រ។
- ស្ថាបត្យកម្មជំនួយដែលបែកខ្ញែក រារាំងដល់អភិក្រមជាប្រពន្ធ័នៃការគ្រប់គ្រងវិស័យសុខាភិបាល ហើយជំរុញការផ្តល់សេវាថែទាំសុខភាពទៅរកអភិក្រមខ្សែបណ្តោយកាន់តែខ្វះសមាហរណកម្ម និងតាមរបៀបជាគំរោងកាន់តែច្រើនឡើង។ ហេតុការណ៏នេះធ្វើឱយតួនាទីមគ្គុទេសភាពរបស់ក្រសួងសុខាភិបាលជួបប្រទះការលំបាកនិងរិតត្បិតសមាហរណកម្មប្រពន្ធ័ហិរញ្ញប្បទាន។
- វិស័យឯកជនរួមចំណែកយ៉ាងសំខាន់ ក្នុងការផ្តល់សេវាសុខភាពក្នុងនេះមានសកម្មភាពសំខាន់ៗរបស់អង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែសមាហរណកម្មអ្នកផ្តល់សេវាទាំងអស់នេះនិងសេវារបស់ពួកគេ ទៅក្នុងក្របខណ្ឌ័នៃការអនុវត្តន៏គោលនយោបាយសុខាភិបាលជាតិនៅទន់ខ្សោយនៅឡើយ។
- សមត្ថភាពនិងចន្លោះប្រហោងនៃការយល់ដឹង ក្នុងការដោះស្រាយបន្ទុកជំងឺដែលទាក់ទងនឹងការផ្លាស់ប្តូររបៀបរបបនៃការរស់នៅ និងភាពបំពុលនៃបរិស្ថាន។

ប្រអប់២ : បញ្ហាប្រឈមមុខនៅ “ផ្នែកទទួលសេវា”

- កំរិតទាបនៃការប្រើប្រាស់សេវាសាធារណៈ :
- ការប្រព្រឹត្តផ្នែកសុខភាព និងការស្វែងរកការថែទាំសុខភាពមិនសមស្រប ដែលនាំទៅរកការទទួលយកសេវាថែទាំពីឱសថស្ថាន កន្លែងលក់ថ្នាំ និងពីអ្នកផ្តល់សេវាដែលបានទទួលការបណ្តុះបណ្តាលតិចតួចក្នុងប្រពន្ធ័។
- ចំណេះដឹង ជំនឿ ប្រពៃណី-ទំនៀមទំលាប់ និងចំងាយផ្លូវក៏មានឥទ្ធិពលលើការសំរេចចិត្តក្នុងការស្វែងរកការថែទាំសុខភាព។
- បញ្ហាយែនឌ័រ អំពើហឹង្សា សិទ្ធិអំណាចដល់ស្ត្រី និងការចូលរួមរបស់បុរស អសន្តិសុខ ស្បៀង ការអប់រំ អនាមយ័ សញ្ញាណនៃការយល់ដឹង ការគោរពតាមវិធីសាស្ត្រនៃការព្យាបាលភាពអាស្រូវ និងការរើសអើង កត្តាទាំងអស់នេះបានកំរិតលទ្ធភាពមកទទួលយកសេវារបស់ក្រុមប្រជាជនដែលងាយរងគ្រោះ។
- ថ្លៃសេវា (ផ្ទាល់និងប្រយោល) សោហ៊ុយធ្វើដំណើរ និងស្បៀងអាហារ ក្នុងអំលុងពេលស្នាក់នៅព្យាបាល គឺជាឧបសគ្គចំបងដល់ការប្រើប្រាស់សេវាសំរាប់ប្រជាជនជាច្រើនពិសេសជនក្រីក្រ។

## ៣. គោលបំណង និង គោលដៅ នៃ ផ.យ.ស ២

វឌ្ឍនភាពឆ្ពោះទៅកាន់ចក្ខុវិស័យយូរអង្វែងនៃវិស័យសុខាភិបាល នឹងត្រូវបានពិនិត្យវាយតំលៃ និងធ្វើបច្ចុប្បន្នភាពលើមូលដ្ឋានទៀងទាត់ តាមរយៈការវាស់វែងលទ្ធផលនៃអន្តរាគមន៍របស់កម្មវិធីសុខភាពទាំងបីដោយផ្ទៀងផ្ទាត់ជាមួយគោលដៅចំណុចដែលបានកំណត់សំរាប់គោលបំណងជាយុទ្ធសាស្ត្រទាំងបីនិងគោលដៅជាយុទ្ធសាស្ត្រទាំង១២ និងតាមរយៈការពិនិត្យរួមគ្នាសមិទ្ធផលប្រចាំឆ្នាំនៃវិស័យសុខាភិបាលនៅក្នុងក្របខណ្ឌរួមនៃការត្រួតពិនិត្យតាមដាននៃ ផ.យ.អ.ជ។

- **គោលបំណងនិងលទ្ធផល**

| ផយស២ គោលបំណងទី១ | លទ្ធផល |
|---|---|
| **បន្ថយការឈឺនិងស្លាប់របស់មាតា-ទារកនិងកុមារ និងការលើកកំពស់សេវាសុខភាពបន្តពូជ** | • ការស្លាប់របស់មាតាចុះថយ<br>• ការស្លាប់របស់ទារក និងកុមារអាយុក្រោម ១ ឆ្នាំចុះថយ<br>• ការស្លាប់របស់កុមារអាយុក្រោម ៥ឆ្នាំចុះថយ<br>• ស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រីល្អប្រសើរ<br>• ស្ថានភាពអាហារូបត្ថម្ភរបស់កុមារល្អប្រសើរ<br>• អត្រាប្រើប្រាស់មធ្យោបាយពន្យាកំណើតកើនឡើង |

| | |
|---|---|
| | • ការសំរាលកូនដោយឆ្មបមានជំនាញកើនឡើង<br>• បន្ថយការឈឺរបស់កុមារ ដោយសារជំងឺរលាកផ្លូវដង្ហើមស្រួច រាគរូស និងជំងឺដែលអាចការពារបានដោយថ្នាំបង្ការ<br>• ការគ្របដណ្តប់នៃការផ្តល់ថ្នាំបង្ការលើកុមារកើនឡើង |
| **ផយស២ គោលបំណងទី២** | **លទ្ធផល** |
| **បន្ថយការឈឺនិងស្លាប់ ដោយសារ ជំងឺអេដស៍ របេង គ្រុនចាញ់ និង ជំងឺឆ្លងដទៃទៀត** | • ការឈឺនិងស្លាប់ដោយជំងឺអេដស៍ចុះថយ<br>• ការឈឺនិងស្លាប់ដោយជំងឺរបេងចុះថយ<br>• ការឈឺនិងស្លាប់ដោយជំងឺគ្រុនចាញ់ចុះថយ<br>• ការឈឺនិងស្លាប់ដោយជំងឺឆ្លងដទៃទៀត រាប់ទាំងជំងឺអាចការពារបាន ដោយថ្នាំបង្ការ ជំងឺលេចឡើងនិងលេចឡើងសារជាថ្មី ចុះថយ |
| **ផយស២ គោលបំណងទី៣** | **លទ្ធផល** |
| **បន្ថយបន្ទុកជំងឺមិនឆ្លង និងបញ្ហាសុខភាពដទៃទៀត** | • ការឈឺនិងស្លាប់ដោយជំងឺផ្លូវចិត្តនិងការប្រើប្រាស់គ្រឿងញៀនថយចុះ<br>• ការឈឺនិងស្លាប់ដោយជំងឺទឹកនោមផ្អែម ថយចុះ<br>• ការឈឺនិងស្លាប់ដោយជំងឺមហារីក ថយចុះ<br>• ភាពងងឹតភ្នែក និងថ្លង់ ថយចុះ<br>• អត្រាប្រេវ៉ាឡង់នៃជំងឺធ្មេញពុកមិនបានប៉ះលើកុមារនិងមនុស្សពេញវ័យថយចុះ<br>• ការឈឺនិងស្លាប់ដោយជំងឺបេះដូង-សរសៃឈាម<br>• ប្រេវ៉ាឡង់នៃការប្រើប្រាស់ថ្នាំជក់ ថយចុះ<br>• ការប្រើប្រាស់គ្រឿងស្រវឹង ថយចុះ<br>• ការឈឺនិងស្លាប់ ដោយរបួស គ្រោះថ្នាក់ និងអំពើហិង្សាថយចុះ<br>• ហានិភ័យសុខភាពបរិស្ថាននិងផលប៉ះពាល់សុខភាពដោយគ្រោះមហន្តរាយ ថយចុះ |

- **គោលដៅ**

| **គោលបំណង១: បន្ថយការឈឺនិងស្លាប់របស់មាតា ទារកនិងកុមារ និងការលើកកំពស់សេវាសុខភាពបន្តពូជ** | |
|---|---|
| គោលដៅ | ១ លើកកំពស់ស្ថានភាពអាហារូបត្ថម្ភរបស់មាតានិងកុមារ<br>២ លើកកំពស់លទ្ធភាពមកទទួលយកពត៌មាននិងសេវាសុខភាពបន្តពូជមានគុណភាព<br>៣ លើកកំពស់លទ្ធភាពមកទទួលយកសេវាសុខភាពសារវ័ន្តសំរាប់មាតានិងទារក និងការប្រព្រឹត្តការថែទាំសុខភាពតាមគ្រួសារបានល្អប្រសើរ<br>៤ ធានានូវលទ្ធភាពមកទទួលយកសេវាសុខភាពសារវ័ន្តសំរាប់កុមារ និងការប្រព្រឹត្តការថែទាំសុខភាពតាមគ្រួសារបានល្អប្រសើរ |

| គោលបំណង២: បន្ថយការឈឺនិងស្លាប់ដោយសារជំងឺអេដស៍ របេង គ្រុនចាញ់ និងជំងឺឆ្លងដទៃទៀត | |
|---|---|
| គោលដៅ | ៥ កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃអ្នកផ្ទុកមេរោគអេដស៍។<br>៦ បង្កើនការរស់រានមានជីវិតរបស់អ្នកផ្ទុកមេរោគអេដស៍/មានជំងឺអេដស៍។<br>៧ សំរេចបានអត្រាស្រាវជ្រាវជំងឺរបេងខ្ពស់ និងរក្សាអត្រាជាសះស្បើយកំរិតខ្ពស់នៃករណីជំងឺរបេង ស្លុតបេកាវិជ្ជមាន។<br>៨ កាត់បន្ថយការស្លាប់ដោយជំងឺគ្រុនចាញ់ និងអត្រាឈឺ ក្នុងចំណោមប្រជាជនទូទៅ។<br>៩ កាត់បន្ថយបន្ទុកនៃជំងឺឆ្លងដទៃទៀត |

| គោលបំណង៣: បន្ថយបន្ទុកជំងឺមិនឆ្លង និងបញ្ហាសុខភាពដទៃទៀត | |
|---|---|
| គោលដៅ | ១០ កាត់បន្ថយ ឥរិយាបទគ្រោះថ្នាក់នាំទៅរកជំងឺមិនឆ្លង :ទឹកនោមផ្អែម ជំងឺបេះដូង–សរសៃឈាម មហារីក ជំងឺផ្លូវចិត្ត ការប្រើប្រាស់គ្រឿងញៀន គ្រោះថ្នាក់និងរបួស ការថែទាំភ្នែក សុខភាពមាត់ធ្មេញ ។ល។<br>១១ លើកកំពស់លទ្ធភាពមកទទួលយកសេវាព្យាបាលនិងការស្តារនិតិសម្បទាបង្ករឡើងដោយជំងឺមិនឆ្លង: ទឹកនោម ផ្អែម ជំងឺបេះដូង–សរសៃឈាម មហារីក ជំងឺផ្លូវចិត្ត ការប្រើប្រាស់គ្រឿងញៀន គ្រោះថ្នាក់ និងរបួស ការថែទាំភ្នែក សុខភាពមាត់ធ្មេញ ។ល។<br>១២ ធានាដំណើរការមុខងារសារវ័ន្តនៃសុខភាពសាធារណ: សុខភាពបរិស្ថាន សុវត្ថិភាពចំណីអាហារ ការគ្រប់គ្រងគ្រោះមហន្តរាយនិងការត្រៀមលក្ខណ: (សំរាប់គ្រាអាសន្ន)។ |

## ៤. គោលដៅចំណុច និងសូចនាករ

| ផយស២ គោលបំណងទី១ បន្ថយការឈឺនិងស្លាប់របស់មាតា ទារកនិងកុមារ និងការលើកកំពស់សេវាសុខភាព បន្តពូជ | | | |
|---|---|---|---|
| សូចនាករ | ទិន្នន័យដើមគ្រា ២០០៥-២០០៨ | គោលដៅចំណុច ២០១០ ( ២០១១ ការពិនិត្យពាក់កណ្តាលអណត្តិ) | គោលដៅ ២០១៥ ការវាយតំលៃ |
| អត្រាសាយកូន (%) | ៣,៤ | ៣,៤ | ៣,០ |
| អត្រាស្លាប់របស់មាតាក្នុងទារកកើតរស់១០០.០០០នាក់ | ៤៧២ | ២៤៣ | ១៤០ |
| អត្រាស្លាប់ទារកទើបប្រសូត្រក្នុងទារកកើតរស់១.០០០នាក់ | ២៨ | ២៥ | ២២ |
| អត្រាស្លាប់របស់កុមារអាយុក្រោម១ឆ្នាំក្នុងទារកកើតរស់ ១.០០០នាក់ | ៦៦ | ៦០ | ៥០ |
| អត្រាស្លាប់របស់កុមារអាយុក្រោម៥ឆ្នាំក្នុងទារកកើតរស់ ១.០០០នាក់ | ៨៣ | ៧៥ | ៦៥ |

| | | | |
|---|---|---|---|
| ប្រេវ៉ាឡង់នៃវិធីពន្យារកំណើតទំនើប | ២៧ | ៤០ | ៦០ |
| ស្ត្រីក្នុងវ័យបន្តពូជដែលមានសន្ទស្សន៍ទំងន់ទាប (Body Mass Index <18.5kg/m (%) | ២០ | ១២ | ៨ |
| ជំងឺស្លេកស្លាំងលើស្ត្រីមានផ្ទៃពោះ (11g/dl) (%) | ៥៧,១ | ៣៩ | ៣៣ |
| % នៃស្ត្រីមានផ្ទៃពោះមានផ្ទុកមេរោគអេដស៍ ទទួលថ្នាំពន្យាជីវិតដើម្បីបង្ការការចំលងពីម្តាយទៅទារក | ៧ | ៤៥ | ៧៥ |
| % នៃការសំរាលកូនដោយបុគ្គលិកសុខាភិបាលមានការបណ្តុះបណ្តាល | ៤៤ | ៥៥ | ៨០ |
| % នៃការសំរាលកូនដោយការវះកាត់ | ១,៨ | ២,៥ | ៤ |
| សមាមាត្រកុមារអាយុក្រោមមួយឆ្នាំបានទទួលថ្នាំបង្ការពេញលេញ (%) | ៦០ | ៧០ | ៨០ |
| % នៃកុមារអាយុក្រោមមួយឆ្នាំបានទទួលថ្នាំបង្ការជំងឺខាន់ស្លាក់-ក្អកមាន់-តេតាណូស៣លើកនិងជំងឺរលាកថ្លើមប្រភេទ បេ | ៨២ | ៩២ | ៩៥ |
| % នៃកុមារអាយុក្រោមមួយឆ្នាំបានទទួលថ្នាំបង្ការជំងឺកញ្រ្ជិល | ៧៩ | ៨៥ | ៩០ |
| សមាមាត្រទារកទទួលការបំបៅដោះក្នុងរយៈពេល១ម៉ោងបន្ទាប់ពីកើត (%) | ៣៥ | ៤៥ | ៦២ |
| សមាមាត្រទារកអាយុ០-៦ខែដែលទទួលការបំបៅដោះតែមួយមុខ (%) | ៦០ | ៦៥ | ៧០ |
| % នៃកុមារអាយុ ៦-៥៩ខែ ទទួលជីវជាតិ អា ២ដូសក្នុងអំឡុងពេល១២ខែចុងក្រោយ | ៨៣ | ៨៥ | ៩០ |
| % នៃកុមារអាយុក្រោម៥ឆ្នាំកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ: ក្រិន *គិតតាមស្តង់ដារថ្មីនៃការលូតលាស់របស់អង្គការសុខភាពពិភពលោក* | ៣៧ *(៤៣)* | ២៨ *(៣៥)* | ២២ *(២៥)* |
| % នៃកុមារអាយុក្រោម ៥ឆ្នាំ មានក្អកឬពិបាកដកដង្ហើម ហើយដែលបានព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ | ៤៨ | ៧០ | ៧៥ |
| សមាមាត្រនៃកុមារអាយុក្រោម៥ឆ្នាំមានជំងឺរាគរូសហើយទទួលទឹកអូរ៉ាលីត (%) | ៥៨ | ៨០ | ៨៥ |

| **ភយស២ គោលបំណងទី២ បន្ថយការឈឺនិងស្លាប់ដោយសារជំងឺអេដស៍ របេង គ្រុនចាញ់ និងជំងឺឆ្លងដទៃទៀត** | | | |
|---|---|---|---|
| **សូចនាករ** | **ទិន្នន័យដើមគ្រា ២០០៥-២០០៥** | **គោលដៅចំណុច ២០១០ ( ២០១១ ការពិនិត្យពាក់កណ្ដាលអាណត្តិ)** | **គោលដៅ ២០១៥ ការវាយតំលៃ** |
| អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ ក្នុងចំណោមពេញវ័យ អាយុពី១៥-៤៩ឆ្នាំ (%) | ០,៦<br>០,៩* | <០,៦<br><០,៩ | <០,៦<br><០,៩ |
| ចំនួនមណ្ឌលប្រឹក្សា-ពិនិត្យឈាមដោយស្មគ្រ័ចិត្តនិងរក្សាការសំងាត់នៅក្នុងវិស័យសាធារណៈនិងឯកជនមិនរកផលកំរៃ | ១៩៤ | ២៥០ | >២៥០ |
| % នៃអ្នកផ្ទុកមេរោគអេដស៍កំរិតខ្ពស់ទទួលការព្យាបាលដោយឱសថពន្យាជីវិតច្រើនមុខ | ៥០ | > ៨៥ | > ៨៥ |
| % នៃអ្នកផ្ទុកមេរោគអេដស៍ទទួលឱសថពន្យាជីវិតនៅរស់រានក្រោយការព្យាបាល ១២ ខែ | គ.ព | >៨៥ | > ៨៥ |
| ប្រេវ៉ាឡង់នៃរបេងបេកាវិជ្ជមានលើប្រជាជន១០០.០០០នាក់ | ២៣៤ | ២១៤ | ១៣៥ |
| អត្រាស្លាប់នៃជំងឺរបេងលើប្រជាជន១០០.០០០នាក់ | ៧៥ | ៦០ | ៣២ |
| អត្រាស្រាវជ្រាវករណីជំងឺរបេងស្ទួតបេកាវិជ្ជមាន (%) | ៦៦ | >៧០ | >៧០ |
| អត្រាជាសះស្បើយនៃការព្យាបាលជំងឺរបេង (%) | >៨៥ | >៨៥ | >៨៥ |
| ចំនួនករណីគ្រុនចាញ់ដែលបានព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈក្នុងចំណោមប្រជាជន ១.០០០ នាក់ | ៤ | ៣,៥ | ៣ |
| អត្រាស្លាប់នៃជំងឺគ្រុនចាញ់លើប្រជាជន១.០០០នាក់ | ០,៣៦ | ០,២ | ០,១ |
| % នៃគ្រួសារដែលរស់នៅក្នុងតំបន់ជំងឺគ្រុនចាញ់ខ្ពស់ (< ១គម ពីព្រៃ) នៃខេត្ត-ក្រុង ២០ដែលមានមុងជ្រលក់ថ្នាំគ្រប់គ្រាន់ (១ មុងសម្រាប់មនុស្ស ២នាក់) | ៦៤ | ៨៥ | ៩៥ |
| អត្រាស្លាប់ដោយជំងឺគ្រុនឈាម ដែលរាយការណ៍ដោយមូលដ្ឋានសុខាភិបាល(%) | ០,៧៤ | ០,៥ | ០,៣ |

គ.ព : គ្មានពត៌មាន

* Expert Consencus Meeting on Estimation of HIV Prevalence 2007, NCHAD

| ផលសុខ២ គោលបំណងទី៣ បន្ថយបន្ទុកជំងឺមិនឆ្លង និងបញ្ហាសុខភាពដទៃទៀត | | | |
|---|---|---|---|
| **សូចនាករ** | **ទិន្នន័យដើមគ្រា ២០០៥-២០០៨** | **គោលដៅចំណុច ២០១០ ( ២០១១ ការពិនិត្យពាក់កណ្ដាលអាណត្តិ)** | **គោលដៅ ២០១៥ ការវាយតំលៃ** |
| ％ នៃការស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ | ៣,៥ | ៣,០ | ២,៨ |
| ％ នៃអ្នករបួសដែលប៉ះទង្គិចក្បាលដោយសារគ្រោះថ្នាក់ចរាចរណ៍ដែលបានទទួលការព្យាបាល | ៤១ | ៣៨ | ៣៥ |
| អាំងស៊ីដង់នៃជំងឺមហារីកមាត់ស្បូនលើប្រជាជន១០.០០០នាក់ ដែលរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ | ២៥ | ២១ | ១២,៥ |
| ប្រេវ៉ាឡង់ជំងឺទឹកនោមផ្អែមលើមនុស្សពេញវ័យដែលបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ | ២ | <២ | <២ |
| អាំងស៊ីដង់នៃជំងឺលើសឈាមលើប្រជាជន១.០០០នាក់ | ២០ | ១៩ | ១៥ |
| ％ នៃមនុស្សពេញវ័យជក់បារី បុរស/ស្ត្រី | ៥៤/៩ | ៤៩/៤ | ៤៤/២ |
| អត្រានៃការងងឹតភ្នែក (％) | ១,២ | ០,៥ | <០,៣ |
| ％ នៃកុមារដែលមានធ្មេញពុកមិនបានប៉ះ | ៨,៩ | <៥ | <៥ |
| ចំនួននៃករណីជំងឺផ្លូវចិត្តដែលបានរាយការណ៍ពីមូលដ្ឋានសុខាភិបាលសាធារណៈ | ១០.០០០ | ១៩.០០០ | ២៨.០០០ |
| ចំនួននៃអ្នកចាក់គ្រឿងញៀនដែលបានចុះឈ្មោះក្នុងការព្យាបាលជំនួសដោយ Opioids | ១០០ | ៤០០ | ១.២០០ |

ជំពូក

៤

# យុទ្ធសាស្ត្រសុខាភិបាល

- ក្របខណ្ឌយុទ្ធសាស្ត្រ
- ក្របខណ្ឌប្រតិបត្តិ
- វិធីសាស្ត្រកសាងយុទ្ធសាស្ត្រ
- យុទ្ធសាស្ត្រ និងសមាសភាគយុទ្ធសាស្ត្រ

# ៤ យុទ្ធសាស្ត្រសុខាភិបាល

## ១. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ផ.យ.ស ២ មានចរិតលក្ខណៈ ៥ យ៉ាងដូចតទៅ(រូបភាព ៦)៖

- ជាក្របខ័ណ្ឌការងារដែលដាក់ " **ការទទួលខុសត្រូវ ប្រសិទ្ធភាព គុណភាព** និង**សមធម៌** " នៅចំកណ្តាលនៃយុទ្ធសាស្ត្រប្រទាក់ក្រឡាទាំង ៥ ដែលគាំទ្រដល់អន្តរាគមន៍នៃកម្មវិធីសុខភាព ចំនួន ៣ ដើម្បីផ្តល់នូវលទ្ធផលសុខភាពដែលប្រសើរជាងមុន ។
- ជាក្របខ័ណ្ឌការងារដែលប្រែក្លាយ **យុទ្ធសាស្ត្រចតុកោណ** របស់រាជរដ្ឋាភិបាលទៅជាសកម្មភាពដើម្បីរួមចំណែកដល់ដំណើរការរយៈពេលវែងនៃកាត់បន្ថយភាពក្រីក្រ។
- ជាក្របខ័ណ្ឌការងារដែលផ្តល់ព័ត៌មាននិងបច្ចុប្បន្នភាពគោលដៅចំណុចនៃ**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** លើមូលដ្ឋានទៀងទាត់ប្រចាំឆ្នាំ។
- ជាក្របខ័ណ្ឌការងារដែលមានពេលវេលាកំណត់និងប្រកាន់យក **គោលដៅអភិវឌ្ឍន៍សហសវត្ស** ជាគោល
- ជាក្របខ័ណ្ឌការងារដែលឆ្លុះបញ្ចាំងពី **គោលការណ៍នៃសេចក្តីប្រកាសក្រុងប៉ារីស** (ភាពម្ចាស់ការ ការតំរៀបតំរង់ សុខដុមនីយកម្ម ការគ្រប់គ្រងដើម្បីសំរេចលទ្ធផល និងការទទួលខុសត្រូវទៅវិញទៅមក) និង **ផែនការសកម្មភាព ស្តីពីការតំរៀបតំរង់ សុខដុមនីយកម្ម ដើម្បីសំរេចលទ្ធផល** របស់រដ្ឋាភិបាល។

រូបភាព ៦: ក្របខណ្ឌយុទ្ធសាស្ត្រ




**សំគាល់:** **ផសស:**ការផ្តល់សេវា -**ហថស:**ហិរញ្ញប្បទានការថែទាំសុខភាព -**ធមស:**ធនធានមនុស្សសុខាភិបាល

**បពស:** ប្រពន្ធ័ព័ត៌មានសុខាភិបាល -**អបស:**អភិបាលកិច្ចប្រពន្ធ័សុខាភិបាល

**សបមទក:**សុខភាពបន្តពូជ–មាតា–ទារក–កុមារ -**ជផ:**ជំងឺឆ្លង -**ជមឆំ:**ជំងឺមិនឆ្លងនិងបញ្ហាសុខភាពដទៃទៀត

**ផយអជ:**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ -**គអសក:**គោលដៅអភិវឌ្ឍសហវត្សកម្ពុជា

## ២. ក្របខ័ណ្ឌប្រតិបត្តិ

សំណាង់ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃផ.យ.ស.២ រួមមានកម្មវិធីសុខភាពចំបងចំនួន៣ ដែលអនុវត្តសំណុំយុទ្ធសាស្ត្រប្រទាក់ក្រឡាចំនួន៥។ តារាងរូបភាព ៧ បង្ហាញពីក្របខ័ណ្ឌប្រតិបត្តិ។ យុទ្ធសាស្ត្រនីមួយៗនៃយុទ្ធសាស្ត្រទាំង៥: **ផ្តល់សេវាសុខភាព ហិរញ្ញប្បទានការថែទាំសុខភាព ធនធានមនុស្សសុខាភិបាល ប្រព័ន្ធពត៌មានសុខាភិបាល** និង**អភិបាលកិច្ចប្រព័ន្ធសុខាភិបាល** ត្រូវយកទៅអនុវត្តនៅក្នុងកម្មវិធីនីមួយៗ។ ការណ៍នេះនឹងធានាការផ្តល់សេវាប្រកបដោយប្រសិទ្ធភាពនិងសង្គតភាព និងត្រួតពិនិត្យតាមដានលទ្ធផលទូទាំងវិស័យសុខាភិបាល ។

ការកំណត់ជ្រើសរើសផ្នែកកម្មវិធីសុខភាព ត្រូវបានធ្វើឡើងដោយផ្អែកលើកត្តាចំបង៣: ១)ភាពស្របគ្នាជាមួយនិងគោលដៅអភិវឌ្ឍន៍សហសវត្សរកម្ពុជានិងរចនាសម្ព័ន្ធថវិកាផ្អែកតាមកម្មវិធី ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍន៍និងអនុវត្តន៍ផែនការប្រតិបត្តិប្រចាំឆ្នាំ ២)ការដាក់បញ្ចូលគ្នាជាក្រុមនូវជំងឺដែលទាក់ទងនិងអាទិភាពសុខភាពរបស់ប្រជាជនដែលត្រូវដោះស្រាយនៅក្នុងជំណាក់កាលនៃការអនុវត្តន៍ផ.យ.ស.២

និង ៣) រក្សាជោគជ័យរបស់អភិក្រមកម្មវិធីជាតិចំពោះកង្វល់សុខភាពសាធារណៈសំខាន់ៗ នៅខណៈពេលបោះទីតាំងអភិក្រមទាំងអស់ នេះរឹងមាំនៅក្នុងវិស័យសុខាភិបាលទូលំទូលាយ ។

យុទ្ធសាស្ត្រនីមួយៗមានសំណុំនៃសមាសធាតុយុទ្ធសាស្ត្រ ។អន្តរាគមន៍ជាយុទ្ធសាស្ត្រក៏ត្រូវបានកំណត់សំរាប់សមាសធាតុយុទ្ធសាស្ត្រនីមួយៗ ។

រូបភាពទី ៧: ក្របខណ្ឌប្រតិបត្តិ ផ.យ.ស.២




## ៣. អភិក្រមយុទ្ធសាស្ត្រសុខាភិបាល

យុទ្ធសាស្ត្រសុខាភិបាលបង្កើតជាទីតាំងសំរាប់ការធ្វើសកម្មភាពរបស់ក្រសួងសុខាភិបាលនិងដៃគូភាគីទាំងអស់នៅក្នុងដំណាក់កាលនៃការអនុវត្តន៍ ផ.យ.ស.២ ។ ការប្រឈមមុខក្នុងការអនុវត្តន៍យុទ្ធសាស្ត្រមានពីរគឺ ទី១) ពង្រឹងជោគជ័យរបស់ ផ.យ.ស.១ និង ទី២)ពង្រីកអន្តរាគមន៍សំខាន់ៗប្រកបដោយប្រសិទ្ធភាពដើម្បីជាអត្ថប្រយោជន៍ផ្នែកសុខភាពដល់ប្រជាជនកម្ពុជាទាំងអស់ ។

នោះគឺជាយុទ្ធសាស្ត្រដែលត្រូវយកទៅអនុវត្តតាមពីរដំណាក់កាល ។ ក្នុងដំណាក់កាលទី១ ត្រូវដាក់ចេញនូវមូលដ្ឋានគោលនយោបាយសំរាប់ពង្រឹងសមិទ្ធផលបច្ចុប្បន្ន ហើយដោះស្រាយឧបសគ្គផ្នែកស្ថាប័ន និងប្រព័ន្ធដើម្បីជោគជ័យនៃដំណាក់កាលពង្រីក ។ ក្នុងដំណាក់កាលទី២ អន្តរាគមន៍សំខាន់ៗនៃយុទ្ធសាស្ត្រដែលបានលើកឡើងនឹងត្រូវបានពង្រីកទៅកាន់ខេត្ត- ក្រុងទាំងអស់ស្របទៅតាមគោលនយោបាយដែលបានកំណត់ច្បាស់លាស់ និងដោយមានការត្រួតពិនិត្យតាមដានយ៉ាងហ្មត់ចត់ ។

## ៤. ផ្នែកជាយុទ្ធសាស្ត្រ

- **ការផ្តល់សេវាសុខភាព** រួមមានវិធានការសុខភាពសាធារណៈដើម្បីប្រយុទ្ធនឹងជំងឺ–ដូចជាការរៀបចំចាត់ចែងការលើកកំពស់សុខភាពដើម្បីកាត់បន្ថយឥរិយាបទគ្រោះថ្នាក់និងគាំពារដល់ផ្នែកសុខភាព–ព្រមទាំងពង្រឹងជាទូទៅការផ្តល់សេវាថែទាំសុខភាពតាមរយៈគោលនយោបាយនិងផែនការ ដោយលែកនិងទូទៅនៃជំងឺចាំបាច់នានា ដោយផ្តោតចំបងទៅលើការលើកកំពស់គុណភាពសេវា ។ ការបង្កើនតំរូវការផ្នែកសុខភាពនិង សិទ្ធិអំណាចរបស់អ្នកជំងឺ គឺជាមធ្យោបាយចំពោះមុខដ៏សំខាន់សំរាប់បង្កើនគុណភាពសេវានិងការទទួលខុសត្រូវក្នុងការផ្តល់សេវា ។

- **ហិរញ្ញប្បទានការថែទាំសុខភាព** ដោះស្រាយការបង្កើនវិនិយោគលើសុខភាព និងការប្រឹងប្រែងដើម្បីបំបាត់របាំងហិរញ្ញវត្ថុក្នុងការទទួលយកសេវាមានគុណភាព។ ការវិភាជន៍ធនធានរបស់រដ្ឋាភិបាលដល់វិស័យសុខាភិបាល គ្រាន់តែជាផ្នែកមួយតែប៉ុណ្ណោះ។ ដូច្នេះត្រូវគូសបញ្ជាក់អំពីបញ្ហានានាជុំវិញតុល្យភាពនៃហិរញ្ញប្បទានរវាងរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ក៏ដូចជាការផ្តល់មូលនិធិឱយបានគ្រប់គ្រាន់ដល់ថ្នាក់ផ្តល់សេវា។ ពង្រឹងយន្តការគាំពារសុខភាពសង្គម ដោយរាប់បញ្ចូលទាំងមូលនិធិសមធម៌ ការធានារ៉ាប់រងសុខភាពតាមសហគមន៍ ការធានារ៉ាប់រងសុខភាពសង្គម និងរួមចំណែកដល់ការកាត់បន្ថយរបាំងហិរញ្ញវត្ថុក្នុងការមកទទួលយកសេវា និងគ្រោះថ្នាក់នៃការចំណាយដ៏មហន្តរាយលើសុខភាព។
- **ធនធានមនុស្សសុខាភិបាល** គ្របដណ្តប់លំដាប់លំដោយលើអន្តរាគមន៍គ្រប់ជ្រុងជ្រោយមួយ។ ១) ធានាកំរិតបរិមាណបុគ្គលិកគ្រប់គ្រាន់ ហើយមានប្រវត្តិវិជ្ជាជីវៈនិងសមត្ថភាពសមស្រប។ ២) ការពិនិត្យសារឡើងវិញកម្មវិធីនៃការបណ្តុះបណ្តាល។ ៣)បង្កើនចំនួនសិស្ស–និស្សិតដែលត្រូវជ្រើសរើសឱយចូលរៀនតាមសាលានិងសកលវិទ្យាល័យ និង ៤)ពង្រឹងវិធានការនានា ដើម្បីការពារគុណភាពបណ្តុះបណ្តាលនិងគ្រូបណ្តុះបណ្តាល។ ឆ្មបត្រូវបានជ្រើសរើសជាពិសេសថាជាក្រុមចំណុចដោយសារតែតួនាទីដ៏សំខាន់របស់ពួកគេ ក្នុងការសំរេចគោលបំណងទូទៅនៃផ.យ.ស.២។ ការរៀបចំកម្មវិធីធនធានមនុស្សត្រូវរាប់បញ្ចូលផងដែរការគោរពក្រមសីលធម៌វិជ្ជាជីវៈ។ តំរូវការចាំបាច់និងជាបន្ទាន់គឺ ការផ្សារភ្ជាប់ទៅនឹងការអនុវត្តន៍កំណែទំរង់បៀវត្សរ៍សំរាប់សេវាសុខភាព។
- **ប្រពន្ធ័ពត៌មានសុខាភិបាល** ដោះស្រាយអំពីតំរូវការទិន្នន័យមានគុណភាពខ្ពស់ ត្រឹមត្រូវគ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា ដើម្បីជាមូលដ្ឋានដល់ការតាក់តែងគោលនយោបាយផ្អែកលើភស្តុតាងការធ្វើផែនការ ការត្រួតពិនិត្យតាមដានស្នាដៃការងារនិងការវាយតំលៃ។ ចំណុចផ្តោតជាចំបង គឺលើកស្ទួយការសំរបសំរួលនិងកិច្ចសហការទាំងក្នុងនិងក្រៅវិស័យសុខាភិបាល តាមរយៈការចែករំលែកទិន្នន័យការគ្រប់គ្រង ការវិភាគ ការផ្សព្វផ្សាយនិងប្រើប្រាស់ ព្រមទាំងការដាក់បញ្ចូលពត៌មានពីវិស័យឯកជននិងការតាមដានថវិកានិងការចំណាយនិងពង្រីកការបណ្តុះបណ្តាល ដើម្បីកសាងសមត្ថភាពប្រពន្ធ័ពត៌មានសុខាភិបាល។
- **អភិបាលកិច្ចវិស័យសុខាភិបាល** ទស្សនៈវិស័យស្តីអំពីអភិបាលកិច្ចនៃ ផ.យ.ស.២ ផ្តោតលើវិមជ្ឈការនិងវិសហមជ្ឈការ។ ការធ្វើឱយត្រឹមត្រូវតាមច្បាប់ចំពោះកិច្ចសន្យាផ្ទៃក្នុង និងកិច្ចសន្យាខាងក្រៅតាមរយៈ**"ទីភ្នាក់ងារប្រតិបត្តិការពិសេស"** និង **"ថវិកាកញ្ចប់"** ពីថ្នាក់ជាតិនិងការកៀងគរធនធាននៅនឹងមូលដ្ឋាន នឹងគ្របដណ្តប់លើសេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុតាមគោលនយោបាយនេះ។ ស្វយ័តភាពដែលនឹងបង្កើននៅថ្នាក់ប្រតិបត្តិនឹងត្រូវកំណត់រួមជាមួយនឹងនិយតកម្មដ៏រឹងមាំ និងមត្តទេសភាពដល់វិស័យឯកជនសុខដុមនីយកម្មនិងការតំរៀបតំរង់ ដើម្បីលទ្ធផលត្រូវបានបញ្ជាក់ច្បាស់ដើម្បីឈានទៅសំរេចគ្របខណ្ឌ័គោលនយោបាយរួមមួយរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ សំរាប់ការអភិវឌ្ឍន៍វិស័យសុខាភិបាល។ យុទ្ធសាស្ត្រនឹងលើកកំពស់ឱយកាន់តែប្រសើរឡើងនូវរូបភាពគ្រប់ជ្រុងជ្រោយនៃការផ្តល់មូលនិធិ

របស់រដ្ឋាភិបាលនិងប្រទេសផ្តល់ជំនួយព្រមទាំងពង្រឹង **សុខដុមនីយកម្ម** (សំរបសំរួលជំនួយក្រៅប្រទេសស្របតាមនិតិវិធី រចនាសម្ពន្ធ័ និងប្រពន្ធ័ជាតិនៅកន្លែងណាដែលអាចប្រព្រឹត្តទៅបាន) និង **តំរៀបតំរង់** (ធានាថាអាទិភាពដែលបានកំណត់ដោយប្រទេសកម្ពុជាក៏ជាអាទិភាពរបស់ប្រទេសផ្តល់ជំនួយ)ស្ថាបត្យកម្មជំនួយឱយស្របតាមបន្ទាត់គោលនយោបាយរបស់រដ្ឋាភិបាលស្តីអំពីវិមជ្ឈការនិងវិសហមជ្ឈការ។

## ៤.១ យុទ្ធសាស្ត្រនៃការផ្តល់សេវាសុខាភិបាល (ផសស)

តាមរយៈយុទ្ធសាស្ត្រនៃការផ្តល់សេវានេះ **គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ** របស់រាជរដ្ឋាភិបាលនឹងត្រូវលើកយកមកអនុវត្ត។ យុទ្ធសាស្ត្រផ្តល់សេវាសុខភាព ទ្រទ្រង់ដល់លទ្ធផលសំខាន់៧នៃសេវាសាធារណៈនិងឯកជន ហើយជាមធ្យោបាយដែលតាមរយៈនេះលទ្ធផលនៃផ.យ.ស.២នឹងត្រូវសំរេចបាន។ យុទ្ធសាស្ត្រ៤ ផ្សេងទៀតត្រូវបានកសាងឡើង ដើម្បីគាំទ្រយុទ្ធសាស្ត្រផ្តល់សេវាសុខភាពឆ្ពោះទៅសំរេចលទ្ធផលខាងលើ។

នៅជំណាច់ឆ្នាំ២០១៥ គ្រប់សហគមន៍ទាំងអស់ នឹងមានលទ្ធភាពទទួលយកសេវាស.ស.អ និងស.ស.ប ពេញលេញពីមូលដ្ឋានសុខាភិបាលសាធារណៈ និងពីអ្នកផ្តល់សេវាឯកជនដែលមានអជ្ញាបណ្ណ័និងការទទួលស្គាល់គុណភាព។ ជោគជយ័នៃកិច្ចសន្យាផ្តល់សេវាសុខភាព នឹងត្រូវបានពង្រីកទូទាំងប្រទេស ហើយនិយតកម្មទៅតាមបរិបទស្ថាបន័នៃវិស័យសាធារណៈនៅកម្ពុជា ដោយផ្តោតជាសំខាន់លើកិច្ចសន្យាផ្ទៃក្នុងនិងស្វ័យភាពលើការគ្រប់គ្រង តាមរយៈទីភ្នាក់ងារប្រតិបត្តិការពិសេសស្របតាមគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល ដែលទ្រទ្រង់ដោយ "ថវិកាកញ្ចប់សំរាប់ការផ្តល់សេវា" នៅថ្នាក់ខេត្ត-ក្រុង។

យុទ្ធសាស្ត្រផ្តល់សេវាសុខភាពប្រើប្រាស់ "ការថែទាំបន្ត" (Continum of care) ដើម្បីពង្រឹងនិងផ្សារភ្ជាប់គ្នារវាង ស.ស.អ និងស.ស.ប អមដោយការពង្រឹងសេចក្តីណែនាំគ្លីនិក និងពិធីសារនៃការព្យាបាល ព្រមទាំងប្រមូលផ្តុំកាន់តែខ្លាំងឡើងលើគុណភាព និងក្របខណ្ឌ័វិជ្ជាជីវៈទាំងក្នុងវិសយ័សុខាភិបាលសាធារណៈនិងឯកជន។

មូលដ្ឋានសុខាភិបាលសេវាសុខភាពដែលត្រូវផ្តល់ និងរចនាសម្ពន្ធ័ទ្រទ្រង់ដទៃទៀតនឹងត្រូវតំរង់គោលដៅ ឱយកាន់តែជិតថែមទៀតទៅរកតំរូវការផ្នែកសុខភាពរបស់ប្រជាជន តាមរយៈផ.គ្រ.សនិងការវាយតំលៃអំពីបន្ទុកជំងឺ។ ការត្រួតពិនិត្យតាមដាននិងការអភិបាលនឹងត្រូវបានពង្រឹងតាមរយៈបង្កើនសមាហរណកម្ម និងការបង្កើតក្រុមត្រួតពិនិត្យតាមដានការផ្តល់សេវាពីនាយកដ្ឋានច្រើនរួមគ្នា ដើម្បីទ្រទ្រង់កម្មវិធីជាតិ មន្ទីរសុខាភិបាលខេត្ត-ក្រុងនិងស្រុកប្រតិបត្តិ។

## ក.	បញ្ហាប្រឈមមុខ

បច្ចុប្បន្នការផ្តល់សេវាសុខភាពនៅប្រទេសកម្ពុជាមានចរិតលក្ខណៈដូចខាងក្រោមនេះ :

- កំណើនសន្សឹមៗនៃការប្រើប្រាស់សេវាសាធារណៈ ។
- គុណភាពនៃការផ្តល់សេវាជាទូទៅមានកំរិតទាប ទាំងនៅផ្នែកសាធារណៈនិងផ្នែកឯកជន
- ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សទាំងលំនាំនៃការរំពឹងទុករបស់អតិថិជន (រាប់បញ្ចូលទាំងចំណង់ចំណូលចិត្តរបស់បុគ្គលម្នាក់ៗលើការថែទាំសុខភាព) និងលំនាំនៃការផ្តល់សេវាសុខភាព ។
- ភាពបែកខ្ញែកនៃសកម្មភាព លំហូរមូលនិធិ ការត្រួតពិនិត្យតាមដាន ការអភិបាលនិងខ្សែរយៈសមត្ថកិច្ចរដ្ឋបាល ។
- យន្តការនិយតកម្មខ្វះប្រសិទ្ធភាព ការសំរបសំរួលរវាងវិស័យសាធារណៈ និងឯកជននៅទន់ខ្សោយ រាប់បញ្ចូលទាំងសេវាឯកជនដែលមិនស្វែងរកផលចំណេញ ។
- លទ្ធភាពភូមិសាស្ត្រក្នុងការមកទទួលយកសេវាមានការលំបាក និងកង្វះពត៌មានស្តីអំពីសេវាសុខភាពសាធារណៈនៅតំបន់ជនបទដាច់ស្រយ៉ាល ។

បញ្ហាប្រឈមមុខទាំងអស់នេះនឹងត្រូវបានដោះស្រាយ តាមរយៈពង្រឹងយុទ្ធសាស្ត្រនៃការផ្តល់សេវាដែលកាន់តែមានប្រសិទ្ធភាព និងកាន់តែមានលក្ខណៈសមាហរណកម្ម ដោយការពង្រឹង និងកសាងលើមូលដ្ឋាននៃស.ស.អ នៅមណ្ឌលសុខភាព និងស.ស.ប នៅមន្ទីរពេទ្យបង្អែក ។ យុទ្ធសាស្ត្រនេះត្រូវបានកំណត់ឡើងដើម្បីបន្ថយភាពបែកខ្ញែកគ្នានៅក្នុងការផ្តល់សេវាសុខភាព ទន្ទឹមគ្នានឹងការគោរពតាមរចនាសម្ព័ន្ធរដ្ឋបាលរបស់ក្រសួងសុខាភិបាលនិងរក្សាមុខងារស្នូលរបស់កម្មវិធីជាតិដែលមានគុណភាពខ្ពស់និងអង្គភាពឯកជនសំខាន់ៗដទៃទៀត ។ នៅកំរិតទូលំទូលាយយន្តការនិយតកម្មអ្នកប្រកបមុខរបរឯកជននឹងត្រូវពង្រឹងដើម្បីធានាឱយមានការគោរពបទដ្ឋានគុណភាពអប្បបរមា ។

## ខ.	សមាសធាតុនិងអន្តរាគមន៍ជាយុទ្ធសាស្ត្រ

### ផសស.១	ពង្រីកការគ្របដណ្តប់ការផ្តល់សេវាសំណុំសកម្មភាពអប្បបរមានិងសំណុំសកម្មភាពបង្គ្រប់យោងតាមផែនការគ្របដណ្តប់សុខាភិបាលនិងតំរូវការរបស់អតិថិជន

**ផសស.១.១**	ពង្រឹងនិងពង្រីកការផ្តល់ ស.ស.អ ដោយមណ្ឌលសុខភាពនិងស.ស.ប ពេញលេញមន្ទីរពេទ្យបង្អែក ពិសេសសេវាឯកទេសនៅមន្ទីរពេទ្យបង្អែកថ្នាក់ជាតិ និងថ្នាក់ខេត្តដែលមានសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ផ្អែកតាមសេចក្តីណែនាំអំពីស.ស.អ និងស.ស.ប ជាមួយនឹងការពង្រឹងប្រពន្ធ័បញ្ជូនជំងឺរវាងមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក ។

ផសស.១.២ កំណត់សំណុំនៃ"ការថែទាំបន្ត"នៅក្នុងស.ស.អ និងស.ស.ប សំរាប់សេវាអាទិភាពនៃសុខភាពបន្តពូជ-មាតា-ទារក-កុមារ ជំងឺឆ្លងនិងជំងឺមិនឆ្លង។ ការថែទាំបន្តទាំងនេះនឹង :

- ប្រើប្រាស់ជាមូលដ្ឋានផ្តល់មូលនិធិ ដើម្បីពង្រឹង ស.ស.អ និង ស.ស.ប
- បញ្ចូលអន្តរាគមន៍នានាទាំងផ្នែកគ្លីនិក ការផ្តល់សេវាតាមមូលដ្ឋាន និងការប្រាស្រ័យទាក់ទង
- បញ្ចូលប្រពន្ធ័បញ្ជូនជំងឺដែលតភ្ជាប់រវាង ស.ស.អ និងស.ស.ប
- បញ្ចូលសេចក្តីណែនាំគ្លីនិក និងពិធីសារនៃការព្យាបាលដែលមានសង្គតភាពជាមួយ ស.ស.អ និងស.ស.ប និងពង្រឹងបន្ថែមដល់សេចក្តីណែនាំអំពី ស.ស.អ និងស.ស.ប ដែលមានស្រាប់។

ផសស.១.៣ ពង្រឹងការត្រួតពិនិត្យតាមដានបែបសមាហរណកម្ម និងការអភិបាលគាំទ្រ នៅថ្នាក់ខេត្ត-ក្រុងនិងស្រុកប្រតិបត្តិ ដើម្បីទ្រទ្រង់ដល់មុខងារនៃការផ្តល់សេវាសុខភាពនៅមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព តាមរយៈការផ្តល់ថវិកាសំរាប់ការត្រួតពិនិត្យតាមដាននិងការអភិបាល។

ផសស.១.៤ ពង្រឹងការត្រួតពិនិត្យតាមដានការផ្តល់សេវានិងការអភិបាល គាំទ្រដោយនាយកដ្ឋាននានានៃក្រសួងសុខាភិបាល ដើម្បីទ្រទ្រង់ដល់មន្ទីរសុខាភិបាល ក្នុងការប្រតិបត្តិតួនាទីនៃការត្រួតពិនិត្យតាមដាននិងការអភិបាលរបស់ខ្លួន តាមរយៈការបង្កើត និងផ្តល់មូលនិធិដល់ក្រុមត្រួតពិនិត្យតាមដាន ការផ្តល់សេវាដែលមានសមាសភាពពីនាយកដ្ឋាននិងកម្មវិធី/មជ្ឈមណ្ឌលជាតិ។

ផសស.១.៥ ពង្រឹងតួនាទីនិងមុខងារនៃការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលតាមរយៈការពង្រឹងការអនុវត្តន៍បែបបទផែនការនីយកម្មប្រចាំឆ្នាំ ដោយរាប់បញ្ចូលទាំងការវិនិច្ឆ័យនិងផ្តល់យោបល់ត្រឡប់លើផែនការ ពិសេសនៅថ្នាក់ខេត្ត- ក្រុងនិងស្រុកប្រតិបត្តិ។

ផសស.១.៦ ពង្រឹងគំរូនៃការថែទាំបែបសមាហរណកម្ម នៃការចុះផ្តល់សេវាដល់មូលដ្ឋាន និងផ្តែកលើសហគមន៍ ជាយុទ្ធសាស្រ្តបន្ទាន់សំរាប់ការពង្រីកអន្តរាគមន៍ផ្នែកសុខភាពមាតា-ទារកនិងការរស់រានរបស់កុមារពិសេសនៅតាមសហគមន៍ដែលពិបាកមកទទួលសេវា នៅមូលដ្ឋានសុខាភិបាលនិងធានាឱយមានការចូលរួមពីរដ្ឋអំណាចមូលដ្ឋាននិងអ្នកស្ម័គ្រចិត្ត(ក្រុម

ទ្រទ្រង់សុខភាពភូមិ) នៅក្នុងការផ្តល់សេវានិងពត៌មាន សំរាប់កែលំអសេវាសុខភាពបន្តពូជ-ទារកនិងកុមារ។

**ផសស.១.៧** លើកស្ទួយរបៀបរបបរស់នៅ តាមរយៈការបង្កើតបរិដ្ឋានមានសុខភាពនិងយុទ្ធសាស្ត្រសំរាប់ការផ្លាស់ប្តូរឥរិយាបទនិងការប្រាស្រ័យទាក់ទង។

## ផសស.២ ពង្រឹងប្រព័ន្ធគាំទ្រការផ្តល់សេវាសុខាភិបាលក្នុងលក្ខណៈសមាហរកម្ម

**ផសស.២.១** ពង្រឹងប្រព័ន្ធបញ្ជូនជំងឺមានប្រសិទ្ធភាព រាប់បញ្ចូលទាំងប្រពន្ធ័បញ្ជូនជំងឺក្នុងសហគមន៍ ព្រមទាំងស្ថាបនាបណ្តាញប្រពន្ធ័បញ្ជូនជំងឺនៅពេលចាំបាច់ តាមរយៈការចងជាចង្កោមស្រុកប្រតិបត្តិ និងខេត្ត-ក្រុង ដើម្បីលើកកំពស់ការប្រើប្រាស់ជាអតិបរមានូវធនធានដែលមានស្រាប់ និងជួយសហគមន៍ឱយគ្រប់គ្រងនិងអនុវត្តប្រពន្ធ័បញ្ជូនអ្នកជំងឺក្នុងសហគមន៍ដោយខ្លួនឯង។

**ផសស.២.២** លើកកំពស់ការរៀបចំចាត់ចែង ការគ្រប់គ្រង និងសមត្ថភាពបច្ចេកទេសនៃសេវាអមវេជ្ជសាស្ត្រ ដោយរាប់បញ្ចូលទាំងសេវាមន្ទីរពិសោធន៍និងសេវាផ្តល់ឈាម។ល។ ដើម្បីគាំទ្រដល់ការធ្វើរោគវិនិច្ឆ័យ ការព្យាបាល និងការថែទាំមានគុណភាពនិងប្រសិទ្ធភាព។

**ផសស.២.៣** ពង្រឹងសមត្ថភាពនិងជំនាញ លើការព្យាករណ៍និងការកំណត់បរិមាណឱសថ បរិក្ខាពេទ្យ ព្រមទាំងពង្រឹងការត្រួតពិនិត្យ និងធានាគុណភាពឱសថ-បរិក្ខាពេទ្យ ជាពិសេសនៅថ្នាក់ខេត្ត-ក្រុងនិងស្រុកប្រតិបត្តិ។

**ផសស.២.៤** គាំរៀបគាំរង់សេវាជំនួយទ្រទ្រង់ទៅតាមសនិទានកម្មនៃតំរូវការ ក្នុងការផ្តល់សេវានិងពង្រឹងប្រពន្ធ័ផ្គត់ផ្គង់ដើម្បីធានាឱយមានឱសថ-បរិក្ខារគ្រប់គ្រាន់និងទាន់ពេលវេលានៅតាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក។

## ផសស.៣ គាំរង់ការផ្តល់សេវានិងអន្តរាគមន៍សុខភាពសាធារណៈឆ្លើយតបទៅនឹងតំរូវការផ្នែកសុខភាព

**ផសស.៣.១** កំណត់បរិមាណរំពឹងទុកនៃសំណុំសេវាសារវន្ត័(ការថែទាំបន្ត) សំរាប់មូលដ្ឋានសុខាភិបាល ដើម្បីតំរង់ទិសនៃអន្តរាគមន៍សុខភាពសាធារណៈ សេវាបង្ការ ព្យាបាលនិងលើកកំពស់សុខភាពទៅតាមតំរូវការ ដោយផ្អែកលើលទ្ធផលនៃការសិក្សាវាយតំលៃគ្រប់ជ្រុងជ្រោយស្តីអំពីបន្ទុកជំងឺទូទាំងប្រទេសនិងកត្តាសង្គមមានឥទ្ធិពលលើសុខភាព។

**ផសស.៣.២** ពិនិត្យសារឡើងវិញផ. គ្រ.សទូទាំងប្រទេស និងអភិវឌ្ឍផែនទីមូលដ្ឋានសុខាភិបាលដោយបំពេញបន្ថែមទិន្នន័យ ស្តីអំពីតំរូវការនៃការផ្តល់សេវាដែលរំពឹងទុក ព្រមទាំងធ្វើបច្ចុប្បន្នភាពរៀងរាល់ ៣ឆ្នាំម្តង។

**ផសស.៣.៣** ពង្រឹងការអនុវត្តន៍ក្របខណ្ឌសំរាប់ប្រពន្ធ័ប្រកាសភាពអាសន្ន និងលើកកំពស់ប្រពន្ធ័តាមដានជំងឺ ការស្រាវជ្រាវទាន់ពេល និងការឆ្លើយតបមានប្រសិទ្ធភាពតាមរយៈការអភិវឌ្ឍន៍គោលនយោបាយជាតិគ្រប់ជ្រុងជ្រោយ និងមគ្គុទេសបច្ចេកទេសចាំបាច់នានា ដើម្បីឆ្លើយតបទៅនឹងភាពអាសន្ននិងគ្រោះមហន្តរាយនិងការពង្រឹងអន្តរាគមន៍របស់ “ក្រុមឆ្លើយតបរហ័ស” ថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង។

## ផសស.៤ អភិវឌ្ឍនិងអនុវត្តបទដ្ឋានគុណភាពនៅទូទាំងវិស័យសុខាភិបាល (សេវារដ្ឋ-ឯកជន-ឯកជនមិនស្វែងរកកំរៃ)

**ផសស.៤.១** ពង្រឹងការអនុវត្តន៍គោលនយោបាយជាតិស្តីពីការកែលំអគុណភាពនៅក្នុងវិសយ័សុខាភិបាល (ខែតុលាឆ្នាំ២០០៥) ដើម្បីផ្តល់ការថែទាំសុខភាពមានគុណភាព សុវត្ថិភាពនិងប្រសិទ្ធភាព ផ្តោតលើអតិថិជនទាន់ពេល និងសមធម៌ ដោយយកចិត្តទុកដាក់ពិសេសដល់សិទ្ធអតិថិជន និយត័កម្មស្ថាបន័ និងការគ្រប់គ្រង ការអនុវត្តន៍គ្លីនិក ការអភិវឌ្ឍន៍ វិជ្ជាជីវៈ និងបរិស្ថាន គាំទ្រឱយមានការលើកកំពស់គុណភាព។

**ផសស.៤.២** អភិវឌ្ឍនិងអនុវត្តប្រពន្ធ័ និងវិធីសាស្រ្តអង្កេតនៅមូលដ្ឋានសុខាភិបាលជាប្រចាំសំរាប់ការតាមដានបន្ត ដើម្បីធានាថាការផ្គត់ផ្គង់ផ្នែកវេជ្ជសាស្រ្ត សំភារៈជាមូលដ្ឋាន និងហេដ្ឋារចនាសម្ពន្ធ័ មានសមស្របទៅតាម ស.ស.អ និង ស.ស.ប ។

**ផសស.៤.៣** បង្កើតយន្តការលើកទឹកចិត្ត ដើម្បីលើកកំពស់គុណភាព ដូចជាការផ្តល់រង្វាន់ និងការទទួលស្គាល់ចំពោះការសំរេចបានលទ្ធផលខ្ពស់ ដោយមានការចូលរួមពីអតិថិជន។

**ផសស.៤.៤** ត្រួតពិនិត្យតាមដានការពេញចិត្តរបស់អតិថិជនតាមរយៈការអង្កេតទៀងទាត់លើអតិថិជន និងការលើកកំពស់ការប្រាស្រយ័ទាក់ទងនិងការសំរបសំរួល ជាមួយគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព ក្រុមទ្រទ្រង់សុខភាពភូមិ ភ្នាក់ងារប្រតិបត្តិមូលនិធិសមធម៌ និងក្រុមប្រឹក្សាឃុំ/សង្កាត់។

**ផសស.៤.៥** ពង្រឹងយន្តការនិយតកម្មក្នុងការផ្ដល់អាជ្ញាបណ្ណ័ដល់វិស័យឯកជន បន្ត ដោយការអនុវត្តន៍ប្រពន្ធ័ទទួលស្គាល់គុណភាពជាជំហានបន្ទាប់ក្រោយ ពីបានបំពេញតាមតំរូវការនៃការចេញអាជ្ញាបណ្ណ័រួចហើយ។ បែបទបទ ដូចគ្នានេះនឹងអនុវត្តជាជំហាន២នៅក្នុងវិស័យសាធារណៈ។

## ផសស.៥ អភិវឌ្ឍគំរូកិច្ចសន្យាដែលជាចំណុចស្នូលនៃវិធីសាស្រ្តគ្រប់ជ្រុងជ្រោយសំរាប់កិច្ចព្រមព្រៀង នៃការផ្ដល់សេវា

**ផសស.៥.១** ពង្រីកកិច្ចសន្យាផ្ដល់សេវាទូទាំងប្រទេស ស្របតាមគោលនយោបាយ និងច្បាប់របស់រាជរដ្ឋាភិបាល តាមរយៈការអនុវត្តន៍ទីភ្នាក់ងារប្រតិបត្តិ ការពិសេស និងកិច្ចព្រមព្រៀងផ្ដល់សេវាដទៃទៀតដែលចុះសំរុងគ្នា (កិច្ច សន្យាផ្ទៃក្នុងនិងខាងក្រៅ) ដើម្បីលើកកំពស់លទ្ធភាពមកទទួលយកសេវា ប្រសិទ្ធភាព គុណភាពនិង សមធម៌ ព្រមទាំងជំរុញឱយអ្នកគ្រប់គ្រង និងអ្នកផ្ដល់សេវាទទួលខុសត្រូវលើលទ្ធផល។ ការរៀបចំចាត់ចែងទាំង នេះនឹងត្រូវអភិវឌ្ឍន៍ដោយអនុលោមតាមគោលនយោបាយស្ដីពីការផ្ដល់ សេវាសាធារណៈរបស់រាជរដ្ឋាភិបាលនិងចងក្រងជាក្រមនៅក្នុងគោល នយោបាយរបស់ក្រសួងសុខាភិបាលស្ដីពីកិច្ចសន្យាផ្ដល់សេវា។ ស្រប តាមគោលនយោបាយស្ដីពីការផ្ដល់សេវាសាធារណៈ ការរៀបចំចាត់ ចែងនេះនឹងធានាឱយមាន:

- ផ្ដោតលើតំរូវការរបស់អ្នកប្រើប្រាស់សេវា ដោយកំណត់ច្បាស់ លាស់ អំពីប្រភេទគុណភាព និងតំលៃសេវាដែលត្រូវផ្ដល់។
- កំណត់ច្បាស់លាស់អំពីលទ្ធផលរំពឹងទុកនិងធនធានដែលអាចរកបាន
- កំណត់ច្បាស់លាស់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាព/ ផ្នែក
- កំណត់ច្បាស់លាស់យន្តការ សំរាប់ការតាមដានត្រួតពិនិត្យ និង ការវាយតំលៃ

**ផសស.៥.២** ប្រើប្រាស់ផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលអនុមត័ដោយក្រសួងសុខា ភិបាលជាមូលដ្ឋានសំរាប់ទីភ្នាក់ងារប្រតិបត្តិការពិសេស និងសំរាប់កិច្ច ព្រមព្រៀងនៃកិច្ចសន្យាដទៃទៀតដែលត្រូវអនុវត្តរវាងក្រសួងសុខាភិបាល ជាមួយអង្គភាពសុខាភិបាលខេត្ត-ក្រុង ទូទាំងវិស័យសុខាភិបាល។

ផសស.៥.៣ តាមស្ថានភាពសមស្របពង្រឹងផែនការនីយតកម្មប្រចាំឆ្នាំ ការកសាងថវិកានិងការផ្តល់មូលនិធិដល់មូលដ្ឋានសុខាភិបាលសាធារណៈ រួមមានទីភ្នាក់ងារប្រតិបត្តិការពិសេសជាមួយនឹង "ថវិកាកញ្ចប់ប្រចាំត្រីមាសសំរាប់ការផ្តល់សេវា" និងតាមការ "បណ្តុំមូលនិធិ" តាមលំដាប់ថ្នាក់ដែលអាចប្រព្រឹត្តទៅបាន (ដូចជានៅក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ក្រសួង សុខាភិបាលមន្ទីរសុខាភិបាលខេត្ត-ក្រុងនិងស្រុកប្រតិបត្តិ) ដោយផ្តោត ជាសំខាន់ដល់ជនក្រីក្រនិងតំបន់ជនបទ។

ផសស.៥.៤ ពង្រឹងសមត្ថភាព និងអភិវឌ្ឍជំនាញទូទាំងវិស័យពិសេសនៅថ្នាក់ខេត្ត-ក្រុងនិងស្រុកប្រតិបត្តិ ដើម្បីចងក្រង គ្រប់គ្រង អនុវត្ត និងត្រួតពិនិត្យតាមដានគ្រប់ទំរង់ទាំងអស់នៃកិច្ចសន្យា។

## ៤.២ យុទ្ធសាស្ត្រហិរញ្ញប្បទានការថែទាំសុខភាព (ហថស)

នៅដំណាច់ឆ្នាំ២០១៥ រូបធាតុផ្សេងៗគ្នា រួមទាំងរចនាសម្ព័ន្ធនៃប្រពន្ធ័ហិរញ្ញប្បទានបច្ចុប្បន្ន នឹងត្រូវដាក់បញ្ចូលនៅក្រោមយុទ្ធសាស្ត្រប្រមូលផ្តុំតែមួយ ដែលត្រួសត្រាយដោយអាទិភាពជាតិ។ យន្តការធានារ៉ាប់រងសុខភាពសង្គមនឹងដាក់ឱយដំណើរការជនក្រីក្រនឹងទទួលបានការគាំពារដោយយន្តការជំនួយសង្គមសមស្រប លំហូរមូលនិធិរដ្ឋ សំរាប់សុខភាពនឹងមានកំរិតសមស្របដើម្បីការផ្តល់សេវាសុខភាពឱយបានគ្រប់គ្រាន់ដល់ប្រជាជនការជួយឧបត្ថម្ភពីប្រទេសផ្តល់ជំនួយនឹងមានសុខដុមនីយកម្ម ព្រមទាំងតំរៀបតំរង់តាមអាទិភាពជាតិ និងគាំទ្រដល់ការផ្តល់សេវាមានប្រសិទ្ធភាព។ ការសំរេចបានគោលដៅទាំងនេះ នឹងជំរុញដល់ចលនាឆ្ពោះទៅរកលទ្ធភាពនៃការគ្របដណ្តប់ជាសកល។

### ក. បញ្ហាប្រឈមមុខ

ហិរញ្ញប្បទានវិស័យបច្ចុប្បន្ននៅប្រទេសកម្ពុជាមានចរិតលក្ខណៈដូចខាងក្រោមនេះ:

- កំរិតនៃការចំណាយសរុបលើការថែទាំសុខភាពរហូតដល់ ៣៩ ដុល្លារអាមេរិក លើប្រជាជនម្នាក់ បើប្រៀបធៀបនឹងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត។
- កំរិតកំណើននៃការចំណាយចរន្តរបស់រដ្ឋលើការថែទាំសុខភាព រហូតដល់១២% នៃថវិកាជាតិសរុប ប៉ុន្តែនៅតែទាបបើប្រៀបធៀបនឹងផលិតផលសរុបក្នុងស្រុកគឺជាង ១% ក្នុងឆ្នាំ២០០៧
- កំរិតខ្ពស់នៃការចំណាយដោយឯកជន ការចំណាយប្រាក់ហោប៉ៅផ្ទាល់របស់គ្រួសារ រហូតដល់ប្រមាណ ២/៣ នៃការចំណាយសរុបលើការថែទាំសុខភាព។
- ការពឹងពាក់លើមូលនិធិអ្នកផ្តល់ជំនួយសំរាប់វិស័យសុខាភិបាលរហូតដល់ ៧ដុល្លារអាមេរិក លើប្រជាជនម្នាក់ក្នុងមួយឆ្នាំ នាឆ្នាំ២០០៧។

- កំរិតប្រាក់បៀវត្ស និងការលើកទឹកចិត្តទាប សំរាប់បុគ្គលិកបំរើការក្នុងវិស័យសុខាភិបាល រាំងរាដល់ការដល់ផ្តល់សេវាមានប្រសិទ្ធភាព ។
- កំរិតទាបនៃមូលនិធិសាធារណៈដែលបានធ្លាក់ដល់ថ្នាក់ផ្តល់សេវា ហើយមានផលប៉ះពាល់ទៅលើការផ្តល់សេវា ។

ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១៥ យុទ្ធសាស្ត្រហិរញ្ញប្បទាននឹងផ្អែកទៅលើការអនុវត្តន៍ "គំរូចំរុះ" នៃហិរញ្ញប្បទានសុខាភិបាល ។ គំរូចំរុះនេះរួមបញ្ចូលនូវៈ ប្រភពចំណូលរដ្ឋនិងឯកជន ការផ្តល់សេវាដោយរដ្ឋជាមួយនឹងឯកជន និងយន្តការបង់ថ្លៃផ្ទាល់ បុរេបង់ថ្លៃ និងហិរញ្ញប្បទានផ្នែកសង្គម ។ នៅក្នុងគំរូនេះ តួនាទីរបស់ដៃគូនិមួយៗមានដូចតទៅៈ

- តួនាទី**រដ្ឋាភិបាល**គឺផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្សនិងចំណាយចរន្តដល់ប្រពន្ធ័សុខាភិបាល អនុវត្តមគ្គុទេសភាពទូទាំងប្រពន្ធ័សុខាភិបាល កំណត់អាទិភាព បង្កើនការផ្តល់សេវាសុខភាពសាធារណៈឱយសមាមាត្រទៅនឹងការផ្តល់សេវាសរុប ធានាប្រសិទ្ធភាពនិងគុណភាព ។ **ការរៀបចំចាត់ចែងកិច្ចសន្យា** ស្របទៅតាមគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាលគឺជាឧបករណ៍ដ៏សំខាន់ក្នុងការបំពេញតួនាទីរបស់រដ្ឋាភិបាល ។
- តួនាទី**អ្នកជំនួយ** គឺផ្តល់ជំនួយបច្ចេកទេសឧបត្ថម្ភគាំទ្រដល់អាទិភាពសុខាភិបាលជាតិនិងបំពេញកង្វះខាតមូលនិធិរវាងធនធានដែលអាចរកបាននិងធនធានដែលត្រូវការចាំបាច់ដើម្បីសំរេចគោលបំណងផ្នែកសុខភាព ។ **សុខដុមនីយកម្មនិងការតំរៀបតំរង់** ពិសេសតាម**ការរៀបចំចាត់ចែង កិច្ចសន្យា** ដែលបានកំណត់នឹងត្រូវការជាចាំបាច់ដើម្បីធ្វើឱយការជួយឧបត្ថម្ភពីអ្នកផ្តល់ជំនួយមានប្រសិទ្ធភាព
- **ការបង់ថ្លៃសេវា** ផ្លូវការដោយនិយតកម្ម នឹងបន្តជាប្រភពចំណូលបន្ថែមដ៏សំខាន់សំរាប់មូលដ្ឋានសុខាភិបាល ដើម្បីផ្តល់ហិរញ្ញវត្ថុដល់ការចំណាយចរន្តនិងការលើកទឹកចិត្តបុគ្គលិក ដោយពង្រឹងការលើកលែងការបង់ថ្លៃសេវាចំពោះអ្នកក្រ ។ តួនាទី**កម្មវិធីមូលនិធិសមធម៌** គឺផ្តល់លទ្ធភាពមកទទួលយកសេវាសុខភាពនិងការពារជនក្រីក្រពីមហន្តរាយនៃការចំណាយលើការថែទាំសុខភាព ។ តួនាទី**ការធានារ៉ាប់រងសុខភាពតាមសហគមន៍**គឺផ្តល់នូវយន្តការប្រមូលផ្តុំហានិភ័យសំរាប់ពលករក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រពន្ធ័ដែលស្ថិតនៅលើបន្ទាត់នៃភាពក្រីក្រ ។ **ការធានារ៉ាប់រងសុខភាពសង្គម**ផ្តល់ការគ្របដណ្តប់ជាសកលដល់និយោជិកដែលមានប្រាក់ឈ្នួល/ប្រាក់ខែ នៅក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រពន្ធ័ ។ គោលដៅខ្ពស់បំផុតនោះគឺប្រមូលគំរោងបុរេបង់ថ្លៃទាំងអស់ឱយស្ថិតនៅក្រោមឆត្រ័រួមនៃការធានារ៉ាប់រងសុខភាពសង្គម ។
- តាមរយៈ**ផ្នែកឯកជន** សេវាសុខភាពអាចនឹងត្រូវផ្តល់ឱយដល់ជនទាំងឡាយណាដែលអាចទ្រាំទ្របានទៅនឹងការចំណាយលើការថែទាំសុខភាព និងការបង់ភាគទានការធានារ៉ាប់រងសុខភាពក្នុងផ្នែកឯកជន ។

## ៩. សមាសធាតុនិងអន្តរាគមន៍ជាយុទ្ធសាស្ត្រ

### ហថស.១ បង្កើនថវិការដ្ឋនិងលើកកំពស់ប្រសិទ្ធភាពក្នុងការវិភាជន៍ធនធានរដ្ឋសំរាប់វិស័យសុខាភិបាល

**ហថស.១.១** ពង្រឹងការតស៊ូមតិរវាងក្រសួងសុខាភិបាលនិងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ដើម្បីបង្កើនចំណែកនៃការចំណាយរបស់រដ្ឋ លើការចំណាយសរុបសំរាប់វិស័យសុខាភិបាល។

**ហថស.១.២** ប្រើប្រាស់ឧបករណ៍ផែនការប្រចាំឆ្នាំនិងរយៈពេលមធ្យម (ផែនការប្រតិបត្តិ ប្រចាំឆ្នាំនិងផែនការរំកិល៣ឆ្នាំ) មានប្រសិទ្ធភាពនៅថ្នាក់វិសយ័ អនុវិសយ័ និងនៅថ្នាក់វិមជ្ឈការឈរលើមូលដ្ឋានអាទិភាព និងតំរូវការផ្នែកសុខភាពរបស់ប្រជាជនក្នុងការកសាងថវិកាយុទ្ធសាស្ត្រប្រចាំឆ្នាំ។

**ហថស.១.៣** អនុវត្តឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុសមស្រប ជំរុញមុខងារនៃការត្រួតត្រានិងគ្រប់គ្រងថវិកាទៅកាន់កន្លែងផ្តល់សេវាសុខភាព។

**ហថស.១.៤** កៀងគរធនធានបន្ថែម ដើម្បីគ្របដណ្តប់ការចំណាយលើការថែទាំសុខភាព ការបង្ការជំងឺមិនឆ្លង ការលើកកំពស់សុខភាព និងបញ្ហាសុខភាពដទៃទៀត ដូចជាគ្រោះថ្នាក់ចរាចរ។

### ហថស.២ តំរៀបតំរង់ការផ្តល់មូលនិធិម្ចាស់ជំនួយជាមួយនឹងយុទ្ធសាស្ត្រ ផែនការនិងអាទិភាពក្រសួងសុខាភិបាល និងពង្រឹងការសំរបសំរួលការផ្តល់មូលនិធិម្ចាស់ជំនួយក្នុងវិស័យសុខាភិបាល

**ហថស.២.១** តំរៀបតំរង់ការផ្តល់មូលនិធិម្ចាស់ជំនួយ ជាមួយនឹងអាទិភាពវិស័យសុខាភិបាលឆ្នាំ ២០០៨-២០១៥ ដោយប្រើប្រាស់បែបបទ និងឧបករណ៍ផែនការកសាងថវិកាប្រចាំឆ្នាំនិងរយៈពេលមធ្យម របស់ក្រសួងសុខាភិបាល។

**ហថស.២.២** សុខដុមនីយកម្មការផ្តល់មូលនិធិពីម្ចាស់ជំនួយតាមរយៈ ការរៀបចំចាត់ចែង"បណ្តុំមូលនិធិ"(pooling) នៅកន្លែងណាដែលអាចប្រព្រឹត្តទៅបាន។

**ហថស.២.៣** តស៊ូមតិលើការព្យាករណ៍ដែលកាន់តែទុកចិត្តបាន អំពីមូលនិធិសំរាប់រយៈពេលមធ្យមទៅរយៈពេលវែងដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍។

**ហថស.២.៤** ពង្រឹងការឧបត្ថម្ភរបស់អង្គការក្រៅរដ្ឋាភិបាល ស្របទៅតាមអាទិភាពរបស់ ផ.យ.ស.២ និងគាំទ្រសកម្មភាពបំពេញបន្ថែមរបស់ពួកគេ ក្នុងការដោះស្រាយបញ្ហាសុខភាពរបស់ក្រុមប្រជាជនទន់ខ្សោយ និងការចូលរួមក្នុងការសន្ទនាលើគោលនយោបាយ។

## ហថស.៣ បន្ថយឧបសគ្គហិរញ្ញវត្ថុនៅពេលទទួលយកសេវាថែទាំសុខភាព និងអភិវឌ្ឍយន្តការគាំពារសុខភាពសង្គម

**ហថស.៣.១** កាត់បន្ថយរបាំងហិរញ្ញវត្ថុ ក្នុងការមកទទួលយកសេវាសុខភាពមានគុណភាព តាមរយៈនិយតកម្មទំរង់បង់ថ្លៃសេវា ពង្រីកការរៀបចំចាត់ចែងមូលនិធិសមធម៌ និងពង្រីកការធានារ៉ាប់រងសុខភាពតាមសហគមន៍ ដែលជាវិធានការអន្តរកាលនៅមុនពេលអភិវឌ្ឍន៍ និងអនុវត្តន៍ការគាំពារសុខភាពជាសកលដោយប្រសិទ្ធភាព។

**ហថស.៣.២** លើកស្ទួយគុណភាពសេវាសុខភាពនិងប្រើប្រាស់ទំរង់បុរេបង់ថ្លៃ និងការគាំពារសុខភាពសង្គមជាឃ្នាស់សំរាប់ការធានាគុណភាព។

## ហថស.៤ គិតគូរពីប្រភពចំបងៗនិងការប្រើប្រាស់ធនធានជាតិនៅថ្នាក់ផ្តល់សេវាសំរាប់អន្តរាគមន៍សុខភាពជាយុទ្ធសាស្ត្រ

**ហថស.៤.១** ហិរញ្ញប្បទានមានប្រសិទ្ធភាពដល់អាទិភាពសុខភាព ផ្អែកលើការសិក្សាស្តីអំពីបន្ទុកនៃជំងឺ និងការគណនាថ្លៃចំណាយលើ “សេវាថែទាំបន្ត” ដែលបានកំណត់ដោយរាប់បញ្ចូលសេវាសុខភាពបន្តពូជ សុខភាពស្ត្រី ទារក និងកុមារ។

**ហថស.៤.២** ការវិភាជន៍សមស្របនៃថវិកាគួរឱយទុកចិត្តដល់អង្គភាពផ្តល់សេវាតាមរយៈការគ្រប់គ្រងថវិកាបែបវិមជ្ឈការ និងមានសមត្ថភាពធ្វើផែនការកសាងថវិកា គណនេយ្យ ព្រមទាំងមានឧបករណ៍សមស្រប។

**ហថស.៤.៣** បង្កើតនិងអនុវត្តគណនីសុខាភិបាលជាតិ ឬប្រភេទដទៃទៀតនៃការអង្កេតមើលលំហូរហិរញ្ញវត្ថុគ្រប់ជ្រុងជ្រោយ និងតាមដានការចំណាយ។

**ហថស.៤.៤** ពង្រីកការរៀប–ចំចាត់ចែងពង្រីកកិច្ចសន្យា ដើម្បីធានាការផ្តល់សេវាមានគុណភាព ព្រមទាំងការផ្តល់មូលនិធិ និងការប្រមូលផ្តុំថវិកាសមស្របជាមួយថវិកាកញ្ចប់ សំរាប់ការផ្តល់សេវាដល់ស្រុកប្រតិបត្តិ និងទីភ្នាក់ងារប្រតិបត្តិការពិសេស។

## ហថស.៥ ភស្តុតាងនិងពត៌មានសំរាប់គោលនយោបាយហិរញ្ញប្បទានសុខាភិបាល

**ហថស.៥.១** ពង្រឹងប្រពន្ធ័តាមដានថវិកានិងការចំណាយពីគ្រប់ប្រភពហិរញ្ញប្បទានទាំងអស់ហើយផ្សារភ្ជាប់ទៅនិងការអភិវឌ្ឍន៍គណនីសុខាភិបាលជាតិ។

**ហ៥ស.៥.២** សមាហរណកម្មទស្សនៈស្ដីពីសមធម៌និងយែនឌ័រ ទៅក្នុងការប្រមូលទិន្នន័យ ហិរញ្ញប្បទានសុខាភិបាល ការវិភាគ និងគោលនយោបាយហិរញ្ញប្បទានសុខាភិបាល។

**ហ៥ស.៥.៣** អនុវត្តការគណនាថ្លៃចំណាយលើ ស.ស.អ និងស.ស.ប និងសំណុំអន្តរាគមន៍ជាសារវន្ត័ដទៃទៀតលើមូលដ្ឋានមួយទៀងទាត់។

**ហ៥ស.៥.៤** សមាហរណកម្មពត៌មានហិរញ្ញប្បទានសុខាភិបាល លទ្ធផលនៃការគណនាថ្លៃចំណាយ និងភស្តុតាងដទៃទៀត ទៅក្នុងគោលនយោបាយហិរញ្ញប្បទានសុខាភិបាល។

**ហ៥ស.៥.៥** លើកកំពស់សមត្ថភាពក្នុងប្រទេស សំរាប់ការសិក្សាស្រាវជ្រាវផ្នែកសេដ្ឋកិច្ចសុខាភិបាល។

## ៤.៣ យុទ្ធសាស្ត្រធនធានមនុស្សសុខាភិបាល (ធមស)

នៅដំណាច់ឆ្នាំ២០១៥ មន្ត្រី-បុគ្គលិកសុខាភិបាលនឹងទទួលបានការបណ្តុះបណ្តាលដ៏ល្អកាន់តែមានសមត្ថភាព និងទទួលបានការលើកទឹកចិត្តកាន់តែប្រសើរឡើង ដោយសារការគ្រប់គ្រងធនធានមនុស្សត្រូវបានកែលំអ ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ ក៏កាន់តែប្រសើរនិងការទទួលខុសត្រូវក្នុងក្របខណ្ឌវិជ្ជាជីវៈត្រូវបានលើកកំពស់។ ការលើកទឹកចិត្ត និងការបណ្តុះបណ្តាលក្នុងពេលបំរើការងារនឹងត្រូវបានសំរបសំរួលដើម្បីពង្រឹងស្នាដៃការងារ ដោយមិនធ្វើឱយប៉ះពាល់ដល់សកម្មភាពស្នូលហើយគ្រឹះស្ថានបណ្តុះបណ្តាលមុនពេលបំរើការងារនឹងស្ថិតនៅលើគន្លងឆ្ពោះទៅសំរេចបទដ្ឋានគុណភាពក៏រិតអន្តរជាតិ។

យុទ្ធសាស្ត្រធនធានមនុស្សសុខាភិបាលផ្តោតលើសមត្ថភាព និងការលើកទឹកចិត្តរបស់បុគ្គលិកសុខាភិបាល ដើម្បីផ្តល់សេវាថែទាំមានគុណភាពដល់ប្រជាជនកម្ពុជាគ្រប់រូប។ យុទ្ធសាស្ត្រនឹងពង្រឹងការអភិវឌ្ឍន៍ និងការគ្រប់គ្រងធនធានមនុស្ស ដោយសង្កត់ធ្ងន់លើការ បណ្តុះបណ្តាលមុនពេលបំរើការងារ រួមជាមួយអភិក្រមរឹងមាំសំរាប់ការគ្រប់គ្រង និងបណ្តុះបណ្តាល។ អភិក្រមអន្តរវិស័យនឹងប្រកាន់យកដើម្បីបង្កើតនិងពង្រឹងនិយាម និងបទដ្ឋាននៃ លក្ខន្តិកៈវិជ្ជាជីវៈ និងយកចិត្តទុកដាក់ដល់ការផ្តល់បរិស្ថានអំណោយផលជាសារវន្ត័សំរាប់ឱយបុគ្គលិកសុខាភិបាលបញ្ចេញស្នាដៃការងារ ប្រកបដោយគុណភាពខ្ពស់។

## ក. បញ្ហាប្រឈមមុខ

ធនធានមនុស្សសុខាភិបាលបច្ចុប្បន្ននៅប្រទេសកម្ពុជាមានចរិតលក្ខណៈដូចខាងក្រោមនេះ:

- ទំហំធនធានមនុស្សហាក់ដូចជាតូច បើប្រៀបធៀបនឹងចំនួនប្រជាជនសរុបទូទាំងប្រទេស។
- កំរិតខ្ពស់នៃការ "និយោជន៍ទ្វេ" នៃអ្នកមានវិជ្ជាជីវៈពេទ្យដែលប្រើប្រាស់ ដោយក្រសួងសុខាភិបាលនិងការត្រួតជាន់គ្នានៃធនធានមនុស្សសុខាភិបាលរវាងវិស័យសាធារណៈនិងឯកជន។
- អតុល្យភាពក្នុងការពង្រាយបុគ្គលិក ដោយចំនួនបុគ្គលិកលើសនៅទីប្រជុំជន រីឯតំបន់ជនបទខ្វះធ្ងន់ធ្ងរ ពិសេសកង្វះឆ្មបច្រើន និងគិលានុបដ្ឋាកអាចខ្វះខ្លះៗ។
- ជំនាញនិងសមត្ថភាពមិនទាន់គ្រប់គ្រាន់ ហើយសមត្ថភាពនៃការគ្រប់គ្រងមានកំរិត ដោយសារគុណភាពទាបនៃទីកន្លែងសំរាប់ការសិក្សាអនុវត្តជាក់ស្តែង និងគុណភាពរបស់បុគ្គលិកបង្រៀនមានកំរិតទាំងក្នុងចំណោមអ្នកបង្ហាត់ និងអ្នកមានមុខងារអប់រំ។
- បៀវត្សទាបនិងការលើកទឹកចិត្តមិនទាន់សមស្រប គួបផ្សំជាមួយការគ្រប់គ្រងស្នាដៃការងារខ្សោយបង្កជាឧបសគ្គដល់ការលើកកំពស់ផលិតភាពនិងគុណភាពសេវា។
- កង្វះការសំរបសំរួលក្នុងសកម្មភាពបណ្តុះបណ្តាល ធ្វើឱយបុគ្គលិកអវត្តមានពីកន្លែងធ្វើការជារឿយៗ។

ផែនការយុទ្ធសាស្រ្តធនធានមនុស្សសុខាភិបាល ២០០៦-២០១៥(ផ.យ.ធ.ម) របស់ក្រសួងសុខាភិបាលបានអត្តសញ្ញាណបញ្ហាសំខាន់ៗដែលត្រូវប្រឈមមុខ ដូចជារចនាសម្ព័ន្ធ ទំហំ និងសមាសភាពនៃធនធានមនុស្ស ការជ្រើសរើសបំរើការងារ និយោជន៍និងការពង្រាយផលិតភាព និងប្រពន្ធ័លាភការបុគ្គលិករូបធាតុទាំងអស់នេះមានផលប៉ះពាល់យ៉ាងខ្លាំងក្លាលើការអភិវឌ្ឍន៍ប្រពន្ធ័សុខាភិបាលសាធារណៈ និងប្រសិទ្ធភាពនៃការផ្តល់សេវាសុខភាព ព្រមទាំងយុទ្ធសាស្រ្តហិរញ្ញប្បទានសុខាភិបាល។ លើសពីនេះទៀតមានការកើនឡើងនៃតំរូវការឱយបុគ្គលិកសុខាភិបាលដោះស្រាយបញ្ហាសុខភាពចាំបាច់នានា ដូចជាការត្រួតត្រាជំងឺឆ្លង បន្ថយបន្ទុកជំងឺមិនឆ្លង-រ៉ាំរ៉ៃ ការរងរបួស ការប៉ះទង្គិចដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរ ការប្រើប្រាស់គ្រឿងញៀន។ល។ ដែលទាំងអស់នេះនាំឱយមានការកើនឡើងនូវតំរូវការនៃសេវាបង្ការសង្គ្រោះបន្ទាន់ និងសេវារថយន្តគិលានសង្គ្រោះ និងវិធានការអប់រំសុខភាព។

កំណែទំរង់បៀវត្សដែលជាភាពរសើបនៃគោលដៅវិស័យសុខាភិបាលសាធារណៈ ហើយដែលទន្ទឹមពេលជាមួយគ្នានេះមានសង្គតភាពស្របទៅតាមគោលនយោបាយសេវាសាធារណៈទូទៅ គឺជាភារៈកិច្ចដែលត្រូវអនុវត្តនៅក្នុងអំលុងពេលនៃផ.យ.ស.២។ ទំរង់នៃការលើកទឹកចិត្តចាំបាច់ត្រូវតែមានភាពបត់បែនគ្រប់គ្រាន់ ដើម្បីអាចតំរង់គោលដៅទៅលើបុគ្គលិកសំខាន់ៗដូចជាឆ្មបជាដើម និងដើម្បីសំរួលដល់ការជ្រើសរើសបុគ្គលិក បញ្ជូនទៅកាន់ទីកន្លែងជនបទនានាដែលលំបាកនឹងទៅដល់ តាមរយៈការទំនុកបំរុងលើសោហ៊ុយធ្វើដំណើរ ផ្តល់ទីកន្លែងស្នាក់នៅ និងការឧបត្ថម្ភផ្នែកសង្គមផ្សេងទៀតដល់គ្រួសារបុគ្គលិកដែលជ្រើសរើសទៅធ្វើការនៅទីកន្លែងទាំងនោះ។ លើសពីនេះការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុចាំបាច់

ត្រូវបំពេញបន្ថែម ដោយការបណ្តុះបណ្តាលទូទាំងប្រទេស ដើម្បីលើកស្ទួយបទដ្ឋានស្តង់ដារនៃការថែទាំពិសេសនៅផ្នែកអាទិភាព ដូចជាបញ្ហាសុខភាពមាតានិងកុមារជាដើម។

## ៩. សមាសធាតុនិងអន្តរាគមន៍ជាយុទ្ធសាស្ត្រ

### ធមស.១ បង្កើនជំនាញបច្ចេកទេសនិងសមត្ថភាពធនធានមនុស្សសុខាភិបាល

**ធមស.១.១** វិនិយោគលើជំនាញគ្លីនិកឱយកាន់តែប្រសើរថែមទៀត តាមរយៈការបណ្តុះបណ្តាលមុនពេលបំរើការងារ (ទាំងនៅគ្រឹះស្ថានបណ្តុះបណ្តាលរដ្ឋនិងឯកជន) ដោយផ្តោតកាន់តែខ្លាំងលើការអនុវត្តន៍ជាក់ស្តែងផ្នែកគ្លីនិកនិងសុខភាពសាធារណៈ រាប់បញ្ចូលទាំងការហ្វឹកហ្វឺនជាក់ស្តែងក្នុងបរិបទតំបន់ជនបទ-ដាច់ស្រយ៉ាលនិងការបង្កើតមន្ទីរពេទ្យបង្រៀន។

**ធមស.១.២** អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលបន្តមានលក្ខណៈជាប្រព័ន្ធលើការងារគ្រប់គ្រង ទាំងគ្រប់គ្រងទូទៅ និងជំនាញជាក់លាក់ ដោយបញ្ចូលកំរិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកធុរកិច្ចរដ្ឋបាល (សាធារណៈ) សំរាប់មន្ត្រីគ្រប់គ្រងជាន់ខ្ពស់និងសញ្ញាបត្រកំរិតឯកទេសផ្នែកគ្រប់គ្រងហិរញ្ញវត្ថុនិងធនធានមនុស្សសំរាប់មន្ត្រីគ្រប់គ្រងគ្រប់ថ្នាក់ក្នុងប្រព័ន្ធសុខាភិបាល។

**ធមស.១.៣** អភិវឌ្ឍនិងអនុវត្តវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ និងមានលក្ខណៈសំរបសំរួលសំរាប់ការបណ្តុះបណ្តាលក្នុងពេលបំរើការងារ ចាប់ផ្តើមដោយការពិនិត្យឡើងវិញនូវគោលនយោបាយ និងសេចក្តីណែនាំសំរាប់ការបណ្តុះបណ្តាលបន្តនិងការពិនិត្យជាប្រចាំលើកម្មវិធីបណ្តុះបណ្តាលដើម្បីធានាឱយកម្មវិធីទាំងនោះ ឆ្លើយតបទៅនឹងតំរូវការផ្នែកសុខភាពរបស់ប្រជាជន។

**ធមស.១.៤** អភិវឌ្ឍ និងអនុវត្តប្រព័ន្ធទទួលស្គាល់គុណភាពសំរាប់គ្រឹះស្ថានបណ្តុះបណ្តាលរដ្ឋនិងឯកជនដែលនឹងត្រូវពង្រឹង តាមរយៈប្រព័ន្ធទទួលស្គាល់គុណភាពកំរិតអន្តរជាតិ និងការចងសម្ព័ន្ធជាមួយសកលវិទ្យាល័យនិងគ្រឹះស្ថានបណ្តុះបណ្តាលនៃបណ្តាប្រទេសអាស៊ាននិងក្នុងពិភពលោក។

**ធមស.១.៥** បង្កើនការបណ្តុះបណ្តាលមូលដ្ឋានសំរាប់ឆ្មបថ្មី (លើកស្ទួយការជ្រើសរើសសិស្សនៅតាមមូលដ្ឋាន) ព្រមទាំងពង្រឹងសមត្ថភាពនិងជំនាញរបស់ឆ្មបដែលបានទទួលការបណ្តុះបណ្តាលរួចហើយ តាមរយៈការបណ្តុះបណ្តាលបន្ត (អនុវត្តអនុសាសន៍ក្នុងរបាយការណ៍នៃការពិនិត្យបច្ចេកវិទ្យាឆ្មបនិងផែនការយុទ្ធសាស្ត្រធនធានមនុស្សសុខាភិបាល២០០៦-០១៥)។

ធមស.១.៦ អភិវឌ្ឍកម្មវិធីអាហារូបករណ៍ដើម្បីជួយដល់ការចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលមុនពេលបំរើការងារ និងក្នុងពេលបំរើការងារនៅតាមមូលដ្ឋានក្នុងប្រទេសនិងនៅក្រៅប្រទេស ព្រមទាំងផ្តល់ពត៌មានគ្រប់ជ្រុងជ្រោយនិងទាន់ហេតុការណ៍ស្តីពីអាហារូបករណ៍ និងឱកាសទទួលអាហារូបករណ៍ដល់បុគ្គលិកសុខាភិបាលនៅក្នុងគេហទំព័រក្រសួងសុខាភិបាល www.moh.gov.kh ។

## ធមស.២ ពង្រឹងក្របខណ្ឌវិជ្ជាជីវៈ ក្រមសីលធម៌ និងគុណភាពការងារ

ធមស.២.១ លើកទឹកចិត្តដល់អង្គភាពស្វយ័តនិយតកម្មសំរាប់វិជ្ជាជីវៈពេទ្យ ដូចជា គណៈគ្រូពេទ្យ គណៈទន្តពេទ្យ គណៈឆ្មប...។ល។ សមាគមវិជ្ជាជីវៈដទៃទៀត។

ធមស.២.២ អភិវឌ្ឍនិងអនុវត្តប្រពន្ធ័ទទួលស្គាល់វិជ្ជាជីវៈនិងផ្តល់អជ្ញាបណ្ណ័ ដល់ធនធានមនុស្សសុខាភិបាលទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។

ធមស.២.៣ អភិវឌ្ឍនិងពង្រឹងការអនុវត្តន៍ លក្ខន្តិកៈមន្ត្រីរាជការសុខាភិបាលក្នុងវិស័យសាធារណៈ ដោយសហការជាមួយគណៈវិជ្ជាជីវៈនិងសមាគមវិជ្ជាជីវៈដទៃទៀត។

## ធមស.៣ បែងចែកនិងការរក្សាទុកបុគ្គលិក ដោយផ្តល់អាទិភាពដល់បុគ្គលិកដែលចាំបាច់សំរាប់អាទិភាពវិស័យសុខាភិបាល

ធមស.៣.១ តំរៀបតំរង់ផែនការនីយកម្មធនធានមនុស្ស និងការគ្រប់គ្រងបុគ្គលិកឱយស្របតាមផែនការនីយកម្មវិស័យសុខាភិបាល និងផែនការគ្របដណ្តប់សុខាភិបាល ។

ធមស.៣.២ អភិវឌ្ឍនិងអនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រងធនធានមនុស្សដើម្បីពង្រាយបុគ្គលិកទៅកាន់ទីកន្លែងដែលខ្វះខាត តាមរយៈកិច្ចសន្យា។

ធមស.៣.៣ បង្កើនចំនួនឆ្មបដែលត្រូវដាក់ និងរក្សាទុកនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈតាមរយៈការអនុវត្តន៍មានប្រសិទ្ធភាពនូវគោលនយោបាយស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភដល់ឆ្មបរបស់រដ្ឋាភិបាល និងការអនុវត្តន៍អនុសាសន៍នៃរបាយការណ៍ពិនិត្យបច្ចេកវិទ្យាឆ្មបនិងផែនការយុទ្ធសាស្រ្តធនធានមនុស្សសុខាភិបាល២០០៦-២០១៥។

## ធមស.៤ ប្រព័ន្ធលាភការ បៀវត្ស និងការលើកទឹកចិត្តតាមស្នាដៃការងារ

**ធមស.៤.១** បន្តការលើកកំពស់ប្រព័ន្ធលាភការនិងបៀវត្ស តាមរយៈកំណែទំរង់រដ្ឋបាលសាធារណៈសំរាប់មន្ត្រីរាជការស៊ីវិលរបស់រាជរដ្ឋាភិបាលកម្ពុជា។

**ធមស.៤.២** លើកកំពស់ការគ្រប់គ្រងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម នៅតាមមូលដ្ឋានសុខាភិបាលមានប្រភពពីការបង់ថ្លៃសេវា មូលនិធិសមធម៌ថវិកា កញ្ចប់សំរាប់ការផ្តល់សេវាប្រចាំត្រីមាស កិច្ចសន្យាផ្តល់សេវា ទីភ្នាក់ងារប្រតិបត្តិការពិសេសការធានារ៉ាប់រងសុខភាពតាម សហគមន៍និង ពីប្រភពផ្សេងទៀត។

**ធមស.៤.៣** ពង្រីកការអនុវត្តន៍កម្មវិធី **"កន្សោមអាទិភាព"** និងយន្តការលើកទឹកចិត្តនានាដែលស្របតាមកម្មវិធីកន្សោមអាទិភាពព្រមទាំងអនុវត្តវិធីសាស្ត្រផ្តល់គ្រឿងលើកទឹកចិត្តដទៃទៀតដល់ "បុគ្គលិកផ្នែកទ្រទ្រង់"។

# ៤.៤ យុទ្ធសាស្ត្រប្រព័ន្ធព័ត៌មានសុខាភិបាល (បពស)

យុទ្ធសាស្ត្រប្រព័ន្ធព័ត៌មានសុខាភិបាល ប្រមូលផ្តុំលើការផ្តល់ព័ត៌មានសុខាភិបាលដែលពាក់ពន្ធ័មានគុណភាពខ្ពស់ និងទាន់ពេលវេលា សំរាប់ជាមូលដ្ឋានជាក់ស្តែងដល់ការដាក់ចេញគោលនយោបាយ ការធ្វើសេចក្តីសំរេចចិត្ត ការអនុវត្តន៍កម្មវិធី ការត្រួតពិនិត្យតាមដានស្នាដៃការងារ និងការវាយតំលៃ ដែលនឹងរួមចំណែកឆ្ពោះទៅរកការលើកកំពស់ស្ថានភាពសុខភាពប្រជាជនកម្ពុជាឱយកាន់តែប្រសើរឡើង។

នៅដំណាច់ឆ្នាំ២០១៥ ប្រព័ន្ធព័ត៌មានសុខាភិបាលជាតិនឹងប្រតិបត្តិតាមបទដ្ឋានស្តង់ដារអន្តរជាតិ មានការទទួលស្គាល់និងការគាំទ្រពីសាធារណៈជន អ្នកប្រើប្រាស់និងអ្នកតាក់តែងគោលនយោបាយ ប្រព័ន្ធព័ត៌មានសុខាភិបាលនឹងផ្តល់ទិន្នន័យដែលមានគុណភាព សំរាប់ការធ្វើសេចក្តីសំរេចចិត្តដោយប្រើប្រាស់មធ្យោបាយទំនាក់ទំនង និងបច្ចេកវិទ្យាព័ត៌មាន ហើយធ្វើឱយព័ត៌មានមានគុណភាពស្តីពីប្រជាសាស្ត្រ–សង្គម សេដ្ឋកិច្ច ឈឺ មរណៈភាពនិងកត្តាគ្រោះថ្នាក់។ ជាមួយគ្នានឹងកែលំអការសំរបសំរួលដល់ការធ្វើផែនការនិងការអនុវត្តន៍អង្កេត។ លើកកំពស់គុណភាព កំណត់ហេតុវេជ្ជសាស្ត្រសំរាប់អ្នកជំងឺ ដើម្បីកែលំអការគ្រប់គ្រងករណីជំងឺ។ ទិន្នន័យតាមដានជំងឺនិងកាន់តែពេញលេញនិងទាន់ពេលវេលា ដើម្បីឆ្លើយតបមានប្រសិទ្ធភាពទៅនឹងការផ្ទុះឡើងនៃជំងឺនិងគ្រួតគ្រាជំងឺ។ ការគ្របដណ្តប់គ្រប់ជ្រុងជ្រោយនឹងអាចសំរេចបានជាមួយនឹងការកែលំអការគ្រប់គ្រងតាមព័ត៌មានវិទ្យាលើហេដ្ឋារចនាសម្ពន្ធ័ ធនធានមនុស្សនិងភស្តុភារ។

## ក. បញ្ហាប្រឈមមុខ

ក្នុងប្រទេសកម្ពុជាខណៈពេលដែលប្រពន្ធ័ព័ត៌មានសុខាភិបាលកំពុងដំណើរការមុខងារជាប្រចាំ លាតសន្ធឹងពីមូលដ្ឋានសុខាភិបាលថ្នាក់ក្រោមបំផុតទៅស្រុកប្រតិបត្តិនិងពីថ្នាក់ខេត្ត-ក្រុងដល់ថ្នាក់កណ្តាល បញ្ហាប្រឈមមុខមួយចំនួនត្រូវបានកំណត់អត្តសញ្ញាណដូចខាងក្រោមនេះ:

- ព័ត៌មានពីវិស័យឯកជនភាគច្រើនលើសលប់មិនត្រូវបានរាប់បញ្ចូល ដូច្នេះព័ត៌មានទាក់ទងតែនឹងមូលដ្ឋានសុខាភិបាលសាធារណៈនិងមន្ទីរពេទ្យថ្នាក់ជាតិ។ ដោយសារតែការប្រើប្រាស់សេវាសាធារណៈមានប្រហែលជាភាគបួននៃការប្រើប្រាស់សេវាសរុបធ្វើឱយទិន្នន័យប្រពន្ធ័ព័ត៌មានមិនអាចយកទៅប្រើប្រាស់បានសំរាប់ការត្រួតពិនិត្យតាមដានស្ថានភាពសុខភាពទូទាំងប្រទេស។
- នៅពេលដែលការសិក្សាមួយចំនួនមិនអាចបង្ហាញបានពីលំនាំមានលក្ខណៈជាប្រពន្ធ័នៃភាពមិនត្រឹមត្រូវនៃទិន្នន័យការពិនិត្យផ្ទៀងផ្ទាត់មើលភាពត្រឹមត្រូវទិន្នន័យបង្ហាញថាភាពមិនត្រឹមត្រូវនៃទិន្នន័យមានជាទូទៅ។
- ថ្វីបើមានការខិតខំប្រឹងប្រែងដើម្បីលើកកំពស់ការប្រើប្រាស់ទិន្នន័យនៅក្នុងការធ្វើផែនការ និងការត្រួតពិនិត្យតាមដានក៏ដោយ ក៏ការប្រើប្រាស់នេះនៅមានកំរិតនៅគ្រប់ថ្នាក់ក្នុងប្រពន្ធ័។
- កង្វះការសំរបសំរួល និងសហការក្នុងចំណោមអ្នកផ្តល់ព័ត៌មាន ទាំងក្នុងនិងក្រៅប្រពន្ធ័សុខាភិបាល។ ទាំងអស់នេះតំរូវឱយមានការអង្កេតសុខភាពជាតិឬការអង្កេតជាតិដោយមានបញ្ចូលម៉ូឌុលសុខភាព ហើយដែលបានធ្វើឡើងទៀងៗគ្នា ដើម្បីផ្តល់ព័ត៌មានពេញលេញសំរាប់ការវិភាគនិន្នាការសុខភាព។
- នៅពេលដែលប្រពន្ធ័តាមដានជំងឺ១២មុខ មានប្រសិទ្ធិភាពដំណើរការ ការរាយការណ៍អំពីករណីជំងឺ និងការត្រួតពិនិត្យតាមដានជំងឺមិនឆ្លងសំខាន់ៗនៅមានភាពខ្សោយ។ប្រពន្ធ័ចុះបញ្ជីកាស៊ីវិលនៅខ្សោយ ហើយការរាយការណ៍អំពីមូលហេតុនៃការស្លាប់នៅមិនទាន់មាន។
- បុគ្គលិកទទួលបន្ទុកការងារប្រពន្ធ័ព័ត៌មាននៅថ្នាក់មូលដ្ឋានមានចំណេះដឹងនិងជំនាញកំរិតទាប និងកង្វះការលើកទឹកចិត្ត។ កង្វះ"ផ្នែករឹង"(hardware) និង "ផ្នែកទន់" (software)នៃបច្ចេកវិទ្យាព័ត៌មាននិងការប្រាស្រយ័ទាក់ទង (ITC) ដើម្បីគ្រប់គ្រងទិន្នន័យមានប្រសិទ្ធភាព និងរៀបចំការវិភាគទិន្នន័យជាមូលដ្ឋាន។

ក្នុងអំលុងពេលនៃផែនការ គំនិតផ្តួចផ្តើមមួយចំនួននឹងត្រូវបានដាក់ចេញដើម្បីពង្រឹងប្រពន្ធ័ព័ត៌មានសុខាភិបាលជាតិក្នុងនោះមាននិតិក្រមថ្មី ដើម្បីបញ្ចូលរបាយការណ៍ពីវិស័យឯកជនពង្រីកការប្រើប្រាស់ ITC នៅគ្រប់ថ្នាក់ពង្រឹងការអភិបាលបណ្តុះបណ្តាលបុគ្គលិក និងមន្ត្រីទទួលបន្ទុកប្រពន្ធ័ព័ត៌មានស្តីអំពីការប្រើប្រាស់ និងការតស៊ូមតិ ដើម្បីបង្កើនការវិភាជន៍ថវិកាសំរាប់ប្រពន្ធ័ព័ត៌មានពិសេសនៅថ្នាក់ខេត្ត-ក្រុងនិងស្រុកប្រតិបត្តិ ព្រមទាំងបញ្ចូលរបាយការណ៍ស្តីពីជំងឺមិនឆ្លង

ចាប់ពីមូលដ្ឋានសុខាភិបាលឡើងទៅ។ កាលានុវត្តភាពតែមួយគត់សំរាប់ពង្រឹងប្រពន្ធ័ពត៌មាន គឺការអនុវត្តន៍ផែនការយុទ្ធសាស្រ្តប្រពន្ធ័ពត៌មានសុខាភិបាល២០០៨-២០១៥ ដែលបានរៀបចំឡើងតាមរយៈកិច្ចសហការអន្តរវិស័យ ហើយដែលបានកំណត់អន្តរាគមន៍ និងសកម្មភាពជាយុទ្ធសាស្រ្តដើម្បីដោះស្រាយបញ្ហាប្រឈមមុខទាំងអស់ខាងលើ។ ដើម្បីធានាឱយមានកិច្ចសហការដោយប្រសិទ្ធភាពក្នុងចំណោមដៃគូទាំងអស់ ក្រុមការងារដៃគូក្នុងប្រពន្ធ័ពត៌មានសុខាភិបាលដែលបានបង្កើតឡើងនិងបន្តប្រជុំ ដើម្បីត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តន៍ផែនការយុទ្ធសាស្រ្តប្រពន្ធ័ពត៌មានសុខាភិបាល នៅក្នុងក្របខណ្ឌ័រួមនៃត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តន៍ ផ.យ.ស.២ ។

## ៩.សមាសធាតុនិងអន្តរាគមន៍ជាយុទ្ធសាស្ត្រ

**បពស.១ បង្កើនភាពត្រឹមត្រូវ ទាន់ពេលវេលានិងពេញលេញនៃទិន្នន័យដែលមានគុណភាពខ្ពស់ពីផ្នែក រដ្ឋនិងឯកជនជាមួយនឹងការលើកកំពស់ការសំរបសំរួលនិងធនធានសំរាប់ប្រព័ន្ធពត៌មានសុខាភិបាល**

**បពស.១.១** ពិនិត្យឡើងវិញនិងពង្រឹងនិតិក្រមបទបញ្ញត្តិនិងនីតិវិធីរដ្ឋបាលដែលទាក់ទងនឹងការកត់ត្រា ការរាយការណ៍ ការរក្សាទុក ការបញ្ជូននិង ការចែកចាយទិន្នន័យសុខាភិបាលដោយគ្របដណ្តប់ទាំងវិស័យសាធារណៈ និងឯកជន។

**បពស.១.២** ពង្រឹងការអភិបាលប្រព័ន្ធពត៌មានសុខាភិបាលនិងការផ្តល់យោបល់ត្រឡប់ដោយផ្តោតលើគុណភាពទិន្នន័យ និងការប្រកាន់ភ្ជាប់ទៅតាមបទដ្ឋាននៃស្នាដៃការងារ ។

**បពស.១.៣** ផ្តល់គ្រឿងលើកទឹកចិត្តនិងផលប្រយោជន៍ដែលផ្សារភ្ជាប់នឹងស្នាដៃការងាររបស់បុគ្គលិកពាក់ពន្ធ័នឹងប្រព័ន្ធពត៌មានសុខាភិបាល នៅគ្រប់កំរិតថ្នាក់ទាំងអស់។

**បពស.១.៤** ពង្រឹងសមត្ថភាពបុគ្គលិកដែលពាក់ព័ន្ធក្នុងប្រព័ន្ធពត៌មានសុខាភិបាលតាមរយៈកម្មវិធីបណ្តុះបណ្តាលក្នុងពេលបំរើការងារនិងបណ្តុះបណ្តាលបន្ត។

**បពស.២ លើកកំពស់ការចែករំលែក ការគ្រប់គ្រង ការវិភាគ ការផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យនៅគ្រប់ថ្នាក់នៃប្រព័ន្ធសុខាភិបាល រួមទាំងទិន្នន័យប្រជាជននិងទិន្នន័យប្រជាសាស្ត្រ-សង្គម**

**បពស.២.១** អភិវឌ្ឍ ថែរក្សានិងប្រើប្រាស់ប្រព័ន្ធ ITC សំរាប់ការគ្រប់គ្រងទិន្នន័យសុខាភិបាល និងការប្រាស័យទាក់ទង (វចនានុក្រមទិន្នន័យនិងឃ្លាំងទិន្នន័យអន្តរទំនាក់ទំនង)។

| | |
|---|---|
| **បពស.២.២** | ផ្តល់ការបណ្តុះបណ្តាលស្តីពីការវិភាគនិងប្រើប្រាស់ទិន្នន័យដោយបញ្ចូលទាំងទិន្នន័យជំរឿន សំរាប់ការធ្វើផែនការនិងការត្រួតពិនិត្យតាមដានដល់អ្នកគ្រប់គ្រងសេវា និងបុគ្គលិកជំរឿនសំខាន់ៗនៅគ្រប់ដំណាក់កាលទាំងអស់នៃការគ្រប់គ្រងជំរឿន ក្នុងភាពជាដៃគូជាមួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ។ |

## បពស.៣ លើកកំពស់ប្រព័ន្ធតាមដានជំងឺថ្នាក់ជាតិ ប្រព័ន្ធកត់ត្រាប្រវត្តិវេជ្ជសាស្ត្ររបស់អ្នកជំងឺនៅមូលដ្ឋានសុខាភិបាលរដ្ឋនិងពង្រឹងករណីរាយការណ៍ជំងឺ ការត្រួតពិនិត្យតាមដាននិងការឆ្លើយតបទៅនឹងជំងឺមិនឆ្លង

| | |
|---|---|
| **បពស.៣.១** | ពង្រឹងប្រពន្ធ័តាមដានជំងឺនិងនីតិវិធីនៅគ្រប់ថ្នាក់រួមទាំងសហគមន៍ រាប់បញ្ចូលទាំងការធ្វើបច្ចុប្បន្នភាពបញ្ជីនៃជំងឺ ដែលត្រូវរាយការណ៍ ការកំណត់និយមន័យករណីជំងឺ ការផ្តល់ពត៌មានជាលាយលក្ខណ៍អក្សរការបញ្ជាក់អះអាងដោយមន្ទីរពិសោធន៍ និងនិតិវិធីនៃការឆ្លើយតប ការរៀបចំផែនទីភូមិសាស្ត្រ អំពីប្រជាជនដែលប្រឈមមុខនឹងគ្រោះថ្នាក់ការចែករំលែកនិងការបោះពុម្ពផ្សាយទិន្នន័យ (តំរូវអនុវត្តទាំងក្នុងវិសយ័សាធារណៈនិងឯកជន) ។ |
| **បពស.៣.២** | អភិវឌ្ឍប្រពន្ធ័រាយការណ៍អំពីជំងឺមិនឆ្លង ក្នុងប្រព័ន្ធតាមដានជំងឺទូទៅនិងប្រពន្ធ័រាយការណ៍ករណីជំងឺនិងការប្រពន្ធ័ឆ្លើយតប ដោយរាប់បញ្ចូលគ្រោះថ្នាក់និងរបួស (តំរូវអនុវត្តទាំងក្នុងវិសយ័សាធារណៈនិងឯកជន) ។ |
| **បពស.៣.៣** | ពិនិត្យកែសំរួល និងពង្រឹងការគ្រប់គ្រងកំណត់ហេតុអ្នកជំងឺ (កំណត់ហេតុវេជ្ជសាស្ត្រការរក្សាទុកនិងការបញ្ចេញប្រើប្រាស់) តាមមូលដ្ឋានសុខាភិបាលរដ្ឋទាំងអស់ រួមទាំងការដាក់លេខកូដតាមចំណាត់អន្តរជាតិនៃជំងឺ |

## បពស.៤ ពង្រីកការចូលរួមរបស់វិសយ័ឯកជននៅក្នុងប្រព័ន្ធពត៌មានសុខាភិបាលជាតិ និងសំរួលការប្រើប្រាស់ ទិន្នន័យសំរាប់ការធ្វើផែនការ ការបែងចែកធនធានការគ្រប់គ្រងធនធានមនុស្ស ហេដ្ឋារចនា សម្ព័ន្ធនិងការផ្គត់ផ្គង់

| | |
|---|---|
| **បពស.៤.១** | ពង្រីកទូលាយការចូលរួមរបស់អ្នកផ្តល់សេវាឯកជន នៅក្នុងប្រព័ន្ធពត៌មានសុខាភិបាលជាតិ រួមទាំងប្រព័ន្ធតាមដានជំងឺ តាមរយៈបញ្ជីសារពើភណ្ឌ័អ្នកផ្តល់សេវាឯកជន ពន្យល់និងផ្តល់ពត៌មានដល់ពួកអំពីច្បាប់ព្រមទាំងផ្តល់ទំរង់បទដ្ឋាន (ស្តង់ដារ) ចាំបាច់នានារួមទាំងការកែតំរូវ“ផ្នែកទន់”នៃប្រពន្ធ័គ្រប់គ្រងពត៌មានសុខាភិបាល(HMISsoftware). |

បពស.៤.២ ពង្រឹងប្រព័ន្ធគាំទ្រដល់ការគ្រប់គ្រងធនធានមនុស្សមូលដ្ឋានសុខាភិបាល និងការគ្រប់គ្រងឱសថតាមរយៈការពិនិត្យវាយតំលៃការអភិវឌ្ឍន៍និតិវិធីនានា រួមមានការអភិវឌ្ឍន៍ប្រព័ន្ធទិន្នន័យពត៌មានវិទ្យា(database) និងការបណ្តុះបណ្តាល។

## ៤.៥ យុទ្ធសាស្ត្រអភិបាលកិច្ចប្រព័ន្ធសុខាភិបាល

នៅដំណាច់ឆ្នាំ២០១៥ ជោគជ័យនៃការអនុវត្តន៍យុទ្ធសាស្ត្រនេះនឹងផ្តល់អត្ថប្រយោជន៍ដល់គ្រប់ទិដ្ឋភាពក្នុងវិស័យសុខាភិបាល តាមរយៈបង្កើនតម្លាភាព និងការសំរបសំរួលនៃការផ្តល់មូលនិធិ ធនធានសម្ពន្ធ័ ការគ្រប់គ្រង និងការទទួលខុសត្រូវ។ ការផ្តល់សេវាតាមបែបវិមជ្ឈការនិងវិសហមជ្ឈការ នឹងទទួលបានការគាំទ្រពីមគ្គុទេសភាពដ៏រឹងមាំនិងការណែនាំរបស់រដ្ឋាភិបាលស្តីអំពីគោលនយោបាយសុខាភិបាលនិតិបញ្ញតិនិងការត្រួតពិនិត្យតាមដាន។ អតិថិជននិងមានជំរើសរវាងសេវារដ្ឋ និងឯកជនស្ថិតក្រោមនិយតកម្មដែលនឹងទទួលខុសត្រូវដោយផ្ទាល់ចំពោះពួកគេនិងសហគមន៍របស់ខ្លួន។

យុទ្ធសាស្ត្រអភិបាលកិច្ចប្រពន្ធ័សុខភិបាលផ្តោតលើ តួនាទីនិងមុខងារនៃប្រពន្ធ័សុខាភិបាលដែលមានតែក្រសួងសុខាភិបាលតែមួយប៉ុណ្ណោះអាចប្រតិបត្តិបាន។ សំខាន់ជាងគេនោះ គឺតួនាទីមគ្គុទេសក៍ភាពដល់វិស័យសុខាភិបាលទាំងមូល។យុទ្ធសាស្ត្រនេះនឹងពង្រឹងលទ្ធភាពក្រសួងសុខាភិបាល ដើម្បីដឹកនាំលើគ្រប់សកម្មភាពទាំងអស់ក្នុងវិស័យសុខាភិបាលនិងពង្រឹងផែនការនីយកម្មយន្តការទទួលខុសត្រូវនិងការសំរបសំរួលមានប្រសិទ្ធភាព សំរាប់ការផ្សារភ្ជាប់កាន់តែល្អប្រសើរឡើងរវាងធនធានទៅនឹងលទ្ធផលសុខភាពល្អ។

ត្រូវការចាំបាច់នូវការចូលរួមទូទាំងវិស័យនិងអភិក្រមគំនិតផ្តួចផ្តើមថ្មីៗ ដើម្បីបំផុសការចូលរួមពីសហគមន៍នៅក្នុងបរិបទដែលចេះតែវិវត្តន៍នៃវិមជ្ឈការ និងសហវិមជ្ឈការ។ ការសន្ទនាយ៉ាងសកម្មប្រកបដោយនយ័ស្ថាបនាជាមួយវិស័យឯកជន ត្រូវបានមើលឃើញទុកជាមុនសំរាប់ការបំពេញបន្ថែមដល់ការពង្រីកកិច្ចសន្យា និងការបង្កើនស្វយ័តភាពស្ថាប័ននៅក្រសួងសុខាភិបាលតាមរយៈការអនុវត្តន៍ទីភ្នាក់ងារប្រតិបត្តិការពិសេស និងយន្តការដទៃទៀតដែលបានលើកឡើងនៅក្នុងគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល។

### ក. បញ្ហាប្រឈមមុខ

ខណៈដែលយុទ្ធសាស្ត្រនៃការផ្តល់សេវាផ្តោតលើលទ្ធផលកំពូលនៃវិស័យសុខាភិបាលយុទ្ធសាស្ត្រអភិបាលប្រពន្ធ័សុខាភិបាលផ្តោតលើមុខងារនានាដែលមានតែក្រសួងសុខាភិបាលជាអ្នកអនុវត្ត កង្វះមុខងារនេះវិស័យសុខាភិបាលមិនអាចមានលទ្ធភាពផ្តល់សេវាបាន។ ក្នុងអំលុងពេលនៃដំណាក់កាលពង្រឹងនៃ

ផ.យ.ស.២ ក្រសួងសុខាភិបាលនឹងត្រូវការចាំបាច់ក្នុងកំណត់អត្តសញ្ញាណនិងការពង្រឹងមុខងារស្នូលរបស់ខ្លួននៅក្នុងបរិបទដែលវិស័យសុខាភិបាលមានលក្ខណៈកាន់តែស្មុគ្រស្មាញ និងសំបូរបែប ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមឆាប់រហ័ស និងកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការទូលំទូលាយរបស់រដ្ឋាភិបាល។ បញ្ហាប្រឈមមុខសំខាន់ៗរួមមាន:

- ការរួមចំណែកនៃវិស័យឯកជនក្នុងវិស័យសុខាភិបាលកំពុងលូតលាស់យ៉ាងខ្លាំងប៉ុន្តែវិធាននិយតកម្មនៅទន់ខ្សោយ។
- ការបន្តអភិវឌ្ឍន៍ស្ថាប័នគឺត្រូវការចាំបាច់ពិសេស:
  - តំរៀបតំរង់លំហូរហិរញ្ញវត្ថុ ជាមួយនឹងសិទ្ធអំណាចនៃការគ្រប់គ្រង និងការទទួលខុសត្រូវលើលទ្ធផល
  - ពង្រឹងការគ្រប់គ្រងថវិកា ពិសេសនៅថ្នាក់ខេត្ត-ក្រុងនិងស្រុកប្រតិបត្តិ
  - ង្កើនស្វយ័តភាពនៃការគ្រប់គ្រងដល់អង្គភាពណាវីងមាំនៅពេលធានាឱយមានការទទួលខុសត្រូវ
  - រក្សាទុកកម្មវិធីនិងមជ្ឈមណ្ឌលជាតិដែលមានគុណភាពការងារខ្ពស់ និងផ្តល់ប្រពន្ធ័គាំទ្រក្នុងពេលជាមួយគ្នានិងការការពារទល់ការផ្លាស់ប្តូរការផ្តល់មូលនិធិពីក្រៅប្រទេសសំរាប់អាទិភាព
- ផលប៉ះទង្គិចជាសក្តានុពលនៃវិមជ្ឈការ និងវិសហមជ្ឈការ មកលើវិស័យសុខាភិបាលនៅមិនទាន់អាចដឹងបាន។ ក្រសួងសុខាភិបាលនឹងចាំបាច់ធានាថា បែបបទនៃកំណែទំរង់នេះនឹងត្រូវយកមកអនុវត្តក្នុងវិស័យសុខាភិបាល តាមលក្ខណៈដែលបង្កើនទុនចូលពីសហគមន៍និងស្វយ័តភាពនៃការគ្រប់គ្រងក្នុងពេលជាមួយគ្នាដោយធានាឱយមានការទទួលខុសត្រូវនិងស្នាដៃការងារនៅថ្នាក់ប្រតិបត្តិ។ ដូច្នេះកត្តាកំណត់ផ្នែកបច្ចេកទេសនិងសេដ្ឋកិច្ចសំរាប់ការបែងចែកមូលដ្ឋានសុខាភិបាល តាមរយៈផែនការគ្របដណ្តប់សុខាភិបាលចាំបាច់ត្រូវបំពេញបន្ថែមដោយ ការតំរៀបតំរង់យ៉ាងជិតស្និតទៅនឹងខ្សែរយៈរដ្ឋបាលនៃរដ្ឋអំណាច។ ទន្ទឹមគ្នានេះ ក្រសួងសុខាភិបាលត្រូវការរក្សានិងពង្រឹងតួនាទីឃ្លាំមើលនិងណែនាំនៅទីស្តីការក្រសួងសុខាភិបាល។
- បញ្ហាប្រឈមមុខផ្នែកសុខភាពដ៏ចំបងនោះនៅក្នុងបណ្តាឆ្នាំខាងមុខ គឺបញ្ហាប្រទាក់ក្រឡាដែលស្ថិតក្រៅអណត្តិផ្លូវការរបស់ក្រសួងសុខាភិបាល។ បញ្ហាទាំងអស់នោះគឺសុវត្ថិភាពចរាចរ អំពើហឹង្សាក្នុងគ្រួសារ ទឹកស្អាត អនាមយ័ ការអប់រំ ការប្រើប្រាស់គ្រឿងញៀន និងកង្វល់ផ្នែកសុខភាពបណ្តាលមកពីបញ្ហាបរិដ្ឋាន។

បច្ចុប្បន្ននេះ ស្ថាបត្យកម្មជំនួយមានចរិតលក្ខណៈដូចតទៅ:

- ការផ្តល់មូលនិធិមានសភាពបែកខ្ញែកពីដៃគូពហុភាគីនិងទ្វេភាគី និងចំនួនដ៏ច្រើននៃដៃគូជាតិ និងអន្តរជាតិដែលធ្វើសកម្មភាពយ៉ាងច្រើនអនេក ក្នុងការឧបត្ថម្ភគាំទ្រដល់ការអភិវឌ្ឍន៍វិស័យសុខាភិបាល។

- ភាគច្រើននៃប្រតិបត្តិការជំនួយ គឺតាមរបៀបជាគំរោង ហើយដៃគូក្រៅប្រទេសពឹងផ្អែកស្ទើរទាំងស្រុងលើនិតិវិធីនិងប្រព័ន្ធគ្រប់គ្រងរបស់ខ្លួនផ្ទាល់ ដែលហេតុនាំឱ្យមានការបែកខ្ញែកយ៉ាងខ្លាំងនៅក្នុងវិស័យ។
- ការយកចិត្តទុកដាក់យ៉ាងខ្លាំងតែទៅលើកម្មវិធីប្រយុទ្ធនឹងជំងឺឆ្លងនៃប្រភពមូលនិធិក្រៅប្រទេស បាននាំឱ្យមានអតុល្យភាព ក្នុងការចំណាយជាអាទិភាពដែលងាកចេញពីការចំណាយលើអាទិភាពជាតិផ្នែកសុខភាព។

## ៩. សមាសធាតុនិងអន្តរាគមន៍ជាយុទ្ធសាស្ត្រ

### អបស.១ សុខដុមនីយកម្មនិងការតំរៀបតំរង់នៅក្រសួងសុខាភិបាលនិងទូទាំងវិស័យ

**អបស.១.១** អភិវឌ្ឍកិច្ចព្រមព្រៀងសំរាប់ភាពជាដៃគូ ដោយរាប់បញ្ចូលទាំងជំនួយបច្ចេកទេសនិងមូលនិធិក្នុងការគាំទ្រដល់ការអនុវត្តន៍ផ.យ.ស.២ ព្រមទាំងសមាហរណកម្មគំនិតផ្តួចផ្តើមផ្នែកសុខភាពលំដាប់ពិភពលោក ទៅក្នុងបែបបទនៃការសំរបសំរួលនិងភាពជាដៃគូដែលមានស្រាប់នៅកម្ពុជា ដើម្បីបន្ថយការចំណាយអន្តរសកម្មភាព និងចៀសវាងការរមូលនៃកម្មវិធីអាទិភាព។

**អបស.១.២** ធានាអោយមាន "**ការជាវយក**" (buy-in) និងការគោរពតាមបែបបទនិង ឧបករណ៍រួមសំរាប់មគ្គុទេសភាពរបស់ក្រសួងសុខាភិបាលពីសំណាក់ដៃគូជាតិនិងអន្តរជាតិ តាមរយៈការពិគ្រោះយោបល់អន្តរវិស័យតាមកាលវិភាគទៀងទាត់ (ក្រុមការងារបច្ចេកទេសសុខាភិបាល និងក្រុមការងារបច្ចេកទេសសុខាភិបាលខេត្ត-ក្រុង ។ល។)

**អបស.១.៣** ពង្រឹងផែនការរំកិល៣ឆ្នាំ ដែលជាបែបបទផែនការនីយកម្មរយៈពេលមធ្យម ដើម្បីតំរៀបតំរង់ និងកំណត់អត្តសញ្ញាណជំនួយរបស់ដៃគូនិងជាមូលដ្ឋាន សំរាប់ផែនការថវិកាយុទ្ធសាស្ត្រនិងជាផែនការវិនិយោគជាអាទិភាពគ្រប់ជ្រុងជ្រោយតែមួយសំរាប់វិស័យសុខាភិបាល។

**អបស.១.៤** តំរៀបតំរង់លំហូរមូលនិធិជំនួយទៅក្នុងវិស័យសុខាភិបាល ដោយកំណត់យក ថវិកាទុកដោយឡែកសំរាប់គាំទ្រវិស័យសុខាភិបាលតាមរបៀបផ្គុំថវិកាមួយចំណែកដែលបាននឹងកំពុងតែអនុវត្ត និងក្រៅបណ្តុំថវិកាដោយគោរពតាមអាទិភាពដែលបានកំណត់ដោយ ផ.យ.ស.២ និងការព្រមព្រៀងគ្នាអំពីទីតាំងរួមសំរាប់ប្រព័ន្ធគ្រប់គ្រងផ្សេងៗគ្នា។

**អបស.១.៥** តំរៀបតំរង់ក្នុងកំរិតអតិបរមានៃយន្តការត្រួតពិនិត្យតាមដាននិងការវាយតំលៃរបស់ដៃគូទៅនឹងក្របខណ្ឌរួមនៃការត្រួតពិនិត្យតាមដាន និងការវាយតំលៃ(ទាំងក្របខណ្ឌសូចនាករ) របស់ផ.យ.ស.២ នោះគឺការពិនិត្យឡើងវិញរួមគ្នាសមិទ្ធផលសុខាភិបាលប្រចាំឆ្នាំដែលជាព្រឹត្តិការណ៍ស្នូល សំរាប់ការសន្ទនា និងការសំរបសំរួលអំពីគោលនយោបាយជាមួយដៃគូក្រៅប្រទេសនិងជាផ្នែកមួយនៃ**ផែនការសកម្មភាពសុខដុមនីយកម្មនិងការតំរៀបតំរង់ដើម្បីលទ្ធផល**ដោយមានកំរិតតម្លាភាពខ្ពស់ដើម្បីឱយដៃគូក្រៅប្រទេសកាត់បន្ថយទំរង់ត្រួតពិនិត្យតាមដានផ្ទាល់ខ្លួន ។

**អបស.១.៦** ពង្រឹងអង្គភាពលទ្ធកម្មសាធារណៈ ទៅតាមនីតិវិធីរបស់រដ្ឋ និងពង្រឹងប្រពន្ធ័ផ្គត់ផ្គង់ ដើម្បីឱយមានឱសថនិងបរិក្ខារពេទ្យគ្រប់គ្រាន់ និងផ្តល់ទាន់ពេលវេលាដល់មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក ។

## អបស.២ ភាពជាដៃគូរវាងរដ្ឋនិងឯកជន

**អបស.២.១** ប្រើប្រាស់កិច្ចសន្យានិងក្របខណ្ឌទីភ្នាក់ងារប្រតិបត្តិការពិសេសនៃគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ រួមជាមួយក្របខណ្ឌត្រួតពិនិត្យតាមដានផែនការប្រតិបត្តិប្រចាំឆ្នាំធ្វើមូលដ្ឋាននៃកិច្ចសន្យា របស់ក្រសួងសុខាភិបាលជាមួយអង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់សេវាឯកជន ដែលត្រូវបានទទួលស្គាល់គុណភាពឱយផ្តល់សេវា ។

**អបស.២.២** អភិវឌ្ឍនិងអនុវត្តប្រព័ន្ធទទួលស្គាល់គុណភាព ដល់អ្នកផ្តល់សេវាឯកជននិងការដាក់បញ្ចូលអ្នកផ្តល់សេវាឯកជន ដែលត្រូវបានទទួលស្គាល់គុណភាពទៅក្នុងផែនការគ្របដណ្តប់សុខាភិបាល ។

**អបស.២.៣** ពង្រឹងការធ្វើផែនការរវាងវិស័យសាធារណៈ និងឯកជននិងការសំរបសំរួលលើប្រពន្ធ័ពត៌មានសុខាភិបាល របាយការណ៍តាមដានជំងឺនិងការផ្តល់យោបល់ត្រលប់តាមរយៈការចូលរួមយ៉ាងសកម្មរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្ត-ក្រុង មន្ទីរសុខាភិបាលខេត្ត–ក្រុង ស្រុកប្រតិបត្តិនិងវិស័យឯកជន ដោយប្រើប្រាស់បទពិសោធន៍ជោគជ័យនៃភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជនរបស់កម្មវិធីជាតិ ។

**អបស.២.៤** សហការជាមួយក្រសួង/ស្ថាបន័ពាក់ពន្ធ័និងសមាគមវិជ្ជាជីវៈនានាពង្រឹងការអនុវត្តន៍ច្បាប់និងនិតិក្រមសុខាភិបាល ។

## អបស.៣ ការស្រាវជ្រាវ គោលនយោបាយ និយតកម្ម និងនិតិកម្ម

**អបស.៣.១** អភិវឌ្ឍសំណុំគោលនយោបាយផ្អែកលើភស្តុតាងគ្រប់ជ្រុងជ្រោយ និងអាចអនុវត្តបានស្របតាមច្បាប់ និយតកម្មនិងគោលនយោបាយ របស់រាជរដ្ឋាភិបាលសំរាប់ផ្នែកចំបងៗដូចជា:

- គោលនយោបាយនៃកិច្ចសន្យាផ្តល់សេវា (រួមមានទីភ្នាក់ងារប្រតិបត្តិការពិសេស កិច្ចសន្យាផ្ទៃក្នុងនិងកិច្ចសន្យាក្រៅ)
- វិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យសុខាភិបាល
- គ្រឹះស្ថានរដ្ឋបាលសាធារណៈដូចជាមន្ទីរពេទ្យ មន្ទីរពិសោធន៍ និង អង្គភាពគាំទ្រផ្សេងទៀត
- ការគាំពារសុខភាពសង្គម មូលនិធិសមធម៌ និងការធានារ៉ាប់រងសុខភាពសង្គម
- ការគ្រប់គ្រងបុគ្គលិក និងប្រពន្ធ័លាភការបុគ្គលិក រួមទាំងការលើកទឹកចិត្តតាមស្នាដៃការងារ ការផ្តល់ប្រាក់លាភការបន្ថែមផ្អែកលើស្នាដៃការងារ ការផ្តល់ប្រាក់បន្ថែមលើបៀវត្ស តាមមូលដ្ឋានសុខាភិបាលសោហ៊ុយប្រចាំថ្ងៃនិងកិច្ចសន្យាបំពេញការងារ
- លទ្ធកម្មនិងការគ្រប់គ្រងប្រពន្ធ័ផ្គត់ផ្គង់ឱសថ-បរិក្ខាពេទ្យ
- ប្រព័ន្ធគ្រប់គ្រងពត៌មានសុខាភិបាលនិងប្រពន្ធ័តាមដានជំងឺ

**អបស.៣.២** ធ្វើការវាយតំលៃគ្រប់ជ្រុងជ្រោយស្តីអំពីបន្ទុកជំងឺនៅទូទាំងប្រទេស

**អបស.៣.៣** ធានាឱយមានការគោរពតាមកាតព្វកិច្ចសុខភាពអន្តរជាតិ រួមមានក្របខណ្ឌ័អនុសញ្ញាស្តីពីគ្រប់គ្រងថ្នាំជក់ និងនិយតកម្មសុខភាពអន្តរជាតិរបស់អង្គការសុខភាពពិភពលោក ។

**អបស.៣.៤** លើកស្ទួយសកម្មភាពសិក្សា ស្រាវជ្រាវសុខភាពសាធារណៈ និងគោលនយោបាយសុខាភិបាលនិងការវិភាគតាមរយៈការបញ្ជូល/ពង្រឹងមុខងារស្រាវជ្រាវរបស់អង្គភាពសុខាភិបាលថ្នាក់កណ្តាល រាប់ទាំងកម្មវិធីជាតិដោយសហការជាមួយស្ថាប័នស្រាវជ្រាវដទៃទៀតនៅកម្ពុជានិងអន្តរជាតិ ។

**អបស.៣.៥** គាំទ្រដល់ការបន្តអនុវត្តន៍សាកល្បងគំនិតផ្តួចផ្តើមថ្មីៗ ក្នុងការផ្តល់សេវាសុខភាពនិងការគ្រប់គ្រងវិស័យសុខាភិបាល តាមរយៈការអភិវឌ្ឍន៍និងការអនុវត្តន៍ក្របខណ្ឌ័និងសេចក្តីណែនាំគ្រប់ជ្រុងជ្រោយ សំរាប់ការស្រាវជ្រាវប្រតិបត្តិ និងគំរោងសាកល្បង ។

**អបស.៣.៦** ពង្រឹងការងារអធិការកិច្ច និងសវនកម្មផ្ទៃក្នុងរបស់ក្រសួងសុខាភិបាល តាមរយៈពង្រឹងការអនុវត្តន៍ច្បាប់និងបែបបទនៃពិភាក្សាផ្នែកច្បាប់ ព្រមទាំងពង្រឹងការសំរបសំរួលនិងសហការជាមួយស្ថាប័នរដ្ឋនានានិងអង្គការសង្គមស៊ីវិល ។

## អបស.៤ ការអភិវឌ្ឍន៍ស្ថាប័ន

**អបស.៤.១** អភិវឌ្ឍសមាហរណកម្មផែនការរំកិល៣ឆ្នាំសំរាប់កម្មវិធីសុខភាពទាំង៣ ដោយបញ្ចូលធនធានទាំងអស់ពីក្រសួងនិងជំនួយ ដើម្បីត្រួសត្រាយដល់ផែនការវិភាជន៍ធនធាននិងការរៀបចំកញ្ចប់ថវិកាសំរាប់កម្មវិធីសុខភាពនិមួយៗនិងធានាថាមូលនិធិជំនួយផ្តល់ឱ្យកម្មវិធីជាតិកាន់តែឆ្លុះបញ្ចាំងអំពីបន្ទុកជំងឺបន្ថែមពីលើការងាររបស់កម្មវិធី ។

**អបស.៤.២** តំរឹមតួនាទីនិងមុខងាររបស់កម្មវិធីជាតិ ដើម្បីធានាឱ្យតួនាទីនិងមុខងារនេះឆ្លើយតបទៅនឹងតំរូវការនៃវិមជ្ឈការនិងវិសហមជ្ឈការនិងឆ្លុះបញ្ចាំងអំពីគោលបំណងរបស់ ផ.យ.ស.២ ។

**អបស.៤.៣** រៀបចំផែនការនិងអនុវត្តប្រភេទស្វយ័ភាពសមស្រប សំរាប់អង្គភាពផ្សេងៗគ្នា យោងទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីអំពីការផ្តល់សេវាសាធារណៈដើម្បីធានាថាស្វយ័ភាពនៃការគ្រប់គ្រងដែលបានបង្កើន គឺឈរលើមូលដ្ឋាននៃការពង្រឹងការទទួលខុសត្រូវ ចំពោះស្នាដៃការងារ ។

## អបស.៥ ពង្រឹងមគ្គុទេសភាពរបស់ក្រសួងសុខាភិបាលតាមរយៈវិមជ្ឈការនិងវិសហមជ្ឈការ

**អបស.៥.១** រៀបចំនិងកៀងគរការឧបត្ថម្ភពីរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ សំរាប់របៀបវារៈនៃការអភិវឌ្ឍន៍ស្ថាបន័ ដូចជាអំពីតួនាទី មុខងារ និងរចនាសម្ព័ន្ធរបស់ក្រសួងសុខាភិបាលតំរូវតាមវិមជ្ឈការ និងវិសហមជ្ឈការ និងផែនការអភិវឌ្ឍន៍ស្ថាបន័របស់ក្រសួងសុខាភិបាល ។

**អបស.៥.២** ផែនការនីយកម្មនៅថ្នាក់កណ្តាលផ្តោតលើគោលដៅនិងគោលដៅចំណុចចំបងៗថ្នាក់ជាតិមួយចំនួនតូចដោយអនុញ្ញាតិឱ្យខេត្ត-ក្រុង និងស្រុកប្រតិបត្តិនូវសមត្ថកិច្ចបត់បែនកាន់តែច្រើនថែមទៀត នៅក្នុងការកែឆ្នៃយុទ្ធសាស្រ្តប្រតិបត្តិដើម្បីដោះស្រាយអាទិភាពសុខភាពនៅនឹងកន្លែង ។

**អបស.៥.៣** ពង្រឹងតួនាទីនិងមុខងារនៃការផ្តល់សេវាសុខភាព នៅថ្នាក់ប្រតិបត្តិតាមរយៈ មន្ទីរសុខាភិបាលខេត្ត-ក្រុងនិងស្រុកប្រតិបត្តិ ដោយអភិវឌ្ឍនិងអនុវត្តកំណែទំរង់រចនាសម្ព័ន្ធចាត់តាំង នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ស្របតាមគោលនយោបាយរាជរដ្ឋាភិបាលស្តីអំពីការផ្តល់សេវាសាធារណៈ និងវិមជ្ឈការនិងវិសហមជ្ឈការ។

**អបស.៥.៤** អភិវឌ្ឍផែនការយុទ្ធសាស្ត្រស្ថាប័ន សំរាប់គ្រប់ផ្នែកទាំងអស់ ដើម្បីជាមគ្គុទេសក៍ដល់ការសំរបតួនាទីនិងមុខងារ ព្រមទាំងរចនាសម្ពន្ធ័ស្ថាប័នស្របតាមវិមជ្ឈការនិងវិសហមជ្ឈការ។

**អបស.៥.៥** ពង្រឹងសមត្ថភាពមគ្គុទេសភាពរបស់ក្រសួងសុខាភិបាលនៅក្នុងបរិបទនៃការផ្លាស់ប្តូររចនាសម្ពន្ធ័អភិបាលកិច្ច តាមរយៈការអភិវឌ្ឍន៍និងអនុវត្តន៍យុទ្ធសាស្ត្ររៀនសូត្រពីវិមជ្ឈការនិងវិសហមជ្ឈការ:

- ពង្រឹងការយល់ដឹងដល់មន្ត្រីគ្រប់គ្រងអំពីឥទ្ធិពលនៃវិមជ្ឈការនិងវិសហមជ្ឈការទៅលើតួនាទីនិងមុខងារនៅគ្រប់ថ្នាក់
- ពង្រឹងសមត្ថភាពស្តីពីការគ្រប់គ្រងការផ្លាស់ប្តូរនេះនៅគ្រប់ថ្នាក់ទាំងអស់
- ចលនាអ្នកដឹកនាំសហគមន៍ និងរដ្ឋអំណាចមូលដ្ឋានដើម្បីបង្កើនការចូលរួមក្នុងការគ្រប់គ្រងនិងពិនិត្យរួមលើប្រពន្ធ័សុខាភិបាល។

## អបស.៦ កៀងគរការឆ្លើយតបពហុវិសយ័ដើម្បីឱយប្រពន្ធ័សុខាភិបាលកាន់តែទទួលខុសត្រូវចំពោះលទ្ធភាពមកទទួលយកសេវាសុខភាពមានគុណភាពដោយប្រជាជនទាំងអស់

**អបស.៦.១** ជំរុញការចូលរួមពីវិសយ័ពាក់ពន្ធ័ទាំងអស់នៅក្នុងកិច្ចសហការអន្តរវិសយ័ដើម្បីកែលំអកត្តាសង្គមដែលមានឥទ្ធិពលលើសុខភាព។

**អបស.៦.២** អនុវត្ត **បញ្ញតិស្តីអំពីសិទ្ធអ្នកផ្តល់សេវានិងសិទ្ធអតិជន** របស់ក្រសួងសុខាភិបាល ដើម្បីពង្រឹងស្មារតីយល់ដឹងអំពីសិទ្ធអតិថិជននិងសិទ្ធអ្នកផ្តល់សេវា។

**អបស.៦.៣** ពង្រឹងអន្តរសកម្មភាពរវាងសហគមន៍ និងអតិថិជនជាមួយអ្នកផ្តល់សេវានៅថ្នាក់ប្រតិបត្តិតាមរយៈការបង្កើតវេទិកានិងយន្តការដទៃទៀត ដោយមានការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីការឥស្សមតិ សំរាប់ការសន្ទនាផ្នែកគោលនយោបាយ និងកំណែទំរង់គោលនយោបាយក្នុងវិសយ័សុខាភិបាល។

**អបស.៦.៤** ពង្រឹងមុខងាររបស់គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមទ្រទ្រង់សុខភាពភូមិ ដែលជាចំណុចគោលនៃការប្រាស្រ័យទាក់ទង រវាងអតិថិជននិងអ្នកផ្តល់សេវាសុខភាព ។

**អបស.៦.៥** ធ្វើឱយប្រសើរឡើងការអភិបាលនៅនឹងកន្លែងនិងការត្រួតពិនិត្យតាមដានការផ្តល់សេវាសុខភាពមានប្រសិទ្ធភាពដោយសហគមន៍ ។

# ជំពូក ៤

# ការអនុវត្តន៍យុទ្ធសាស្រ្តសុខាភិបាលតាមរយៈផ្នែកកម្មវិធីសុខភាព

- អភិក្រមនៃផ្នែកកម្មវិធីសុខភាព
- សុខភាពបន្តពូជ មាតា ទារក កុមារ
- ជំងឺឆ្លង
- ជំងឺមិនឆ្លង

# ៥ ការអនុវត្តន៍យុទ្ធសាស្ត្រសុខាភិបាលតាមរយៈផ្នែកកម្មវិធីសុខភាព

## ១.   អភិក្រមផ្នែកកម្មវិធីសុខភាព

### ១.១   សេចក្តីផ្តើម

ផ.យ.ស.២ នឹងត្រូវយកទៅអនុវត្តតាមរយៈផ្នែកកម្មវិធីសុខភាពទាំង៣ : សុខភាពបន្តពូជ មាតា ទារកនិងកុមារ (ស.ប.ម.ទ.ក) ការប្រយុទ្ធនឹងជំងឺឆ្លង (ប្រ.ជ.ឆ) និងការប្រយុទ្ធនឹងជំងឺមិនឆ្លងនិងបញ្ហាសុខភាពដទៃទៀត (ប្រ.ជ.ម.ឆ)។ អន្តរកាលអេពីដេមីញូសាស្ត្រ ដែលកំពុងកើតមានរួចទៅហើយនៅប្រទេសកម្ពុជាមានផលប៉ះពាល់យ៉ាងច្បាស់លាស់សំរាប់កម្មវិធីសុខភាពខាងលើនេះ។ ផ្នែកកម្មវិធីសុខភាពទាំង៣ត្រួតជាន់គ្នា។ ដូច្នេះការសំរបសំរួលថ្នាក់ជាតិនៅក្រសួងសុខាភិបាល គឺមានសារៈសំខាន់ណាស់ក្នុងការធានាឱយមានការត្រួតពិនិត្យ ការផ្សារភ្ជាប់ និងមគ្គទេសភាពក្នុងវិស័យសុខាភិបាលទាំងមូល។

ការអភិវឌ្ឍន៍ផ្នែកកម្មវិធីសុខភាពនេះនឹងផ្តោតលើ :

- **បញ្ហាប្រឈមមុខសំរាប់ផ្នែកកម្មវិធីនិមួយៗ :** ឈរលើបញ្ហាប្រឈមមុខនេះ ក្របខណ្ឌប្រតិបត្តិមួយអាចនឹងត្រូវកំណត់ឡើង ដោយបញ្ចូលទាំងសូចនាករសំរាប់ការធ្វើផែនការកម្មវិធីលំអិតនិងការអនុវត្តន៍។
- ***ភាពត្រួតជាន់គ្នានិង "ឈ្នាន់រួម" រវាងផ្នែកកម្មវិធីសុខភាពទាំង ៣ :*** ជាការចាំបាច់ត្រូវចាត់ទុកអ្នកជំងឺចាំបាច់ជាផ្នែកមួយនៃវិស័យសុខាភិបាលសមាហរណកម្មនិងជាចំណែកទាំងស្រុងនៅក្នុងកិច្ចដំណើរការមុខងាររបស់ផ្នែកកម្មវិធីសុខភាពទាំងបី។

ដូច្នេះទំនាក់ទំនងរវាងផ្នែកកម្មវិធីត្រូវតែរឹងមាំ ហើយការសំរបសំរួលក្នុងចំណោមកម្មវិធី

ជាតិ មជ្ឈមណ្ឌលជាតិ នាយកដ្ឋាន និងអង្គភាពដទៃទៀតដែលអនុវត្តផ្នែកកម្មវិធីទាំងនេះ ក៏ត្រូវតែរឹងមាំដូចគ្នា។ អភិបាលកិច្ចផ្នែកគឺនិកបែបសមាហរណកម្មដែលមានបំណងទ្រទ្រង់ ដល់សកម្មភាពរបស់មូលដ្ឋានសុខាភិបាល តំរង់ទិសដោយស.ស.អនិងស.ស.ប អាចមាន ប្រសិទ្ធភាពនិងប្រសិទ្ធផល ដរាបណាមុខងាររបស់មូលដ្ឋានសុខាភិបាលទាំងនេះ ជាផ្នែក មួយនៃ“សេវាដែលមិនដាច់ចេញពីគ្នា”។

- **តំរូវការសំរាប់អន្តគមន៍លើជំងឺ:** ជានិច្ចកាលគឺ ធំធេងជាងធនធានដែលអាចរកបាន។ ធនធាន (សេដ្ឋកិច្ចនិងមនុស្ស) ចាំបាច់ត្រូវតែចែកចាយរវាងផ្នែកកម្មវិធីទាំងបី និងអង្គភាពអនុវត្តដទៃទៀត ដោយឈរលើមូលដ្ឋានអភិសមាចារនៃការពិចារណា ចំនួនអ្នកជំងឺនិងថ្លៃចំណាយដែលភ្ជាប់ជាមួយការពិនិត្យវាយតំលៃលើចំនួនឆ្នាំនៃគុណភាពជីវិត ដែលជាផលបច្ចុយ័នៃកិច្ចអន្តរាគមន៍។
- **ជំហរនៃផ្នែកកម្មវិធីសុខភាព ទាំង៣** នៅក្នុងបរិបទនៃដំណាក់កាលអន្តរកាលអេពីដេមីញ្ញូសាស្ត្រនៅប្រទេសកម្ពុជា។

ភាពមិនចំណុះលើក្រសួងសុខាភិបាលនៃផ្នែកអនុវត្តនានានៅក្នុងផ្នែកកម្មវិធីសុខភាពទាំង៣ មានកំរិតខុស១គ្នា។ផ្នែកដែលធ្វើការងារក្នុងកម្មវិធី ស.ប.ម.ទ.ក និងកម្មវិធីប្រ.ជ.ឆ ដូចជាមានស្វយ័ភាពខ្ពស់ ដោយសារតែទទួលហិរញ្ញប្បទានដាច់ដោយលែកពីអ្នកផ្តល់ជំនួយ។ បើប្រៀបធៀបជាមួយកម្មវិធី ប្រ.ជ.ម.ឆ កម្មវិធីនេះមានស្វយ័ភាពតិចតួច។

កម្មវិធីប្រយុទ្ធនឹងជំងឺនៅក្នុងផ.យ.ស ២ នឹងប្រមូលផ្តុំលើអន្តរាគមន៍ប្រយុទ្ធនឹងជំងឺ ឬហានិភយ័ជំងឺនៅទីណាដែលអាចធ្វើបាន ដោយប្រើប្រាស់វិធីសាស្ត្រ“ចំណាយតិចទទួលផលច្រើន”សំរាប់អន្តរាគមន៍ដែលនឹងបង្កើនចំនួនឆ្នាំនៃគុណភាពជីវិត តាមរយៈសកម្មភាពបង្ការព្យាបាល ស្តារនិតិសម្បទា និងការព្យាបាលសំរាលការឈឺចាប់ (ភាគច្រើនពីជំងឺមហារីក)។ ការអនុវត្តន៍គោលការណ៍ចំបងនេះតំរូវឱយមានការសិក្សាអំពីបន្ទុកជំងឺនៅប្រទេសកម្ពុជា។ ការសិក្សានេះនឹងផ្តល់ពត៌មានបន្ថែមសំរាប់ផ្នែកកម្មវិធីសុខភាពទាំងបី។ អត្ថប្រយោជន៍នៃការសិក្សាថ្នាក់តំបន់ដែលមានបច្ចុប្បន្នក្នុងប្រទេសជិតខាងកម្ពុជា គឺមានកំរិតព្រំដែន ដោយសារតែភាពខុសប្លែកគ្នានៃទិន្នន័យបន្ទុកជំងឺរវាងតំបន់អាស៊ីខាងត្បូងនិងតំបន់អាស៊ីខាងកើតនិងប៉ាស៊ីហ្វិកមានការប្រែប្រួលនៅក្នុងទិដ្ឋភាពជាច្រើន។ លើសពីនេះទៀតការសិក្សាអំពីបន្ទុកជំងឺនឹងសំរួលដល់ការពិនិត្យសារឡើងវិញនូវសកម្មភាពដែលបានអធិប្បាយនៅក្នុងស.ស.អ និងស.ស.បសំរាប់មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក។ សន្ទានកម្មជាមួយការពិនិត្យសារឡើងវិញនៃផ.គ្រ.ស ធ្វើឱយការសិក្សានេះ អាចជួយដល់ការគណនាថ្លៃចំណាយលំអិតនិងការធ្វើផែនការសំរាប់បុគ្គលិក។

ធនធានសំរាប់ការធ្វើការកម្មវិធីការអនុវត្តន៍និងការត្រួតពិនិត្យតាមដានគឺមាននៅថ្នាក់ជាតិ ប៉ុន្តែធនធានដូចគ្នានេះនៅខ្សត់ខ្សោយនៅថ្នាក់ខេត្ត-ក្រុង។ កសាងសមត្ថភាពក្នុងការធ្វើផែនការ និងការអនុវត្តន៍ផ្នែកកម្មវិធីសុខភាពនៅខេត្ត-ក្រុងនិងស្រុក គឺជាអាទិភាពខ្ពស់មួយ។

ដោយផ្តោតទៅលើការពង្រឹងប្រពន្ធ័សុខាភិបាលនៅក្នុង ផ.យ.ស.២ តំរូវការដ៏ចាំបាច់គឺ ៖

- ផ្សារភ្ជាប់ សមាហរណកម្ម និងការពង្រឹងកំលាំងគ្នា នៃផ្នែកកម្មវិធីសុខភាពទាំងបី និង អង្គភាព អនុវត្តទាំងអស់ទៅនឹងប្រពន្ធ័សុខាភិបាលទាំងមូល គឺមានសារៈសំខាន់ណាស់។
- សមាហរណកម្មនៃផ្នែកកម្មវិធីសុខភាពចាំបាច់ត្រូវបញ្ជាក់ច្បាស់ តាមរយៈប្រពន្ធ័អភិបាលកិច្ចគ្លីនិក
- ផ្នែកកម្មវិធីសុខភាពនិមួយៗ ត្រូវការឱយមានក្របខណ្ឌ័សំរាប់ការអនុវត្តន៏ ផែនការរំកិល ៣ ឆ្នាំ និងប្រតិទិនពេលវេលាទៅតាម ផ.យ.ស.២ ដែលក្នុងនេះមានបញ្ជាក់គោលដៅចំណុចនៃការប្រតិបត្តិ ដែលមិនបានដាក់បញ្ចូលនៅក្នុងគោលដៅចំណុចជាយុទ្ធសាស្រ្តសំរាប់ផ្នែកកម្មវិធីសុខភាពនិមួយៗ។
- តួនាទីនិងការទទួលខុសត្រូវនៅក្នុងផ្នែកកម្មវិធីសុខភាពនឹងត្រូវបានពិនិត្យសារឡើងវិញ ហើយតំរៀបតំរង់ឱយបានជិតស្និទ្ធ ជាមួយគោលបំណងនៃផ.យ.ស.២ និងតំរូវការនៃវិមជ្ឈការនិងវិសហមជ្ឈការ។

## ១.២ ដំណាក់កាលអន្តរកាលប្រជាសាស្រ្តនិងរោគរាតត្បាតសាស្រ្ត

រយៈពេលផែនការនៃផ.យ.ស.២ គឺវែងបន្តិចបើប្រៀបធៀបជាមួយផ.យ.ស.១។ ផ.យ.ស.២ ប្រព្រឹត្តទៅនៅក្នុងអំលុងពេលមួយដែលត្រូវបានកត់សំគាល់ ដោយការផ្លាស់ប្តូរយ៉ាងឆាប់រហ័សស្ទើរតែគ្រប់ទិដ្ឋភាពទាំងអស់នៃវិស័យសង្គមនៅប្រទេសកម្ពុជា។ ដូច្នេះតំរូវការចាំបាច់គឺត្រូវគិតគូរដល់កត្តាអន្តរកាលនានាដែលជាសម្ពាធកាន់តែខ្លាំងជាងពេលមុនៗ។

ពេញមួយអំលុងពេលនៃ ផ.យ.ស.២ សុខភាពប្រជាជនក្នុងប្រទេសកម្ពុជាទំនងជាវិវត្តន៏ឆ្ពោះទៅកាន់សុខភាពប្រជាជននៃប្រទេសដែលមានបន្ទុកជំងឺទ្វេ។ មានន័យថា តំរូវការធនធានយ៉ាងច្រើនសំបើមសំរាប់ផ្នែកកម្មវិធីសុខភាពទាំងបី នឹងមានរយៈពេលយូរ។ បន្ទុកទ្វេនៃកំណើនជំងឺនេះចាំបាច់ត្រូវមានវិធីសាស្រ្តល្អក្នុងការកំណត់អាទិភាពដែលនឹងអភិវឌ្ឍន៏ដោយក្រសួងសុខាភិបាល សំរាប់ប្រើប្រាស់នៅក្នុងផ្នែកដូចខាងក្រោមនេះ ៖

- ការថែទាំផ្នែកគ្លីនិកជាប្រចាំ
- ផែនការនីយកម្មនៅក្នុងផ្នែកកម្មវិធីនិមួយៗ
- ពង្រឹងនិងបច្ចុប្បន្នភាពសំណុំសកម្មភាពអប្បបរមា និងសំណុំសកម្មភាពបង្គ្រប់
- ការវិភាជន៏ធនធានគាំទ្រភាពក្រីក្រទូទាំងផ្នែកកម្មវិធីសុខភាពទាំងបី និងគ្រប់ខេត្ត-ក្រុង

ការអភិវឌ្ឍន៏និងការពង្រឹងតួនាទីមគ្គុទេសក៏ភាពរបស់ក្រសួងសុខាភិបាល គប្បីជួយជ្រោមជ្រែងដល់ការបង្កើតឱយមានការសន្ទនាប្រកបដោយនយ័ស្ថាបនាជាមួយអ្នកផ្តល់សេវាឯកជន ហើយកំណត់បាននូវតួនាទីសមស្របសំរាប់ពួកគេ។

ការកសាងសមត្ថភាពក្នុងការធ្វើផែនការនិងកសាងថវិកាខេត្ត-ក្រុង និងកាន់តែមានសារៈសំខាន់ខ្លាំងឡើងនៅក្នុងអំលុងពេលនៃផ.យ.ស.២ ដោយហេតុថានៅតំបន់ទីប្រជុំជននិងតំបន់ជនបទដាច់ស្រយាល ការផ្លាស់ប្តូរអំពីសេចក្តីត្រូវការនិងតំរូវការផ្នែកសុខភាពចេះតែកើនឡើងជាលំដាប់។

**សង្ខេប**

- កំណើនប្រជាជននិងបំរែបំរួលនៃការពង្រាយប្រជាជនតំរូវឱយធ្វើការពិនិត្យកែសំរួលឡើងវិញ ផ.គ្រ.ស។ ខេត្ត-ក្រុងនឹងចូលរួមកាន់តែសកម្មថែមទៀតនៅក្នុងផែនការនីយកម្ម ហើយការកសាងសមត្ថភាពចាំបាច់ត្រូវតែអភិវឌ្ឍន៍ ដើម្បីផ្តល់ការគាំទ្រដ៏រឹងមាំ ដល់ការធ្វើផែនការសុខាភិបាលនៅថ្នាក់វិជ្ជមការ និងវិសហមជ្ឈការដែលតំរូវឱយមានការចូលរួមកាន់តែច្រើនឡើង។
- ប្រទេសកម្ពុជាកំពុងឈានចូលទៅក្នុងដំណាក់កាល"បន្ទុកទ្វេនៃជំងឺ"។ បញ្ហានេះនឹងមានផលប៉ះពាល់យ៉ាងជ្រាលជ្រៅទៅលើធនធានមនុស្ស និងហិរញ្ញវត្ថុដែលកំពុងខ្វះខាត។
- តំរូវការសេវាសុខភាពដែលចេះតែកើនឡើងទៅតាមបន្ទុកទ្វេនៃជំងឺអាចគ្រប់គ្រងបាន តាមរយៈប្រព័ន្ធមធ្យូតមួយសំរាប់ការកំណត់អាទិភាព។
- ប្រព័ន្ធសំរាប់ការកំណត់អាទិភាពនឹងជំពាក់ជំពិន ទៅគ្រប់ថ្នាក់ទាំងអស់នៃប្រព័ន្ធសុខាភិបាលជាអាទិ៍ ការថែទាំផ្នែកគ្លីនិកជាប្រចាំ ផែនការនីយកម្មនៅក្នុងនិងរវាងផ្នែកកម្មវិធីសុខភាពទាំងបី សេវានៅក្នុង ស.ស.អ និង ស.ស.ប និងការសំរេចលើថវិកាសំរាប់វិស័យសុខាភិបាល។

## ២. ផ្នែកកម្មវិធីសុខភាពបន្តពូជ-មាតា-ទារកនិងកុមារ

ស.ប.ម.ទ.ក គឺជាអាទិភាពមួយក្នុងចំណោមអាទិភាពផ្នែកសុខភាពបួន ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ វឌ្ឍនភាពបានកើតមានជាទូទៅ នៅក្នុងផ្នែកស.ប.ម.ទ.ក។ ការវិវត្តន៍ជាវិជ្ជមាននេះនាំមុខដោយកត្តា២យ៉ាង: ទីមួយមានការគាំទ្រផ្នែកនយោបាយដ៏រឹងមាំដល់ការខិតខំប្រឹងប្រែង ក្នុងការត្រួតត្រាស្ថានការណ៍ជុំវិញបញ្ហាសុខភាពមាតានិងកុមារ និងទីពីរសកម្មភាពអន្តរាគមន៍នៅក្នុងសុខភាពមាតានិងកុមារមានការអភិវឌ្ឍន៍និងអនុវត្តយ៉ាងល្អរួចមកហើយ។

ការប្រើប្រាស់សេវាបានកើនឡើងចំពោះសេវាសុខភាពបន្តពូជ មាតានិងកុមារ ដូចជាការពិនិត្យគភ៌មុនពេលសំរាល ការសំរាលកូនដោយវេជ្ជបណ្ឌិត/ឆ្មប និងការសំរាលកូននៅតាមមូលដ្ឋានសុខាភិបាល អត្រាប្រើប្រាស់មធ្យោបាយពន្យាកំណើត និងការផ្តល់ថ្នាំបង្ការ ប៉ុន្តែជាទូទៅនៅខ្ពស់នៅឡើយ។ សុខភាពកុមារមានភាពប្រសើរឡើងយ៉ាងខ្លាំង

រវាងឆ្នាំ២០០០និង២០០៥ អត្រាស្លាប់របស់កុមារអាយុក្រោម១ឆ្នាំនិង៥ឆ្នាំ បានថយចុះជិត ៣០%។ ស្ថានភាពអាហារូបត្ថម្ភរបស់កុមារ និងស្ត្រីក៏ត្រូវបានលើកកំពស់ ប៉ុន្តែកង្វះអាហារូបត្ថម្ភ និងគ្រិននៅតែខ្ពស់ក្នុងចំណោមប្រទេសក្នុងតំបន់។ ការគ្របដណ្តប់នៃការផ្តល់ថ្នាំបង្ការត្រូវបានធ្វើឱយប្រសើរឡើងគ្រប់អង់ទីហ្សែនទាំងអស់ អត្រាអាំងស៊ីដង់នៃជំងឺកញ្ជ្រឹលមានកំរិតទាបបំផុត ហើយជំងឺគ្រុនស្វិតដៃជើងត្រូវបានលុបបំបាត់ទាំងស្រុង នៅដំណាច់ឆ្នាំ ២០០០។ ទោះជាដូច្នេះក្តី ជំងឺតេតាណូសលើទារកទើបនឹងកើតនៅតែជាបញ្ហា ហើយសមាមាត្រនៃកុមារដែលបានទទួលថ្នាំបង្ការពេញលេញនៅតែទាបជាងគោលដៅចំណុច។

## ២.១ បញ្ហាប្រឈមមុខ

ស្ថានភាពសុខភាពស្ត្រីមិនបានកែលំអ ដូចស្ថានភាពសុខភាពរបស់កុមារទេ។ អត្រាស្លាប់របស់មាតានៅតែខ្ពស់មិនអាចទទួលយកបាន ហើយការវិនិយោគក្នុងការផ្តល់សេវានឹងទាមទារជាចាំបាច់ ដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍសហសវត្ស។

តំរូវការសេវាសាធារណៈសំរាប់សុខភាពមាតានិងកុមារ មិនបានលើកើនឡើងដូចដែលបានរំពឹងទុក។ អន្តរាគមន៍នៅផ្នែកតំរូវការមានសារៈសំខាន់ណាស់ ដើម្បីលើកកំពស់ការប្រើប្រាស់សេវាដែលបានកែលំអ។ ការណ៍នេះតំរូវឱយមានការផ្តល់ "សេវាថែទាំបន្ត" សំរាប់ ស.ប.ម.ទ.ក ដែលបានកំណត់ច្បាស់លាស់ដែលគាំទ្រដោយយុទ្ធសាស្ត្រប្រាស្រយ័ទាក់ទងមានប្រសិទ្ធភាព ដើម្បីបង្កើនល្បឿននៃតំរូវការសេវា។

មានភាពខុសគ្នានៃលទ្ធផលសុខភាពមាតា និងកុមារ រវាងក្រុមអ្នកមានបំផុតនិងអ្នកក្របំផុត។ មានកំនត់សំគាល់ថាវិសមធម៌នៅក្នុងការប្រើប្រាស់សេវា និងលទ្ធភាពមកទទួលយកសេវាថែទាំកំពុងកើនឡើង។ សេវាសុខភាពដែលបានកែលំអឱយប្រសើរឡើង ហាក់ដូចជាផ្តល់អត្ថប្រយោជន៍រួចទៅហើយដល់ក្រុមប្រជាជនទទន់ខ្សោយ។ ទិន្នន័យនៃអ.ប្រ.ស២០០៥ ស្តីអំពីលទ្ធផលសុខភាពនិងអត្រានៃការប្រើប្រាស់សេវានៅក្នុងក្រុមប្រជាជនដែលមានស្ថានភាពសេដ្ឋកិច្ច-សង្គមខុសៗគ្នាកំពុងបង្ហាញយ៉ាងច្បាស់ថាទិដ្ឋភាពសមធម៌នៃស.ប.ម.ទ.កត្រូវតែទទួលបានការយកចិត្តទុកដាក់ខ្លាំង។ គោលដៅចំណុចនិងសូចនាករចាំបាច់ត្រូវតែកំនត់ដើម្បីកាត់បន្ថយវិសមធម៌ក្នុងផ្នែកសុខភាពមាតានិងកុមារ។

## ២.២ អាទិភាព សេវាជាសារវន្ត គោលបំណង និងគោលដៅនៃស.ប.ម.ទ.កៈ

**គោលបំណង១: បន្ថយការឈឺនិងស្លាប់របស់មាតាទារកនិងកុមារនិងការលើកកំពស់សេវាសុខភាពបន្តពូជ**

**គោលដៅ** ១ លើកកំពស់ស្ថានភាពអាហារូបត្ថម្ភរបស់មាតានិងកុមារ

២ លើកកំពស់លទ្ធភាពមកទទួលយកពត៌មាននិងសេវាសុខភាពបន្តពូជមានគុណភាព

៣ លើកកំពស់លទ្ធភាពមកទទួលយកសេវាសុខភាពសារវ័ន្តសំរាប់មាតានិងទារកនិងការប្រព្រឹត្តការថែទាំសុខភាពតាមគ្រួសារបានល្អប្រសើរ

៤ ធានានូវលទ្ធភាពមកទទួលយកសេវាសុខភាពសារវ័ន្តសំរាប់កុមារនិងការប្រព្រឹត្ត ការថែទាំសុខភាពតាមគ្រួសារបានល្អប្រសើរ

**អាទិភាពនិងសេវាជាសារវន្ត័**

- ផែនការគ្រួសារនិងការពន្យារកំណើត
- ការពន្លូតកូនមានសុវត្ថិភាព
- សុខភាពមាតានិងកុមារ
- អាហារូបត្ថម្ភ
- ការថែទាំគភ៌មុនសំរាល
- ការទប់ស្កាត់ការចំលង HIV ពីម្តាយទៅទារក
- ការថែទាំករណីសម្ភពបន្ទាន់
- ចាក់ផ្តល់ថ្នាំបង្ការរួមទាំងការលុបបំបាត់ជំងឺកព្រៀលនិងតេតាណូស ការបញ្ចូលវ៉ាក់សាំងថ្មី
- សមាហរណកម្មការគ្រប់គ្រងជំងឺកុមារ
- ការថែទាំសារវន្ត័ដល់កុមារ
- ការស្លាប់ទារកនិងកុមារ
- សុខភាពវ័យជំទង់/យុវវ័យ
- ការអនុវត្តន៍តាមគ្រួសារ

## ២.៣ ស.ប.ម.ទ.ក ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រផ.យ.ស.២

ឯកសារចំបងចំនួន៤សំរាប់ស.ប.ម.ទ.ក **គឺយុទ្ធសាស្ត្រជាតិសំរាប់សុខភាពបន្តពូជនិងសុខភាពផ្លូវភេទ យុទ្ធសាស្ត្រដើម្បីការរស់រានរបស់កុមារ ផែនការយុទ្ធសាស្ត្រ៥ឆ្នាំសំរាប់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ និងយុទ្ធសាស្ត្រជាតិអាហារូបត្ថម្ភ**។ គោលនយោបាយនិងសេចក្តីណែនាំនៅក្នុងឯកសារទាំង ៤ នេះបានឆ្លុះបញ្ចាំងនៅក្នុងសំណុំនៃការបណ្តុះបណ្តាល ស.ស.អ និង ស.ស.ប។

គោលដៅជាយុទ្ធសាស្ត្រទាំង៤ នៃយុទ្ធសាស្ត្រជាតិសំរាប់សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ គឺ: លើកស្ទួយគោលនយោបាយនិងបរិដ្ឋានធនធាន បង្កើននិងពង្រឹងការផ្តល់សេវាមានគុណភាព លើកកំពស់ការយល់ដឹងរបស់សហគមន៍និងបង្កើនតំរូវការលើសេវា និងពង្រីកគោលនយោបាយនិងការអភិវឌ្ឍន៍យុទ្ធសាស្ត្រផ្អែកលើភស្តុតាង។ យុទ្ធសាស្ត្រនេះបង្ហាញពីសំណុំសេវាសារវន្ត័សំរាប់សុខភាពបន្តពូជ។

យុទ្ធសាស្ត្រដើម្បីការរស់រានរបស់កុមារបង្ហាញគោលដៅយុទ្ធសាស្ត្រចំនួន៦: (១)លើកកំពស់ការសំរបសំរួលផែនការនីយកម្ម និងការតាក់តែងគោលនយោបាយ ពង្រឹងធនធានមនុស្សនិងការកសាងសមត្ថភាព (២)លើកស្ទួយសកម្មភាពសហគមន៍ ដើម្បីការរស់រានរបស់កុមារ (៣)ធានាមធ្យោបាយ

ហិរញ្ញវត្ថុដើម្បីការរស់រានរបស់កុមារ (៤)លើកស្ទួយប្រសិទ្ធភាពនិងគុណភាពក្នុងការផ្តល់សេវា និង (៥)ពង្រឹងការត្រួតពិនិត្យតាមដាននិងវាយតំលៃ។ យុទ្ធសាស្ត្រនេះមានបំណងសំរេចការគ្របដណ្តប់ជាសកលនៃបណ្ណ័ពិន្ទុនៃការរស់រានរបស់កុមារទាំង១២ចំណុច ។អន្តរាគមន៍នឹងយកទៅអនុវត្តតាមរយៈសំណុំសមាហរណកម្មនៃសកម្មភាពនៅចំណុចនៃការផ្តល់សេវា ។

គោលដៅរួមនៃផែនការយុទ្ធសាស្ត្រ៥ឆ្នាំសំរាប់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ គឺលើកកំពស់ការរស់រាននិងសុខភាពកុមារ និងគាំទ្រដល់ការសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សទី១និងទី៤ ដោយត្រួតត្រាលប់បំបាត់រាល់ជំងឺទាំងអស់ដែលអាចការពារបានដោយថ្នាំបង្ការ ដែលជាគោលដៅចំណុចនៃកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ។យុទ្ធសាស្ត្រនេះគ្របដណ្តប់ផ្នែកយុទ្ធសាស្ត្រចំនួន៤ : (១)តាមដាននិងត្រួតត្រាជំងឺ (២) ប្រពន្ធ័សុខាភិបាលនិងការគ្រប់គ្រង (៣)ការផ្គត់ផ្គង់ការប្រាស្រយ័ទាក់ទងនិងការបណ្តុះបណ្តាលនិង (៤)ការផ្តល់សេវា

យុទ្ធសាស្ត្រជាតិអាហារូបត្ថម្ភ មានរយៈពេលពីឆ្នាំ ២០០៨-២០១៥ ហើយគោលបំណងរួមនៃយុទ្ធសាស្ត្រនេះគឺរួមចំណែកលើកកំពស់ការរស់រានរបស់មាតានិងកុមារនិងភាពប្រសើរឡើងនៃស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រីនិងកុមារ ។

ឯកសារចំបងទាំងបួនខាងលើនេះដាក់ផ្នែកកម្មវិធី ស.ប.ម.ទ.ក នៅក្នុងចំហររឹងមាំមួយដើម្បីសំរេចគោលបំណងនៅក្នុងផ្នែកនៃកម្មវិធី ។ អន្តរាគមន៍នឹងត្រូវកំណត់ឱយបានល្អនិងជាក់ស្តែង ដែលនឹងនាំឆ្ពោះទៅរកលទ្ធផលល្អ នោះគឺការគ្របដណ្តប់ជាសកលអាចនឹងសំរេចបាន បើសិនជាធនធានអាចរកបានគ្រប់គ្រាន់ ។

| **យុទ្ធសាស្ត្រ ផ.យ.ស.២** | **សមាសភាគនិងអន្តរាគមន៍សំខាន់ៗនៃសុខភាពបន្តពូជ សុខភាពមាតា-ទារក-កុមារ** |
|---|---|
| ការផ្តល់សេវា | • ការថែទាំបន្តនៃសំណុំសេវា ស.ប.ម.ទ.ក នៅមណ្ឌលសុខភាព(ស.ស.អ) និងមន្ទីរពេទ្យបង្អែក(ស.ស.ប) ត្រូវផ្អែកលើយុទ្ធសាស្ត្រសំរាប់ការរស់រានរបស់កុមារ ការផ្តល់ថ្នាំបង្ការអាហារូបត្ថម្ភ និងសុខភាពបន្តពូជ<br>• យុទ្ធសាស្ត្រប្រាស្រយ័ទាក់ទងសំរាប់ ស.ប.ម.ទ.ក ដើម្បីទ្រទ្រង់ការអភិវឌ្ឍន៍សុខភាពសហគមន៍ និងបង្កើនតំរូវសេវាសារវន្ត័ផ្នែកស.ប.ម.ទ.ក<br>• ការត្រួតពិនិត្យតាមដាននិងការអភិបាលរួមគ្នា នៅមូលដ្ឋានសុខាភិបាលដោយក្រុមបច្ចេកទេសចំរុះ<br>• តំរៀបតំរង់សេវាជំនួយដទៃទៀតទៅតាមសេចក្តីត្រូវការនៃ ស.ប.ម.ទ.ក រួមមានមន្ទីរពិសោធន៍ ការផ្គត់ផ្គត់ឱសថ–សំភារៈបរិក្ខារ លើកស្ទួយសេវាផ្តល់ឈាមដើម្បីទ្រទ្រង់ដល់ការថែទាំសម្ភពបន្ទាន់ការគ្រប់គ្រងជំងឺគ្រុនឈាម និងអាទិភាពដទៃទៀតនៃ ស.ប.ម.ទ.ក<br>• ពង្រីកការអនុវត្តន៍គោលនយោបាយស្តីអំពីកិច្ចសន្យាសេវា |

| | |
|---|---|
| | • ពង្រឹងគំរូនៃការថែទាំបែបសមាហរណកម្ម នៃការចុះផ្តល់សេវាដល់មូលដ្ឋាន និងផ្តែកលើសហគមន៍ជាយុទ្ធសាស្រ្តបន្ទាន់ សំរាប់ការពង្រីកអន្តរាគមន៍លើសុខភាពមាតា-ទារក និងរស់រានរបស់កុមារ ពិសេសនៅតាមសហគមន៍ដែលពិបាកមកទទួលសេវានៅមូលដ្ឋានសុខាភិបាល និងធានាឱយមានការចូលរួមពីរដ្ឋអំណាចមូលដ្ឋាននិងអ្នកស្ម័គ្រចិត្ត (ក្រុមទ្រទ្រង់សុខភាពភូមិ) នៅក្នុងការផ្តល់សេវា និងពត៌មានចាំបាច់សំរាប់ ស.ប.ម.ទ.ក។ |
| **ហិរញ្ញប្បទាន ការថែទាំសុខភាព** | • បន្ថយឧបសគ្គហិរញ្ញវត្ថុក្នុងការទទួលយកសេវាស.ប.ម.ទ.កដោយនិយតកម្មលើការបង់ថ្លៃសេវាការបញ្ចូលស.ប.ម.ទ.កទៅក្នុងកម្មវិធីមូលនិធិសមធម៌ និងការធានារ៉ាប់រងសុខភាពតាមសហគមន៍ ការពង្រីកការគ្របដណ្តប់មូលនិធិសមធម៌និងការធានារ៉ាប់រងសុខភាពតាមសហគមន៍ និងការផ្តល់ថ្នាំបង្ការដោយមិនបង់ថ្លៃ។<br>• លើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដល់អ្នកផ្តល់សេវានឹងការពារអតិថិជន ដើម្បីធានាដល់សមធម៌ក្នុងការផ្តល់ស.ប.ម.ទ.ក (ការផ្ទេរសាច់ប្រាក់-cash transfer ការសំរាលកូនដោយមិនបង់ថ្លៃ ផ្តល់បណ្ណ័សុខភាព-vouchers ។ល។) |
| **ធនធានមនុស្ស សុខាភិបាល** | • ការអនុវត្តន៍ពេញលេញនូវអនុសាសន៍ ដែលបានលើកឡើងនៅក្នុងរបាយការណ៍ស្តីពីការពិនិត្យបច្ចេកវិទ្យាឆ្មបនិងដោយក្រុមការងារជាន់ខ្ពស់ផ្នែកបច្ចេកវិទ្យាឆ្មប<br>• ពង្រឹងជំនាញបច្ចេកទេសនិងសមត្ថភាពនៅថ្នាក់ ស.ស.អ និង ស.ស.ប តាមរយៈការបណ្តុះបណ្តាលមានគុណភាពនិងគ្រប់ជ្រុងជ្រោយការសិក្សាអប់រំការរក្សាទុកបុគ្គលិក ការចេញអាជ្ញាបណ្ណ័ និងប្រពន្ធ័ចុះបញ្ជីកា។ |
| **ប្រពន្ធ័ពត៌មាន សុខាភិបាល** | • ពង្រឹងការត្រួតពិនិត្យតាមដានទិន្នន័យពាក់ពន្ធ័នឹងសមធម៌និងយែនឌ័រនៅទូទាំងខេត្ត- ក្រុងនិងស្រុកប្រតិបត្តិ។<br>• បង្កើនភាពពេញលេញនៃទិន្នន័យសំខាន់ៗ តាមរយៈការពង្រីកការពិនិត្យការស្លាប់របស់មាតា ដាក់ឱយប្រើប្រាស់ការពិនិត្យការស្លាប់ជុំវិញកំណើត និងសមាហរណកម្មការ ចុះបញ្ជីអត្រានុកូលដ្ឋាននៅក្នុងប្រពន្ធ័សុខាភិបាល។ |
| **អភិបាលកិច្ច ប្រពន្ធ័សុខាភិបាល** | • សេចក្តីណែនាំច្បាស់លាស់និងតំរែតំរង់ការអនុវត្តន៍ក្រមវិជ្ជាជីវៈបុគ្គលិក<br>• គោលនយោបាយស្តីពីការគ្រប់គ្រងបុគ្គលិក រួមមានប្រពន្ធ័លាភការ<br>• គោលនយោបាយស្តីអំពីអ្នកបំរើការងារសុខភាពតាមសហគមន៍ដោយរាប់បញ្ចូលទាំងសេចក្តីណែនាំអំពីការឱយប្រើប្រាស់ឱសថ |

## ២.៤ គោលដៅចំណុចនិងសូចនាករនៃ ស.ប.ម.ទ.ក

គោលដៅចំណុចនិងសូចនាករ មានរៀបរាប់លំអិតនៅក្នុងយុទ្ធសាស្ត្រជាតិសំរាប់សុខភាពបន្តពូជនិងសុខភាពផ្លូវភេទ យុទ្ធសាស្ត្រដើម្បីការរស់រានរបស់កុមារ ផែនការយុទ្ធសាស្ត្រ ៥ឆ្នាំសំរាប់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ និងយុទ្ធសាស្ត្រជាតិអាហារូបត្ថម្ភ។ វឌ្ឍនភាពចាំបាច់ត្រូវតែវាស់វែងនៅថ្នាក់ខេត្ត-ក្រុង ដើម្បីត្រួសត្រាយសកម្មនៅថ្នាក់ផ្តល់សេវា។ ប្រការនេះនឹងកាន់តែមានសារៈសំខាន់នៅពេលដែលវិមជ្ឈការនិងវិសហមជ្ឈការកំពុងមានវឌ្ឍនភាព។

អត្រាស្លាប់របស់កុមារអាយុក្រោម១ឆ្នាំ ក្រោម៥ឆ្នាំ និងអត្រាស្លាប់របស់មាតានៅថ្នាក់ខេត្ត-ក្រុង ត្រូវវិភាគនៅក្នុងការអង្កេតប្រជាសាស្ត្រនិងសុខភាពទៅតាមតំបន់ជនបទនិងទីប្រជុំជនកំរិតអនក្ខរកម្ម និងកំរិតនៃភាពក្រីក្រនៅតាមខេត្ត-ក្រុង បើអាចធ្វើបាន។

| សូចនាករ | ប្រចាំឆ្នាំ | ស្ទង់ ព.ស.ភ | ទិន្នន័យដើមគ្រា ២០០៥-២០០៦ | គោលដៅចំណុច ២០១០ (២០១១ ព.ព.អ) | គោលដៅចំណុច ២០១៥ ការប៉ាន់ស្មាន |
|---|---|---|---|---|---|
| **ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា** | | | | | |
| អត្រាសាយកូនសរុប | | | ៣,៤ | ៣,៤ | ៣,០ |
| អត្រាមរណភាពមាតា ក្នុងទារកកើតរស់ ១០០.០០០ នាក់ | | | ៤៧២ | ២៤៣ | ១៤០ |
| អត្រាស្លាប់ទារកទើបប្រសូត្រក្នុងទារកកើតរស់១.០០០ នាក់ | | | ២៨ | ២៥ | ២២ |
| អត្រាស្លាប់កុមារអាយុក្រោមមួយឆ្នាំក្នុងទារកកើតរស់១.០០០ នាក់ | | | ៦៦ | ៦០ | ៥០ |
| អត្រាស្លាប់កុមារអាយុក្រោមប្រាំឆ្នាំក្នុងទារកកើតរស់១.០០០នាក់ | | | ៨៣ | ៧៥ | ៦៥ |
| ជំងឺស្លេកស្លាំងលើស្ត្រីក្នុងវ័យបន្តពូជ (%) | | | ៤៦,៦ | ៣២ | ១៩ |
| ជំងឺស្លេកស្លាំងនៅក្នុងស្ត្រីមានផ្ទៃពោះ (%) | | | ៥៧,១ | ៣៩ | ៣៣ |
| ស្ត្រីក្នុងវ័យបន្តពូជដែលមាន BMI ទាប (<18.5 Kg/m2) (%) | | | ២០ | ១២ | ៨ |
| សមាមាត្រទារកដែលបានដាក់ឱ្យបៅដោះ មួយម៉ោងក្រោយកំណើត | | | ៣៥ | ៤៥ | ៦២ |
| សមាមាត្រទារកអាយុ០-៦ខែដែលបានទទួលការបំបៅដោះតែមួយមុខ (%) | | | ៦០ | ៦៥ | ៧០ |
| % នៃកុមារអាយុក្រោម ៥ ឆ្នាំ ខ្វះទម្ងន់ | | | ៣៦ | ២៩ | ២២,៦ |
| *គិតតាមស្តង់ដារនៃការលូតលាស់ថ្មីរបស់អង្គការសុខភាពពិភពលោក* | | | (២៩) | (២៥) | (២០) |
| % នៃកុមារអាយុក្រោម ៥ ឆ្នាំ ដែលស្គមស្គាំង | | | ៧,៣ | ៧ | ៥ |
| % នៃកុមារអាយុក្រោម ៥ ឆ្នាំដែលមានកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃៈក្រិន | | | ៣៧ | ២៨ | ២២ |
| *គិតតាស្តង់ដារនៃការលូតលាស់ថ្មីរបស់អង្គការសុខភាពពិភពលោក* | | | (៤៣) | (៣៥) | (២៥) |
| សមាមាត្រកុមារអាយុក្រោម១ឆ្នាំដែលបានទទួលថ្នាំបង្ការពេញលេញ (%) | | | ៦០ | ៧០ | ៨០ |
| % នៃកុមារអាយុក្រោម ៥ ឆ្នាំ មានក្អកឬពិបាកដកដង្ហើមដែលបានព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ | | | ៤៨ | ៧០ | ៧៥ |

| | | | | | |
|---|---|---|---|---|---|
| សមាមាត្រកុមារដែលមានជំងឺរាគដែលបានទទួលទឹកអូរ៉ាលីត (%) | | | ៥៨ | ៨០ | ៨៥ |
| **ប្រព័ន្ធព័ត៌មានសុខាភិបាល** | | | | | |
| % នៃមណ្ឌលសុខភាពដែលបានអនុវត្តយុទ្ធសាស្ត្រ IMCI | ✓ | | ៥៦ | ៧៥ | ៨០ |
| ប្រេវ៉ាឡង់នៃវិធីពន្យារកំណើតទំនើប | ✓ | ✓ | ២៧ | ៤០ | ៦០ |
| ពិនិត្យផ្ទៃពោះមុនសំរាល២ដងឬច្រើនដងដោយបុគ្គលិកសុខាភិបាល (%) | ✓ | ✓ | ៦៨ | ៧៣ | ៩០ |
| % នៃស្ត្រីមានផ្ទៃពោះដែលបានទទួលជាតិដែក/ហ្វូលិកបន្ថែម | ✓ | | ៦៩ | ៧៥ | ៩០ |
| % នៃស្ត្រីមានផ្ទៃពោះដែលបានទទួលថ្នាំបង្ការតេតាណូសយ៉ាងតិច២ ដង | ✓ | | ៦៩ | ៨៥ | ៩០ |
| % នៃស្ត្រីមានផ្ទៃពោះដែលបានទទួល ART សំរាប់ PMTCT | ✓ | ✓ | ៧ | ៤៥ | ៧៥ |
| % នៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមានការបណ្តុះបណ្តាល | ✓ | ✓ | ៤៤ | ៥៥ | ៨០ |
| % នៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាលនៅមូលដ្ឋានសុខាភិបាល | ✓ | | ២២ | ៤០ | ៧០ |
| % នៃការសម្រាលកូនដោយការវះកាត់ | ✓ | ✓ | ១,៨ | ២,៥ | ៤ |
| % នៃស្ត្រីក្រោយសម្រាលដែលបានទទួលជាតិដែក/ហ្វូលិកបន្ថែម | ✓ | | ៥៧ | ៨៥ | ៩០ |
| % នៃកុមារអាយុក្រោមមួយឆ្នាំដែលបានចាក់ថ្នាំបង្ការ DPT3-HepB | ✓ | | ៨២ | ៩២ | ៩៥ |
| % នៃកុមារអាយុក្រោមមួយឆ្នាំដែលបានទទួលថ្នាំបង្ការជំងឺកញ្ជ្រិល | ✓ | ✓ | ៧៩ | ៨៥ | ៩០ |
| % នៃកុមារអាយុ ៦-៥៩ ខែដែលបានទទួលជីវជាតិអា ២ដូសក្នុងរយៈពេល ១២ខែចុងក្រោយ | ✓ | | ៨៣ | ៨៥ | ៩០ |
| %នៃកុមារអាយុ៦-៥៩ ខែ ដែលបានទទួលមេបង់ដាហ្វូល រាល់៦ខែម្តង | ✓ | | ៩០ | ៩៨ | ១០០ |
| អត្រាស្លាប់ដោយជំងឺគ្រុនឈាមដែលរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ | ✓ | ✓ | ០,៧៤ | ០,៥ | ០,៣ |

**ព.ស.ឆ:** ការពិនិត្យរួមគ្នាសមិទ្ធផលសុខាភិបាលប្រចាំឆ្នាំ

**ព.ព.អ:** ការពិនិត្យឡើងវិញពាក់កណ្តាលអណត្តិ

## ៣. ផ្នែកកម្មវិធីជំងឺរបេង

ការប្រយុទ្ធនឹងជំងឺរបេងគឺជាអាទិភាពមួយក្នុងចំណោមអាទិភាពផ្នែកសុខភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជាចំនួន៣ទាក់ទងនឹងជំងឺរបេង។ ប្រទេសកម្ពុជាឆ្លងកាត់កម្មវិធីប្រយុទ្ធនឹងជំងឺរបេងដែលបានបង្ហាញថា សមិទ្ធផលដ៏ធំធេងអាចសំរេចបាននៅពេលដែលមានធនធានគ្រប់គ្រាន់។ កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួនតូចក្នុងពិភពលោកដែលបានសំរេចគោលដៅចំណុច ៧/៥ និងកំពុងស្ថិតនៅលើផ្លូវឆ្ពោះទៅសំរេចបានគោលដៅអភិវឌ្ឍន៍សហសវត្សទាំងអស់ផ្នែកជំងឺរបេង។

ប្រទេសកម្ពុជាមានកម្មវិធី ប្រយុទ្ធជំងឺឆ្លង ដែលមានការដឹកនាំរឹងមាំ និងមានចក្ខុវិស័យជាយុទ្ធសាស្ត្រច្បាស់លាស់។ វឌ្ឍនភាពក្នុងការត្រួតត្រាជំងឺឆ្លងគឺកិច្ចដំណើរការនៃភាពខ្លាំងរបស់កម្មវិធី។ មានកត្តាគន្លឹះមួយចំនួនដែលរួមចំណែកដល់ជោគជយ័នេះ។ ការផ្តល់ប្រាក់ឧបត្ថម្ភផ្អែកតាមស្នាដៃការងារបានផ្តល់នូវប្រព័ន្ធលាភការមានលក្ខណៈប្រកួតប្រជែង ហើយបានពង្រឹងដល់មូលដ្ឋានធនធានមនុស្ស។ ភាពរឹងមាំនៃការធ្វើផែនការ ការត្រួតពិនិត្យតាមដាននិងវាយតំលៃរបស់កម្មវិធី/មជ្ឈមណ្ឌលជាតិបានធ្វើឱយការប្រើប្រាស់ធនធានមានប្រសិទ្ធភាព សមាហរណកម្មខ្សែរបណ្តោយធានាឱយមានការឆ្លើយតបយ៉ាងឆាប់រហាស់សំរាប់ការត្រួតត្រាជំងឺឆ្លង។ ការកែលំអការព្យាបាលដោយប្រើប្រាស់ឱសថផ្សំនិងឱសថថ្មី ផ្តល់ភាពរឹងមាំដល់អន្តរាគមន៍ប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ជាពិសេសជំងឺរបេង និងវិធានការការពារមានប្រសិទ្ធភាព ហើយការលើកស្ទួយការអប់រំសុខភាពស្តីពីការកាត់បន្ថយឥរិយាបទគ្រោះថ្នាក់ទទួលបានជោគជយ័ក្នុងអេដស៍។ កម្មវិធីប្រយុទ្ធជំងឺឆ្លង ដោយការឆ្លើយតបពហុវិស័យក៏ទទួលបានជោគជយ័ ដោយសារមានកិច្ចសហការគ្នាយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជន។

នៅក្នុងអំលុងពេលនៃការអនុវត្តន៍ ផ.យ.ស.២ មជ្ឈមណ្ឌលជាតិនិងកម្មវិធីជាតិនឹងត្រូវសំរប តួនាទីនិងមុខងាររបស់ខ្លួន ដើម្បីប្រើប្រាស់ឱយអស់លទ្ធភាពនូវកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។ អង្គភាពទាំងនេះចាំបាច់ផងដែរត្រូវតែបង្ការភាពមិនប្រាកដប្រជាដែលអាចកើតមានចំពោះមូលនិធិក្រៅប្រទេស ហើយដោះស្រាយឧបសគ្គដែលកំពុងជួបប្រទះ តាមរយៈការសំរបសំរួលកាន់តែជិតស្និទ្ធថែមទៀត ការធ្វើផែនការរួមគ្នានិងការអនុវត្តន៍ជាមួយក្រសួងសុខាភិបាល មន្ទីរសុខាភិបាលខេត្ត-ក្រុង និងស្រុកប្រតិបត្តិ។ ការណ៍នេះនឹងធ្វើឱយមជ្ឈមណ្ឌលជាតិ/កម្មវិធីជាតិរក្សាបាននូវសមិទ្ធផលបច្ចុប្បន្នរបស់ខ្លួន នៅពេលលើកកំពស់គុណភាពទូទៅនៃសេវា និងពង្រឹងផ្នែកសំខាន់ៗ ដូចជាមន្ទីរពិសោធន៍ សមត្ថភាពធ្វើរោគវិនិច្ឆ័យ ការតាមដានជំងឺ ការគ្រប់គ្រងការចំលងរោគ ពត៌មានជាយុទ្ធសាស្ត្រ និងមុខងារនិយត័កម្មលើឱសថ។

## ៧.១ បញ្ហាប្រឈមមុខ

នៅខណៈពេលដែលតួនាទីនៃជំងឺឆ្លង នៅក្នុងបន្ទុកជំងឺនៅកម្ពុជាចុះថយ ជំងឺឆ្លងនៅមានតួនាទីចំបងដដែល ហើយតំរូវឱយរក្សានិងបង្កើនការប្រុងប្រយត្ន័។ ចាំបាច់ត្រូវមានការត្រៀមខ្លួនទុកជាមុនក្នុងកំរិតខ្ពស់ ដោយសារគ្រោះថ្នាក់នៃការលេចឡើងនូវជំងឺថ្មីៗ និងការលេចឡើងសារជាថ្មីនៃជំងឺដែលបានកើតមានរួចមកហើយ។

បញ្ហាប្រឈមមុខដ៏សំខាន់សំរាប់កិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធនឹងជំងឺឆ្លង នៅក្នុងអំលុងពេលនៃផ.យ.ស.២ រួមមាន:

- ផ្នែកចំបងខ្លះនៃការប្រយុទ្ធនឹងជំងឺនៅតែខ្វះខាតមូលនិធិយ៉ាងច្រើន
- ភាពស៊ាំជាមួយឱសថ ពិសេសរបេងនិងគ្រុនចាញ់
- ចរាចរឱសថប្រឆាំងគ្រុនចាញ់ក្លែងក្លាយ
- ការបន្តគំរាមកំហែងដោយជំងឺដែលបានកើតមានរួចមក ហើយរាប់ទាំងជំងឺដែលបានលុបបំបាត់រួចហើយនៅកម្ពុជា ក៏ដូចជាការគំរាមកំហែងដែលកំពុងកើតមាននៃបរិបូណ៌ (ការផ្លាស់ប្តូរបំលែងរូប) នៃវីរុស
- សេរូទីបចំរុះនៃវីរុសគ្រុនឈាមគួបផ្សំនឹងការចំលងដ៏លឿននៃវីរុស តាមកំណើនប្រជាជននិងចំណាកស្រុករវាងតំបន់ជនបទ-ប្រជុំជន ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាននៅខ្វះខាត
- ការចំលងជំងឺឆ្លងកាត់ព្រំដែន ការគំរាមកំហែងនៃជំងឺឆ្លងក្នុងតំបន់និងពិភពលោក ដូចជាលទ្ធភាពនៃការចំលងជំងឺគ្រុនផ្តាសាយបក្សី
- ត្រូវការចាំបាច់ការចូលរួមរបស់រដ្ឋាភិបាលនិងដៃគូដើម្បីត្រួតត្រាជំងឺហ្សូណូទិកដូចជាជំងឺឆ្កែឆ្កួត
- រក្សាការប្រុងប្រយត្ន័ដោយមិនធ្វេសប្រហែស ទប់ទល់នឹងការវិលត្រឡប់មកវិញនៃជំងឺដែលអាំងស៊ីដង់កំពុងថយចុះ ពិសេសនៅចំពោះភស្តុតាងអន្តរជាតិនៃអាំងស៊ីដង់ HIV ដែលកំពុងងើបឡើងវិញម្តងទៀត
- ផ្សារភ្ជាប់រវាងជំងឺឆ្លងនិងជំងឺមិនឆ្លង ហើយដែលត្រូវការអភិក្រមមានលក្ខណៈសមាហរណកម្ម (ដូចជា មហារីកកស្បូន មហារីកថ្លើម.....)
- ថ្លៃចំណាយដ៏ខ្ពស់លើការព្យាបាលផលវិបាកនៃជំងឺឆ្លងរ៉ាំរ៉ៃ
- ការប្រែប្រួលនៃការផ្តល់មូលនិធិក្រៅប្រទេសសំរាប់អន្តរាគមន៍ជំងឺជាក់លាក់ ក៏ដូចជាកង្វះការគាំទ្រក្រៅប្រទេសដល់ជំងឺដែលបង្ហាញពីការគំរាមកំហែងធ្ងន់ធ្ងរនៅកម្ពុជា
- រក្សាគុណភាពនៃអន្តរាគមន៍របស់កម្មវិធីជាតិលើជំងឺដោយឡែក២ នៅក្នុងបរិបទដែលប្រព័ន្ធសុខាភិបាលនៅទន់ខ្សោយ ពិសេសទាក់ទងនឹងធនធានមនុស្ស ការគ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាល ការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ឱសថ និងប្រព័ន្ធតាមដានជំងឺ ។

## ៣.២ អាទិភាព សេវាសារវន្ត គោលបំណង និងគោលដៅនៃផ្នែកកម្មវិធីជំងឺឆ្លង

**គោលបំណង២: បន្ថយអត្រាឈឺនិងអត្រាស្លាប់ដោយសារជំងឺអេដស៍ របេង គ្រុនចាញ់ និងជំងឺឆ្លងដទៃទៀត**

**គោលដៅ** ៥ កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃHIV

៦ បង្កើនការរស់រានមានជីវិតរបស់អ្នកផ្ទុកមេរោគអេដស៍/មានជំងឺអេដស៍

៧ សំរេចបានអត្រាស្រាវជ្រាវជំងឺរបេងខ្ពស់ និងរក្សាអត្រាជាសះស្បើយក៏រិតខ្ពស់នៃករណីជំងឺរបេងស្ទួតបេការិជ្ជមាន

៨ កាត់បន្ថយការស្លាប់ដោយជំងឺគ្រុនចាញ់ និងអត្រាឈឺក្នុងចំណោមប្រជាជនទូទៅ

៩ កាត់បន្ថយបន្ទុកនៃជំងឺឆ្លងដទៃទៀត

**អាទិភាពនិងសេវាជាសារវន្ត**

- ជំងឺឆ្លងប្រដាប់បន្តពូជ
- HI/ជំងឺអេដស៍ ជំងឺកាមរោគ
- របេង ឃ្លង់
- គ្រុនចាញ់
- គ្រុនឈាម
- រោគបណ្តាលមកពីព្រូន
- Helminthiasis, schistomosiasis
- ជំងឺដែលទើបនិងលេចឡើង ឬលេចឡើងសារជាថ្មី
- ការអនុវត្តន៍និតិក្រមសុខភាពអន្តរជាតិ (International Health Regulations)

## ៣.៣ ការអនុវត្តន៍យុទ្ធសាស្រ្តផ.យ.ស.២ ក្នុងផ្នែកកម្មវិធីជំងឺឆ្លង

បញ្ហាប្រឈមមុខដែលបានរៀបរាប់ខាងលើនេះផ្តល់នូវបរិបទ សំរាប់ពង្រឹងអន្តរាគមន៍នៅក្នុងអំលុងពេលនៃ ផ.យ.ស.២ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងផ្នែកកម្មវិធីជំងឺឆ្លងនៅក្នុងក្របខណ្ឌប្រតិបត្តិរួមនៃផ.យ.ស.២ ក៏ដូចជាក្របខណ្ឌផែនការរបស់មជ្ឈមណ្ឌលជាតិ/កម្មវិធីជាតិនិមួយៗនៅក្នុងផ្នែកកម្មវិធីប្រយុទ្ធជំងឺឆ្លង។ សមត្ថភាពបច្ចេកទេសដ៏រឹងមាំនៃកម្មវិធីជាតិជំងឺដោយលែកៗ អាចជួយមជ្ឈមណ្ឌលជាតិកម្មវិធីជាតិឱយរៀបចំនិងអនុវត្តដោយជោគជយ័នូវផែនការរបស់ខ្លួន ដែលជាកត្តារួមចំណែកដល់ជោគជយ័បច្ចុប្បន្ន។ ជាការពិតណាស់ ការរីករាលដាលនៃភាពខ្លាំងផ្នែកបច្ចេកទេសសំរាប់ប្រពន្ធ័សុខាភិបាលជាទូទៅ គឺជាភស្តុតាងជាក់ស្តែងនៅក្នុងផ្នែកផែនការនីយកម្ម ការត្រួតពិនិត្យតាមដាននិងវាយតំលៃ។

ផ.យ.ស.២ មិនមានបំណងនឹងជំនួសផែនការយុទ្ធសាស្រ្តនៃកម្មវិធីនិមួយៗទេ ប៉ុន្តែគឺផ្តល់ឱយនូវបរិបទផែនការនីយកម្មទូទាំងប្រពន្ធ័។ ផ.យ.ស.២ ត្រូវបានកសាងឡើងនៅលើផែនការយុទ្ធសាស្រ្តដែលកំពុងអនុវត្តបច្ចុប្បន្ន។ ផ.យ.ស.២បានដាក់ចេញនូវក្របខណ្ឌយុទ្ធសាស្រ្តទូលំទូលាយមួយ សំរាប់វដ្តផែនការនីយកម្មនៃកម្មវិធីជាតិ។ ផែនការយុទ្ធសាស្រ្តនឹងផ្តល់នូវការផ្សារភ្ជាប់គ្នារវាងការធ្វើផែនការសំរាប់ជំងឺដោយលែកៗ ប្រពន្ធ័សុខាភិបាលជាទូទៅ ជាមួយផ.យ.អ.ជនិងគោលដៅអភិវឌ្ឍសហសវត្សរកម្ពុជា។ ដូច្នេះ វាជាការចាំបាច់ត្រូវប្រើប្រាស់ផែនការយុទ្ធសាស្រ្ត និងក្របខណ្ឌអនុវត្តរបស់កម្មវិធីជាតិនិមួយៗ សំរាប់អន្តរាគមន៍និងយុទ្ធសាស្រ្តលំអិតនៃកម្មវិធីជំងឺដោយលែកៗ។

ផែនការយុទ្ធសាស្រ្តនៅក្នុងផ្នែកកម្មវិធីប្រយុទ្ធជំងឺឆ្លងរួមមាន ផែនការយុទ្ធសាស្រ្តជាតិសំរាប់ HIV អេដស៍២០០៦-២០១០ ផែនការយុទ្ធសាស្រ្តជាតិសំរាប់ប្រយុទ្ធជំងឺរបេង២០០៦-២០១០ ផែនការ

យុទ្ធសាស្ត្រ សំរាប់កម្មវិធីប្រយុទ្ធជំងឺគ្រុនចាញ់ ២០០៦-២០១០ និងផែនការយុទ្ធសាស្ត្រសំរាប់ជំងឺលេចឡើងថ្មី២០០៧។

គោលបំណងទូទៅនៃផែនការយុទ្ធសាស្ត្រជាតិសំរាប់ HIV អេដស៍គឺៈ(១) កាត់បន្ថយករណីចំលងថ្មីនៃ HIV (២)ផ្តល់ការថែទាំនិងការគាំទ្រដល់អ្នកផ្ទុកនិងអ្នករងគ្រោះដោយ HIV អេដស៍ និង (៣)កាត់បន្ថយផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនិងមនុស្សជាតិនៃ HIV អេដស៍លើបុគ្គលគ្រួសារ សហគមន៍និងសង្គម។ យុទ្ធសាស្ត្រចំនួន៧ត្រូវបានលើកឡើងជាមួយនឹងគោលដៅព្រមទាំងសកម្មភាព ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រនៅក្នុងផ្នែកបង្ការ ការថែទាំគ្រប់ជ្រុងជ្រោយ ការសំរាលបន្ទុកផលប៉ះពាល់ មគ្គទេសភាពរបស់រដ្ឋាភិបាល គោលនយោបាយសាធារណៈ ពត៏មាន(ការត្រួតពិនិត្យតាមដាន ការវាយតំលៃនិងការស្រាវជ្រាវ) និងការកៀងគរ-បែងចែកធនធានដោយសមធម៌និងមាននិរន្តភាព។

ផែនការយុទ្ធសាស្ត្រជាតិសំរាប់ប្រយុទ្ធជំងឺរបេងផ្តោតលើផ្នែកគោលនយោបាយចំនួន៧ៈ (១)មគ្គទេសភាពនៃការប្រយុទ្ធនឹងជំងឺរបេងនិងការព្យាបាលតាមរយៈ ស.ស.អ និង ស.ស.ប (២)គោលនយោបាយផែនការនិងសេចក្តីណែនាំច្បាស់លាស់ (៣)ការធានាគុណភាព (៤)ការប្រើប្រាស់ធនធានមានប្រសិទ្ធភាពនិងប្រសិទ្ធផល (៥)កៀងគរធនធាននិងការកំណត់អាទិភាព (៦)ប្រពន្ធ័ពត៏មាននិងការស្រាវជ្រាវសំរាប់ការគ្រប់គ្រងកម្មវិធីនិង (៧)ភាពជាដៃគូនិងការសំរបសំរួល។ យុទ្ធសាស្ត្រសំខាន់ៗស្តីអំពីការធានានិរន្តភាព នៃវិធីសាស្ត្រព្យាបាលដោយពិនិត្យផ្ទាល់ (DOTs) នៅមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក និងការពង្រីកDOTs នៅតាមសហគមន៍ និងអន្តរាគមន៍លើរបេង-HIV ពង្រឹងការគ្រប់គ្រងការផ្គត់ផ្គង់ឱសថប្រឆាំងជំងឺរបេងនិងសំភារៈមន្ទីរពិសោធន៍ ដោយរាប់បញ្ចូលទាំងការដាក់ឱយប្រើប្រាស់ឱសថច្រើនមុខប្រឆាំងជំងឺរបេងក្នុងគ្រាប់តែមួយ (Fixed-Dose Combination) បន្តការធ្វើរោគវិនិច្ឆ័យនិងការព្យាបាលរបេងនៅសេវាសាធារណៈដោយឥតបង់ថ្លៃ។

ផែនការយុទ្ធសាស្ត្រសំរាប់កម្មវិធីប្រយុទ្ធជំងឺគ្រុនចាញ់ត្រូវបានអភិវឌ្ឍជុំវិញទិសដៅជាយុទ្ធសាស្ត្រនៃការផ្លាស់ប្តូរឥរិយាបទនិងការប្រាស្រយ័ទាក់ទង ការគ្របដណ្តប់នៃមុងជ្រលក់ថ្នាំការពារមូសដែលប្រើប្រាស់បានយូរអង្វែង ការពង្រីកការធ្វើរោគវិនិច្ឆ័យនិងការព្យាបាលទាន់ពេលវេលា ការកសាងសមត្ថភាពភាពជាដៃគូជាមួយអង្គការជាតិនិងអន្តរជាតិដោយរាប់ពញ្ចូលទាំងសង្គមស៊ីវិលនិងការកៀងគរធនធានមនុស្សហិរញ្ញវត្ថុនិងសំភារៈ។ អន្តរាគមន៍ប្រយុទ្ធជំងឺគ្រុនចាញ់ដែលត្រូវប្រកាន់យកក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រត្រូវបានដាក់បញ្ចូលជាបួនសំណុំ ដែលមានសមាសភាគមួយចំនួននៅក្នុងសំណុំនិមួយៗ។ **សំណុំបង្ការ**រួមមានការផ្លាស់ប្តូរឥរិយាបទនិងការប្រាស្រយ័ទាក់ទងដែលបង្គ្រប់ដោយសេវាមុងជ្រលក់ថ្នាំការពារមូសសំរាប់ក្រុមប្រជាជនប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់និងទាប។ **សំណុំធ្វើរោគវិនិច្ឆ័យនិងការព្យាបាលទាន់ពេលវេលា** នឹងមានអន្តរាគមន៍ តាមរយៈមូលដ្ឋានសុខាភិបាលសាធារណៈ អ្នកផ្តល់សេវាឯកជននិងអ្នកធ្វើការងារគ្រុនចាញ់តាមភូមិ។ **សំណុំការស្រាវជ្រាវនិងតាមដានជំងឺ** រួមមានការតាមដានជំងឺគ្រុនចាញ់ កែលំអគុណភាពប្រពន្ធ័ពត៏មានសុខាភិបាល និងការស្រាវជ្រាវប្រតិបត្តិ។ **សំណុំការងារ**

**គ្រប់គ្រង** មានការធ្វើផែនការ ការគ្រប់គ្រងនិងសំរបសំរួលធនធាន និងការពង្រឹង ការត្រួតពិនិត្យតាមដាននិងការវាយតំលៃ។

ផែនការយុទ្ធសាស្ត្រសំរាប់ជំងឺលេចឡើងថ្មីគឺ ផ្តោតទៅលើការពង្រឹងសមត្ថភាពជាតិសំរាប់ការតាមដាននិងត្រួតត្រាជំងឺដែលលេចឡើងថ្មី តាមរយៈការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាតិ និងធនធានដើម្បីស្រាវជ្រាវឆ្លើយតប ត្រួតពិនិត្យតាមដាន បង្ការនិងគ្រប់គ្រងជំងឺនិងតាមរយៈការបណ្តុះបណ្តាលអំពីរោគវិនិច្ឆ័យ និងការស្រាវជ្រាវអំពីដើមីញូសាស្ត្ររបស់ជំងឺ។ ផែនការយុទ្ធសាស្ត្រនេះផ្តល់នូវយុទ្ធសាស្ត្រលំអិតគាំទ្រដល់គោលបំណង៥ : (១)ពង្រឹងក្របខណ្ឌនៃប្រពន្ធ័ប្រកាសភាពអាសន្ននៃជំងឺដែលលេចឡើងថ្មី (២)អភិវឌ្ឍយន្តការដើម្បីឆ្លើយតបចំពោះសក្តានុពលនៃភាពអាសន្នសុខភាពសាធារណៈដែលជាកង្វល់អន្តរជាតិឱយបានទាន់ពេលវេលា និងមានលក្ខណៈជាប្រពន្ធ័ (៣)ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ជាតិសំរាប់ជំងឺលេចឡើងថ្មី (៤)ពង្រឹងការត្រួតត្រាឆ្លងរោគក្នុងអំឡុងពេលនៃការផ្ទុះរាតត្បាតនៃជំងឺ និង(៥)លើកកំពស់ការប្រាស្រយ័ទាក់ទងនិងការសំរបសំរួលជាមួយវិស័យផ្សេងៗទៀត។

ដូចបានអធិប្បាយនៅក្នុងតារាងខាងក្រោមនេះ យុទ្ធសាស្ត្រដែលបានអភិវឌ្ឍសំរាប់ផែនការយុទ្ធសាស្ត្រនៃជំងឺដោយលែកមានភាពចំណុះជាមួយយុទ្ធសាស្ត្រទូលំទូលាយទូទាំងវិស័យរបស់ ផ.យ.ស.២។

| **យុទ្ធសាស្ត្រផ.យ.ស.២ សមាសភាគ និងអន្តរាគមន៍ជាយុទ្ធសាស្ត្រនៃជំងឺឆ្លងសំខាន់ៗ** | |
|---|---|
| **ការផ្តល់សេវាសុខាភិបាល** | • ពង្រឹងការដាក់តម្រឹម និងសម្របសម្រួលការផ្តល់សេវាតាមខ្សែបណ្តោយទៅក្នុងស.ស.អនិងស.ស.ប តាមរយៈការដាក់បញ្ចូលគោលនយោបាយកម្មវិធីការរៀបចំផែនការសកម្មភាពអភិវឌ្ឍន៍និងធនធានទៅក្នុងផែនការថ្នាក់ខេត្តក្រុងថ្នាក់ស្រុកនិងចូលរួមក្នុងការវាយតម្លៃនិងយន្តការផ្តល់ព័ត៌មានត្រឡប់យោងតាមបែបបទធ្វើផែនការរបស់ក្រសួងសុខាភិបាល។<br>• ផ្តល់ការគាំទ្របច្ចេកទេសដល់មន្ទីរសុខាភិបាល និងស្រុកប្រតិបត្តិ ដើម្បីធ្វើការត្រួតពិនិត្យតាមដានរួមគ្នានិងការអភិបាលរួមបញ្ចូលនៅមូលដ្ឋានសុខាភិបាល។<br>• ពង្រឹងជំនាញ និងសមត្ថភាពនៅក្នុងការព្យាករណ៍ និងការកំណត់បរិមាណនៃសំភារៈបរិក្ខាពេទ្យ ជាមួយគ្នានឹងការពង្រឹងប្រព័ន្ធគាំទ្រនិងគ្រប់គ្រងឱសថ។<br>• ពង្រឹងការធានានិងត្រួតពិនិត្យគុណភាព ដែលទាក់ទងនឹងជំងឺឆ្លង ពិសេសពាក់ព័ន្ធទៅនឹងការអនុវត្តន៍នៃវិស័យឯកជននិងការចែកចាយឱសថដែលមានឥទ្ធិពលខ្លាំង ដើម្បីជៀសវាងការវិវត្តន៍ប្រកបដោយគ្រោះថ្នាក់ ទៅរកភាពស៊ាំរបស់មេរោគជាមួយឱសថផ្សះ–អង់ទីប៊ីយ៉ូទិក (ឱសថសម្រាប់ជំងឺរបេងនិងគ្រុនចាញ់)<br>• គាំទ្រដល់រចនាសម្ព័ន្ធមូលដ្ឋាន (ក្រុមប្រឹក្សាឃុំ–សង្កាត់–ស្រុក)និងសហគមន៍ដើម្បីដើរតួនាទី ក្នុងការលើកកម្ពស់សុខភាពជាទូទៅ (ដាក់បញ្ចូលពេញលេញជាមួយស.ប.ម.ទ.កនិងជ.ម.ឆ)រួមទាំងការចាក់ថ្នាំបង្ការ និងពិសេសសម្រាប់ |

| | |
|---|---|
| | ជំងឺកាមរោគ/មេរោគអេដស៍/ជំងឺអេដស៍ របេង គ្រុនចាញ់ គ្រុនឈាមនិងជំងឺឆ្លងដទៃទៀត ។<br>• ពង្រឹងប្រព័ន្ធប្រកាសអាសន្នសម្រាប់ជំងឺដែលកើតឡើងថ្មីៗ (ការតាមដានជំងឺដោយផ្អែកលើព្រឹត្តិការណ៍ជាក់ស្តែងការតាមដានជំងឺដោយផ្អែកលើសូចនាករ)<br>• បង្កើតយន្តការដើម្បីឆ្លើយតបទៅនឹងសក្តានុពល នៃគ្រោះអាសន្នសុខភាពសាធារណៈ ដែលជាកង្វល់ថ្នាក់អន្តរជាតិក្នុងលក្ខណៈជាប្រព័ន្ធ និងទាន់ពេលវេលា (ប្រព័ន្ធឆ្លើយតបរហ័សក្រុមការងារឆ្លើយតបរហ័សថ្នាក់ខេត្តនិងថ្នាក់ជាតិការទប់ស្កាត់រហ័ស)។<br>• វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងប្រពន្ធ័ភស្តុភារ សំរាប់ការផ្តល់សេវាសមស្របដោយរាប់បញ្ចូលសមត្ថភាពមន្ទីរពិសោធន៍ជាតិសម្រាប់ជំងឺដែលកើតឡើងថ្មី (បណ្តាញមន្ទីរពិសោធន៍សម្រាប់ការតាមដាននិងឆ្លើយតបនឹងជំងឺដែលកើតឡើងថ្មីការពង្រឹងសមត្ថភាព/ការបណ្តុះបណ្តាលមន្ទីរពិសោធន៍ថ្នាក់កណ្តាលនិងខេត្ត គោលនយោបាយស្តីពីសេវាមន្ទីរពិសោធន៍វេជ្ជសាស្ត្រ ការតាមដានផ្អែកលើមន្ទីរពិសោធន៍ ការស្រាវជ្រាវប្រតិបត្តិ) អគារជំងឺរបេង មន្ទីរពិសោធន៍និងវិទ្យុសាស្រ ពង្រឹងនិងពង្រីកបណ្តាញមន្ទីរពិសោធន៍ដោយរាប់បញ្ចូលទាំងការបណ្តុះមេរោគ ការធ្វើតេស្តរកមើលភាពកបនៃឱសថ ដើម្បីធានាដល់ការប្រើប្រាស់សេវាមន្ទីរពិសោធន៍មានគុណភាព ។<br>• ពង្រឹងការទប់ស្កាត់ការឆ្លងរោគក្នុងពេលផ្ទុះជំងឺ (គោលនយោបាយស្តីពីការបង្ការការឆ្លងជំងឺនិងកម្មវិធីជាតិបង្ការការឆ្លងរោគ គោលការណ៍ណែនាំជាតិស្តីពីការបង្ការ ការឆ្លងរោគ ការបណ្តុះបណ្តាល និងការហ្វឹកហាត់ស្តីពីការបង្ការការឆ្លងរោគសម្រាប់បុគ្គលិកមន្ទីរពេទ្យ និងក្រុមឆ្លើយតបរហ័ស ប្រព័ន្ធ/ដំណើរការចែកចាយឧបករណ៍ការពារផ្ទាល់ខ្លួន ការបង្កើត/ថែទាំអគារដាក់ជំងឺដាច់ពីគ្នានៅថ្នាក់ខេត្ត–ក្រុង ។<br>• បង្កើនការគ្រប់ដណ្តប់ការបង្ការប្រកបដោយប្រសិទ្ធភាព រាប់បញ្ចូលនូវវិធានការនានានៅមូលដ្ឋានសុខាភិបាល ដូចជាការបង្ការការឆ្លងជំងឺ គ្រប់គ្រងកាកសំណល់ ព្រមទាំងការថែទាំគ្រប់ជ្រុងជ្រោយ និងអន្តរាគមន៍កាត់បន្ថយផលប៉ះពាល់ ។<br>• ដាក់ឱ្យប្រើប្រាស់នូវថ្នាំរួមបញ្ចូលគ្នា២,៣,៤មុខ នៃឱសថប្រឆាំងនឹងរោគរបេង ដើម្បីបង្កើនការគោរពតាមគោលការណ៍ព្យាបាល ពីសំណាក់អ្នកជំងឺកាត់បន្ថយបន្ទុកការងាររបស់បុគ្គលិកសុខាភិបាល និងលើកកម្ពស់ការគ្រប់គ្រងឱសថព្រម |

| | |
|---|---|
| | ទាំងរក្សាការព្យាបាលដោយ DOTS បានល្អ នៅគ្រប់ថ្នាក់ដោយសំដៅលើមណ្ឌលសុខភាពពង្រីក DOTS តាមសហគមន៍ និងពង្រីកយុទ្ធសាស្ត្រ DOTS ដើម្បីឱយសហគមន៍ (សមាជិកសហគមន៍និងអតីតអ្នកជំងឺរបេង) ចូលរួមកាន់តែសកម្មថែមទៀតក្នុងការប្រយុទ្ធជំងឺរបេង។<br>• ផ្តល់ឧបករណ៍ dipstick/អតិសុខុមទស្សន៍ សំរាប់ធ្វើរោគវិនិច្ឆ័យនិងព្យាបាលជាមួយកញ្ចប់ថ្នាំព្យាបាល artesunate និងថ្នាំព្យាបាលជំងឺគ្រុនចាញ់ដទៃទៀតដល់មូលដ្ឋានសុខាភិបាលទាំងអស់។ dipstick និងកញ្ចប់ថ្នាំព្យាបាល artesunate នឹងផ្តល់ឱយភូមិក្នុងតំបន់គ្រុនចាញ់ ដោយអ្នកធ្វើការងារគ្រុនចាញ់តាមភូមិ និងការផ្សព្វផ្សាយទីផ្សារអំពីផលិតផល Malacheck និង Malarine ក្នុងវិសយ័ឯកជន។<br>• ផ្តល់សេវាជ្រលក់ថ្នាំមុងបន្ថែមពីរលើក សំរាប់ក្រុមប្រជាជនដែលប្រឈមមុខគ្រោះថ្នាក់ខ្ពស់និងទាប ចែកចាយមុងជ្រលក់ថ្នាំដែលប្រើប្រាស់បានយូរអង្វែងដោយឥតគិតថ្លៃក្នុងតំបន់គ្រុនចាញ់ខ្ពស់ និងការផ្សព្វផ្សាយទីផ្សារអំពីមុងជ្រលក់ថ្នាំដែលប្រើប្រាស់បានយូរអង្វែង និងឃើតព្យាបាលក្នុងតំបន់ដែលមានចលនាប្រជាជនបណ្តោះអាសន្នទៅនៅក្នុងព្រៃ។<br>• ពិនិត្យសារឡើងវិញនិងកែសំរួលសេចក្តីណែនាំជាតិស្តីពីការធ្វើរោគវិនិច្ឆយគ្លីនិកនិងការគ្រប់គ្រងជំងឺគ្រុនឈាម ដើម្បីប្រើប្រាស់នៅមន្ទីរពេទ្យបង្អែកខេត្ត និងបង្កើតសេចក្តីណែនាំអនុវត្តជាក់ស្តែងព្រមទាំងផ្ទាំងរូបភាពដើម្បីជួយដល់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកថ្នាក់ស្រុកក្នុងការយល់ដឹងជាមុន និងការបញ្ជូនករណីគ្រុនឈាមធ្ងន់ធ្ងរ។ |
| **ហិរញ្ញប្បទានសម្រាប់ការថែទាំសុខភាព** | • ដាក់តម្រូវថវិកាកម្មវិធីជាមួយអាទិភាពវិស័យសុខាភិបាលឆ្នាំ២០០៨-១៥ ដោយប្រើប្រាស់ឧបករណ៍ធ្វើផែនការនិងកសាងថវិកានីយប្រចាំឆ្នាំ និងរយៈពេលមធ្យម និងឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុ។<br>• ធានាដល់ការមានធនធានសម្រាប់បន្តការផ្តល់សេវាដោយឥតគិតថ្លៃ សម្រាប់ជំងឺរបេង មេរោគអេដស៍ និងគ្រុនចាញ់។<br>• បង្កើនការវិភាជន៍ថវិកា ប្រកបដោយចីរភាពនិងសមធម៌សម្រាប់ការឆ្លើយតបថ្នាក់ជាតិទៅនឹងជំងឺឆ្លង។ |
| **ធនធានមនុស្ស** | • បង្កើតអភិក្រមទូលំទូលាយ និងក្នុងលក្ខណៈសម្របសម្រួល សម្រាប់កម្មវិធីបណ្តុះបណ្តាលសមស្របទាំងការបណ្តុះបណ្តាលមុន និងក្នុងពេលបំរើការងារដោយផ្តោតការយកចិត្តទុកដាក់លើការអនុវត្តគ្លីនិកនិងសុខភាពសាធារណៈ។ |

| | |
|---|---|
| | • ធ្វើវិមជ្ឈការបន្ថែមទៀតលើការបណ្តុះបណ្តាលបន្តដល់គ្រូបង្គោលថ្នាក់ខេត្ត ។<br>• កសាងសមត្ថភាពថ្នាក់ខេត្តនិងស្រុកទូទៅ (ឧ.ជំនាញគ្រប់គ្រង) ដើម្បីកែលំអវិធីសាស្ត្រតាមដានជំងឺ និងការត្រៀមនិងឆ្លើយតបនឹងការផ្ទុះជំងឺ ។<br>• ពង្រឹងសមត្ថភាពបច្ចេកទេសរបស់បុគ្គលិកថ្នាក់កណ្តាលនិងថ្នាក់ខេត្តសម្រាប់ការតាមដានជំងឺឆ្លងនិងការឆ្លើយតបនឹងការផ្ទុះជំងឺ ការបណ្តុះបណ្តាលផ្នែកអេពីដេមីញ៉ូសាស្ត្រ ការបណ្តុះបណ្តាលសម្រាប់មន្ទីរពិសោធន៍ ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគ្លីនិកសម្រាប់គ្រូពេទ្យព្យាបាល ។<br>• រៀបចំវគ្គបណ្តុះបណ្តាលបំប៉នបន្ថែមលើផ្នែកសំខាន់ៗ ដូចជាការព្យាបាលដោយត្រួតពិនិត្យផ្ទាល់ (DOTS) របេង /HIV របេងស៊ាំនឹងថ្នាំ របេងក្រៅសួត របេងកុមារ និងមន្ទីរពិសោធន៍ និងដើម្បីដាក់បញ្ចូលយុទ្ធសាស្ត្រដូតស៍ទៅក្នុងកម្មវិធីសិក្សារបស់សាលាពេទ្យ និងថែទាំវេជ្ជសាស្ត្រ ។<br>• រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការធ្វើរោគវិនិច្ឆ័យនិងការគ្រប់គ្រងជំងឺគ្រុនឈាមដល់បុគ្គលិកមន្ទីរពេទ្យនិងមណ្ឌលសុខភាព និងផ្តល់ការផ្គត់ផ្គង់សំភារៈបរិក្ខារនិងធនធានមនុស្សដល់មន្ទីរពេទ្យខេត្ត– ក្រុងទាំងអស់និងមន្ទីរពេទ្យថ្នាក់ស្រុកមួយចំនួនក្នុងអំលុងពេលមានផ្ទុះជំងឺគ្រុនឈាម ។ |
| **ប្រព័ន្ធព័ត៌មានសុខាភិបាល** | • ពង្រឹងប្រព័ន្ធតាមដានជំងឺ (ប្រព័ន្ធប្រកាសអាសន្នពីដំបូង) និងស្តង់ដារនៃនីតិវិធី រួមទាំងការគាំទ្រផ្នែកព័ត៌មានវិទ្យា ការធ្វើបច្ចុប្បន្នភាពនិយមន័យជំងឺ ការជូនដំណឹងជាមុន ការបញ្ជាក់ពីមន្ទីរពិសោធន៍និងនីតិវិធីឆ្លើយតប ការគូសផែនទីប្រជាជនដែលប្រឈមមុខនឹងគ្រោះថ្នាក់ និងការចែករំលែកទិន្នន័យ និងការបោះពុម្ពផ្សាយ ។<br>• ធ្វើវិមជ្ឈការការងារតាមដាន និងត្រៀមសម្រាប់ការផ្ទុះជំងឺ ដោយមានវិធានការកណ្តាលសម្រាប់ប្រើប្រាស់ធនធានដែលមានស្រាប់នៅពេលមានផ្ទុះជំងឺ ។<br>• ពង្រឹងការត្រួតពិនិត្យតាមដានភាពស៊ាំនៃឱសថ និងបង្កើតមណ្ឌលតាមដានភាពស៊ាំម៉ូលេគុលនៅថ្នាក់ជាតិ ។<br>• សមាហរណកម្មពេញលេញនៃប្រព័ន្ធរាយការណ៍ និងត្រួតពិនិត្យតាមដានរបស់កម្មវិធីទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាលនៅថ្នាក់ប្រតិបត្តិ ។<br>• បង្កើតយន្តការសម្រាប់ផ្តល់ព័ត៌មានអំពីហានិភ័យ ក្នុងចំណោមនាយកដ្ឋានទាំងឡាយក្នុងក្រសួងសុខាភិបាល ។<br>• សមាហរណកម្មនិងសម្របសម្រួលប្រព័ន្ធតាមដានគ្លីនិក ប្រព័ន្ធតាមដានតាមមន្ទីរពិសោធន៍ និងប្រព័ន្ធតាមដានបសុសត្វ (សម្រាប់ជំងឺដែលឆ្លងពីសត្វមក |

| | |
|---|---|
| | មនុស្ស) ដែលមាននៅនឹងកន្លែងរួចទៅហើយ។ |
| **អភិបាលកិច្ចប្រព័ន្ធសុខាភិបាល** | • តំរឹមតួនាទីនិងមុខងារ និងរចនាសម្ព័ន្ធនាពេលអនាគតនៃកម្មវិធីជាតិស្របតាមវិមជ្ឈការនិងវិសហមជ្ឈការនិងផែនការអភិវឌ្ឍន៍ស្ថាប័នក្រសួងសុខាភិបាល។<br>• ប្រើប្រាស់គំរូដែលបានឯកភាពគ្នា និងប្រព័ន្ធគ្រប់គ្រងសម្រាប់ការអនុវត្តសកម្មភាពកម្មវិធីដែលបានទទួលការគាំទ្រផ្នែកថវិកាពីខាងក្រៅ ដើម្បីគាំទ្រការផ្តល់សេវាសុខភាពនៅថ្នាក់ខេត្តនិងស្រុក។<br>• បង្កើតនិងអនុវត្តវិធីសុខដុមនីយកម្មសម្រាប់ការត្រួតពិនិត្យតាមដាននិងវាយតម្លៃជាផ្នែករួមនៃផែនការសកម្មភាពសុខដុមនីយកម្មការតំរៀបតំរង់ដើម្បីលទ្ធផល។<br>• អភិវឌ្ឍយុទ្ធសាស្ត្រជាតិទូលំទូលាយដោយផ្អែកលើភ័ស្តុតាងសម្រាប់ជំងឺគ្រុនឈាមរួមទាំងការប្រយុទ្ធនិងភ្នាក់ងារចម្លងការងារតាមដាន ការឆ្លើយតបនិងការផ្ទុះជំងឺការគ្រប់គ្រងករណីជំងឺនិងការអប់រំនិងការយល់ដឹងរបស់សហគមន៍។<br>• អភិវឌ្ឍគោលនយោបាយជាតិទូលំទូលាយមួយ និងគោលការណ៍ណែនាំបច្ចេកទេស ជាក់ស្តែងសម្រាប់ការឆ្លើយតបនឹងគ្រោះអាសន្ននិងគ្រោះមហន្តរាយ។<br>• គោលនយោបាយស្តីពីការអនុវត្តន៍ក្នុងវិស័យឯកជនសម្រាប់ការចែកចាយឱសថដើម្បីកាត់បន្ថយការវិវត្តន៍ទៅជាការស៊ាំនឹងអង់ទីប៊ីយ៉ូទិកនិងឱសថគ្រុនចាញ់។<br>• មគ្គុទ្ទេសក៍ភាពប្រកបដោយប្រសិទ្ធភាពនៃវិស័យរដ្ឋ និងវិស័យក្រៅរដ្ឋាភិបាលសម្រាប់ការអនុវត្តន៍ការឆ្លើយតបទៅនឹងមេរោគអេដស៍/ជំងឺអេដស៍ នៅថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន។<br>• បង្កើនលទ្ធភាពទទួលបានព័ត៌មានសម្រាប់អ្នកតាក់តែងគោលនយោបាយ និងអ្នករៀបចំផែនការកម្មវិធី តាមរយៈការតាមដាន ការវាយតម្លៃ និងការស្រាវជ្រាវ។<br>• សហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាផ្នែកឯកជនដែលពាក់ព័ន្ធ បង្កើតយន្តការមួយសម្រាប់ដោះស្រាយការប្រយុទ្ធនឹងជំងឺឆ្កែឆ្កួត និងជំងឺដែលឆ្លងពីសត្វមកមនុស្សផ្សេងៗទៀត។<br>• ការចូលរួមអន្តរវិស័យសម្រាប់មគ្គុទេសក៏ភាពសុខាភិបាល រួមទាំងជាពិសេសទឹក ស្អាតនិងអនាម័យ និងការកំចាត់ភ្នាក់ងារចម្លងរោគ។<br>• អភិវឌ្ឍយុទ្ធសាស្ត្រនិងផែនការជាក់លាក់ ដើម្បីឱ្យផ្នែកឯកជនចូលរួមនៅក្នុងសកម្មភាពកំចាត់ជំងឺរបេងក៏ដូចជាយុទ្ធសាស្ត្រនិងផែនការដើម្បីដោះស្រាយជំងឺរបេងស្ទួត អវិជ្ជមានបេកា ជំងឺរបេងក្រៅសួត ជំងឺរបេងដែលស៊ាំនឹងថ្នាំ និងជំងឺរបេងកុមារ។<br>• ធ្វើការអង្កេតដែលសំខាន់សម្រាប់ការកំចាត់រោគរបេង ដូចជាការអង្កេតស្តីពី |

| | |
|---|---|
| | អត្រាប្រេវ៉ាឡង់ជំងឺរបេង ការអង្កេតស្តីពីភាពស៊ាំនឹងថ្នាំរបស់ជំងឺរបេង ។ល។ និងរៀបចំ ការសិក្សាផ្សេងៗទៀត រួមទាំងការស្រាវជ្រាវប្រតិបត្តិ/គ្លីនិកស្តីពី ឥរិយាបថស្វែងរក ការថែទាំសុខភាពរបស់អ្នកជំងឺរបេង ផលប៉ះពាល់នៃជំងឺរបេងទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ។ល។<br>• បន្តការស្រាវជ្រាវការព្យាបាលគ្រុនចាញ់ដោយ artesunate តាមរយៈការសិក្សាតាមដានភាពស៊ាំនៃឱសថ ។<br>• ធ្វើបច្ចុប្បន្នភាពសេចក្តីណែនាំព្យាបាលដោយផ្អែកលើភស្តុតាងដែលលេចឡើង ។<br>• ពង្រឹងក្របខ័ណ្ឌនៃប្រព័ន្ធប្រកាសអាសន្នពីដំបូង សម្រាប់ការប្រយុទ្ធនឹងជំងឺឆ្លង និងការជូនដំណឹងជាមុន ដោយការពិនិត្យឡើងវិញ/ការបង្កើត/ការអនុម័តច្បាប់ និងគោលនយោបាយជាតិដោយពិចារណាអំពីនិយ័តកម្មសុខភាពអន្តរជាតិដែលទើបកែសម្រួលថ្មី ។ |

## ៣.៤ គោលដៅចំណុចនិងសូចនាករនៃផ្នែកកម្មវិធីជំងឺឆ្លង

| សូចនាករ | ប្រចាំឆ្នាំ | ព.ស.ភ ស្នូល | ទិន្នន័យដើមគ្រា ២០០៧-២០០៨ | គោលដៅចំណុច ២០១០ (២០១១ ព.ព.អ) | គោលដៅចំណុច ២០១៥ ការវាយតម្លៃ |
|---|---|---|---|---|---|
| **ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា** | | | | | |
| អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមមនុស្សអាយុ១៥-៤៩ | | | ០,៦<br>០,៩ | < ០,៦<br>< ០,៩ | < ០,៦<br>< ០,៩ |
| អត្រាស្លាប់នៃជំងឺរបេង លើប្រជាជន ១០០.០០០ នាក់ | | | ៧៥ | ៦០ | ៣២ |
| អត្រាស្លាប់ដោយជំងឺគ្រុនចាញ់ លើប្រជាជន ១.០០០ នាក់ | | | ០,៣៦ | ០,២ | ០,១ |
| **ប្រព័ន្ធព័ត៌មានសុខាភិបាល** | | | | | |
| ៉ នៃស្ត្រីមានផ្ទៃពោះដែលបានទទួល ART សម្រាប់ PMTCT | ✓ | ✓ | ៧ | ៤៥ | ៧៥ |
| ចំនួនកន្លែងផ្តល់ប្រឹក្សា-ធ្វើតេស្តឈាមដោយសម្ងាត់ និងស្ម័គ្រចិត្តដែលដំណើរការនៅក្នុងវិស័យសាធារណៈនិងវិស័យមិនគិតផលកម្រៃ | ✓ | | ១៩៤ | ២៥០ | >២៥០ |
| ៉ នៃអ្នកផ្ទុកមេរោគអេដស៍ដែលប្រើឱសថពន្យាជីវិតនៅរស់ក្រោយការព្យាបាលរយៈពេល ១២ខែ | ✓ | ✓ | គ.ព | >៨៥ | > ៨៥ |
| អត្រាស្រាវជ្រាវករណីជំងឺរបេងស្ងួត បេកាវិជ្ជមាន (៉) | ✓ | ✓ | ៦៦ | >៧០ | >៧០ |
| អត្រាជាសះស្បើយនៃការព្យាបាលជំងឺរបេង (៉) | ✓ | ✓ | >៨៥ | >៨៥ | >៨៥ |
| អាំងស៊ីដង់គ្រុនចាញ់ក្នុងមនុស្ស ១.០០០ នាក់ដែលបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាល | | | ៤,២ | ៣,៥៨ | ២,១៦ |

| | | | | | |
|---|---|---|---|---|---|
| ចំនួនករណី គ្រុនចាញ់ដែលបានព្យាបាលនៅមូលដ្ឋានសុខាភិបាល សាធារណ:ក្នុងចំណោមប្រជាជន ១.០០០ នាក់ | ✓ | ✓ | ៤ | ៣,៥ | ៣ |
| % នៃគ្រួសាររស់នៅតំបន់ជំងឺគុនចាញ់ខ្ពស់ (១គ.មពីព្រៃ)នៃខេត្ត-ក្រុងទាំង ២០ ដែលមានមុងជ្រលក់ថ្នាំគ្រប់គ្រាន់ (មុង១សំរាប់មនុស្ស២នាក់) | ✓ | | ៦៤ | ៨៥ | ៩៥ |
| អត្រាស្លាប់ដោយជំងឺគ្រុនឈាមរាយការណ៍ដោយមូលដ្ឋានសុខាភិបាល | | | ០,៧៤ | ០,៥ | ០,៣ |

**គ.ព:** គ្មានពត៌មាន

# ៤. ផ្នែកកម្មវិធីជំងឺមិនឆ្លងនិងបញ្ហាសុខភាពដទៃទៀត

គ្រោះថ្នាក់គឺជាមូលហេតុនាំមុខមួយនៃមរណ:ភាពសម្រាប់កុមារ ។សុខភាពផ្លូវចិត្តនិងការប្រើប្រាស់គ្រឿងញៀនអាចជាកត្តាពាក់ព័ន្ធធ្ងន់ធ្ងរចំពោះការរំលោភនិងអំពើហឹង្សាប្រឆាំងស្ត្រីនិងកុមារ ។ អត្រាឈឺដោយសារជំងឺរ៉ាំរ៉ៃធ្វើឱ្យផលិតភាពធ្លាក់ចុះ ហើយថ្លៃចំណាយលើការមកព្យាបាលយឺតយ៉ាវ ដូចជាជំងឺលើសឈាមនិងទឹកនោមផ្អែមអាចជាមូលហេតុធ្វើឱ្យមហន្តរាយដល់អ្នកដែលមានប្រាក់ចំណូលទាប ។ ជំងឺទឹកនោមផ្អែមគឺជាកត្តាមួយដែលរួមចំណែកដល់ផលវិបាកក្នុងពេលមានផ្ទៃពោះ ។ បញ្ហាសុខភាពផ្សេងៗទៀតគឺពាក់ព័ន្ធទៅនឹងភាពបំពុលនៃបរិស្ថាននិងការផ្លាស់ប្តូរអាកាសធាតុជាសកលកង្វះអនាម័យនិងភាពស្អាត ក៏ដូចជាលទ្ធភាពទទួលបានទឹកស្អាត ។

ជំងឺមិនឆ្លងនឹងបង្កជាបន្ទុកកាន់តែខ្លាំងមួយដល់ប្រព័ន្ធសុខាភិបាលទាំងមូលហើយនឹងក្លាយជាបញ្ហាដែលគេអាចមើលឃើញកាន់ច្បាស់មួយនៅក្នុងរយ:ពេលប៉ុន្មានឆ្នាំខាងមុខនេះ ។

យុទ្ធសាស្ត្រចម្បងដើម្បីដោះស្រាយជំងឺមិនឆ្លង គឺចាំបាច់ត្រូវធ្វើការបង្ការ ហើយក្រសួងសុខាភិបាលចាំបាច់ត្រូវពង្រឹងនិងត្រួតពិនិត្យតាមដានវិធានការបង្ការនៅគ្រប់វិស័យទាំងអស់ ។ ការកំណត់អាទិភាពប្រកបដោយប្រសិទ្ធភាព គឺជាបញ្ហាគន្លឹះមួយសម្រាប់បន្តការរៀបចំកម្មវិធីជំងឺមិនឆ្លង ហើយជំងឺនានាដែលបានជ្រើសរើសសម្រាប់ការកំណត់អាទិភាពនឹងត្រូវដាក់បញ្ចូលជាសមាសធាតុជាមូលដ្ឋាននៃស.ស.អ និងស.ស.ប ។

## ៤.១ បញ្ហាប្រឈមមុខ

បញ្ហាដែលកាន់តែធំមួយសម្រាប់សេវាសុខភាពកម្ពុជា គឺការចេះតែកើនឡើងនៃការឈឺនិងការស្លាប់នៃប្រជាជនកម្ពុជាដែលបណ្តាលមកពីជំងឺមិនឆ្លង **មុនពេល**មានការថយចុះស្របគ្នានៃជំងឺឆ្លងកើតមាន

ខ. ការលេចឡើងបន្ទុកទ្វេនៃជំងឺ ។

ការកើនឡើងនៃជំងឺមិនឆ្លងដែលបានចុះបញ្ជីគឺត្រូវបានពន្យល់ដោយកត្តាជាច្រើនដូចជា:

- កត្តានៃការផ្លាស់ប្តូររបៀបរស់នៅនិងការប្រព្រឹត្តិ“ ឥរិយាបទប្រឈមមុខនឹងគ្រោះថ្នាក់” ដូចជាការជក់បារី ការផ្លាស់ប្តូរទម្លាប់នៃការហូបចុក ការផឹកគ្រឿងស្រវឹង ការប្រើថ្នាំញៀន

បន្តិចម្តងៗនឹងនាំឱ្យកើនជាលំដាប់នូវអត្រាអាំងស៊ីដង់ និងប្រេវ៉ាឡង់នៃជំងឺ បេះដូង-សរសៃឈាម រួមមានជំងឺលើសឈាម ជំងឺមហារីក ជំងឺទឹកនោមផ្អែម និងជំងឺដាច់សរសៃឈាមក្នុងខួរក្បាល។

- ការកែលំអការធ្វើរោគវិនិច្ឆ័យ និងការកែលំអលទ្ធភាពទទួលយកការថែទាំសុខភាព នឹងរកឃើញនូវជំងឺមិនឆ្លងដែលកាលពីមុនរកមិនឃើញ។
- ក្នុងខណៈដែលមិនមានសកម្មភាពទប់ស្កាត់ ការរីកលូតលាស់នៃតំបន់ទីក្រុង និងការកើនឡើងនៃចរាចរនឹងរួមចំណែកគ្នាធ្វើឱ្យមានការកើនឡើងករណីគ្រោះថ្នាក់ចរាចរណ៍តាមផ្លូវ និងការកើនឡើងនៃជំងឺដែលបណ្តាលមកពីបរិស្ថានមិនស្អាត។
- ជំងឺមិនឆ្លងនឹងលេចឡើងពីចំណោមប្រជាជនដែលមានអាយុច្រើន និងបណ្តាលឱ្យមានកម្រិតកាន់តែខ្ពស់នៃជំងឺដែលទាក់ទងនឹងសរសៃប្រសាទជាឧទាហរណ៍។ ពិការភាពដែលបណ្តាលមកពីជំងឺភ្នែកនិងរលាកសន្លាក់ ក៏បណ្តាលឱ្យមានការកើនឡើងនូវបន្ទុកនិងក្លាយទៅជាបន្ទុកដ៏សំខាន់មួយចំពោះបុគ្គល និងសេវាសុខភាពនានាផងដែរ។
- ការផ្លាស់ប្តូរការយល់ដឹង និងតម្លៃអាចធ្វើឱ្យជំងឺផ្លូវចិត្តមានកាន់តែច្រើន ដែលទាមទារនូវអន្តរាគមន៍វេជ្ជសាស្ត្រ។
- កំណើនសេដ្ឋកិច្ចឆាប់រហ័សនិងឧស្សាហកម្មវូបនីយកម្ម ធ្វើឱ្យមានការកើនឡើងនៃការគំរាមកំហែងដល់សុខភាពបរិស្ថាន។

កំណើនប្រេវ៉ាឡង់នៃជំងឺមិនឆ្លងនឹងដើរតួសំខាន់មួយ សម្រាប់ការឆ្លើយតបនៃប្រព័ន្ធសុខាភិបាល ដោយសារហេតុផលបីយ៉ាង:

- សេវាសុខភាពសព្វថ្ងៃ គឺត្រូវបានបំពាក់សម្ភារៈល្អបំផុត សម្រាប់ការដោះស្រាយជំងឺឆ្លង និងការថែទាំសុខភាពមាតានិងទារក។ ដើម្បីដោះស្រាយកំណើនយ៉ាងឆាប់រហ័សនៃជំងឺមិនឆ្លងឱ្យបានក្នុងរយៈពេលខ្លីមួយ គឺត្រូវការប្រមូលផ្តុំបទពិសោធន៍គ្លីនិក និងបង្កើតទៅជាគោលការណ៍ណែនាំគ្លីនិក បង្រៀនបុគ្គលិកសារឡើងវិញ និងធ្វើឱ្យសាធារណៈជនយល់ដឹងពីលទ្ធភាពដែលអាចទទួលរងគ្រោះដោយជំងឺទាំងនេះ។
- ជាញឹកញាប់ទាមទារការព្យាបាលមួយជីវិត និងចំណាយច្រើនទាំងសម្រាប់ប្រព័ន្ធសុខាភិបាល និងសម្រាប់អ្នកជំងឺ។ទិដ្ឋភាពនៃការចំណាយលើជំងឺមិនឆ្លងនឹងក្លាយទៅជាសមាសធាតុសំខាន់មួយ ក្នុងការបង្កើតឡើងនូវសមាសធាតុធានារ៉ាប់រងនានានៅក្នុងយុទ្ធសាស្ត្រហិរញ្ញប្បទានសុខាភិបាល។វិធានការអាទិភាវូបនីយកម្មដែលបានពិភាក្សាខាងលើ គឺមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីសម្រេចបានថវិកាសមស្របសម្រាប់ជំងឺមិនឆ្លង ក្នុងការបណ្តុះបណ្តាលបុគ្គលិកនៅក្នុងកម្មវិធីឱសថនិងក្នុងការតាក់តែងវិធានការការពារ។

- ជំងឺមិនឆ្លងជាច្រើនអាចទប់ស្កាត់បានដោយប្រើវិធានការការពារ។ វិធានការទាំងនោះទាមទារការសហការកម្រិតខ្ពស់មួយរវាងក្រសួងនានា និងវិស័យនៅក្នុងវិធីសាស្ត្រពហុវិស័យ។ "ពហុវិស័យ" បែបនេះជារឿយៗមានការលំបាកដោយសារភាពផ្ទុយគ្នានៃគោលដៅក្នុងវិស័យ និងទាមទារឱយមានការចែកចាយព័ត៌មាន ស្តីអំពីផលលំបាកនៃវិធានការគោលនយោបាយ និងការវិនិយោគ។

## ៤.២ អាទិភាព សេវាសារវន្ត គោលបំណង និងគោលដៅនៃផ្នែកកម្មវិធីជំងឺមិនឆ្លងនិងបញ្ហាសុខភាពផងទៃទៀត

| គោលបំណង៣: បន្ថយបន្ទុកជំងឺមិនឆ្លង និងបញ្ហាសុខភាពផងទៃទៀត | |
|---|---|
| គោលដៅ | ១០ កាត់បន្ថយឥរិយាបទគ្រោះថ្នាក់នាំទៅរកជំងឺមិនឆ្លង: ទឹកនោមផ្អែម ជំងឺបេះដូង-សរសៃរឈាម មហារីកសុខភាពផ្លូវចិត្ត ការប្រើប្រាស់គ្រឿងញៀន គ្រោះថ្នាក់និងរបួស ការថែទាំភ្នែក សុខភាពមាត់ធ្មេញ ។ល។ |
| | ១១ លើកកំពស់លទ្ធភាពមកទទួលយកសេវាព្យាបាល និងការស្តារនិតិសម្បទាបង្ករឡើងដោយជំងឺមិនឆ្លង: ទឹកនោម ផ្អែម ជំងឺបេះដូង-សរសៃរឈាម មហារីកសុខភាពផ្លូវចិត្ត ការប្រើប្រាស់គ្រឿងញៀន គ្រោះថ្នាក់ និងរបួស ការថែទាំភ្នែក សុខភាពមាត់ធ្មេញ។ល។ |
| | ១២ ធានាដំណើរការមុខងារសារវ័ន្តនៃសុខភាពសាធារណ: សុខភាពបរិស្ថាន សុវត្ថិភាពចំណីអាហារ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការត្រៀមលក្ខណ: (សំរាប់គ្រាអាសន្ន)។ |

**អាទិភាពនិងសេវាផាសារវន្ត**

- ជំងឺទឹកនោមផ្អែម
- ជំងឺមហារីក
- ជំងឺសរសៃរឈាមនិងបេះដូង
- សុខភាពផ្លូវចិត្ត រួមទាំងការ ប្រើប្រាស់គ្រឿងញៀន
- ការបង្ការជំងឺខ្វាក់
- សុខភាពមាត់ធ្មេញ
- ហានិភយ័សុខភាពបរិស្ថាន
- របួស គ្រោះថ្នាក់
- សុខភាពការងារ
- ការស្តារនីតិសម្បទា
- រោគមនុស្សចាស់
- សុវត្ថិភាពចំណីអាហារ
- ថ្នាំជក់

## ៤.៣ ការអនុវត្តន៍យុទ្ធសាស្ត្រផ.យ.ស.២ ក្នុងផ្នែកកម្មវិធីជំងឺមិនឆ្លងនិងបញ្ហាសុខភាពផ្សេងទៀត

ផែនការយុទ្ធសាស្ត្រ ជ.ម.ឆ ពាក់ព័ន្ធដែលកំពុងអភិវឌ្ឍបច្ចុប្បន្ននេះនិងត្រូវបញ្ចប់ក្នុងពេលខាងមុខរួមមាន :ផែនការយុទ្ធសាស្ត្រជាតិសំរាប់ជ.ម.ឆ២០០៧-២០១០ ផែនការសកម្មភាពជាតិស្តីពីសុខភាពបរិដ្ឋាន២០០៧-២០១០ ផែនការយុទ្ធសាស្ត្រសុខភាពផ្លូវចិត្ត២០០៨-២០១២ និងផែនការយុទ្ធសាស្ត្រសកម្មភាពជាតិស្តីពីការគ្រប់គ្រងថ្នាំជក់។

ផែនការយុទ្ធសាស្ត្រជ.ម.ឆផ្តល់នូវក្របខណ្ឌកំរតិខ្ពស់សំរាប់ការធ្វើផែនការអំពីជ.ម.ឆទាំងអស់។ ផែនការនេះមានគោលបំណង៤: (១)ពង្រឹងការគ្រប់គ្រងស្ថាប័ន និងអនុវត្តរចនាសម្ពន្ធ័សំរាប់ជ.ម.ឆ (២)អភិវឌ្ឍប្រព័ន្ធតាមដានជ.ម.ឆ (៣)កាត់បន្ថយកត្តាគ្រោះថ្នាក់របស់ប្រជាជន (៤)សមធម៌នៃជ.ម.ឆ ឈរលើមូលដ្ឋានប្រព័ន្ធសុខាភិបាល។

ផែនការសកម្មភាពជាតិស្តីពីសុខភាពបរិដ្ឋាន២០០៧-២០១០ និងផែនការយុទ្ធសាស្ត្រសកម្មភាពជាតិស្តីពីការគ្រប់គ្រងថ្នាំជក់ គឺជាផែនការអន្តរវិស័យ មិនគ្រាន់តែមានការចូលរួមពីក្រសួងសុខាភិបាលប៉ុណ្ណោះទេ គឺមានទាំងពីក្រសួងនិងអាជ្ញាធរជាតិដទៃទៀតដោយរាប់ទាំងក្រសួងបរិស្ថាន អប់រំ-យុវជននិងកីឡា ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ ពាណិជ្ជកម្ម យុត្តិធម៌ ធនធានទឹក រដ្ឋសភាជាតិ និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។ ផ្នែកជាអាទិភាពចំនួន៨នៃបរិដ្ឋាន ត្រូវបានកំណត់សំរាប់ប្រទេសកម្ពុជាហើយដែលយុទ្ធសាស្ត្រនិងអន្តរាគមន៍អន្តរវិស័យបាននឹងកំពុងអភិវឌ្ឍ។ ផ្នែកទាំងអស់នោះគឺ: ការផ្គត់ផ្គង់ទឹកនិង គុណភាពទឹក អនាមយ័និងភាពស្អាត គុណភាពខ្យល់ កាកសំណល់រឹងសារជាតិពុលនិងគ្រោះថ្នាក់សុខភាពវិជ្ជាជីវៈការផ្លាស់ប្តូរអាកាសធាតុនិងប្រព័ន្ធអេកូ គ្រោះមហន្តរាយ និងសង្គ្រោះបន្ទាន់។

សេចក្តីព្រាងនៃផែនការយុទ្ធសាស្ត្រសុខភាពផ្លូវចិត្ត២០០៨-២០១២ បានកំណត់គោលដៅចំបង ៣:(១)ពង្រីក និងលើកកំពស់ការចែកចាយដោយសមធម៌នូវសេវាព្យាបាល បង្ការ និងលើកកំពស់សុខភាពជាមូលដ្ឋាន តាមរយៈស.ស.អ នៅមណ្ឌលសុខភាពនិង ស.ស.ប នៅមន្ទីរពេទ្យបង្អែក។ (២)កែលំអគុណភាពនៃការបណ្តុះបណ្តាលមុននិងក្រោយបញ្ចប់ការសិក្សា និងការបណ្តុះបណ្តាលលើការថែទាំ បែងចែកបុគ្គលិកដោយសមធម៌ បង្កើនបៀវត្សតាមរយៈកំណែទំរង់បៀវត្សរបស់រាជរដ្ឋាភិបាល និងវិធានការគ្រប់គ្រងបុគ្គលិក (៣)អភិវឌ្ឍច្បាប់និងគោលនយោបាយ ព្រមទាំងពង្រឹងរចនាសម្ពន្ធ័ស្ថាប័នសុខភាពផ្លូវចិត្ត ដើម្បីលើកស្ទួយការផ្តល់សេវា ការធ្វើផែនការ និងការសំរបសំរួលមានប្រសិទ្ធភាព។ អន្តរាគមន៍ជាយុទ្ធសាស្ត្រ សំរាប់គោលដៅនិមួយៗ ត្រូវបានអភិវឌ្ឍទៅតាមយុទ្ធសាស្ត្រទាំង៥ របស់ .យ.ស.២ ដើម្បីធានាដល់ការតំរៀបតំរង់យ៉ាងជិតស្និទ្ធទៅនឹងមជ្ឈមណ្ឌល/កម្មវិធីដទៃទៀតរបស់ក្រសួងសុខាភិបាល ហើយអនុញ្ញាតិឱយមានការបំពេញបន្ថែមកំលាំងគ្នាទៅវិញទៅមកសំរាប់ផ្នែកសំខាន់ៗដែលមានការខ្វះខាតធនធាន។

ស្របតាមផែនការយុទ្ធសាស្ត្រជាតិស្តីពីជំងឺមិនឆ្លង ការធ្វើកម្មវិធីត្រូវតែផ្តោតជាសំខាន់លើវិធានការការពារ។ យុទ្ធសាស្ត្របង្ការត្រូវការចាំបាច់នូវសេចក្តីណែនាំថ្នាក់ជាតិរឹងមាំ ហើយស្របទៅតាមបទដ្ឋានស្តង់ដារនិងគំរូអន្តរជាតិ។បន្ថែមលើសនេះទៀតម៉្យដែលជាតិក៏ត្រូវបង្កើតដែរ។ អនុសញ្ញាស្តីពីថ្នាំជក់គឺជាចំណុចចាប់ផ្តើមមួយ ក្នុងចំណោមចំណុចចាប់ផ្តើមជាច្រើនទៀត ដើម្បីបង្កើតឡើងនូវគោលការណ៍ណែនាំទាំងនោះ។ គោលការណ៍ណែនាំត្រូវតែមានលក្ខណៈឆ្លងវិស័យ។ ក្រសួងសុខាភិបាលត្រូវតែជាចំណុចគោលសម្រាប់ ការសហការអន្តរក្រសួង ដើម្បីនាំយកទិដ្ឋភាពនៃការការពារជំងឺទៅបង្កើតជាគោលនយោបាយដែលអាចប្រើបាននៅគ្រប់ក្រសួងទាំងអស់។

អត្រាអាំងស៊ីដង់និងប្រេវ៉ាឡង់កាន់តែខ្ពស់នៃជំងឺមិនឆ្លង ទាមទារនូវការព្យាបាលយូរអង្វែង និងចំណាយច្រើនក៏ដូចជាការស្តារនីតិសម្បទា និងការថែទាំបណ្តោះអាសន្នត្រូវការនូវការកំណត់អាទិភាព។ ការបង្កើតគោលការណ៍ណែនាំសម្រាប់ព្យាបាលនិងស្តារនីតិសម្បទានៃជំងឺមិនឆ្លង ត្រូវតែពិចារណាជាផ្នែកមួយនៃការកែសម្រួល ស.ស.អ និង ស.ស.ប។

ការសិក្សាទូទៅមួយពីការកំណត់អាទិភាព ដោយប្រើប្រាស់វិធីសាស្ត្ររួមបញ្ចូលគ្នាមួយដែលទាក់ទង នឹងក្រមសីលធម៌ សេដ្ឋកិច្ច និងអេពីដេមីសាស្ត្រ ត្រូវបានស្នើឡើងដើម្បីឱ្យក្លាយជាទីតាំងឈរជើងសម្រាប់ការបង្កើតនូវគោលការណ៍ណែនាំទាំងនេះ និងសម្រាប់ការកែសម្រួល ស.ស.អ និង ស.ស.ប។ ការកែសម្រួលស.ស.អ និងស.ស.ប នឹងមានផលសំខាន់ដល់ថវិកាសុខាភិបាលទូទៅ និងការចំណាយដើម្បីពង្រីកសេវាសុខភាព។

កិច្ចខិតខំប្រឹងប្រែងនានា ក្នុងការធ្វើអង្កេតពីការវិវត្តន៍អេពីដេមីសាស្ត្រនៃជំងឺមិនឆ្លង និងត្រូវការនូវប្រភពធនធានដែលមាននៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល។

| **យុទ្ធសាស្ត្រផ.យ.ស.២** | **សមាសភាគនិងអន្តរាគមន៍សំខាន់ៗនៃផ្នែកកម្មវិធីជំងឺមិនឆ្លង** |
|---|---|
| **ការផ្តល់សេវាសុខភាព** | • ពង្រឹងការបង្ការតាមរយៈសកម្មភាពអប់រំលើកកំពស់សុខភាពសំរាប់ជ.ម.ឆ ក្នុងនេះរួមមានលើកកំពស់ការយល់ដឹងនិងរបៀបរបបរស់នៅមានសុខភាពល្អ<br>• ពង្រឹងការពិនិត្យរកនិងការគ្រប់គ្រងជំងឺមិនឆ្លង នៅក្នុងស.ស.អនិងស.ស.ប និងតាមរយៈប្រពន្ធ័បញ្ជូនជំងឺរឹងមាំ និងការអភិវឌ្ឍន៍ការថែទាំបន្តគ្រប់ជ្រុងជ្រោយសំរាប់ជ.ម.ឆ ដោយរួមមានសេចក្តីណែនាំស្តីពីការព្យាបាលនិងការស្តារនិតិសម្បទា។<br>• តំរៀបតំរង់មូលដ្ឋានសុខាភិបាលនិងសេវាសំរាប់ក្រុមប្រជាជនប្រឈមមុខនឹងគ្រោះថ្នាក់តាមរយៈផែនការគ្របដណ្តប់សុខាភិបាលដោយមានទិន្នន័យស្តីពីសេចក្តីត្រូវការនៃការផ្តល់សេវាដែលរំពឹងទុករួមមានគ្រោះថ្នាក់ចរាចរនិងការថែទាំសង្គ្រោះបន្ទាន់។ |

| | |
|---|---|
| | • អភិវឌ្ឍ និងពង្រីកសេវាឯកទេសសំរាប់សុខភាពផ្លូវចិត្ត ដោយរាប់បញ្ចូលទាំងការប្រើប្រាស់ថ្នាំញៀន តាមរយៈសកម្មភាពអប់រំសុខភាពនិងបង្ការនៅគ្រប់ខេត្ត-ក្រុង ពង្រីកសេវាសំរាកព្យាបាល និងពិនិត្យជំងឺផ្លូវចិត្តនៅថ្នាក់ស.ស.ប.កំរិត៣ ទាំងអស់ លើកកំពស់ការគ្របដណ្តប់សេវាជំងឺផ្លូវចិត្ត នៅមន្ទីរពេទ្យបង្អែកស.ស.ប.កំរិត១និង២ និងបង្កើតមណ្ឌលស្តារនិតិសម្បទាជំងឺផ្លូវចិត្តថ្នាក់តំបន់បន្ថែមមួយថ្មីទៀតនៅមន្ទីរពេទ្យបង្អែកស.ស.ប.កំរិត៣។<br>• អភិវឌ្ឍ អនុវត្តពិធីសារ សេចក្តីណែនាំអនុវត្តគ្លីនិក និតិក្រម បទដ្ឋាននៃការថែទាំក្រមសីលធម៌នៃការអនុវត្តន៍គ្លីនិកផ្នែកព្យាបាលជំងឺផ្លូវចិត្តរាប់ទាំងគំរូនៃការអនុវត្តន៍គ្លីនិកនិងសេចក្តីណែនាំក្រមសីលធម៌ក្នុងជំងឺផ្លូវចិត្តសំរាប់ប្រើប្រាស់ដោយវេជ្ជបណ្ឌិតនិងគិលានុប្បដ្ឋាកយិកាបំពេញការងារក្នុងផ្នែកជំងឺផ្លូវចិត្ត។<br>• អភិវឌ្ឍគោលនយោបាយជាតិគ្រប់ជ្រុងជ្រោយ និងសេចក្តីណែនាំបច្ចេកទេសសំរាប់ការសង្គ្រោះបន្ទាន់និងការឆ្លើយតបនឹងគ្រោះមហន្តរាយ។ |
| **ហិរញ្ញប្បទានការថែទាំសុខភាព** | • កាត់បន្ថយឧបសគ្គផ្នែកហិរញ្ញវត្ថុចំពោះការពិនិត្យរក និងព្យាបាលជំងឺមិនឆ្លង ដោយធ្វើការនិយ័តកម្មទៅលើគម្រោងថ្លៃសេវាការពង្រីកមូលនិធិសមធម៌ និងការពង្រីកគម្រោងធានារ៉ាប់រងសុខភាពសហគមន៍ ជាវិធានការរយៈពេលមធ្យមមួយ មុនពេលអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការធានារ៉ាប់រងសុខភាពសង្គមជាសកល។<br>• កៀងគរធនធានបន្ថែម ដើម្បីគ្របដណ្តប់ការចំណាយលើការថែទាំសុខភាព ការបង្ការជំងឺមិនឆ្លង ការលើកកំពស់សុខភាព និងបញ្ហាសុខភាពដទៃទៀតដូចជាគ្រោះថ្នាក់ចរាចរ។ |
| **ធនធានមនុស្សសុខាភិបាល** | • លើកកម្ពស់ជំនាញបច្ចេកទេស និងសមត្ថភាពជំងឺសម្រាប់ការគ្រប់គ្រង និងការបង្ការជំងឺមិនឆ្លង តាមរយៈការបណ្តុះបណ្តាលនិងការអប់រំប្រកបដោយគុណភាព ការរក្សាបុគ្គលិកទុក ការផ្តល់អាជ្ញាប័ណ្ណ និងប្រព័ន្ធចុះបញ្ជីនិងវិធានការគាំទ្រផ្សេងៗទៀត ។<br>• បង្កើតនូវអភិក្រមទូលំទូលាយ មានលក្ខណៈសម្របសម្រួល សម្រាប់កម្មវិធីបណ្តុះបណ្តាលជំងឺមិនឆ្លង ដោយផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនថែមទៀតលើការអនុវត្តន៍គ្លីនិកនិងសុខភាពសាធារណៈ ពិសេសការបង្ការ ។<br>• ដាក់ឱយមានយ៉ាងហោចណាស់ “គ្រូពេទ្យព្យាបាល” ដែលបានទទួលការបណ្តុះបណ្តាលរយៈ៣ខែផ្នែកវិកលវិទ្យា នៅមន្ទីរពេទ្យបង្អែកកំរិត២ទាំងអស់ និងបែងចែកឡើងវិញគិលានុប្បដ្ឋាកយិកា ដែលបានទទួលការបណ្តុះបណ្តាល |

| | |
|---|---|
| | រយៈ៣ខែ ផ្នែកវិកលវិទ្យានិង “គ្រូពេទ្យព្យាបាល” (ជាង៤០០នាក់)ដែលបច្ចុប្បន្នមិនបំរើការក្នុងផ្នែកសុខភាពផ្លូវចិត្ត ដើម្បីធ្វើឱយមានសមធម៌ក្នុងការចែកចាយសេវាទៅកាន់កន្លែងដែលខ្វះខាតសេវាបំរើ។ |
| ប្រពន្ធ័ពត៌មានសុខាភិបាល | • បង្កើតប្រព័ន្ធតាមដាន និងរាយការណ៍អំពីករណី និងការឆ្លើយតបចំពោះជំងឺមិនឆ្លង រួមទាំងគ្រោះថ្នាក់និងរបួស ។<br>• កែសម្រួល និងពង្រឹងការគ្រប់គ្រងកំណត់ត្រាអ្នកជំងឺ (កំណត់ត្រាវេជ្ជសាស្ត្រ ការរក្សាទុកនិងការយកមកប្រើ) នៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ រួមទាំងការដាក់កូដ ICD ។<br>• បង្កើតប្រពន្ធ័ពត៌មានវិទ្យាផ្នែកសុខភាពផ្លូវចិត្តសំរាប់ការស្រាវជ្រាវការត្រួតពិនិត្យតាមដានស្នាដៃការងារនិងការទទួលខុសត្រូវ។<br>• អភិវឌ្ឍប្រពន្ធ័តាមដាន ដើម្បីត្រួតពិនិត្យតាមដានប្រេវ៉ាឡង់នៃការជក់បារីនិងផលប៉ះពាល់នៃគោលនយោបាយ។ |
| អភិបាលកិច្ចប្រពន្ធ័សុខាភិបាល | • អនុវត្តការពិនិត្យវាយតំលៃគ្រប់ជ្រុងជ្រោយអំពីបន្ទុកជំងឺដើម្បីធ្វើជាមូលដ្ឋានសំរាប់ការអភិវឌ្ឍន៍គោលនយោបាយស្តីពីជំងឺមិនឆ្លង។<br>• ពង្រឹងខ្លាំងក្លា ការចូលរួមអន្តរវិសយ័សំរាប់មគ្គុទេសភាព ក្នុងវិសយ័សុខាភិបាលនិងលើកកំពស់ការយល់ដឹងអំពីជ.ម.ឆនិងការបង្ការ ដោយផ្តោតចំបងលើគ្រោះថ្នាក់ចរាចរ ជំងឺទឹកនោមផ្អែម សុខភាពផ្លូវចិត្តនិងការប្រើប្រាស់គ្រឿងញៀន សម្ពាធឈាមខ្ពស់ ។ល។<br>• ក្នុងភាពជាដៃគូជាមួយក្រសួងពាក់ពន្ធ័នានា ពង្រឹងវិធានច្បាប់ថ្នាំជក់-គ្រឿងស្រវឹងក្នុងនេះមានការអភិវឌ្ឍន៍និតិក្រមដែលពាក់ពន្ធ័សំរាប់ការអនុវត្តន៏ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំជក់ ដោយនិយតកម្មការគ្មានផ្សែងបារីកន្លែងធ្វើការនិងទីសាធារណៈ ព្រមទាំងយន្តការនិងវិធានការផាកពិនយ័។<br>• អភិវឌ្ឍគោលនយោបាយសុខភាពផ្លូវចិត្ត ដើម្បីធានាឱយមានការអភិវឌ្ឍន៏សេវាជំងឺផ្លូវចិត្តប្រកបដោយសុខដុមនីយកម្ម និងមានសណ្តាប់ធ្នាប់ និងអភិវឌ្ឍច្បាប់សំរាប់សុខភាពផ្លូវចិត្ត ដើម្បីនិយតកម្មការអនុវត្តន៏សេវាជំងឺផ្លូវចិត្ត ការថែទាំជំងឺផ្លូវចិត្តនិងការចងសម្ពន្ធ័ភាពវិជ្ជាជីវៈ និងការការពារទាំងអ្នកជំងឺនិងអ្នកមានវិជ្ជាជីវៈផ្នែកវិកលវិទ្យា។<br>• អភិវឌ្ឍគោលនយោបាយដើម្បីការពារក្រុមប្រជាជនងាយរងគ្រោះ ដូចជាស្ត្រីនិងកុមារ ដោយសាររបួសនិងអំពើហិង្សា។<br>• អភិវឌ្ឍគោលនយោបាយស្តីអំពីសុខភាពបរិដ្ឋាននិងយុទ្ធសាស្ត្រនានាដែល |

| | |
|---|---|
| | ពាក់ពន្ធ័ក្នុងនេះមានគោលនយោបាយស្តីអំពីការវាយតំលៃផលប៉ះពាល់លើសុខភាពពីការអភិវឌ្ឍន៍និងគំរោងផ្សេងៗ។ |

## ៩.៤ គោលដៅចំណុចនិងសូចនាករនៃផ្នែកកម្មវិធីជំងឺមិនឆ្លងនិងបញ្ហាសុខភាពដទៃទៀត

| សូចនាករ | ប្រចាំឆ្នាំ | ព.ស.ស ឆ្នាំ | ទិន្នន័យមូលដ្ឋាន ២០០៥-២០០៦ | គោលដៅចំណុច ២០១០ ( ២០១១ ព.ព.ស) | គោលដៅចំណុច ២០១៥ ការវាយតម្លៃ |
|---|---|---|---|---|---|
| **ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា** | | | | | |
| ៖ នៃការស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ | | | ៣,៥ | ៣,០ | ២,៨ |
| **ប្រពន្ធ័ពត៌មានសុខាភិបាល** | | | | | |
| ៖ នៃអ្នករបួសដែលមានការប៉ះទង្គិចក្បាលដោយសារគ្រោះថ្នាក់ចរាចរណ៍ដែលបានទទួលការព្យាបាល | ✓ | ✓ | ៤១ | ៣៨ | ៣៥ |
| អាំងស៊ីដង់នៃជំងឺមហារីកមាត់ស្បូនលើមនុស្ស ១០.០០០នាក់ ដែលបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ | ✓ | | ២៥ | ២១ | ១២,៥ |
| ប្រេវាឡង់ជំងឺទឹកនោមផ្អែមលើមនុស្សពេញវ័យដែលបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ | ✓ | ✓ | ២ | <២ | <២ |
| អាំងស៊ីដង់នៃជំងឺលើសឈាមក្នុងចំណោមប្រជាជន ១.០០០ នាក់ | ✓ | | ២០ | ១៩ | ១៥ |
| ៖ នៃមនុស្សពេញវ័យជក់បារី បុរស/ស្ត្រី | ✓ | | ៥៤/៩ | ៤៩/៤ | ៤៤/២ |
| អត្រានៃការងងឹតភ្នែក (៖) | ✓ | | ១,២ | ០,៥ | <០,៣ |
| ៖ នៃកុមារដែលមានធ្មេញពុកមិនបានប៉ះ | ✓ | | ៨,៩ | <៥ | <៥ |
| ចំនួននៃករណីជំងឺផ្លូវចិត្តដែលបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាល | ✓ | ✓ | ១០.០០០ | ១៩.០០០ | ២៨.០០០ |
| ចំនួនអ្នកចាក់គ្រឿងញៀនដែលបានចុះឈ្មោះក្នុងការព្យាបាលជំនួសដោយ Opioids | ✓ | | ១០០ | ៤០០ | ១.២០០ |

# ជំពូក ៦

# ក្របខណ្ឌនៃការអនុវត្តន៍ ត្រួតពិនិត្យតាមដាននិងវាយតំលៃ

- អភិក្រមជំហានៗ
- ក្របខណ្ឌអនុវត្តន៍
- ក្របខណ្ឌត្រួតពិនិត្យតាមដាននិងវាយតំលៃ
- ក្របខណ្ឌសូចនាករ

# ៦ ក្របខណ្ឌអនុវត្តន៍, ត្រួតពិនិត្យតាមដាន, ក្របខណ្ឌវាយតំលៃ

## ១. អតិក្រមជំហានៗក្នុងការអនុវត្តន៍ ផ.យ.ស.២

មានកត្តាបរិបទមួយចំនួនដែលតំរូវឱយការអនុវត្តន៍ ផ.យ.ស.២ ប្រព្រឹត្តទៅតាមលំដាប់លំដោយនៃពេលវេលាក្នុងការឈានឆ្ពោះទៅសំរេចគោលបំណងរបស់ ផ.យ.ស.២ :

- **ទីមួយ -បរិបទគោលនយោបាយ:** ក្រសួងសុខាភិបាលនឹងធ្វើការសំរេចចិត្ត អំពីក្របខណ្ឌគោលនយោបាយសំខាន់ៗដែលទាក់ទងនឹងតំរូវការផ្នែកហិរញ្ញប្បទាន និងអភិបាលកិច្ចប្រពន្ធ័សុខាភិបាលនៅក្នុងក្របខណ្ឌនៃការអនុវត្តន៍កម្មវិធីវិមជ្ឈការនិងវិសហវិមជ្ឈការ ។ ឆ្នាំ២០០៨ត្រូវបានចាត់ទុកថាជាឆ្នាំនៃការត្រៀមរៀបចំដែលក្នុងរយៈពេលនេះបែបបទនៃការសំរេចចិត្តនឹងបញ្ចប់ ហើយប្រព្រឹត្តទៅស្របគ្នាជាមួយនឹងដំណាក់កាលបន្តបន្ទាប់នៃការពង្រឹងនិងការអនុវត្តន៍ ។
- **ទីពីរ -បរិបទស្ថាបន័:** ការចាត់ចែងរៀបចំរចនាសម្ពន្ធ័ស្ថាបន័សុខាភិបាល និងការកសាងសមត្ថភាពស្ថាបន័ នឹងប្រព្រឹត្តទៅនៅគ្រប់ថ្នាក់នៅក្នុងប្រពន្ធ័សុខាភិបាល-ថ្នាក់កណ្តាល ខេត្ត- ក្រុង ស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាលដោយរាប់បញ្ចូលទាំងសហគមន៍ ។
- **ទីបី -បរិបទសេដ្ឋកិច្ច:** ធនធាននឹងត្រូវពង្រីកតាមសង្វាក់ ដែលរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយទទួលយកបាន ។ ក្របខណ្ឌហិរញ្ញប្បទានវិស័យសុខាភិបាលសំរាប់រយៈមធ្យមទៅរយៈពេលវែងចាំបាច់ត្រូវផ្សារភ្ជាប់ទៅក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចប្រទេសកម្ពុជាដែលនឹងតំរូវឱយមានដាក់ចេញយុទ្ធសាស្រ្តតាមលំដាប់លំដោយ ។

ជាផលបច្ច័យការអនុវត្តន៍ផ.យ.ស.២ នឹងប្រព្រឹត្តទៅតាមពីរដំណាក់កាល។

| ខ្សែរថ | ដំណាក់កាលពង្រឹង<br>២០០៨-២០១០ | ដំណាក់កាលពង្រីក<br>២០១១-២០១៥ |
|---|---|---|
| **១. ការសំរេចចិត្តពីសំណុំគោលនយោបាយសំខាន់ៗ** | | |
| ក.ពិនិត្យកែសំរួល/អភិវឌ្ឍផែនការយុទ្ធសាស្ត្រតាមអនុវិស័យ | ◆────◆ | |
| ខ.អភិវឌ្ឍឧបករណ៍អនុវត្តគោលនយោបាយ/យុទ្ធសាស្ត្រ | ◆────◆ | ◆────◆ |
| គ.កំណត់សំណុំគោលនយោបាយ | ◆────◆ | |
| **២. ការអភិវឌ្ឍន៍ស្ថាបន័និងការពង្រឹងសមត្ថភាព** | | |
| ក.ការរៀបចំចាត់ចែងស្ថាបន័ | ◆────◆ | |
| ខ.ការពង្រឹងសមត្ថភាព | ◆────◆ | ◆────◆ |
| **៣. ការរៀបចំចាត់ចែងសំរាប់ការអនុវត្តន៍** | | |
| ក.ការកៀងគរធនធាន | ស្រុកប្រតិបត្តិដែលនឹងកំណត់ | គ្រប់ស្រុកប្រតិបត្តិ |
| ខ.ការត្រៀមរៀបចំសំរាប់ដំណាក់កាលពង្រីក | អ.ប្រ.ស/ពាក់កណ្តាលអណត្តិ | ផ.យ.ស.៣ |

## ១.១ ដំណាក់កាលពង្រឹង ២០០៨-២០១០

ដំណាក់កាលពង្រឹងនឹងប្រព្រឹត្តទៅតាម “ខ្សែរថ” ៣ស្របគ្នា ដែលនឹងផ្តល់មូលដ្ឋានរឹងមាំសំរាប់ការដាក់ចេញគោលនយោបាយ និងការពង្រីក។

- **ខ្សែរថទី១: ការសំរេចចិត្តអំពីសំណុំគោលនយោបាយសំខាន់ៗ និងការអភិវឌ្ឍន៍ឧបករណ៍ប្រតិបត្តិ**

  **ក. ពិនិត្យកែសំរួល/អភិវឌ្ឍផែនការយុទ្ធសាស្ត្រតាមអនុវិស័យឱ្យស្របទៅតាមអាទិភាពនិងយុទ្ធសាស្ត្រ ផ.យ.ស.២**

  **ខ. អភិវឌ្ឍឧបករណ៍សំរាប់**ការអនុវត្តន៍គោលនយោបាយ/ក្របខណ្ឌយុទ្ធសាស្ត្រ/ផែនការយុទ្ធសាស្ត្រដែលមានស្រាប់ :

  (១) ក្របខណ្ឌអនុវត្ត/ផែនទីផ្លូវសំរាប់ការអនុវត្តន៍ ផ.យ.ស.២

  (២) គោលនយោបាយស្តីអំពីគុណភាពក្នុងវិស័យសុខាភិបាល (ដាក់ចេញឆ្នាំ២០០៦)

  (៣) ផែនការអភិវឌ្ឍធនធានមនុស្សវិស័យសុខាភិបាល២០០៦-២០១៥ (ដាក់ចេញឆ្នាំ២០០៦)

  (៤) ផែនការគ្របដណ្តប់សុខាភិបាល (ពិនិត្យកែសំរួលផ្អែកតាមវិមជ្ឈការនិងវិសហមជ្ឈការ)

  (៥) ក្របខណ្ឌយុទ្ធសាស្ត្រហិរញ្ញប្បទានសុខាភិបាល ២០០៨-២០១៥ (ឆ្នាំ២០០៨)

  (៦) ផែនការយុទ្ធសាស្ត្រប្រពន្ធ័ពត៏មានសុខាភិបាល ២០០៨-២០១៥ (ឆ្នាំ២០០៨)

  (៧) ផែនការអភិវឌ្ឍស្ថាបន័ (ឆ្នាំ២០០៨)

  (៨) ក្របខណ្ឌគោលនយោបាយស្តីការចូលរួមរបស់សហគមន៍ក្នុងវិស័យសុខាភិបាល (កំពុងពិនិត្យកែសំរួលលើគោលនយោបាយដែលដាក់ចេញនៅឆ្នាំ២០០៣)

(៩) គោលនយោបាយស្តីពីការវាយតំលៃផលប៉ះពាល់លើសុខភាព (កំពុងផ្តួចផ្តើម)

គ. **កំណត់សំណុំគោលនយោបាយសំខាន់ៗ ដែលត្រូវធ្វើការសំរេចចិត្ត រួមមានគោលនយោបាយស្តីអំពី:**

(១) ការអនុវត្តន៍វិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យសុខាភិបាល

(២) សុខដុមនីយកម្មនិងការតំរៀបតំរង់ដើម្បីលទ្ធផល រួមទាំងជំនួយបច្ចេកទេស

(៣) កិច្ចសន្យាផ្តល់សេវា (ទីភ្នាក់ងារប្រតិបត្តិការពិសេស កិច្ចសន្យាផ្ទៃក្នុងនិងខាងក្រៅ)

(៤) មូលនិធិសមធម៌និងការតំរង់អន្តរាគមន៍ទៅរកជនក្រីក្រនិងជនងាយរងគ្រោះ

(៥) ការគ្រប់គ្រងបុគ្គលិក រាប់បញ្ចូលទាំងប្រពន្ធ័លាភការនិងនិយោជន៍ទ្វេ

(៦) សំណុំសេវាសុខភាពបន្តពូជ-មាតា-ទារកនិងកុមារ រួមទាំងមូលនិធិ ដោយផ្សារភ្ជាប់ជាមួយការរៀបចំចាត់ចែងកិច្ចសន្យានិងកម្មវិធីមូលនិធិសមធម៌

(៧) និយតកម្មគ្រឹះស្ថានសាធារណៈ: រដ្ឋបាលដូចជាមន្ទីរពេទ្យមន្ទីរពិសោធន៍និងអង្គភាពទ្រទ្រង់

(៨) យុទ្ធសាស្ត្រប្រាស្រយ័ទាក់ទង

(៩) និយតកម្មលទ្ធកម្មនិងការគ្រប់គ្រងឱសថនិងបរិក្ខា

(១០) ផ្តួចផ្តើមការសន្ទនាអំពីគោលនយោបាយស្តីពីវិស័យសាធារណៈ:-ឯកជន

- **ខ្សែរថទី៧: ការអភិវឌ្ឍន៍ស្ថាប័ននិងការពង្រឹងសមត្ថភាព នៅអង្គភាពថ្នាក់កណ្តាល ខេត្ត-ក្រុង ស្រុកប្រតិបត្តិ មូលដ្ឋានសុខាភិបាល និងឃុំ-សង្កាត់**

ត្រូវប្រព្រឹត្តទៅតាមគោលនយោបាយនិងក្របខណ្ឌ័យុទ្ធសាស្ត្រទាំងអស់ខាងលើ ពិសេសគឺ:

(១) គោលនយោបាយនៃការអនុវត្តន៍វិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យសុខាភិបាល

(២) កិច្ចសន្យាផ្តល់សេវា (ទីភ្នាក់ងារប្រតិបត្តិការពិសេស កិច្ចសន្យាផ្ទៃក្នុង និងខាងក្រៅ)

(៣) គោលនយោបាយស្តីពីការគ្រប់គ្រងបុគ្គលិក រាប់បញ្ចូលទាំងប្រពន្ធ័លាភការ

(៤) ក្របខណ្ឌ័គោលនយោបាយស្តីការចូលរួមរបស់សហគមន៍ក្នុងវិស័យសុខាភិបាល

(៥) ផែនការអភិវឌ្ឍស្ថាបន័

ការអភិវឌ្ឍន៍ស្ថាបន័ និងការពង្រឹងសមត្ថភាព ត្រូវបានលើកឡើងក្នុងយុទ្ធសាស្ត្រទី៣ (ធនធានមនុស្សសុខាភិបាល)និងយុទ្ធសាស្ត្រ៥ (អភិបាលកិច្ចប្រពន្ធ័សុខាភិបាល)។ រចនាសម្ពន្ធ័ក្រសួងសុខាភិបាលនឹងត្រូវពិនិត្យឡើងវិញ ហើយចាត់ចែង-រៀបចំសំរាប់ការអនុវត្តន៍ផ.យ.ស.២ ដោយផ្តល់ការយកចិត្តទុកដាក់ជាចំបងៗលើ:

ក. ពិនិត្យវាយតំលៃឡើងវិញតួនាទី និងមុខងារនៅក្នុងក្រសួងសុខាភិបាល ដើម្បីអនុញ្ញាតិឱយមាន "កន្លែងមួយ" ទទួលខុសត្រូវលើការផ្តល់សេវានៃប្រពន្ធ័សុខាភិបាលទូទាំងវិស័យសាធារណៈ។

ខ. ពង្រឹងបែបបទនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទូទាំងក្រសួងសុខាភិបាល

គ. ពង្រឹងសមត្ថកិច្ចក្រសួងសុខាភិបាលសំរាប់ការគ្រប់គ្រងធនធានមនុស្ស ដោយរាប់បញ្ចូលទាំងការតំរៀបតំរង់ខ្សែរយៈសមត្ថកិច្ចជាមួយនិងលំហូរធនធាន និងរចនាសម្ពន្ធ័ នៃការទទួលខុសត្រូវ។

ឃ. ពង្រឹងសមត្ថកិច្ចនិងការទទួលខុសត្រូវនៃផ្នែកកម្មវិធីសុខភាពទាំងបី ពិសេសរចនាសម្ពន្ធ័នៃការទទួលខុសត្រូវ និងលំហូរមូលនិធិទៅតាមខ្សែរយៈសមត្ថកិច្ច។

- **ខ្សែរថទី៣: ការរៀបចំចាត់ចែងការអនុវត្តន៍និងការត្រៀមរៀបចំសំរាប់ដំណាក់កាលពង្រីក**

  **ក.** ការកៀងគរធនធាន សំរាប់ការអនុវត្តន៍សំណុំគោលនយោបាយដែលបានព្រមព្រៀង ថ្នាក់ក្រោមនៃស្រុកប្រតិបត្តិមួយចំនួន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់និងទៅតាមទំហំធនធានហិរញ្ញវត្ថុដែលអាចរកបាន:

  - គោលនយោបាយស្តីពីកិច្ចសន្យាផ្តល់សេវា
  - គោលនយោបាយស្តីពីកម្មវិធីមូលនិធិសមធម៌
  - គោលនយោបាយស្តីពីការគ្រប់គ្រងបុគ្គលិករាប់ទាំងប្រពន្ធ័លាភការ
  - គោលនយោបាយស្តីពី ស.ស.អ/ស.ស.ប នៃការថែទាំ
  - ការគ្រប់គ្រងប្រពន្ធ័ពត៌មាន
  - ផែនការអភិវឌ្ឍស្ថាប័ន

  **ខ.** ការត្រៀមរៀបចំសំរាប់ដំណាក់កាលពង្រីក

  - ការចូលរួមក្នុងការត្រៀមរៀបចំដំណើរការការអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ ២០១០

## ១.២ ដំណាក់កាលពង្រីក ២០០១-២០១៥

- **ខ្សែរថទី១: ការសំរេចចិត្តពីសំណុំគោលនយោបាយសំខាន់ៗ និងការអភិវឌ្ឍន៍ឧបករណ៍ប្រតិបត្តិ**

  បន្តការពិភាក្សាអំពី:

  - សុខដុមនីយកម្មនិងការតំរៀបតំរង់ដើម្បីលទ្ធផល (ទិសដៅឆ្ពោះទៅកាន់អភិក្រមគ្រប់គ្រងបើកទូលាយទូទាំងវិស័យ)
  - ភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន
  - គោលនយោបាយ/យុទ្ធសាស្ត្រនានាដែលតំរូវឱយមាននៅក្នុងអំឡុងពេលនៃការអនុវត្តន៍ ផ.យ.ស.២ និងលទ្ធផលនៃ អ.ប្រ.ស ២០១០។

- **ខ្សែរថទី២: ការអភិវឌ្ឍន៍ស្ថាប័ននិងការពង្រឹងសមត្ថភាព នៅអង្គភាពថ្នាក់កណ្តាលខេត្ត-ក្រុង ស្រុកប្រតិបត្តិ មូលដ្ឋានសុខាភិបាល និងឃុំ-សង្កាត់** និងបន្តដោយផ្តោតលើស្រុកប្រតិបត្តិថ្មី។

- **ខ្សែរថទី៣: ការរៀបចំចាត់ចែងការអនុវត្តន៍**

**ក.** បន្តការកៀងគរធនធាន ដើម្បីអនុវត្តន៍សំណុំគោលនយោបាយដែលបានព្រមព្រៀង និងក្របខណ្ឌ យុទ្ធសាស្រ្តសំខាន់ៗដទៃទៀតនៅស្រុកប្រតិបត្តិដែលនៅសល់។

**ខ.** បន្តការគាំទ្រដល់ស្រុកប្រតិបត្តិ ក្នុងដំណាក់ពង្រឹងដើម្បីធានានិរន្តភាពមុខងារនិងហិរញ្ញវត្ថុ និងការគ្របដណ្តប់ជាសកល នៅដំណាច់ឆ្នាំ ២០១៥។

**គ.** ការត្រៀមរៀបចំសំរាប់ការអភិវឌ្ឍន៍ ផ.យ.ស.៣ (២០១៦-២០២០)

- អនុវត្តការពិនិត្យវាយតំលៃផ.យ.ស.២ ពាក់កណ្តាលអណត្តិនៅឆ្នាំ២០១១ ផ្អែកលើលទ្ធផលនៃការ អ.ប្រ.ស ឆ្នាំ២០១០
- ត្រៀមរៀបចំសំរាប់អ.ប្រ.ស២០១៥ និងការវាយតំលៃផ.យ.ស.២ ផ្អែកលើអ.ប្រ.ស២០១៥។

## ២. ក្របខណ្ឌអនុវត្ត

- **ផែនការរំកិល៣ឆ្នាំផ្សាភ្ជាប់ទៅនឹងក្របខណ្ឌថវិកាយុទ្ធសាស្រ្ត (ក្រសួងសេដ្ឋកិច្ច_ហិរញ្ញវត្ថុ) និងកម្មវិធីវិនិយោគសាធារណ: (ក្រសួងផែនការ)**
- **ផែនការប្រតិបត្តិប្រចាំឆ្នាំ និងការកសាងថវិកាតាមកម្មវិធី**

រូបភាព ៨: ការផ្សាភ្ជាប់រវាងផ.យ.ស.២ និងផែនការរំកិល៣ឆ្នាំនិងផែនការប្រតិបត្តិប្រចាំឆ្នាំ




### ២.១ ផែនការរំកិល៣ឆ្នាំ

ផែនការរំកិល៣ឆ្នាំ គឺជាក្របខណ្ឌផែនការរយៈពេលមធ្យម។ ផែនការនេះត្រូវកសាងឡើងលើ យុទ្ធសាស្រ្តទូលំទូលាយរបស់ ផ.យ.ស.២ ដែលបានកំណត់គោលបំណង និងគោលដៅចំណុចរយៈពេលវែង។ផែនការនេះក៏ឈរលើមូលដ្ឋានតំរូវផ្នែកហិរញ្ញវត្ថុផងដែរ(តំរូវការធនធានពីថ្នាក់ក្រោម)និងការ

ប៉ាន់ស្មានអំពីកញ្ចប់ធនធានដែលមានពី គ្រប់ ប្រភពទាំងអស់ (ក្នុងនិងក្រៅ ប្រទេសពន្យាករណ៍ដោយថ្នាក់លើ ) ការចំណាយដែលថ្នាក់ក្រោម ត្រូវការ និងការព្យាករណ៍កញ្ចប់ធនធានដោយថ្នាក់លើ នឹងស៊ីគ្នានៅក្នុង បរិបទនៃផែនការនីយកម្ម ប្រចាំឆ្នាំនិងបែបបទថវិកា ដើម្បីផ្តល់ពត៌មានដល់ការសំរេចចិត្តលើការវិភាជន៍ ធនធានដល់អាទិភាពទាំងក្នុងវិស័យនិងទូទាំងវិស័យ ។

បែបបទនឹង"រំកិលទៅមុខ"ជារៀងរាល់ឆ្នាំ ដើម្បីបញ្ចូលការផ្លាស់ប្តូរ (គោលនយោបាយតំរូវការ និងធនធាន )ហើយច្បាមយកអាទិភាពថ្មីដែលកំណត់ដោយការពិនិត្យរួមគ្នាសមិទ្ធផលសុខាភិបាល ប៉ុន្តែមិន សំរាប់ការប្រែប្រួលធំៗដែលងាកចេញពីយុទ្ធសាស្ត្រទូទៅឬពីអ្វីដែលបានកំណត់រួចមកហើយ ។ ប្រសិនបើ អនុវត្តបានសមស្របបែបបទនេះនឹងកែលំអយ៉ាងខ្លាំងដល់ការវិភាជន៍ធនធាននិងការព្យាករណ៍មូលនិធិសំរាប់ វិស័យសុខាភិបាលហើយផ្សារភ្ជាប់ធនធានដែលវិភាជន៍រួចហើយទៅនឹងលទ្ធផលនៃការផ្តល់សេវា ។

នៅក្នុង ក្របខណ្ឌនៃផែនការរំកិល៣ឆ្នាំផែនការ ប្រតិបត្តិ ប្រចាំឆ្នាំនឹង ត្រូវអភិវឌ្ឍន៍ដោយមានសកម្ម ភាពលំអិត (រាប់បញ្ចូលទាំងថវិកា )និង ប្រតិទិន ។ ពីបរិបទដែលបានរៀបរាប់ខាងលើផែនការរំកិល៣ឆ្នាំមាន បំណង :

- ប្រែក្លាយយុទ្ធសាស្ត្រ ផ.យ.ស ២ ជាសកម្មភាពជាក់ស្តែង
- ផ្តល់ពត៌មានដល់ការវិភាជន៍/វិភាជន៍ឡើងវិញធនធានសំរាប់ ៣ឆ្នាំខាងមុខ និង ត្រួសត្រាយ ការប្តេជ្ញាចិត្តអំពីធនធានដោយរដ្ឋាភិបាលនិងដៃគូសុខាភិបាល ។
- សំរបសំរួលកម្មវិធីជំនួយដល់វិស័យសុខាភិបាល តាមរយៈការពិគ្រោះយោបល់ទូទាំងវិស័យ និងអណត្តិការវិភាជន៍តាមរយៈការពិនិត្យរួមគ្នាសមិទ្ធផលសុខាភិបាល ប្រចាំឆ្នាំ
- បង្កើតមូលដ្ឋានសំរាប់កសាង ក្របខណ្ឌថវិកាយុទ្ធសាស្ត្រ ដើម្បីកំណត់កញ្ចប់ថវិការបស់រដ្ឋា ភិបាលដោយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- ផ្តល់ ក្របខណ្ឌសំរាប់ការអភិវឌ្ឍន៍ផែនការ ប្រតិបត្តិ ប្រចាំឆ្នាំ

ដើម្បីព ង្រឹងអភិ ក្រមសមាហរណកម្មនិងធានាថាលំហូរមូលនិធិឆ្លុះបញ្ចាំងពីខ្សែរយៈទទួលខុស ត្រូវ និងសមត្ថកិច្ចកម្មវិធីសុខភាពទាំង៣ផ្នែកនិងខេត្ត- ក្រុងនិមួយៗនឹងរៀបចំផែនការរំកិល៣ឆ្នាំមានលក្ខណៈរួម បញ្ចូលដែលនឹងបង្កើតជាមូលដ្ឋានសំរាប់ផែនការរំកិល៣ឆ្នាំសំយោគដែលរៀបចំដោយ ក្រសួងសុខាភិបាល ។

ផែនការរំកិល៣ឆ្នាំ នឹងផ្សារភ្ជាប់ដោយផ្ទាល់ និងកំណត់យកជាផែនការវិនិយោគជាអាទិភាព សំរាប់ ក្រសួងសុខាភិបាល ។

## ២.២ ផែនការប្រតិបត្តិប្រចាំឆ្នាំ

ផ.យ.ស.២ ជា ក្របខណ្ឌណែនាំសំរាប់ គ្រប់សកម្មភាពទាំងអស់ នៅក្នុងវិស័យសុខាភិបាល ។ គោលបំណង និងគោលដៅចំណុចរបស់ ផ.យ.ស.២ នឹង ត្រូវបាន ប្រតិបត្តិតាមរយៈការអភិវឌ្ឍន៍ និង អនុវត្តន៍ផែនការ ប្រតិបត្តិ ប្រចាំឆ្នាំដែលផ្សារភ្ជាប់ជាមួយថវិកាតាមកម្មវិធី នៅ គ្រប់ថ្នាក់ទាំងអស់នៃ ប្រពន្ធ័ សុខាភិបាលដើម្បីសំរេចគោលបំណងនេះ ។ ដូច្នេះ ក្រុមម ន្ត្រី គ្រប់ គ្រងសុខាភិបាលនៅ គ្រប់ថ្នាក់តំរូវឱយ

ពិនិត្យមើលសមាសភាគយុទ្ធសាស្ត្រ និងអន្តរាគមន៍ជាយុទ្ធសាស្ត្រដែលបានកំណត់ក្រោមកម្មវិធីសុខភាពនិមួយៗក្នុង ផ.យ.ស.២ ហើយប្រើប្រាស់វា ដើម្បីបង្កើតក្របខណ្ឌសំរាប់អន្តរាគមន៍និងសកម្មភាពរបស់ខ្លួន ។ការណ៍នេះនឹងបង្កើតឡើងនូវចំណងទាក់ទងមួយច្បាស់លាស់និងដោយផ្ទាល់រវាងគោលបំណងដែលបានកំណត់និងគោលដៅនិមួយៗ ដែលបានរៀបរាប់ក្នុងផ.យ.ស.២ និងគោលដៅដទៃទៀតដែលបានកំណត់ដោយមណ្ឌលគ្រប់គ្រងថវិកាថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ហើយធ្វើឱយផែនការប្រតិបត្តិប្រចាំឆ្នាំវិសយ័សុខាភិបាលឆ្លុះបញ្ចាំងកាន់តែល្អប្រសើរនូវបំណងរបស់ ផ.យ.ស.២ ។

- **តួនាទីនៃផែនការប្រតិបត្តិប្រចាំឆ្នាំ**

បច្ចុប្បន្នផែនការប្រតិបត្តិប្រចាំឆ្នាំស្ថិតក្នុងឆ្នាំទី៥ នៃការអនុវត្តន៍ទូទាំងវិសយ័ ។ ផែនការប្រតិបត្តិប្រចាំឆ្នាំបានកសាងឡើង ទុកជាយន្តការដែលមានឥទ្ធិពលលើការសំរេចចិត្តលើការវិភាជន៍ធនធានជាទូទៅទូទាំងវិសយ័សុខាភិបាលប៉ុណ្ណោះទេ (តាមរយៈការចូលរួមក្នុងការវិភាជន៍ធនធាន) តែក៏ជាពត៏មានផ្នែកធនធានសំរាប់អ្នកធ្វើសេចក្តីសំរេចចិត្ត និងមន្ត្រីគ្រប់គ្រងកម្មវិធី ដើម្បីឱយពួកគេអាចបន្តការតំរៀបតំរង់សកម្មភាពនៃកម្មវិធីរបស់ខ្លួនទៅតាមគោលដៅនិងយុទ្ធសាស្ត្ររបស់ ផ.យ.ស.២ ។ ផែនការនេះនឹងធ្វើឱយក្រសួងសុខាភិបាលអាចសំរេចបានកំរិតខ្ពស់នៃសមាហរណកម្មនៅក្នុងផែនការនីយកម្ម និងសង្គតភាពនៅក្នុងអភិក្រមនានាទូទាំងវិសយ័សុខាភិបាល ។

ផែនការប្រតិបត្តិប្រចាំឆ្នាំចាំបាច់ត្រូវតែសង្គតភាព ជាមួយបែបបទនៃការគ្រប់គ្រង និងយន្តការទទួលខុសត្រូវចំពោះការកសាងថវិកាតាមកម្មវិធី ។ ផែនការនេះនឹងផ្តល់គ្រឹះមូលដ្ឋានសំរាប់ទីភ្នាក់ងារប្រតិបត្តិការពិសេស កិច្ចសន្យាផ្ទៃក្នុង និងខាងក្រៅ និងការត្រួតពិនិត្យតាមដាន ក៏ដូចជាគាំទ្រដល់ ''ថវិកាកញ្ចប់សំរាប់ការផ្តល់សេវា'' របស់ខេត្ត- ក្រុង ។ភាពលំអិតនៃផែនការនឹងអាស្រយ័លើកត្តាមួយចំនួនពិសេស គឺកំរិតនៃវិមជ្ឈការនិងវិសហមជ្ឈការដែលតំរូវដោយ ''ច្បាប់សំរាប់រៀបចំអង្គការ'' និងបែបបទថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ចំណុចសំខាន់របស់ផែនការប្រតិបត្តិប្រចាំឆ្នាំ គឺ :

- ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំលំអិត
- ណែនាំដោយអាទិភាពក្នុងវិសយ័កំណត់ដោយការពិនិត្យរួមគ្នាសមិទ្ធផលសុខាភិបាលប្រចាំឆ្នាំ
- ប្រើប្រាស់កញ្ចប់ថវិការបស់រដ្ឋាភិបាល និងដៃគូចេញពីផែនការរំកិល៣ឆ្នាំ ផ្តល់មូលដ្ឋានសំរាប់ទីភ្នាក់ងារប្រតិបត្តិការពិសេស កិច្ចសន្យាក្រៅនិង ''ថវិកាកញ្ចប់'' របស់ខេត្ត- ក្រុង
- បញ្ចូលសកម្មភាពនិងធនធានវិភាជន៍ពីកម្មវិធីជាតិ ទៅក្នុងផែនការរបស់មូលដ្ឋានសុខាភិបាលសំរាប់ការសំយោគនៅថ្នាក់ស្រុកប្រតិបត្តិ និងនៅថ្នាក់លើបន្តបន្ទាប់
- ផែនការសកម្មភាពខេត្ត- ក្រុងត្រូវពិនិត្យ/សំរេចដោយក្រសួងសុខាភិបាល នៅមុនពេលខេត្ត-ក្រុងដាក់សំណើអំពីផែនការថវិកា

- **គោលការណ៍ណែនាំសំរាប់អភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំ**

---

១. បែបបទដែលមានការចូលរួមក្នុងការអភិវឌ្ឍន៍ផែនការ

២. ការកំណត់អាទិភាពត្រូវផ្អែកតាមការពិនិត្យលទ្ធផលវិស័យសុខាភិបាលប្រចាំឆ្នាំនិងការពិនិត្យលទ្ធផលប្រចាំឆ្នាំរបស់អង្គភាពនិមួយៗ

៣. កសាងផែនការនិងថវិកាសំដៅលើលទ្ធផល

---

- **បែបបទដែលមានការចូលរួមក្នុងការកសាងផែនការ**

បែបបទផែនការនីយកម្មត្រូវបានតាក់តែងឡើង ដើម្បីឱយមានការចូលរួមពីគ្រប់ដៃគូទាំងអស់ចាប់តាំងពីការពិនិត្យរួមគ្នាសមិទ្ធផលប្រចាំឆ្នាំនិងការកំណត់អត្តសញ្ញាណអាទិភាពរហូតដល់ការអភិវឌ្ឍន៍សកម្មភាពរបស់អង្គភាពនិមួយៗ ដោយឈរលើសំណុំគោលដៅរួម និងអន្តរាគមន៍ជាយុទ្ធសាស្ត្រដែល បានឯកភាពគ្នា និងបែបបទនៃការពិនិត្យវិនិច្ឆយ័ផែនការ និងការផ្តល់យោបល់ត្រឡប់ចំពោះមុខផ្ទាល់នៅលើផែនការប្រតិបត្តិប្រចាំឆ្នាំនិមួយៗ។ ពង្រឹងបែបបទផែនការនីយកម្មផ្តល់ឱយអង្គភាព/ផ្នែកនិមួយៗ និងដៃគូសុខាភិបាលរបស់ខ្លួននូវឱកាសដែលមានអនុភាពទៅលើការវិភាជន៍ធនធានទូលំទូលាយមួយតាមរយៈការចែករំលែកពត៌មាន ទន្ទឹមគ្នានេះក៏រក្សាបាននូវការគ្រួតត្រារបស់ខ្លួនលើធនធានដែលវិភាជន៍ឱយនៅក្នុងការប្រតិបត្តិ។

- **ការកំណត់អាទិភាពផ្អែកតាមការពិនិត្យរួមគ្នាសមិទ្ធផលប្រចាំឆ្នាំវិស័យសុខាភិបាលនិងរបស់អង្គភាពនិមួយៗ**

គោលបំណងជាយុទ្ធសាស្ត្ររបស់ផ.យ.ស.២ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងអាទិភាពវិសយ័សុខាភិបាលដែលបានកំណត់ឡើងរៀងរាល់ឆ្នាំនៅពេលពិនិត្យរួមគ្នាសមិទ្ធផលសុខាភិបាលប្រចាំឆ្នាំ។ លទ្ធផលនេះបង្កើតមូលដ្ឋានសំរាប់ផែនការនីយកម្មប្រចាំឆ្នាំ ដែលទាក់ទងនឹងធនធានដែលអាចរកបានក្នុងឆ្នាំនិមួយៗ។ អាទិភាពទាំងនេះផ្តោតលើផ្នែកដែលត្រូវយកចិត្តទុកដាក់ជាបន្ទាន់ក្នុងអនាគតដ៏ខ្លី ដោយទទួលស្គាល់ថាសកម្មភាពនៃវិសយ័សុខាភិបាលមានលក្ខណៈទូលំទូលាយ ហើយការធ្វើផែនការប្រតិបត្តិត្រូវតែគិតដល់គោលបំណងជាយុទ្ធសាស្ត្ររបស់ ផ.យ.ស ២។

**គោលដៅជាយុទ្ធសាស្ត្រ:** ផ.យ.ស.២ បានកំណត់នូវចង្កោមគោលដៅជាយុទ្ធសាស្ត្រ សំរាប់កម្មវិធីសុខភាពដែលនឹងរួមចំណែកដោយផ្ទាល់ទៅនឹងអាទិភាពមួយឬច្រើន ដែលកំណត់ដោយការពិនិត្យរួមគ្នាសមិទ្ធផលសុខាភិបាលប្រចាំឆ្នាំ។គោលដៅជាច្រើនឆ្លុះបញ្ចាំងដោយផ្ទាល់ទៅលើយុទ្ធសាស្ត្រសុខាភិបាលទាំង៥ និងអន្តរាគមន៍ជាយុទ្ធសាស្ត្រ ខណៈពេលដែលគោលដៅដទៃទៀតបានផ្តោតទៅលើបុរេលក្ខខណ្ឌសំរាប់ការអនុវត្តន៍មានប្រសិទ្ធភាពនៃយុទ្ធសាស្ត្រដែលបានស្នើឡើង ។

**សកម្មភាព:** ការអភិវឌ្ឍន៍សកម្មភាពសំរាប់ផែនការប្រតិបត្តិប្រចាំឆ្នាំដោយឯករាជ្យ គឺជារូបធាតុដ៏មានសារៈសំខាន់មួយនៃការសំយោគផែនការ។ មន្ត្រីគ្រប់គ្រងនៅមូលដ្ឋានសុខាភិបាលនិងតាមអង្គភាព

ទូទាំងប្រទេស ចាំបាច់ត្រូវតែអភិវឌ្ឍសកម្មភាពនៃផែនការរបស់ខ្លួន ដោយផ្អែកលើចង្កោមអន្តរាគមន៍ជាយុទ្ធសាស្ត្ររបស់ផ.យ.ស.២ ដែលពាក់ពន្ធ័ទៅនឹងតួនាទីមុខងារនិងសមត្ថភាពនៃអង្គភាពរបស់ខ្លួន។ ជាលទ្ធផល ការផ្សារភ្ជាប់គ្នាបែបនេះនឹងធ្វើឱយរឹងមាំដល់វឌ្ឍនភាពទូទាំងវិស័យ ឆ្ពោះទៅកាន់ការសំរេចសមិទ្ធផលដែលជាគោលដៅយុទ្ធសាស្ត្ររបស់ផ.យ.ស.២។ ការអភិវឌ្ឍន៍សកម្មភាពទាំងអស់នេះ គឺជាទិដ្ឋភាពដ៏សំខាន់នៃបែបបទផែនការនីយកម្ម “ពីក្រោមឡើងលើ” ដែលនឹងធ្វើឱយផែនការប្រតិបត្តិប្រចាំឆ្នាំក្លាយជាឧបករណ៍ដ៏មានអានុភាពសំរាប់ការវិភាជន៍ធនធានទូទាំងវិស័យសុខាភិបាល។

- **ការកសាងផែនការនិងថវិកាសំដៅលើលទ្ធផល**

ផលប្រយោជន៍សំខាន់មួយនៃបែបបទផែនការនីយកម្ម “ពីក្រោមឡើងលើ” ដោយមានកិច្ចចូលរួមសហការនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ គឺជាយន្តការផ្តល់ពត៏មានសំខាន់ៗ ស្តីពីបញ្ហាប្រឈមមុខនិងកាលានុវត្តភាពនៅថ្នាក់ប្រតិបត្តិដល់ការសំរេចចិត្តដែលនឹងត្រូវធ្វើឡើងនៅថ្នាក់កណ្តាល និងខេត្ត-ក្រុង។ ពត៏មាននេះរួមមាន បញ្ហាប្រឈមមុខចំបងៗដែលត្រូវដោះស្រាយ និងជំរើសនានាដែលមានដើម្បីដោះស្រាយបញ្ហាប្រឈមមុខទាំងអស់នេះ នៅចំពោះមុខឧបសគ្គ័រយៈពេលមធ្យមទៅរយៈពេលវែង ធនធានដែលអាចរកបានឬរំពឹងថានឹងមាននិងប្រភពនៃធនធានទាំងអស់នោះ ព្រមទាំងថ្លៃចំណាយដែលបានគិតទុកសំរាប់សកម្មភាព ព្រមទាំងតំរូវការនៃការផ្តល់មូលនិធិដែលពាក់ពន្ធ័។

## ២.៣ បែបបទផែនការនីយកម្មប្រចាំឆ្នាំនិងប្រតិទិន

បែបបទផែនការនីយកម្មប្រចាំឆ្នាំត្រូវបានតាក់តែងឡើង ដើម្បីលើកស្ទួយវប្បធម៌វិមជ្ឈការផែនការនីយកម្មក្នុងវិស័យសុខាភិបាលដែលនឹងជួយដល់មន្ត្រីគ្រប់គ្រងនៅតាមមូលដ្ឋាន/អង្គភាពឱយធ្វើការសំរេចចិត្តកាន់តែត្រឹមត្រូវក្នុងការធ្វើផែនការដើម្បីទ្រទ្រង់ដល់អាទិភាពវិស័យសុខាភិបាល និងអាទិភាពមូលដ្ឋានដែលបានកំណត់តាមរយៈការពិនិត្យលទ្ធផលប្រចាំឆ្នាំ។ ការធ្វើផែនការបែបវិមជ្ឈការទាមទារឱយមានការសំយោគរួមបញ្ចូលគ្នានៃផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ស្រុកប្រតិបត្តិ (រួមមានផែនការប្រចាំឆ្នាំមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងការិយាល័យស្រុកប្រតិបត្តិ)ទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ខេត្ត-ក្រុង។

នាយកដ្ឋានផែនការនិងពត៏មានសុខាភិបាល-សហការជាមួយនាយកដ្ឋានថវិកានិងហិរញ្ញវត្ថុ ដឹកនាំការពិនិត្យវិនិច្ឆ័យនិងផ្តល់យោបល់ត្រឡប់លើផែនការប្រតិបត្តិប្រចាំឆ្នាំរបស់អង្គភាពសុខាភិបាលនិមួយៗ ហើយសំយោគជាផែនការប្រតិបត្តិប្រចាំឆ្នាំវិស័យសុខាភិបាលទាំងមូល។ នៅចុងបញ្ចប់ផែនការនេះត្រូវបានពិនិត្យនិងអនុមត័ដោយគណៈកម្មការដឹកនាំវិស័យសុខាភិបាល (សមាជិករួមមានមន្ត្រីជាន់ខ្ពស់ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការ)នៅមុនពេលអនុវត្តផែនការ។តារាង១០ ខាងក្រោមនេះបង្ហាញអំពីសកម្មភាពសំខាន់ៗដែលផ្សារភ្ជាប់ជាមួយប្រតិទិននៃបែបបទផែនការនីយកម្មប្រចាំឆ្នាំវិស័យសុខាភិបាល។

នៅខណៈពេលដែលបែបបទនៃការអភិវឌ្ឍន៍ផែនការប្រតិបត្តិប្រចាំឆ្នាំ កំពុងតែវិវត្តមានតំរូវការចាំបាច់ក្នុងការពង្រឹងការអនុវត្តន៍បែបបទផែនការនីយកម្មប្រចាំឆ្នាំនេះ ដើម្បីឱយការធ្វើផែនការពីក្រោមមកលើកាន់តែមានប្រសិទ្ធភាព ពិសេសនៅថ្នាក់ស្រុកប្រតិបត្តិនិងនៅតាមមូលដ្ឋានសុខាភិបាលដែលសមត្ថភាពជំនាញក្នុងការធ្វើផែនការនិងកសាងថវិកាត្រូវបានមើលឃើញថានៅមានកំរិត ដូច្នេះតំរូវឱយមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការពង្រឹងសមត្ថភាពប្រកបដោយចិរភាព ។

**តារាង ១០ បែបបទផែនការនីយកម្មប្រចាំឆ្នាំនិងប្រតិទិន**

| សកម្មភាពចំបង | ពេលវេលា | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ម | ក | ម | ម | ឧ | ម | ក | ស | ក | ត | វ | ធ |
| ១- ពិនិត្យលទ្ធផលប្រចាំឆ្នាំៈមណ្ឌលសុខភាព មន្ទីរពេទ្យ ស្រុកប្រតិបត្តិ ខេត្ត-ក្រុង ថ្នាក់កណ្តាល | | | | | | | | | | | | |
| ២- រៀបចំផែនការរំកិល៣ឆ្នាំសំរាប់វិស័យ/ក្របខណ្ឌថវិកាយុទ្ធសាស្ត្រ- ខេត្ត-ក្រុង-កណ្តាល | | | | | | | | | | | | |
| ៣- សន្និបាទសុខាភិបាលប្រចាំឆ្នាំ/ពិនិត្យរួមគ្នាសុខាភិបាលប្រចាំឆ្នាំ( ពិនិត្យលទ្ធផលប្រចាំឆ្នាំ ផ.យ.ស.២) /ពិនិត្យរួមគ្នាផែនការរំកិល ៣ ឆ្នាំ | | | | | | | | | | | | |
| ៤- រៀបចំផែនការប្រចាំឆ្នាំរួមទាំងថវិកាតាមអង្គភាពទាំងអស់ | | | | | | | | | | | | |
| ក្របខណ្ឌថវិកាយុទ្ធសាស្ត្រក្រសួងសុខាភិបាលផ្ញើទៅក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ | | | | X | | | | | | | | |
| ៥- ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្ត-ក្រុងពិនិត្យផែនការប្រតិបត្តិប្រចាំឆ្នាំខេត្ត-ក្រុង | | | | | | | | | | | | |
| ៦- **អង្គភាពខេត្តក្រុង-ថ្នាក់កណ្តាលផ្ញើផែនការប្រចាំឆ្នាំមកនាយកដ្ឋានផែនការ** | | | | | | | | | | | | |
| ៧- ពិនិត្យវិនិច្ឆ័យផែនការ និងផ្តល់យោបល់ត្រឡប់ | | | | | | | | | | | | |
| ៨- ផ្ញើផែនការកែតំរូវមកនាយកដ្ឋានផែនការ | | | | | | | | | | | | |
| ការចចារអំពីថវិកានៅក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ | | | | | | | | X | | | | |
| ៩- រៀបចំពង្រាងផែនការប្រចាំឆ្នាំវិស័យសុខាភិបាល-ថវិកា | | | | | | | | | | | | |
| ១០- ក្រសួងសុខាភិបាលនិងដៃគូអភិវឌ្ឍន៍រួមគ្នាពិនិត្យផែនការប្រតិបត្តិប្រចាំឆ្នាំ | | | | | | | | | | | | |
| ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុបង្ហាញផែនការថវិកាជូនរាជរដ្ឋាភិបាល | | | | | | | | | | X | | |
| ១១- ពិនិត្យឡើងវិញពង្រាងផែនការប្រចាំឆ្នាំបន្ទាប់ពីការអនុមត័ថវិកាដោយគណៈរដ្ឋមន្ត្រី | | | | | | | | | | | | |
| ថវិកាជាតិអនុមត័ដោយអង្គការនិតិបញ្ញតិ | | | | | | | | | | | | X |
| ១២- បញ្ចប់ផែនការប្រចាំឆ្នាំបន្ទាប់ពីអង្គការនិតិបញ្ញតិអនុមត័ថវិកាលើថវិកាជាតិ | | | | | | | | | | | | |
| ១៣- គណៈកម្មការដឹកនាំវិស័យសុខាភិបាលពិនិត្យ-អនុមត័ផែនការប្រចាំឆ្នាំ | | | | | | | | | | | | |
| ១៤- ពិនិត្យឡើងវិញចុងក្រោយផែនការប្រចាំឆ្នាំដោយអង្គភាពនិមួយៗនិងរៀបចំផែនការត្រីមាសសំរាប់ការអនុវត្តន៍ និងចាប់ផ្តើមសារជាថ្មីបែបបទផែនការនីយកម្មឆ្នាំបន្ត | | | | | | | | | | | | |
| **ឆ្នាំហិរញ្ញវត្ថុចាប់ផ្តើមថ្ងៃទី១ខែមករា និងបញ្ចប់ថ្ងៃទី៣១ខែធ្នូ** | | | | | | | | | | | | |
| ១៥- ការពិនិត្យតាមដានស្នាដៃអនុវត្តផែនការប្រចាំឆ្នាំ តាមរយៈការពិនិត្យប្រចាំត្រីមាស | | | | | | | | | | | | |
| ១៦- ការពិនិត្យពាក់កណ្តាលឆ្នាំនៃការអនុវត្តន៍ផែនការប្រតិបត្តិប្រចាំឆ្នាំ | | | | | | | | | | | | |
| | | | **ត្រីមាស១** | | | **ត្រីមាស២** | | | **ត្រីមាស៣** | | | **ត្រីមាស៤** |

## ២.៤ ការកសាងថវិកាតាមកម្មវិធី

ជាផ្នែកមួយនៃកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្រសួងសុខាភិបាលបានចាប់ផ្តើមអនុវត្តសាកល្បងមួយផ្នែកនៅថ្នាក់រដ្ឋបាលកណ្តាលក្នុងការកសាងផែនការនិងថវិកាតាមកម្មវិធីពីឆ្នាំ២០០៦ ។

ការកសាងថវិកាតាមកម្មវិធី គឺជាចំណាត់ថ្នាក់នៃការចំណាយឈរលើមូលដ្ឋានកម្មវិធី និងជាឧបករណ៍ដ៏មានសារៈប្រយោជន៍សំរាប់ការវិភាគន័ធនធាន។ ការអនុវត្តន៍វិធីសាស្ត្រនេះព្យាយាមផ្សារភ្ជាប់ការចំណាយនៅលើសកម្មភាពកម្មទាំងអស់នៅក្នុងវិធីនិមួយៗទៅនឹងលទ្ធផល និងបង្កើនយន្តការទទួលខុសត្រូវ ជាមួយគ្នានេះអាចឱយអ្នកតាក់តែងគោលនយោបាយដឹងច្បាស់ថា តើលុយសាធារណៈត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច។

ការអនុវត្តន៍មានប្រសិទ្ធភាពនៃការកសាងថវិកាតាមកម្មវិធីគឺតំរូវការ:

- ថវិកាគួរឱយទុកចិត្តបាន និងការទទួលខុសត្រូវរបស់អង្គភាពសាមី
- សមត្ថភាពបច្ចេកទេសនិងស្ថាប័ន
- លទ្ធផលអាចវាស់វែងបាន
- ពត៏មាននិងសមត្ថភាពដើម្បីធ្វើផែនការវែងនិង
- មានការចូលរួមពីអ្នកផ្តល់ជំនួយ

ផ.យ.ស.២ បានកំណត់គោលបំណងនិងគោលដៅច្បាស់លាស់សំរាប់វិស័យសុខាភិបាលរួមទាំងយន្តការត្រួតពិនិត្យតាមដានវឌ្ឍនភាពប្រចាំឆ្នាំនៃការអនុវត្តន៍ផ.យ.ស.២(តាមរយៈការពិនិត្យរួមគ្នាសមិទ្ធផលសុខាភិបាលប្រចាំឆ្នាំ)ដែលត្រូវបានបញ្ចូលទៅក្នុងបែបបទនៃផែនការនីយកម្មនិងក្របខណ្ឌរួមនៃការត្រួតពិនិត្យតាមដាននិងវាយតំលៃ។ ការកសាងថវិកាតាមកម្មវិធីនឹងរួមចំណែកដល់ការពង្រឹងបែបបទខាងលើនេះដោយសារបែបបទទាំងអស់នេះ។

ក្របខណ្ឌយុទ្ធសាស្ត្រ និងក្របខណ្ឌប្រតិបត្តិរបស់ ផ.យ.ស.២ តំរូវឱយផែនការប្រតិបត្តិប្រចាំឆ្នាំរៀបចំឡើងដោយ **កម្មវិធីសុខភាព ៣** ដែលឆ្លុះបញ្ចាំងពីអាទិភាពផ្នែកសុខភាពរបស់ប្រជាជន និង **អនុកម្មវិធី** មួយចំនួនទាក់ទងនឹងគោលដៅទាំង១២ របស់ផ.យ.ស.២។ សកម្មភាពផែនការនៃអង្គភាពទាំងអស់ត្រូវតែដាក់ទៅតាមអនុកម្មវិធីនិមួយៗ ដែលគោលដៅចំណុច និងសូចនាករត្រូវតែតំរៀបតំរង់ទៅតាមសមាសភាគយុទ្ធសាស្ត្រ និងអន្តរាគមន៍ជាយុទ្ធសាស្ត្ររបស់ ផ.យ.ស.២ ធ្វើដូច្នេះយុទ្ធសាស្ត្រសុខាភិបាលទាំង៥ គឺត្រូវបានដាក់អនុវត្តដោយសង្គតភាពទូទាំងកម្មវិធីសុខភាពទាំង៣។

## ៣. ក្របខណ្ឌត្រួតពិនិត្យតាមដាននិងវាយតំលៃ

វឌ្ឍនភាពក្នុងការអនុវត្តន៍ ផ.យ.ស.២ នឹងត្រូវបានត្រួតពិនិត្យតាមដាន តាមរយៈការពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ និងការពិនិត្យពាក់កណ្តាលអណត្តិនៃផែនការនិងបន្តដោយការវាយតំលៃនៅវគ្គបញ្ចប់នៃផែនការដើម្បីបញ្ជាក់អំពីផលប៉ះពាល់របស់ផែនការទៅលើការធ្វើឱយស្ថានភាពសុខភាពប្រសើរឡើង។

ក្របខណ្ឌបង្ហាញខាងក្រោម គឺជាឧបករណ៍សំរាប់ក្រសួងសុខាភិបាលត្រួតពិនិត្យតាមដាន និងវាយតំលៃឈរលើមូលដ្ឋានទៀងទាត់ដើម្បីទទួលបានពត៏មានសំរាប់ធ្វើការសំរេចចិត្តផ្នែកគោលនយោបាយ។ ក្របខណ្ឌសូចនាករលើកស្ទួយដល់ការប្រើប្រាស់ពត៏មានទាំងបរិមាណនិងគុណភាព ព្រមទាំងការធ្វើការសំរេចចិត្តផ្អែកលើភស្តុតាង។ ក្របខណ្ឌសូចនាករនេះនឹងត្រូវបានពិនិត្យមើលឡើងវិញជារឿយៗដើម្បីធានាថា

ពត៌មានដែលប្រមូលបាន គឺមានប្រយោជន៍សំរាប់មន្ត្រីតាក់តែងគោលនយោបាយ និងមន្ត្រីគ្រប់គ្រងនៅគ្រប់ថ្នាក់នៃប្រពន្ធ័សុខាភិបាល។

មានការគិតទុកថា ដៃគូសុខាភិបាលទាំងអស់នឹងប្រើប្រាស់ក្របខណ្ឌ័នេះ (រាប់បញ្ចូលទាំងសំណុំសូចនាករដែលបានឯកភាពគ្នា)ដើម្បីពិនិត្យវឌ្ឍនភាពនៃកម្មវិធី/គំរោងរបស់ខ្លួនក្នុងវិស័យសុខាភិបាល។

**រូបភាព ៩:ក្របខណ្ឌ័ត្រួតពិនិត្យតាមដាននិងវាយតំលៃ ផ.យ.ស.២**




## ៧.១ ការពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំនៃផ.យ.ស.២

ផ.យ.ស.២ នឹងត្រូវបានប្រតិបត្តិតាមរយ:ការអនុវត្តន៍ផែនការប្រតិបត្តិប្រចាំឆ្នាំ ដូច្នេះវឌ្ឍនភាពប្រចាំឆ្នាំនៃផ.យ.ស.២ នឹងត្រួតពិនិត្យតាមដានតាមរយ:ការពិនិត្យរួមគ្នាសមិទ្ធផលសុខាភិបាលប្រចាំឆ្នាំ ដែលបានប្រព្រឹត្តទៅយ៉ាងទៀងទាត់រៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ២០០៤។ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនឹងត្រូវបានរៀបចំ (គំរូរបាយការណ៍នឹងភ្ជាប់ជាមួយសេចក្តីណែនាំអំពីការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ) ដោយឈរលើមូលដ្ឋាននៃការប្រើប្រាស់ពត៌មានពីការពិនិត្យលទ្ធផលប្រចាំឆ្នាំ នៃការអនុវត្តន៍ផែនការប្រតិបត្តិរបស់អង្គភាពសុខាភិបាលគ្រប់ថ្នាក់ទូទាំងប្រពន្ធ័សុខាភិបាល យោងតាមបែបបទផែនការនីយកម្មប្រចាំឆ្នាំ ។

លក្ខណ:សម្បត្តិនៃការពិនិត្យរួមគ្នាសមិទ្ធផលសុខាភិបាលប្រចាំឆ្នាំ គឺ:

- ពិនិត្យស្នាដៃការងារឆ្នាំមុន ដោយផ្តោតលើសូចនាករស្នូលដែលបានជ្រើសរើស។
- កំណត់អាទិភាព ផ.យ.ស.២ ឡើងវិញ ដើម្បីផ្តល់ពត៌មានដល់ការវិភាជន៍ធនធាន/វិភាជន៍ឡើងវិញ ហើយផ្សារភ្ជាប់អាទិភាពនេះទៅនឹងការធ្វើផែនការប្រចាំឆ្នាំនិងបែបបទថវិកា។

- ពង្រឹងតួនាទីរបស់ក្រសួងសុខាភិបាល ក្នុងការណែនាំនិងអណត្តិដល់ការវិភាជន៍ធនធានទៅតាមផែនការរំកិល៣ឆ្នាំ ហើយអាចឱយដៃគូតំរៀបតំរង់ឡើងវិញជាអតិបរមាតាមដែលអាចធ្វើបានននូវកម្មវិធីនិងធនធានរបស់ខ្លួនទៅនឹងសកម្មភាពអាទិភាពនៅក្នុងផែនការរំកិល៣ឆ្នាំ។
- ផ្តល់យន្តការទទួលខុសត្រូវសំខាន់សំរាប់ក្រសួងសុខាភិបាលនិងដៃគូសុខាភិបាលនៅក្នុងការធ្វើផែនការគ្រប់គ្រងធនធាន និងលើកកំពស់ការសំរេចចិត្តដើម្បីឱយទទួលបានលទ្ធផល។
- តំរៀបតំរង់ជាមួយយន្តការត្រួតពិនិត្យតាមដានរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ដោយបច្ចុប្បន្នភាពប្រចាំឆ្នាំគោលដៅចំណុចទាក់ទងសុខភាព នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (គោលដៅចំណុចនៃវិសយ័ត្រូវបានកែសំរួល ហើយបង្ហាញក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ)។

ការពិនិត្យរួមគ្នាសមិទ្ធផលសុខាភិបាលប្រចាំឆ្នាំដែលប្រព្រឹត្តទៅរួមគ្នាជាមួយសន្និបាទសុខាភិបាលប្រចាំឆ្នាំ ដោយមានការចូលរួមអង្គភាពសុខាភិបាលគ្រប់ថ្នាក់ ក្រសួង អង្គភាពពាក់ពន្ធ័ ដៃគូអភិវឌ្ឍន៍ អាជ្ញាធរខេត្ត-ក្រុង ក្រុមប្រឹក្សាឃុំ-សង្កាត់ តំណាងសហគមន៍ តំណាងវិសយ័ឯកជន អង្គការសង្គមស៊ីវិល ដូចជាសមាគមវិជ្ជាជីវៈ អង្គការក្រៅរដ្ឋាភិបាល វិសយ័ឯកជនស្វែងរកផលកំរៃ ព្រមទាំងដៃគូដទៃទៀត។

## ៣.២ ការពិនិត្យពាក់កណ្តាលអណត្តិនៃផ.យ.ស.២-ឆ្នាំ២០១១

- **ប្រព្រឹត្តទៅនៅពេលបញ្ចប់ដំណាក់កាលពង្រឹងនៃការអនុវត្តន៍ផ.យ.ស.២ ពិនិត្យនិងផ្តល់អនុសាសន៍សំរាប់ដំណាក់កាលពង្រីក។**
- **ពេលអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១១-២០១៥ ពិនិត្យពាក់កណ្តាលអណត្តិនៃផ.យ.ស.២ បច្ចុប្បន្នភាពនិងឱយការណ៍ដល់បែបបទអភិវឌ្ឍផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។**
- **ការអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០១០ ឱយការណ៍ដល់ការពិនិត្យពាក់កណ្តាលអណត្តិនៃ ផ.យ.ស.២ ។**

ការពិនិត្យពាក់កណ្តាលអណត្តិនៃ ផ.យ.ស.២ នឹងប្រព្រឹត្តទៅនៅក្នុងឆ្នាំ២០១១ មួយផ្នែកផ្អែកលើលទ្ធផលនៃអ.ប.សឆ្នាំ២០១០ ដែលលទ្ធផលអាចនឹងប្រើប្រាស់បាននៅឆ្នាំ២០១១។ ការពិនិត្យពាក់កណ្តាលអណត្តិនេះនឹងរួមចំណែកដល់ការកែតំរូវពាក់កណ្តាលទីនិងការធ្វើបច្ចុប្បន្នភាពផ.យ.ស.២ សំរាប់រយៈពេលពីឆ្នាំ២០១១ទៅដល់២០១៥តាមរយៈការពិនិត្យវឌ្ឍនភាពនិងសមិទ្ធផលវិសយ័សុខាភិបាល។

### ៣.៣ ការវាយតំលៃ ផ.យ.ស.២-ឆ្នាំ២០១៥

ផ.យ.ស.២ នឹងត្រូវបានវាយតំលៃនៅឆ្នាំបញ្ចប់នៃផែនការ។ ដូចគ្នានឹងការពិនិត្យពាក់កណ្តាលអណត្តិដែរ ការវាយតំលៃផ.យ.ស.២ នឹងផ្អែកលើលទ្ធផលនៃ អ.ប.ស ឆ្នាំ២០១៥ ហើយលទ្ធផលនៃការវាយតំលៃចុងក្រោយនេះ នឹងយកទៅប្រើប្រាស់សំរាប់ការកសាងផ.យ.ស.៣ (២០១៦-២០២០)។

## ៤. ក្របខណ្ឌសូចនាករសំរាប់ការត្រួតពិនិត្យតាមដាននិងវាយតំលៃ

### ៤.១ គោលបំណង

គោលបំណងនៃក្របខណ្ឌសូចនាករមាន ៣យ៉ាងដូចខាងក្រោមនេះ:

- ត្រួតពិនិត្យតាមដាននិងវាយតំលៃស្នាដៃវិស័យសុខាភិបាលក្នុងការលើកស្ទួយលទ្ធផលសុខភាពតាមរយៈការអនុវត្តន៍ ផ.យ.ស.២
- បន្សុទ្ធគោលនយោបាយសុខាភិបាលដែលមាន ដោយពិចារណាទៅលើវឌ្ឍនភាពដែលបានកើតមាននៅក្នុងអំលុងពេលនៃការអនុវត្តន៍ ផ.យ.ស.២ និង
- ជួយឱយមន្ត្រីតាក់តែងគោលនយោបាយសំរេចចិត្តលើប្រសិទ្ធភាពនៃអន្តរាគមន៍ផ្សេងៗគ្នា និងជំរើសគោលនយោបាយ

ការធ្វើសេចក្តីសំរេចចិត្តផ្អែកលើភស្តុតាង គឺជាការប្រើប្រាស់ពត៌មានត្រឹមត្រូវនិងទាន់ពេលវេលាដើម្បីធ្វើការសំរេចចិត្តត្រឹមត្រូវ។ ដើម្បីយល់ដឹងពីផលប៉ះពាល់នៃអន្តរាគមន៍របស់គោលនយោបាយទៅលើស្ថានភាពសុខភាពមន្ត្រីសំរេចផ្អែកគោលនយោបាយរបស់ក្រសួងសុខាភិបាលត្រូវការចាំបាច់យ៉ាងខ្លាំងទាត់ទិន្នន័យដែលអាចទុកចិត្តបានស្តីអំពីឥរិយាបទផ្នែកសុខភាព ការប្រើប្រាស់សេវា ការគ្របដណ្តប់ គុណភាពនិងថ្លៃចំណាយ។ ពត៌មានទាំងអស់នេះអាចបញ្ជាក់បានតាមរយៈសូចនាករដែលត្រូវបានជ្រើសរើសយកដោយម៉ត់ចត់ដើម្បីវាស់វែងស្នាដៃវិស័យសុខាភិបាល និងផលប៉ះពាល់នៃគោលនយោបាយទៅលើសុខភាពនិងការអភិវឌ្ឍន៍។

តាមរយៈបែបទបទផែនការនីយត័កម្មប្រចាំឆ្នាំដ៏ខ្លាំងទាត់គ្រប់នាយកដ្ឋាន កម្មវិធីជាតិ និងអង្គភាពថ្នាក់កណ្តាលទាំងអស់អនុញ្ញាតិឱយប្រមូលពត៌មានបន្ថែមក្នុងករិតអតិបរមាប្រសិនចាំបាច់ សំរាប់ផែនការគ្រប់គ្រងនិងត្រួតពិនិត្យតាមដានសកម្មភាព/កម្មវិធីរបស់ខ្លួន។ ដូចគ្នានេះដែរមន្ទីរសុខាភិបាលខេត្តក្រុងនិងស្រុកប្រតិបត្តិដោយរាប់ទាំងមូលដ្ឋានសុខាភិបាលអាចប្រមូលពត៌មានបន្ថែមស្តីពីសូចនាករសំខាន់ៗសំរាប់ការងារគ្រប់គ្រងនិងផែនការសេវារបស់ខ្លួន (ការត្រួតពិនិត្យតាមដានប្រចាំត្រីមាស ពិនិត្យលទ្ធផលប្រចាំឆ្នាំ)។ សូចនាករថ្នាក់ជាតិខ្លះអាចប្រមូលបានពីថ្នាក់ខេត្ត-ក្រុង ហើយបំរើឱយគោលដៅពីរ: ផ្តល់ពត៌មានដល់គោលនយោបាយជាតិ និងត្រួតពិនិត្យតាមដានផែនការថ្នាក់ខេត្ត-ក្រុង និងស្រុកប្រតិបត្តិ)។

ប្រភពពត៌មានចំបងសំរាប់សូចនាករទាំងអស់នេះអាចនឹងប្រមូលបាន តាមរយៈប្រព័ន្ធពត៌មានសុខាភិបាលរួមនិងលទ្ធភាពនៃការប្រើប្រាស់ពត៌មានបន្ថែមដែលអាចរកបានពីក្រសួង-ស្ថាប័នដទៃទៀត និង

ការអង្កេតនានា ដូចជា៖ការអង្កេតប្រជាសាស្ត្រនិងសុខភាព ការអង្កេតសេដ្ឋកិច្ច-សង្គម ជំរឿនប្រជាជន ។ល។

## ៩.២ សូចនាករសំរាប់ការត្រួតពិនិត្យតាមដាននិងវាយតំលៃ

- **កំរិតទូទៅនៃការអភិវឌ្ឍន៍** សូចនាករសំរាប់ត្រួតពិនិត្យតាមដាន និងវាយតំលៃ ផ.យ.ស.២ គឺឈរលើមូលដ្ឋាននៃគោលនយោបាយនិងអាទិភាពដែលបានលើកឡើងក្នុងផែនការ។ ផ.យ.ស.២ បញ្ជាក់យ៉ាងច្បាស់អំពីចក្ខុវិស័យរបស់ក្រសួងសុខាភិបាលគឺ “**លើកកំពស់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពនៃវិស័យសុខាភិបាល ដើម្បីភាពកាន់តែប្រសើរឡើងនៃសុខភាពនិងសុខុមាលភាពរបស់ប្រជាជនទាំងអស់ ពិសេសប្រជាជនក្រីក្រ ស្ត្រីនិងកុមារ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចនិងសង្គមកិច្ចនិងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា**”។ ដើម្បីលើកស្ទួយសុខភាព ក្រសួងសុខាភិបាលត្រូវការមានពត៌មានស្តីអំពីកំរិតទូទៅនៃការអភិវឌ្ឍន៍នៃប្រទេសកម្ពុជា។ ដោយសារការអភិវឌ្ឍន៍ប្រទេសកំពុងចលនាទៅមុខយ៉ាងលឿន ប្រទេសកម្ពុជាកាន់តែមានលទ្ធភាពផ្តល់តំរូវការជាមូលដ្ឋានដល់ប្រជាជនកម្ពុជា។ សូចនាករជំរើសខាងក្រោមនេះបង្ហាញរូបភាពនៃកំណើនសេដ្ឋកិច្ចរួមនិងការអភិវឌ្ឍន៍មនុស្សក្នុងប្រទេសកម្ពុជា។

១. សន្ទស្សន៍នៃការអភិវឌ្ឍន៍មនុស្ស
២. ផលិតផលសរុបក្នុងស្រុកសំរាប់ប្រជាជនម្នាក់
៣. % នៃគ្រួសារដែលស្ថិតនៅក្រោមចំណាត់ថ្នាក់ភាពក្រីក្រ
៤. អត្រាអនក្ខរកម្មស្ត្រី
៥. អត្រាសាយកូន
៦. អាយុកាលមធ្យមរបស់បុរសនិងស្ត្រី
៧. អត្រាកំណើតក្នុងប្រជាជន ១០០០ នាក់
៨. អត្រាស្លាប់ក្នុងប្រជាជន ១០០០ នាក់

- **លើកស្ទួយស្ថានភាពសុខភាព** ដើម្បីបង្ហាញអំពីការផ្លាស់ប្តូរនៃស្ថានភាពសុខភាពទូទៅ និងសុខមាលភាពរបស់ប្រជាជនកម្ពុជាក្នុងអំលុងពេលមួយសូចនាករលទ្ធផលដែលបានជ្រើសរើស ដើម្បីវាយតំលៃផលប៉ះពាល់នៃ ផ.យ.ស.២ មានដូចខាងក្រោមនេះ៖

១. អត្រាស្លាប់របស់កុមារអាយុក្រោម១ ឆ្នាំ ក្នុងចំណោមទារកកើតរស់ ១០០០នាក់
២. អត្រាស្លាប់របស់ទារកទើបនឹងកើត ក្នុងចំណោមទារកកើតរស់ ១០០០នាក់
៣. អត្រាស្លាប់របស់កុមារអាយុក្រោម៥ ឆ្នាំ ក្នុងចំណោមទារកកើតរស់ ១០០០នាក់
៤. % នៃកុមារដែលមានជំងឺកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ

៥. អត្រាស្លាប់របស់មាតា ក្នុងចំណោម ទារកកើតរស់ ១០០.០០០នាក់
៦. អត្រាប្រេវ៉ាឡង់នៃ ក្នុងចំណោមមនុស្សពេញវ័យអាយុពី ១៥-៤៩ ឆ្នាំ
៧. អត្រាដោយសារជំងឺរបេង ក្នុងចំណោមប្រជាជន ១.០០០ នាក់
៨. អត្រាស្លាប់នៃជំងឺគ្រុនចាញ់ ក្នុងចំណោមប្រជាជន ១.០០០ នាក់
៩. % នៃការស្លាប់ដោយសារគ្រោះថ្នាក់ចរាចរ

សូចនាករទាំងនេះ ត្រូវបំបែកដើម្បីឱ្យដឹងទៅតាម ក្រុម ប្រជាជនដែលមានស្ថានភាពសេដ្ឋកិច្ចសង្គម ខុសៗគ្នាក៏ដូចតាមទីតាំងភូមិសាស្ត្រ និងយេនឌ័រ។

- **លើកកំពស់ស្នាដៃការងារប្រព័ន្ធសុខាភិបាលនិងសេវា** ជាមធ្យោបាយ ដើម្បីសំរេចបានការលើកស្ទួយសុខភាពសូចនាករស្នូលត្រូវបានជ្រើសរើសសំរាប់វាស់វែងវឌ្ឍនភាព ប្រចាំឆ្នាំនៅក្នុងយុទ្ធសាស្ត្រទាំង ៥ និងកម្មវិធីសុខភាពទាំង ៣ ដោយផ្តោតចំបងលើ:
  - បង្កើនធនធានសំរាប់វិសយ័សុខាភិបាលវាស់វែង ប្រសិទ្ធភាព (ការបែងចែកនិងប្រើប្រាស់)
  - លើកស្ទួយដំណើរមុខងារនៃប្រព័ន្ធ
  - បង្កើនលទ្ធភាពមកទទួលយកសេវា ការប្រើប្រាស់ ការគ្របដណ្តប់ និងគុណភាព

ក្របខណ្ឌសូចនាករស្នូលសំរាប់ការត្រួតពិនិត្យតាមដានវឌ្ឍនភាពប្រចាំឆ្នាំនៃផ.យ.ស.២

ស១. % នៃប្រជាជនដែលទទួលបានសេវា ស.ស.អ MPA ពេញលេញ
ស២. អត្រាប្រើប្រាស់គ្រែ
ស៣. រយៈពេលមធ្យមនៃការសំរាកព្យាបាល (ចំនួនថ្ងៃ)
ស៤. %នៃឱសថសារវ័ន្ត(១៥មុខក្នុងបញ្ជី) នៅមណ្ឌលសុខភាពដែលបានប្រឈមមុខនឹងការដាច់ស្តុក
ស៥. % អតិថិជនដែលពេញចិត្តនឹងគុណភាពសេវាសាធារណៈ
ស៦. ការពិគ្រោះជំងឺ (ករណីថ្មី) ក្នុងមួយឆ្នាំ
ស៧. ប្រេវ៉ាឡង់នៃវិធីពន្យារកំណើតទំនើប
ស៨. ពិនិត្យផ្ទៃពោះ ២ ដង ឬច្រើនដងដោយបុគ្គលិកសុខាភិបាល
ស៩. % នៃស្ត្រីមានផ្ទៃពោះដែលបានទទួល ART សម្រាប់ PMTCT
ស១០. % នៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមានការបណ្តុះបណ្តាល
ស១១. % នៃការសម្រាលកូនដោយវះកាត់
ស១២. % នៃកុមារអាយុក្រោមមួយឆ្នាំដែលបានចាក់ថ្នាំបង្ការជំងឺកញ្ជ្រិល
ស១៣. % នៃអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ដែលប្រើឱសថពន្យាជីវិតនៅរស់រានក្រោយពីការព្យាបាលរយៈពេល១២ខែ

សខ១៤. អត្រាស្រាវជ្រាវករណីជំងឺរបេងសួត បេកាវិជ្ជមាន (%)

សខ១៥. អត្រាជាសះស្បើយនៃការព្យាបាលជំងឺរបេង (%)

សខ១៦. ចំនួនករណីគ្រុនចាញ់ដែលបានព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈក្នុងប្រជាជន១.០០០នាក់

សខ១៧. អត្រាស្លាប់ដោយជំងឺគ្រុនឈាមបានរាយការណ៍មកសុខាភិបាលសាធារណៈ

សខ១៨. ប្រេវ៉ាឡង់ជំងឺទឹកនោមផ្អែមលើមនុស្សពេញវ័យដែលបានរាយការណ៍ពីមូលដ្ឋានសុខាភិបាលសាធារណៈ

សខ១៩. % នៃអ្នករបួសដែលប៉ះទង្គិចក្បាលដោយសារគ្រោះថ្នាក់ចរាចរណ៍បានទទួលការព្យាបាល

សខ២០. ចំនួននៃករណីជំងឺផ្លូវចិត្តដែលបានរាយការណ៍ពីមូលដ្ឋានសុខាភិបាល

សខ២១. ចំណែកនៃថវិកាជរបស់សុខាភិបាលខេត្ត-ក្រុងដែលបានចំណាយនៅមន្ទីរសុខាភិបាលខេត្ត-ក្រុង ការិយាល័យស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព

សខ២២. អត្រាគ្របដណ្តប់នៃមូលនិធិសមធម៌

សខ២៣. ការគ្របដណ្តប់នៃការអនុវត្តន៍កិច្ចសន្យាផ្តល់សេវា

សខ២៤. ចំនួនមណ្ឌលសុខភាពដែលមានបុគ្គលិកតាមគោលការណ៍ណែនាំ MPA

សខ២៥. % នៃមន្ទីរសុខាភិបាលខេត្តទទួលពត៌មានត្រលប់អំពី HIS ពីក្រសួង

សខ២៦. % នៃមូលនិធិជំនួយសម្រាប់សុខភាពដែលបានដាក់បញ្ចូលក្នុងផែនការរំកិល៣ឆ្នាំ

សខ២៧. % នៃគ្រឹះស្ថានឯកជនដែលបានផ្តល់អាជ្ញាប័ណ្ណៈពហុគ្លីនិក បន្ទប់ពិគ្រោះជំងឺ ឱសថស្ថាន

សខ២៨. ចំនួនគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពដែលដំណើរការ

សំណុំសូចនាករ (ដោយបញ្ចូលទាំងសូចនាករស្នូលខាងលើ) សំរាប់ត្រួតពិនិត្យតាមដានស្នាដៃទូទៅនៃវិស័យសុខាភិបាលប្រចាំឆ្នាំមានបង្ហាញនៅក្នុងតារាង ឧបសម្ព័ន្ធ។ ឈរលើទស្សនៈនៃការធ្វើផែនការប្រចាំឆ្នាំ សូចនាករទាំងអស់នេះនឹងត្រូវបានបញ្ចូលទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលបង្កើតបានជាមូលដ្ឋាននៃការរៀបចំចាត់ចែងទីភ្នាក់ងារប្រតិបត្តិការពិសេស កិច្ចសន្យាផ្តល់សេវា រួមទាំងការលើកទឹកចិត្តតាមស្នាដៃការងារ។ មណ្ឌលគ្រប់គ្រងថវិកានៅគ្រប់ថ្នាក់ទាំងអស់អាចបន្ថែមសូចនាករខ្លះទៀត ដើម្បីត្រួតពិនិត្យតាមដានអន្តរាគមន៍និងសកម្មភាពនៃផែនការរបស់ខ្លួនដោយម៉ត់ចត់។

ជំពូក ៧

# ថ្លៃចំណាយនិងមូលនិធិ សំរាប់អន្តរាគមន៍ជាយុទ្ធសាស្ត្រ

- ថ្លៃចំណាយលើការបង្កើនការប្រើប្រាស់សេវា
- ថ្លៃចំណាយពង្រីកកិច្ចសន្យាផ្តល់សេវា
- ថ្លៃចំណាយលើការពង្រីកមូលនិធិសមធម៌
- ថ្លៃចំណាយលើអន្តរាគមន៍សុខភាពបន្តពូជ
- ថ្លៃចំណាយលើអន្តរាគមន៍ការរស់រានរបស់កុមារ
- ប្រាក់លាភការបន្ថែមផ្អែកលើស្នាដៃការងារ

# ៧ ថ្លៃចំណាយ និងមូលនិធិសំរាប់អន្តរាគមន៍ជាយុទ្ធសាស្ត្រ

## ១. សេចក្តីផ្តើម

ជំពូកនេះ ដាក់ចេញនូវថ្លៃចំណាយក្នុងពេលអនាគតដែលអាចកើតឡើង សម្រាប់យុទ្ធសាស្ត្រជាគន្លឹះខ្លះដែលត្រូវបានចាត់ទុកថាជាផ្នែកមួយនៃផ.យ.ស.២។ គោលបំណងនៃការពិនិត្យលើថ្លៃចំណាយនេះ គឺដើម្បីផ្តល់នូវក្របខ័ណ្ឌទូលំទូលាយមួយ ស្តីពីអាទិភាពធនធានជាមធ្យោបាយមួយនៃការបង្ហាញអំពីការវិភាជន៍ធនធានរបស់ម្ចាស់ជំនួយ និងរដ្ឋាភិបាលក្នុងការគាំទ្រដល់ការអនុវត្តផ.យ.ស២។ ការគណនាថ្លៃចំណាយលំអិតសំរាប់សកម្មភាពនៅក្នុងយុទ្ធសាស្ត្រនិងកម្មវិធី គឺមិនមានបង្ហាញនៅទីនេះទេ ហើយនឹងត្រូវអនុវត្តតាមរយៈការកែសម្រួលផ.គ្រ.ស និងបែបបទផែនការរំកិលពាឆ្នាំនិងផែនការប្រតិបត្តិប្រចាំឆ្នាំ។

## ២. សមាសភាគថ្លៃចំណាយនិងសម្មតិកម្ម

អន្តរាគមន៍ជាយុទ្ធសាស្ត្រ ដែលមានផលប៉ះពាល់ដល់ធនធានចម្បងៗ ហើយត្រូវបានចាត់ទុកថាជាសមាសភាគនៃការគណនាថ្លៃចំណាយ ផ.យ.ស.២ រួមមាន :

- ការបង្កើនការប្រើប្រាស់សេវាតាមកំណើនប្រជាជន ក៏ដូចជាការកើនឡើងនូវតម្រូវការសម្រាប់សេវាសុខភាពសាធារណៈ
- ការពង្រីកការចុះកិច្ចសន្យា
- ការពង្រីកមូលនិធិសមធម៌

- ការពង្រីកអន្តរាគមន៍គន្លឹះនានា សំដៅលើកកម្ពស់សុខភាពមាតានិងកុមារ (ដូចមានរៀបរាប់នៅក្នុងយុទ្ធសាស្ត្រសុខភាពបន្តពូជនិងការរស់រានរបស់កុមារ)
- ការបង្កើនការចំណាយលើបៀវត្ស ដោយសារកំណែទម្រង់បៀវត្ស

ការសន្មតដែលពាក់ព័ន្ធនឹងថ្លៃចំណាយដែលបានប៉ាន់ស្មាន រួមមាន :

- ការកើនឡើងដែលរំពឹងទុកនៅក្នុងការប្រើប្រាស់សេវា
- កម្រិតនៃថ្លៃចំណាយឯកតានៃសេវាផ្សេងៗនៅមូលដ្ឋានសុខាភិបាលនានា
- ការកើនឡើងដែលរំពឹងទុកនៅក្នុងថ្លៃចំណាយឯកតា ដើម្បីជំរុញឱ្យគុណភាពសេវាកាន់តែមានភាពល្អប្រសើរឡើង
- លទ្ធភាពដែលអាចពង្រីកសេវាបាននៅថ្លៃចំណាយ marginal cost (ឧ.ដោយសន្មតថាមានសមត្ថភាពបម្រុង ហើយបុគ្គលិកដែលមានស្រាប់នៅក្នុងមូលដ្ឋានសុខាភិបាលបច្ចុប្បន្ននិងការងារបន្ថែមទៀត) ដោយប្រៀបធៀបទៅនឹងថ្លៃចំណាយពេញលេញ (ដែលតម្រូវឱ្យមានចំនួនបុគ្គលិកបន្ថែមទៀតធ្វើការនៅក្នុងមូលដ្ឋានសុខាភិបាលដែលមានស្រាប់ ក៏ដូចជាបុគ្គលិកបន្ថែមទៀតធ្វើការនៅក្នុងមូលដ្ឋានសុខាភិបាលថ្មីផងដែរ)។
- លទ្ធភាពដែលអាចបំពេញការប្រើប្រាស់សេវាបានដោយប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ដោយមិនចាំបាច់ធ្វើការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធថ្មី។

## ២.១ សូចនាករសម្រាប់ការប្រើប្រាស់សេវា

អត្រាប្រើប្រាស់សេវាបាននិងកំពុងកើនឡើងយ៉ាងរហ័សនៅក្នុងប្រទេសកម្ពុជាទោះបីជាបានចាប់ផ្តើមពីកម្រិតទាបបំផុតក៏ដោយ ។

**និន្នាការនៃការពិគ្រោះជំងឺក្រៅ**

| | ថ្នាក់ខេត្ត | មន្ទីរពេទ្យជាតិ | ករណីពិគ្រោះជំងឺ/មនុស្សម្នាក់/១ឆ្នាំ |
|---|---|---|---|
| ២០០២ | ៤.៥៩៥.៩៣៩ | ២៣៣.៦៥០ | ០,៤០ |
| ២០០៣ | ៤.៥៩៧.៨៧៦ | ៣៦៨.៥១៧ | ០,៣៩ |
| ២០០៤ | ៥.៣៨៨.៨៨៥ | ៥២៦.៣០៣ | ០,៤០ |
| ២០០៥ | ៦.២៥៤.៧២៦ | ៦៩៧.៦៤៦ | ០,៥០ |
| ២០០៦ | ៧.៥១០.៥៥៨ | ៨៨៦.៨៩៥ | ០,៦០ |
| កំណើនប្រចាំឆ្នាំជាមធ្យម ២០០២-២០០៦ | ១៣,១ | ៣៩,៦ | |

ប្រភព : ស្ថិតិប្រចាំឆ្នាំក្រសួងសុខាភិបាល

## ២.២ សច្ចតិកម្មសម្រាប់ថ្លៃចំណាយ

### ថ្លៃចំណាយក្នុងមួយឯកតា

ថ្លៃចំណាយក្នុងមួយឯកតា គឺផ្អែកទៅលើការវិភាគថ្លៃចំណាយមួយឯកតាពីមូលដ្ឋានសុខាភិបាលនៅក្នុងស្រុកប្រតិបត្តិចុះកិច្ចសន្យាដែលត្រូវបានសន្មតថាដំណើរការដោយមានប្រសិទ្ធផលខ្ពស់គួរសម និងមានគុណភាពដែលអាចទទួលយកបាន។ ថ្លៃចំណាយមួយឯកតាត្រូវបានគេសន្មតថានៅតែស្ថិតក្នុងកម្រិតដដែល។ដូច្នេះស្ថានភាពនេះមិនតម្រូវឱ្យមានការខិតខំប្រឹងប្រែងបន្ថែមដើម្បីលើកកម្ពស់គុណភាពនោះទេ។

### ថ្លៃចំណាយមួយឯកតា

| មូលដ្ឋានសុខាភិបាល | សេវា | ថេរ | អថេរ | សរុប |
|---|---|---|---|---|
| មន្ទីរពេទ្យ | ថ្លៃចំណាយលើការពិគ្រោះជំងឺក្រៅម្នាក់ | ១,៧២ | ០,៩៨ | ២,៧០ |
| | ថ្លៃចំណាយលើអ្នកជំងឺសំរាកពេទ្យម្នាក់ | ២,០១ | ៧,៦៤ | ១៨,៨៩ |
| មណ្ឌលសុខភាព | ថ្លៃចំណាយលើការពិគ្រោះជំងឺក្រៅម្នាក់ | ០,៥៧ | ០,៥៩ | ១,១៦ |

ប្រភព :ការគណនាថ្លៃចំណាយប័ណ្ណពិន្ទុកុមារ ២០០៧

### ថ្លៃចំណាយបន្ទាប់បន្សំធៀបនឹងថ្លៃចំណាយពេញលេញ (Marginal vs. Full cost)

អត្រាប្រើប្រាស់គ្រែនៅក្នុងមន្ទីរពេទ្យ ទោះបីជាកំពុងតែកើនឡើងក៏ដោយក៏នៅតែស្ថិតក្រោមកម្រិតអតិបរមាជាមធ្យមដែរ។នេះបង្ហាញថាមានវិសាលភាពខ្ពស់សម្រាប់ឆ្លើយតបទៅនឹងតម្រូវការនាពេលអនាគតជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ដោយប្រើប្រាស់កាន់តែប្រសើរនូវសមត្ថភាពដែលកំពុងមាន។ ការគណនាថ្លៃចំណាយនេះសន្មតថា គ្រប់សេវាទាំងអស់អាចត្រូវបានផ្តល់ ដោយការចំណាយបន្ទាប់បន្សំតែប៉ុណ្ណោះ ហើយពុំចាំបាច់ត្រូវការថ្លៃចំណាយថេរបន្ថែមឡើយ។

ក្នុងករណីត្រូវការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងតម្រូវការដែលកំពុងកើនឡើងការវិនិយោគបែបនេះនឹងត្រូវគ្របដណ្តប់ក្រោមការកែសម្រួលនិងការអនុវត្តន៍ ផ.គ្រ.ស។

### ថ្លៃចំណាយមួយឯកតានៃអន្តរាគមន៍ជាក់លាក់

| | |
|---|---|
| **ថ្លៃចំណាយបូកយោងនៃកិច្ចសន្យា** | |
| នៅថ្នាក់មណ្ឌលសុខភាព | $ ០,៤៨ លើមនុស្សម្នាក់ក្នុងមួយឆ្នាំ |
| នៅថ្នាក់មន្ទីរពេទ្យ | $ ០,៦០ លើមនុស្សម្នាក់ក្នុងមួយឆ្នាំ |
| **ថ្លៃចំណាយមូលនិធិសមធម៌** | |
| ថ្លៃចំណាយលើមនុស្សម្នាក់ក្នុងមួយឆ្នាំ<br>ថ្លៃចំណាយលើសមាជិកមូលនិធិសមធម៌ម្នាក់ | $ ០,៥០<br>$ ១,៤០ |

**ប្រភព** Lane 2007 **និង** URC

## ៣. ថ្លៃចំណាយលើការពង្រីកអន្តរាគមន៍

### ៣.១ ថ្លៃចំណាយលើការបង្កើនការប្រើប្រាស់សេវា

ឧបមាថាការប្រើប្រាស់នឹងកើនឡើងនៅក្នុងកម្រិតដូចគ្នានឹងឆ្នាំ២០០២-២០០៦ ហើយមូលដ្ឋានសុខាភិបាលនិងបុគ្គលិកដែលមានស្រាប់អាចឆ្លើយតបនឹងតម្រូវការដែលកើនឡើងនៅក្នុងដំណាក់កាលពង្រឹងនោះ ថ្លៃចំណាយដែលកើនឡើងសម្រាប់ការប្រើប្រាស់នឹងច្រើនជាងមុន ដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម :

**ថ្លៃចំណាយចរន្តដែលកើនឡើងនៃការប្រើប្រាស់សេវាច្រើនជាងមុន (គិតជា លានដុល្លារអាមេរិក)**

| | ២០០៨ | ២០១០ | ២០១២ | ២០១៥ |
|---|---|---|---|---|
| ការប្រើប្រាស់ច្រើនជាងមុន-ថ្លៃចំណាយចរន្ត | ២,០ | ៦,១ | ១៣,១ | ២៣,៩ |

### ៣.២ ថ្លៃចំណាយលើការពង្រីកកិច្ចសន្យា

ការសន្មតជាក់លាក់សម្រាប់ថ្លៃចំណាយលើការពង្រីកកិច្ចសន្យាទាក់ទងទៅនឹងល្បឿននៃការពង្រីកកិច្ចសន្យា ។ដោយពិចារណាទៅលើអភិក្រមជាដំណាក់កាល៧ដែលបានកំណត់ក្នុង ផ.យ.ស.២ ការគ្របដណ្តប់ទាំងស្រុងនៃកិច្ចសន្យាអាចសម្រេចនៅដំណាច់ឆ្នាំ២០១៥ ។

ថ្លៃចំណាយលើការចាត់ចែងពង្រីកកិច្ចសន្យាពាក់ព័ន្ធទៅនឹងកំណើនប្រជាជនដែរ ប៉ុន្តែសន្មតថាធាតុចូលបន្ថែមក្នុងមនុស្សម្នាក់នៅតែស្ថិតក្នុងកម្រិតដដែល ។

កំហិតនៃការគណនាថ្លៃចំណាយគឺថា អភិក្រមនេះផ្តោតទាំងស្រុងទៅលើថ្លៃចំណាយ លើការផ្តល់សេវា ។ នៅពេលដែលគោលនយោបាយជាតិស្តីពីកិច្ចសន្យាត្រូវបានកំណត់ច្បាស់លាស់ការគណនាថ្លៃចំណាយនេះនឹងត្រូវបានពិនិត្យឡើងវិញដើម្បីពិចារណាអំពីតម្រូវការចាំបាច់នានាសំរាប់ពង្រឹងសមត្ថភាពថ្នាក់ខេត្ត-ក្រុងនិងស្រុក ក៏ដូចជាការផ្លាស់ប្តូរតួនាទីរបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងបរិស្ថានកិច្ចសន្យាថ្មី ។

**ថ្លៃចំណាយកើនឡើងទាក់ទងទៅនឹងការពង្រីកសេវាចុះកិច្ចសន្យា (គិតជា លានដុល្លារអាមេរិក)**

| | ២០០៨ | ២០១០ | ២០១២ | ២០១៥ |
|---|---|---|---|---|
| ការគ្របដណ្តប់ជាសកលត្រឹមឆ្នាំ ២០១៥ | ២,០២ | ៦,០៥ | ១០,០៩ | ១៦,១៥ |

### ៣.៣ ថ្លៃចំណាយសម្រាប់ការពង្រីកមូលនិធិសមធម៌

ការពង្រីកមូលនិធិសមធម៌នឹងប្រព្រឹត្តទៅតាមល្បឿនដូចគ្នានឹងការពង្រីកកិច្ចសន្យាដែរ ព្រមទាំងផ្តោតលើការគ្របដណ្តប់ជាសកលត្រឹមឆ្នាំ២០១៥ ។

តួលេខនៃថ្លៃចំណាយសរុបអាចប្រែប្រួលទៅតាមកត្តាដែលបានព្យាករណ៍ទុកនានា ដូចជាកំណើនប្រជាជន ប៉ុន្តែនៅមានសមាសធាតុខ្លះដែលមិនពិបាកនឹងព្យាករណ៍ទុកដូចជាកម្រិតចុះថយនៃភាពក្រីក្រ ។

គោលនយោបាយស្តីពីការបង់ថ្លៃសេវានឹងមានឥទ្ធិពលទៅលើតម្លៃ និងទៅលើវិក្ក័យប័ត្រមូលនិធិសមធម៌។ បន្ថែមពីលើនេះថ្លៃចំណាយនេះត្រូវតែបានពិនិត្យឡើងវិញ បន្ទាប់ពីក្រសួងសុខាភិបាលមានគោលនយោបាយមួយច្បាស់លាស់ស្តីពីមូលនិធិសមធម៌ត្រូវបានដាក់ឱ្យប្រើប្រាស់។ សមាសធាតុនៃគោលនយោបាយក្នុងពេលអនាគតដែលអាចមានឥទ្ធិពលទៅលើថ្លៃចំណាយសរុបគឺ :

- ការពង្រីកយ៉ាងលឿននៃមូលនិធិសមធម៌ដែលផ្តោតទៅលើតែមន្ទីរពេទ្យ ឬ
- ការពង្រីកមូលនិធិសមធម៌ដោយផ្តោតទៅលើទាំងមន្ទីរពេទ្យ និងមណ្ឌលសុខភាព
- បង្កើនការគាំទ្រ ដើម្បីកំណត់មូលនិធិសមធម៌ដំណើរការក្នុងតំបន់ក្រីក្រ ខណៈពេលផ្តល់ការវិភាជន៍ថវិកាទាបជាងមុនសម្រាប់មូលនិធិសមធម៌ដែលដំណើរការនៅក្នុងតំបន់ ដែលធូរធារជាងនេះ (ពោលគឺគោលដៅចំណុចនៃទីតាំងភូមិសាស្ត្រ)។
- ផលប៉ះពាល់នៃទំនាក់ទំនងរវាងមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក (ការពង្រីកទៅមណ្ឌលសុខភាពនឹងបង្វែរតម្រូវការចេញពីមន្ទីរពេទ្យបង្អែកគ្របដណ្តប់លើប្រជាជន កាន់តែច្រើនជាងមុនសម្រាប់ថ្លៃចំណាយនៃការព្យាបាលក្នុងមួយឯកតាតូចជាងមុន ប៉ុន្តែតម្រូវការនៃការបញ្ជូនជំងឺកាន់ច្រើនឡើង)
- ការសម្រេចចិត្តលើការកំណត់អត្តសញ្ញាណអ្នកក្រីក្រទុកជាមុន និងភាពញឹកញាប់ដែលគួរធ្វើកិច្ចការនេះ។

**ថ្លៃចំណាយដែលកើនឡើងទាក់ទងទៅនឹងការពង្រីកមូលនិធិសមធម៌ (គិតជាលានដុល្លារ)**

| | ២០០៨ | ២០១០ | ២០១២ | ២០១៥ |
|---|---|---|---|---|
| ការគ្របដណ្តប់ជាសកលត្រឹមឆ្នាំ២០១៥ | ០,៧៤ | ២,២៣ | ៣,៧១ | ៥,៩៤ |

## ៣.៤ ថ្លៃចំណាយលើអន្តរាគមន៍សុខភាពបន្តពូជ

ការគណនាថ្លៃចំណាយនៃយុទ្ធសាស្ត្រសុខភាពបន្តពូជ ពិចារណាអំពីថ្លៃចំណាយលើការផ្តល់សេវាក៏ដូចជាលក្ខខណ្ឌបង្គ្រប់ផ្សេងៗដូចជា ថ្លៃចំណាយលើការជ្រើសរើសឆ្មបបន្ថែម ថ្លៃចំណាយលើប្រតិបត្តិការរបស់កម្មវិធីជាតិ និងថ្លៃចំណាយប្រតិបត្តិសម្រាប់ថ្នាក់មន្ទីរពេទ្យបង្អែក/ផ្នែកសុខភាពកុមារ និងមាតា និងស្រុកប្រតិបត្តិ ដោយបូកបន្ថែមថ្លៃចំណាយសម្រាប់កម្មវិធីចុះមូលដ្ឋាននិងថ្លៃចំណាយលើការវិនិយោគ ។

**តារាង ១៤: អន្តរាគមន៍ដែលបានដាក់បញ្ចូលនៅក្នុងគំរូនៃការគណនាថ្លៃចំណាយ**

| ការរៀបចំផែនការគ្រួសារ | ការពិនិត្យផ្ទៃពោះ និងការថែទាំក្នុងពេលសម្រាល | ផលវិបាកនៃការសម្ភព |
|---|---|---|
| ១ ថ្នាំពន្យារកំណើតដោយលេប (ថ្នាំគ្រាប់) | ១១ ការថែទាំមុនពេលសម្រាល | ១៦ ការឈឺពោះរយៈពេលយូរ (> ១៨ម៉ោង) |
| ២ ថ្នាំចាក់ | ១២ ការបង្ការនៅក្នុងពេលថែទាំមុនពេលសម្រាល | ១៧ ការសម្រាលដោយប្រើដង្កៀប ឬដោយបូម |
| ៣ ស្រោមអនាម័យ-បុរស | ១៣ ការព្យាបាលគ្រុនចាញ់នៅក្នុងពេលពិនិត្យផ្ទៃពោះ | ១៨ ការសម្រាលដោយវះកាត់ |
| ៤ ស្រោមអនាម័យ-ស្ត្រី | | |
| ៥ កងដាក់ស្បូន IUD | ១៤ ការថែទាំក្នុងពេលសម្រាល | ១៩ ការធ្លាក់ឈាមក្រោយសម្រាល |
| ៦ កងដាក់ដៃ | ១៥ ការថែទាំក្រោយពេលសម្រាល | ២០ ការក្លាយរោគក្រោយសម្រាល |
| ៧ ការSterilization លើបុរស | | ២១ ការឡើងឈាមក្នុងពេលមានផ្ទៃពោះ |
| ៨ Sterilization លើស្ត្រី | | |
| ៩ វិធីផ្សេងៗទៀត | | |
| ១០ ការការពារមិនឱ្យមានកូនបន្ទាន់ | | |
| **លក្ខខណ្ឌមាតាដទៃទៀត** | **អន្តរាគមន៍ទារកទើបកើត** | **ជំងឺកាមរោគនិងការឆ្លងរោគតាមផ្លូវបន្តពូជ** |
| ២២ ការឆ្លងរោគតាមបំពង់នោម | ២៥ ការថែទាំទារកទើបកើតតាមធម្មតា | ២៨ ក្លាមីឌៀ |
| | | ២៩ ប្រមេះទឹកបាយ |
| | | ៣០ ជំងឺស្វាយ |
| ២៣ រោគរលាកសុដន | ២៦ ការព្យាបាលផលវិបាកលើទារកក្រោយកំណើត | ៣១ ទ្រីកូម៉ូណាស់ |
| | | ៣២ ជំងឺរលាកផាល (PID) |
| ២៤ ការថែទាំការរំលូតគ្រប់ជ្រុងជ្រោយ | ២៧ ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន | ៣៣ ការឆ្លងរោគតាមផ្លូវបន្តពូជ (កង់ឌីដា ផ្សិត និង BV) |

ប្រភព: ការសិក្សាអំពីថ្លៃចំណាយលើសុខភាពបន្តពូជ

អត្រាគ្របដណ្តប់គោលដៅចំណុច គឺស្របគ្នានឹងគោលដៅចំណុចជាតិ។ ថ្លៃចំណាយត្រូវបានប៉ាន់ស្មាន តាមរយៈការសិក្សាអំពីថ្លៃចំណាយពីក្រោមទៅលើ។ ទោះបីជាការសិក្សាអំពីថ្លៃចំណាយលើសុខភាពបន្តពូជពីដំបូងបែងចែកពីភាពខុសគ្នារវាងកម្រិតបច្ចុប្បន្ន និងកម្រិតដែលល្អបំផុតនៃថ្លៃចំណាយលើបុគ្គលិកក៏ដោយ (ធៀបទៅនឹងកម្រិតប្រាក់បំណាច់នៅក្នុងស្រុកប្រតិបត្តិជាប់កិច្ចសន្យា) មានតែកម្រិតនៃបុគ្គលិកបច្ចុប្បន្នប៉ុណ្ណោះ ត្រូវបានយកមកពិភាក្សានៅទីនេះ ដើម្បីជៀសវាងការរាប់ត្រួតគ្នាជាមួយនឹងថ្លៃចំណាយលើការពង្រីកកិច្ចសន្យា។

លទ្ធផលនៃការសិក្សាអំពីថ្លៃចំណាយ បានបង្ហាញថាការចំណាយសម្រាប់សេវាសុខភាពបន្តពូជចាំបាច់ត្រូវបង្កើនពី៧,៤ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ក្នុងឆ្នាំ២០០៦ ទៅដល់ ១៦,៦លានដុល្លារអាមេរិកក្នុង១ឆ្នាំក្នុងឆ្នាំ២០១៥។ ចំនួននេះស្មើនឹងការចំណាយសរុបបន្ថែមចំនួន ១០៤,៩លានដុល្លារអាមេរិកសម្រាប់ឆ្នាំ២០០៨-១៥ និងថ្លៃចំណាយកើនឡើងក្នុងមនុស្សម្នាក់ចំនួន ០,៩ ដុល្លារអាមេរិកក្នុងឆ្នាំ ២០១៥ ។

**រូបភាព១០: ថ្លៃចំណាយដែលកើនឡើង_យុទ្ធសាស្ត្រសុខភាពបន្តពូជ**




## ៣.៥ ថ្លៃចំណាយលើអន្តរាគមន៍នៃការរស់រានរបស់កុមារ

ការសិក្សាស្តីពីអន្តរាគមន៍សម្រាប់ការរស់រានរបស់កុមារ បានប៉ាន់ប្រមាណថ្លៃចំណាយទៅលើអន្តរាគមន៍ ចំនួន១១ ក្នុងចំណោមអន្តរាគមន៍លើប័ណ្ណពិន្ទុទាំង១២ (អន្តរាគមន៍ស្តីពីការសម្រាលដោយបុគ្គលិកជំនាញមានដាក់បញ្ចូលនៅក្នុងការសិក្សាស្តីពីថ្លៃចំណាយ សម្រាប់សុខភាពបន្តពូជដូចមានបញ្ជាក់ខាងលើ) ក្នុងបរិបទនៃសំណុំសកម្មភាពអប្បបរមា និងសំណុំសកម្មភាពបង្គ្រប់ ។

អភិក្រមនេះប៉ាន់ប្រមាណទៅលើថ្លៃចំណាយនៃការផ្តល់សេវា នៅតាមមូលដ្ឋានសុខាភិបាលមួយចំនួនដែល"**អនុវត្តការងារល្អ**"ប៉ុន្តែបានផ្តល់នូវអនុសាសន៍ឱ្យមានការវិភាគបន្ថែមទៀត ដើម្បីធ្វើឱ្យលទ្ធផលកាន់តែមានភាពល្អប្រសើរនិងមានភាពតំណាង។ នេះអាចជាកិច្ចការសមស្របមួយសម្រាប់ដំណាក់កាលពង្រឹង (នៃការអនុវត្តន៍ ផ.យ.ស.២)។

ការសិក្សានេះគណនាថ្លៃចំណាយ ដោយប៉ាន់ស្មានពីថ្លៃចំណាយក្នុងមួយឯកតា នៅថ្នាក់ផ្សេងៗ (ភូមិ មណ្ឌលសុខភាព និងមន្ទីរពេទ្យស្រុក) និងគុណថ្លៃចំណាយឯកតាទាំងនេះជាមួយនឹងគោលដៅចំណុចនៃការគ្របដណ្តប់។ ថ្លៃចំណាយត្រូវបានធ្វើវិភាជន៍ដោយយោងទៅតាមវិធីសាស្ត្រទម្ងន់ធៀបដែលបានមកពីមតិអ្នកជំនាញស្តីពីចំនួនស្តង់ដានៃរយៈពេលគិតជានាទី ដែលអ្នកផ្តល់សេវាប្រើប្រាស់សម្រាប់អន្តរាគមន៍នីមួយៗ។ ជាថ្មីម្តងទៀតការសិក្សាបានផ្តល់អនុសាសន៍ថាគួរពិនិត្យឡើងវិញលើទម្ងន់ទាំងនេះក្នុងលក្ខណៈជាប្រព័ន្ធជាងនេះ។ ថ្លៃចំណាយបន្ថែមនៃការពង្រីកអន្តរាគមន៍មានបង្ហាញនៅក្នុងតារាង និងក្រាហ្វិកខាងក្រោមនេះ

**ថ្លៃចំណាយកើនឡើងសុទ្ធនៃការពង្រីកអន្តរាគមន៍នៅលើប័ណ្ណពិន្ទុកុមារ**

| | ២០០៨ | ២០១០ | ២០១២ | ២០១៥ |
|---|---|---|---|---|
| លើកកម្ពស់លទ្ធភាពទទួលបានអន្តរាគមន៍រស់រានរបស់កុមារ | (០,៥) | ១,៧ | ៤,៧ | ១០,៦ |

## ៣.៦ ប្រាក់លាភការបន្ថែមផ្អែកលើស្នាដៃការងារ

គម្រោងផ្តល់ប្រាក់លាភការផ្អែកលើស្នាដៃការងារ គឺជាមធ្យោបាយមួយនៃការផ្តល់កំរិតលាភការចាំបាច់ដល់បុគ្គលិកដែលបានជ្រើសរើសយកដើម្បីឱយបំពេញការទទួលខុសត្រូវរបស់ពួកគេ ដោយជំនួសប្រព័ន្ធនៃការផ្តល់ប្រាក់លើកទឹកចិត្តបន្ថែមម្តងម្កាល។ ថ្លៃចំណាយនៃគម្រោងនេះ មានបង្ហាញនៅក្នុងតារាង ១៥ ខាងក្រោម សម្រាប់ការចំណាយលើកំណែទម្រង់បៀវត្សនៅក្នុងវិស័យសុខាភិបាល។ សម្មតិកម្មនៅទីនេះគឺថាគម្រោងលាភការដោយផ្អែកលើស្នាដៃការងារត្រូវបានអនុវត្តក្នុងឆ្នាំ២០០៨ ។

**តារាង១៥: ថ្លៃចំណាយកើនឡើងចាន់ស្មាននៃគម្រោងលាភការដោយផ្អែកលើស្នាដៃការងារ**

| ថ្លៃចំណាយសរុបប្រចាំឆ្នាំ និងថ្លៃចំណាយកើនឡើងនៃសំណើ លាភការដោយផ្អែកលើស្នាដៃការងារ | | | | |
|---|---|---|---|---|
| ថ្នាក់ | បុគ្គលិក | បៀវត្សសរុប | ថ្លៃចំណាយកើនឡើង | |
| | ចំនួន | កោដិរៀល | កោដិរៀល | លានដុល្លារអាមេរិក |
| ក្រសួងសុខាភិបាល | ១៦០ | ៣,៣០ | ២,៥០ | ០,៦១ |
| មន្ទីរសុខាភិបាលខេត្ត | ៧៥០ | ១០,២៦ | ៨,២៥ | ២,០១ |
| កម្មវិធីជាតិ | ៣៦០ | ៥,៣០ | ៤,២២ | ១,០៣ |
| **សរុប** | **១.២៧០** | **១៨,៨៧** | **១៤,៩៧** | **៣,៦៥** |

ប្រភព : Lane 2007 ដកចេញពីសមាសភាគអភិវឌ្ឍន៍ស្ថាប័នកម្ពុជា និងការផ្តល់ប្រាក់បៀវត្សបន្ថែមផ្អែកតាម ស្នាដៃការងារ នៃគម្រោងទ្រទ្រង់វិស័យសុខាភិបាល OPM មិថុនា ២០០៦។

# ៤. ថ្លៃចំណាយសរុប លទ្ធភាពផ្តល់ថវិកាបាន និងលំហសារពើពន្ធ

ការសន្មតទាំងឡាយខាងក្រោមនេះ ត្រូវបានប្រើប្រាស់ដើម្បីគណនាសេណារីយ៉ូករណីជាមូលដ្ឋានមួយសម្រាប់អនុវត្តយុទ្ធសាស្ត្រគន្លឹះ និងប៉ាន់ស្មានអំពីលំហសារពើពន្ធដែលអាចមាន។

| **យុទ្ធសាស្ត្រគន្លឹះ** | **ការសន្មតសេណារីយ៉ូករណីជាមូលដ្ឋាន** |
|---|---|
| បង្កើនការប្រើប្រាស់សេវាសុខភាពសាធារណៈ: | ការប្រើប្រាស់សេវាកើនឡើងក្នុងល្បឿនដូចគ្នានឹងឆ្នាំ២០០២-២០០៦ ការកើនឡើងនៃការប្រើប្រាស់សេវា អាចប្រព្រឹត្តបាននៅក្នុងមូលដ្ឋានសុខាភិបាលដែលមានស្រាប់ នៅក្នុងដំណាក់កាលពង្រឹង។ តំរូវការឱយមានមូលដ្ឋានសុខាភិបាលថ្មីនឹងត្រូវបានពិចារណា នៅពេលមានការកែសម្រួល និងអនុវត្តផែនការគ្របដណ្តប់សុខាភិបាល។ |
| ការពង្រីកកិច្ចសន្យា | ការគ្របដណ្តប់ជាសកលនៅដំណាច់ឆ្នាំ ២០១៥ |
| ការពង្រីកមូលនិធិសមធម៌ | ការគ្របដណ្តប់ជាសកលនៅដំណាច់ឆ្នាំ ១០១៥ ក្នុងតម្លៃមួយឯកតា ០,៥ ដុល្លា ក្នុងមនុស្សម្នាក់ |

| | |
|---|---|
| ការអនុវត្តន៍យុទ្ធសាស្ត្រសុខភាពបន្តពូជ និងការរស់រានរបស់កុមារ | យុទ្ធសាស្ត្រសុខភាពបន្តពូជនិង យុទ្ធសាស្ត្ររស់រានរបស់កុមារត្រូវបានអនុវត្ត ដើម្បីសម្រេចបានគោលដៅចំណុចជាតិដែលបានកំណត់ នៅក្នុង ផ.យ.ស.២<br>តម្រូវការបុគ្គលិក (បង្កើនបរិមាណនិងបង្កើនបៀវត្ស) ត្រូវបានផាត់ចេញដើម្បីជៀសវាងការរាប់ត្រួតគ្នា ជាមួយនិងការពង្រីកកិច្ចសន្យា និងការគ្របដណ្តប់របស់គម្រោងលាភការដោយផ្អែកលើស្នាដៃការងារ |
| ប្រាក់លាភការដល់បុគ្គលិក | លាភការដោយផ្អែកលើស្នាដៃការងារត្រូវបានអនុវត្តពេញលេញក្នុងឆ្នាំ ២០០៨ |

**តារាង១៦: ការសន្និតលំហសារពើពន្ធសម្រាប់សេណារីយ៉ូផ្អែកលើករណី**

| សេណារីយ៉ូស្តីពីការពង្រីក បញ្ជាក់ក្នុងតម្លៃដុល្លារថេរឆ្នាំ២០០៧ សំរាប់២០០៦_១៥ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
| ផលទុនជាតិសរុប (GDP) | លានដុល្លារ | ៦.៥៦៨ | ៧.០៤១ | ៧.៤៨៦ | ៧.៩៥៦ | ៨.៤៦០ | ៨.៩៩៩ | ៩.៥៧១ | ១០.១៨១ | ១០.៨២៩ | ១១.៥១៨ |
| កំណើនផលទុនជាតិសរុប | % | | ៧,២ | ៦,៣ | ៦,៣ | ៦,៣ | ៦,៤ | ៦,៤ | ៦,៤ | ៦,៤ | ៦,៤ |
| ការចំណាយចរន្តធៀបនឹងផលទុនជាតិសរុប | % | ៩,០ | ៩,៨ | ៩,៧ | ៩,៨ | ១០,០ | ១០,២ | ១០,៤ | ១០,៦ | ១០,៨ | ១១,០ |
| ការចំណាយចរន្ត | លានដុល្លារ | ៥៩៤,៣ | ៦៩២,០ | ៧២៤,១ | ៧៨៣,៣ | ៨៤៨,១ | ៩១៩,០ | ៩៩៥,៨ | ១០៧៨,៩ | ១១៦៩,០ | ១២៦៦,៧ |
| ចំណែកនៃចំណាយចរន្តលើសុខាភិបាល | % | ១០,៦ | ១២,០ | ១២,០ | ១២,០ | ១២,០ | ១២,០ | ១២,០ | ១២,០ | ១២,០ | ១២,០ |
| ថវិកាសុខាភិបាល | លានដុល្លារ | ៦៣,២ | ៨៣,៣ | ៨៧,១ | ៩៤,៣ | ១០២,១ | ១១០,៦ | ១១៩,៨ | ១២៩,៨ | ១៤០,៧ | ១៥២,៤ |
| ការកើនឡើងនៃថវិកាសុខាភិបាលធៀបនឹងឆ្នាំ ២០០៧ | លានដុល្លារ | | | ៣,៩ | ១១,០ | ១៨,៨ | ២៧,៣ | ៣៦,៦ | ៤៦,៦ | ៥៧,៤ | ៦៩,២ |
| កំណត់សម្គាល់:ការព្យាករណ៍សម្រាប់ផលទុនជាតិសរុប និងការចំណាយចរន្តពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ- ក្របខណ្ឌចំណាយរយៈពេលមធ្យម។ ការចំណាយលើសុខភាព: ការប៉ាន់ស្មានឆ្នាំ២០០៦និងថវិកាឆ្នាំ២០០៧។ សំរាប់ ២០០៨–១៥ ការគណនាគិត ១២ភាគរយ នៃការចំណាយចរន្តដូចមានបង្ហាញនៅក្នុង ផ.យ.អ.ជ ២០០៦-១០។ | | | | | | | | | | | |

ដោយអនុវត្តនូវសេណារីយ៉ូទាំងនេះ ថ្លៃចំណាយដែលប៉ាន់ស្មាននៃយុទ្ធសាស្រ្តគន្លឹះ និងលំហសារពើពន្ធដែលកើនឡើងត្រូវបានបង្ហាញនៅក្នុងតារាង១៧ ខាងក្រោមនេះ ។

**តារាង១៧: ថ្លៃចំណាយប៉ាន់ស្មានទៅលើយុទ្ធសាស្រ្តជាគន្លឹះ (គិតជាលានដុល្លារអាមេរិក)**

| | **២០០៨** | **២០១០** | **២០១២** | **២០១៥** |
|---|---|---|---|---|
| ការប្រើប្រាស់កើនឡើង – ថ្លៃចំណាយចរន្ត | ២,០ | ៦,១ | ១៣,១ | ២៣,៩ |
| លើកកម្ពស់លទ្ធភាពទទួលសេវាសុខភាពបន្តពូជ | ២,៦ | ១២,៥ | ១៨,៥ | ២៨,២ |
| លើកកម្ពស់លទ្ធភាពទទួលអន្តរាគមន៍រស់រានកុមារ | (០,៥) | ១,៧ | ៤,៧ | ១០,៦ |
| កិច្ចសន្យា | ២,០២ | ៦,០៥ | ១០,០៩ | ១៦,១៥ |
| មូលនិធិសមធម៌ | ០,៧៤ | ២,២៣ | ៣,៧១ | ៥,៩៤ |
| គម្រោងផ្តល់ប្រៀវត្សរ៍ផ្អែកលើគុណបំណាច់ | ៣,៧ | ៣,៧ | ៣,៧ | ៣,៧ |
| **សរុប - អាទិភាពស្នូល** | **១០,៦** | **៣២,៣** | **៥៣ ,៨** | **៨៨,៥** |
| **លំហសារពើពន្ធកើនឡើង** | **៣,៩** | **១៨,៨** | **៣៦,៦** | **៦៩,២** |

រូបភាព ១១:លទ្ធភាពផ្តល់ថវិកានៃអន្តរាគមន៍ជាយុទ្ធសាស្រ្ត
ថ្លៃចំណាយសរុបនៃអាទិភាពស្នូលប្រៀបធៀបទៅនឹងលំហសារពើពន្ធដែលអាចមាន




តួលេខខាងលើប្រៀបធៀបថ្លៃចំណាយលើយុទ្ធសាស្រ្តសំខាន់ៗ ជាមួយនឹងលំហសារពើពន្ធដែលអាចមាន សម្រាប់រដ្ឋាភិបាលក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។ ថ្លៃចំណាយទាំងនេះគឺហួសពីមធ្យោបាយដែលរដ្ឋអាចមានលទ្ធភាព ដូច្នេះនឹងត្រូវការធនធានពីម្ចាស់ជំនួយយ៉ាងច្រើន ទោះបីជាការគាំទ្រពីម្ចាស់ជំនួយដែលបានផ្តល់ដល់វិស័យសុខាភិបាលបច្ចុប្បន្នមានលំដាប់ល្អប្រសើរក៏ដោយ។

## ក្របខណ្ឌសូចនាករសម្រាប់ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ

| សូចនាករ | ប្រចាំឆ្នាំ | សូចនាករស្នូល ព.ស.ឆ | ទិន្នន័យដើមគ្រា ២០០៨ តំលៃ | ទិន្នន័យដើមគ្រា ២០០៨ ឆ្នាំ | គោលដៅ ចំណុច២០១០ (២០១១ពិនិត្យពាក់កណ្តាលអាណត្តិ) | គោលដៅចំណុច ២០១៥ ការវាយតម្លៃ |
|---|---|---|---|---|---|---|
| **ការអភិវឌ្ឍន៍ទូទៅ** សូចនាករផ្តល់រូបភាពអំពីកំណើនសេដ្ឋកិច្ចជាទូទៅនិងការអភិវឌ្ឍន៍មនុស្សនៅកម្ពុជានិងអាចត្រូវបានប្រើប្រាស់ ដើម្បីប្រៀបធៀបជាមួយប្រទេសដទៃទៀត។ | | | | | | |
| ១. សន្ទស្សន៍នៃការអភិវឌ្ឍន៍មនុស្ស *(a)* | ✓ | ✓ | ០,៥៩៨ | ២០០៥ | | |
| ២. ផលិតផលសរុបក្នុងស្រុកក្នុងមនុស្សម្នាក់ក្នុង១ឆ្នាំ *(b)* | ✓ | ✓ | ៥១៣US$ | ២០០៦ | | |
| ៣. ％ នៃគ្រួសារក្រោមបន្ទាត់ក្រីក្រ *(b)* | | | ៣៤,៧១ | ២០០៦ | ២៥ | |
| ៤. អត្រាសាយកូនសរុប *(c)* | | | ៣,៤ | ២០០៥ | ៣,៤ | ៣,០ |
| ៥. អត្រាអក្ខរកម្មរបស់ស្ត្រី *(d)* | | | ៦៤ | ២០០៤ | | |
| ៦. អាយុកាលរំពឹងទុករបស់បុរស/ស្ត្រី *(b)* | | | ៥៧/៦៤ | ២០០៦ | | |
| ៧. អត្រាកំណើតដុលក្នុងប្រជាជន ១.០០០នាក់ *(c)* | | | ២៥,៦ | ២០០៥ | | |
| ៨. អត្រាស្លាប់ដុលក្នុងប្រជាជន ១.០០០នាក់ | | | *គ្មានព័ត៌មាន* | | | |
| **លើកកម្ពស់សុខភាព** សូចនាករបង្ហាញពីការផ្លាស់ប្តូរនៃស្ថានភាពសុខភាពក្នុងអំលុងពេលមួយ និងអំពីការគ្រប់គ្រងដោយប្រសិទ្ធភាពនូវជំងឺចម្បងៗនៅក្នុងវិស័យសាធារណៈ ដែលនឹងវាយតំលៃរៀងរាល់ ៥ឆ្នាំម្តងតាមរយៈ អ.ប្រ.ស និងប្រភពដទៃទៀត។ | | | | | | |
| ១. អត្រាមរណភាពមាតាក្នុង ទារកកើតរស់១០០.០០០នាក់ | | | ៤៧២ | ២០០៥ | ២៤៣ | ១៤០ |
| ២. អត្រាស្លាប់ទារកទើបប្រសូត្រក្នុងទារកកើតរស់១.០០០នាក់ | | | ២៨ | ២០០៥ | ២៥ | ២២ |
| ៣. អត្រាស្លាប់កុមារអាយុក្រោម១ឆ្នាំក្នុងទារកកើតរស់១.០០០នាក់ | | | ៦៦ | ២០០៥ | ៦០ | ៥០ |
| ៤. អត្រាស្លាប់កុមារអាយុក្រោម៥ឆ្នាំក្នុងទារកកើតរស់១.០០០នាក់ | | | ៨៣ | ២០០៥ | ៧៥ | ៦៥ |
| ៥. ％ នៃកុមារក្រោម៥ឆ្នាំដែលមានកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ:ក្រិន<br>*គិតតាមស្តង់ដារថ្មីនៃការលូតលាស់របស់អង្គការសុខភាពពិភពលោក* | | | ៣៧<br>*(៤៣)* | ២០០៥ | ២៨<br>*(៣៥)* | ២២<br>*(២៥)* |
| ៦. ％ នៃកុមារក្រោម៥ ឆ្នាំខ្វះទម្ងន់<br>*គិតតាមស្តង់ដារថ្មីនៃការលូតលាស់របស់អង្គការសុខភាពពិភពលោក* | | | ៣៦<br>*(២៩)* | ២០០៥ | ២៩<br>*(២៥)* | ២២,៦<br>*(២០)* |
| ៧. ％ នៃកុមារអាយុក្រោម ៥ ឆ្នាំដែលស្គមស្គាំង | | | ៧,៣ | ២០០៥ | ៧ | ៥ |
| ៨. ជំងឺស្លេកស្លាំងលើស្ត្រីក្នុងវ័យបន្តពូជ (％) | | | ៤៦,៦ | ២០០៥ | ៣២ | ១៩ |

| | | | | | | |
|---|---|---|---|---|---|---|
| ៩. ជំងឺស្លេកស្លាំងនៅក្នុង ស្ត្រីមានផ្ទៃពោះ (%) | | | ៥៧,១ | ២០០៥ | ៣៩ | ៣៣ |
| ១០. ស្ត្រីក្នុងវ័យបន្តពូជដែលមាន BMI ទាប (%) | | | ២០ | ២០០៥ | ១២ | ៨ |
| ១១. សមាមាត្រទារកដែលបានដាក់ឱ្យបៅដោះក្នុងរយៈពេលមួយម៉ោងក្រោយកំណើត (%) | | | ៣៥ | ២០០៥ | ៤៥ | ៦២ |
| ១២. សមាមាត្រទារកអាយុ ០-៦ ខែ ដែលបានទទួលការបំបៅដោះតែមួយមុខ (%) | | | ៦០ | ២០០៥ | ៦៥ | ៧០ |
| ១៣. សមាមាត្រកុមារក្រោមមួយឆ្នាំដែលបានទទួលថ្នាំបង្ការពេញលេញ (%) | | | ៦០ | ២០០៥ | ៧០ | ៨០ |
| ១៤. កុមារអាយុក្រោម ៥ ឆ្នាំ មានក្អកឬពិបាកដកដង្ហើមដែលបានព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ (%) | | | ៤៨ | ២០០៥ | ៧០ | ៧៥ |
| ១៥. សមាមាត្រកុមារដែលមានជំងឺរាគដែលបានទទួលORT (%) | | | ៥៨ | ២០០៥ | ៨០ | ៨៥ |
| *១៦.* អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមមនុស្សអាយុ ១៥-៤៩ឆ្នាំ (%) *(c)* *(e)* | | | ០,៦<br>០,៩ | ២០០៥<br>២០០៧ | < ០,៦<br>< ០,៩ | < ០,៦<br>< ០,៩ |
| ១៧. អត្រាស្លាប់នៃជំងឺរបេងលើប្រជាជន ១០០.០០០ នាក់ *(f)* | | | ៧៥ | ២០០៧ | ៦០ | ៣២ |
| ១៨. អត្រាស្លាប់នៃជំងឺគ្រុនចាញ់លើប្រជាជន ១.០០០ នាក់ *(c)* | | | ០,៣៦ | ២០០៥ | ០,២ | ០,១ |
| ១៩. អត្រាស្លាប់ដោយជំងឺគ្រុនឈាមដែលរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ | ✓ | ✓ | ០,៧៤ | ២០០៥ | ០,៥ | ០,៣ |
| ២០. % នៃមរណភាពដោយសារគ្រោះថ្នាក់ចរាចរណ៍ | | | ៣,៥ | ២០០៥ | ៣,០ | ២,៨ |
| **ការផ្តល់សេវាសុខភាព** សូចនាករភាគច្រើនបង្ហាញពីការផ្លាស់ប្តូរ ការមកទទួលនិងប្រើប្រាស់សេវា ការគ្របដណ្តប់និងគុណភាពនៃការថែទាំ ហើយសូចនាករខ្លះទៀតក៏បង្ហាញពីការផ្លាស់ប្តូរនៃស្ថានភាពសុខភាពផងដែរ។ សូចនាករនេះនិងតាមដានរៀងរាល់ឆ្នាំតាមរយៈប្រព័ន្ធព័ត៌មានសុខាភិបាល និង ប្រភពផ្សេងទៀត។ | | | | | | |
| ១. % នៃមណ្ឌលសុខភាពផ្តល់ ស.ស.អ MPA ពេញលេញ | ✓ | | ន.ប | | ន.ក | ន.ក |
| ២. % នៃមន្ទីរពេទ្យបង្អែកផ្តល់ ស.ស.ប CPA ពេញលេញ | ✓ | | ន.ប | | ន.ក | ន.ក |
| ៣. % នៃប្រជាជនដែលទទួលបានសេវា MPA ពេញលេញ | ✓ | ✓ | ន.ប | | ន.ក | ន.ក |
| ៤. % នៃប្រជាជនដែលទទួលបានសេវា CPA2 | ✓ | | ន.ប | | ន.ក | ន.ក |
| ៥. អត្រាប្រើប្រាស់គ្រែ (%) | ✓ | ✓ | ៧៥ | ២០០៧ | > ៧៥ | > ៧៥ |
| ៦. រយៈពេលមធ្យមនៃការសំរាកព្យាបាល (ចំនួនថ្ងៃ) | ✓ | ✓ | ៥ | ២០០៧ | ៥ | ៥ |
| ៧. % នៃឱសថសារវ័ន្ត (១៥ មុខក្នុងបញ្ជី) នៅមណ្ឌលសុខភាពដែលបានប្រឈមមុខនឹងការដាច់ស្តុក | ✓ | ✓ | ៥,៧ | ២០០៧ | ៥ | ៣ |
| ៨. ចំនួនមូលដ្ឋានសុខាភិបាលដែលបានអនុវត្តគោលការណ៍ណែនាំគ្លីនិកយោងតាម MPA និង CPA | ✓ | | ន.ប | | ន.ក | ន.ក |

| | | | | | | |
|---|---|---|---|---|---|---|
| ៩. % នៃអតិថិជនដែលពេញចិត្តនឹងគុណភាពសេវាសាធារណៈ | ✓ | ✓ | ន.ប | | ន.ក | ន.ក |
| ១០. ការពិគ្រោះជំងឺ (ករណីថ្មី) លើប្រជាជនម្នាក់ក្នុងមួយឆ្នាំ | ✓ | ✓ | | | | |
| – ករណីពិគ្រោះជំងឺទាំងអស់ | | | ០,៥១ | ២០០៧ | ០,៦ | ១ |
| – កុមារក្រោម៥ ឆ្នាំ | | | ១,៥ | ២០០៧ | ១,៧ | ២ |
| ១១. % នៃមណ្ឌលសុខភាពដែលបានអនុវត្តយុទ្ធសាស្ត្រ IMCI | ✓ | | ៥៦ | ២០០៧ | ៧៥ | ៨០ |
| ១២. ប្រេវ៉ាឡង់នៃវិធីពន្យារកំណើតទំនើប *(c)* | ✓ | ✓ | ២៧ | ២០០៥ | ៤០ | ៦០ |
| ១៣. ពិនិត្យផ្ទៃពោះមុនសំរាល ២ដង ឬ ច្រើនដងដោយបុគ្គលិកសុខាភិបាល (%) *(c)* | ✓ | ✓ | ៦៨<br>៦០ | ២០០៧<br>២០០៥ | ៧៣ | ៩០ |
| ១៤. % នៃស្ត្រីមានផ្ទៃពោះដែលបានទទួលជាតិដែក/ហ្វូលិកបន្ថែម | ✓ | | ៦៩ | ២០០៧ | ៧៥ | ៩០ |
| ១៥. % នៃស្ត្រីមានផ្ទៃពោះទទួលថ្នាំបង្ការជំងឺតេតាណូសយ៉ាងតិច ២ដង | ✓ | | ៦៩ | ២០០៧ | ៨៥ | ៩០ |
| ១៦. % នៃស្ត្រីមានផ្ទៃពោះដែលបានទទួល ART សម្រាប់ PMTCT | ✓ | ✓ | ៧ | ២០០៧ | ៤៥ | ៧៥ |
| ១៧. % នៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមានការបណ្តុះបណ្តាល *(c)* | ✓ | ✓ | ៤៤ | ២០០៥ | ៥៥ | ៨០ |
| ១៨. %នៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាលនៅមូលដ្ឋានសុខាភិបាល *(c)* | ✓ | | ២២ | ២០០៥ | ៤០ | ៧០ |
| ១៩. % នៃការសម្រាលកូនដោយវះកាត់ | ✓ | ✓ | ១,៨ | ២០០៧ | ២,៥ | ៤ |
| ២០. % នៃស្ត្រីក្រោយសម្រាលដែលបានទទួលជាតិដែក/ហ្វូលិកបន្ថែម | ✓ | | ៥៧ | ២០០៧ | ៨៥ | ៩០ |
| ២១. % នៃកុមារអាយុក្រោមមួយឆ្នាំដែលបានចាក់ថ្នាំបង្ការ DPT3-HepB | ✓ | | ៨២ | ២០០៧ | ៩២ | ៩៥ |
| ២២. % នៃកុមារអាយុក្រោមមួយឆ្នាំបានទទួលថ្នាំបង្ការជំងឺកញ្ជ្រិល | ✓ | ✓ | ៧៩ | ២០០៧ | ៨៥ | ៩០ |
| ២៣. % នៃកុមារអាយុ ៦-៥៩ ខែដែលបានទទួលវីតាមីនអា ២ ដូសក្នុងរយៈពេល១២ខែចុងក្រោយ | ✓ | | ៨៣ | ២០០៧ | ៨៥ | ៩០ |
| ២៤. % នៃកុមារអាយុ ៦-៥៩ ខែដែលបានទទួលមេបង់ដាហ្សូល រាល់ ៦ខែម្តង | ✓ | | ៩០ | ២០០៦ | ៩៨ | ១០០ |
| ២៥. ចំនួនកន្លែងផ្តល់ប្រឹក្សា-ធ្វើតេស្តឈាមដោយសម្ងាត់ និងស្ម័គ្រចិត្តដែលដំណើរការនៅក្នុងវិស័យសាធារណៈនិងវិស័យមិនគិតផលកម្រៃ | ✓ | | ១៩៤ | ២០០៧ | ២៥០ | > ២៥០ |
| ២៦. % នៃអ្នកផ្ទុកមេរោគអេដស៍កំរិតខ្ពស់ទទួលការព្យាបាលដោយឱសថពន្យាជីវិតច្រើនមុខ | ✓ | | ៥០ | ២០០៧ | > ៨៥ | > ៨៥ |

| | | | | | | |
|---|---|---|---|---|---|---|
| ២៧. ٪ នៃអ្នកផ្ទុកមេរោគអេដស៍ដែលប្រើឱសថពន្យាជីវិតនៅរស់ក្រោយការព្យាបាលរយៈពេល១២ខែ | ✓ | ✓ | *គ្មានពត៌មាន* | | > ៨៥ | > ៨៥ |
| ២៨. ប្រេវ៉ាឡង់នៃរបេងបេកាវិជ្ជមានលើប្រជាជន ១០០.០០០នាក់ | | | ២៣៤ | ២០០៧ | ២១៤ | ១៣៥ |
| ២៩. អត្រាស្រាវជ្រាវករណីជំងឺរបេងស្ទួតបេកាវិជ្ជមាន (٪) | ✓ | ✓ | ៦៦ | ២០០៧ | > ៧០ | > ៧០ |
| ៣០. អត្រាជាសះស្បើយនៃការព្យាបាលជំងឺរបេង (٪) | ✓ | ✓ | > ៨៥ | ២០០៧ | > ៨៥ | > ៨៥ |
| ៣១. ចំនួនករណីគ្រុនចាញ់ដែលបានព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈក្នុងចំណោមប្រជាជន ១.០០០ នាក់ | ✓ | ✓ | ៤ | ២០០៧ | ៣,៥ | ៣ |
| ៣២. អាំងស៊ីដង់ជំងឺគ្រុនចាញ់ក្នុងមនុស្ស ១.០០០ នាក់ដែលបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ | | | ៤,២ | ២០០៧ | ៣,៥៨ | ២,១៦ |
| ៣៣. ٪ នៃគ្រួសារដែលរស់នៅក្នុងតំបន់ជំងឺគ្រុនចាញ់ខ្ពស់(<១គម ពីព្រៃ) នៃខេត្ត-ក្រុង ២០ ដែលមានមុងជ្រលក់ថ្នាំគ្រប់គ្រាន់ (១ មុងសម្រាប់មនុស្ស ២នាក់) | ✓ | | ៦៤ | ២០០៧ | ៨៥ | ៩៥ |
| ៣៤. ប្រេវ៉ាឡង់ជំងឺទឹកនោមផ្អែមលើមនុស្សពេញវ័យដែលបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ | ✓ | ✓ | ២ | ២០០៥ | < ២ | < ២ |
| ៣៥. អាំងស៊ីដង់ជំងឺមហារីកមាត់ស្បូនលើមនុស្ស ១០.០០០នាក់ដែលបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ | ✓ | | ២៥ | ២០០៣ | ២១ | ១២,៥ |
| ៣៦. អាំងស៊ីដង់នៃជំងឺលើសឈាមលើមនុស្ស ១.០០០ នាក់ | ✓ | | ២០ | ២០០៧ | ១៩ | ១៥ |
| ៣៧. អត្រានៃការងងឹតភ្នែក (٪) | ✓ | | ១,២ | ១៩៩៥ | ០,៥ | <០,៣ |
| ៣៨. ٪ នៃកុមារដែលមានធ្មេញពុកមិនបានប៉ះ | ✓ | | ៨,៩ | ២០០៧ | < ៥ | < ៥ |
| ៣៩. ចំនួននៃករណីជំងឺផ្លូវចិត្តដែលបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ | ✓ | ✓ | ១០.០០០ | ២០០៧ | ១៩.០០០ | ២៨.០០០ |
| ៤០. ចំនួននៃអ្នកចាក់គ្រឿងញៀនដែលបានចុះឈ្មោះក្នុងការព្យាបាលជំនួសដោយ Opioids | ✓ | | ១០០ | ២០០៧ | ៤០០ | ១.២០០ |
| ៤១. ٪ នៃមនុស្សពេញវ័យជក់បារី បុរស/ស្ត្រី | ✓ | | ៥៤/៩ | ២០០៤ | ៤៩/៤ | ៤៤/២ |
| ៤២. ٪ នៃអ្នករបួសដែលមានការប៉ះទង្គិចក្បាលដោយសារគ្រោះថ្នាក់ចរាចរណ៍ដែលបានទទួលការព្យាបាល | ✓ | ✓ | ៤១ | ២០០៧ | ៣៨ | ៣៥ |
| **ធាតុចូល/ដំណើរការនៃប្រព័ន្ធសុខាភិបាល** | | | | | | |
| **ហិរញ្ញប្បទាន** | | | | | | |
| ៤៣. ចំណែកនៃការចំណាយរបស់រដ្ឋលើសុខភាព: *(b)* | ✓ | | | | | |
| • ធៀបនឹងការចំណាយសរុបរបស់រដ្ឋាភិបាល ٪ | | | ១១,៣ | ២០០៧ | ន.ក | ន.ក |
| • គិតជាភាគរយនៃ GDP ٪ | | | ១,០ | ២០០៧ | ន.ក | ន.ក |
| ៤៤. ការចំណាយជាក់ស្តែងគិតជា٪នៃថវិកាដែលបានអនុម័ត *(b)* | | | ៩១ | ២០០៧ | យ៉ាងតិច៩០ | យ៉ាងតិច៩០ |

| | | | | | | |
|---|---|---|---|---|---|---|
| ៤៥. ការចំណាយលើសុខភាពរបស់រដ្ឋក្នុងមនុស្សម្នាក់ក្នុង១ឆ្នាំ *(b)* | ✓ | | US$ ៦ | ២០០៧ | ន.ក | ន.ក |
| ៤៦. ចំណែកនៃថវិកាជំនួយដែលបានរាយការណ៍នៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ (%) | ✓ | | ៦៦ | ២០០៧ | ១០០ | ១០០ |
| ៤៧. ភាគទានម្ចាស់ជំនួយលើសុខភាពសាធារណៈក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំ *(i)* | ✓ | | US$ ៧ | ២០០៧ | ន.ក | ន.ក |
| ៤៨. ការចំណាយលើសុខភាពរបស់គ្រួសារក្នុងម្នាក់ក្នុង១ឆ្នាំ *(c)* | ✓ | | US$ ២៤ | ២០០៥ | ន.ក | ន.ក |
| ៤៩. ចំណែកនៃថវិការដ្ឋនៃសុខាភិបាលខេត្ត-ក្រុងចំណាយនៅ:*(b)* | ✓ | ✓ | ន.ប | | ន.ក | ន.ក |
| • មន្ទីរសុខាភិបាលខេត្ត-ក្រុង | | | | | | |
| • ការិយាល័យស្រុកប្រតិបត្តិ | | | | | | |
| • មន្ទីរពេទ្យបង្អែក | | | | | | |
| • មណ្ឌលសុខភាព | | | | | | |
| ៥០. ការគ្របដណ្តប់នៃមូលនិធិសមធម៌: *(j)* | ✓ | ✓ | | | | |
| • % នៃប្រជាជនរស់ក្រោមបន្ទាត់នៃភាពក្រីក្រត្រូវបានការពារដោយមូលនិធិសមធម៌ | | | ន.ប | | ន.ក | ន.ក |
| • % នៃមូលដ្ឋានសុខាភិបាល (មន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព) អនុវត្តមូលនិធិសមធម៌ | | | ន.ប | | ន.ក | ន.ក |
| ៥១. ការគ្របដណ្តប់នៃការធានារ៉ាប់រងសុខភាពនៅសហគមន៍ *(j)* | ✓ | | | | | |
| • ចំនួនគំរោងការធានារ៉ាប់រងសុខភាពនៅសហគមន៍ដែលបានអនុវត្ត | | | ៩ | ២០០៧ | ន.ក | ន.ក |
| • ចំនួនសមាជិកដែលទទួលផលប្រយោជន៍ (គ្រួសារ/មនុស្ស) | | | ៤៥០០០នាក់ | ២០០៧ | ន.ក | ន.ក |
| ៥២. ការគ្របដណ្តប់នៃការអនុវត្តន៍កិច្ចសន្យាផ្តល់សេវា *(j)* | ✓ | ✓ | | | | |
| • ចំនួនស្រុកប្រតិបត្តិអនុវត្តកិច្ចសន្យា | | | ២០ | ២០០៧ | ន.ក | ន.ក |
| • ចំនួនមូលដ្ឋានសុខាភិបាលអនុវត្តទីភ្នាក់ងារប្រតិបត្តិការពិសេស | | | ០ | ២០០៧ | ន.ក | ន.ក |
| ៥៣. ការចំណាយប្រចាំឆ្នាំលើសុខភាពរបស់គ្រួសារសំរាប់មនុស្សម្នាក់ក្នុងវិស័យសាធារណៈ: *(j)* | ✓ | | US$០,៨៦ | ២០០៧ | ន.ក | ន.ក |
| **ធនធានមនុស្ស** | | | | | | |
| ៥៤. ផលធៀបរវាងវេជ្ជបណ្ឌិតរបស់ក្រសួងសុខាភិបាលនឹងប្រជាជន ១០.០០០នាក់ តាមទីកន្លែង: *(k)* | ✓ | | | | | |
| • ទូទាំងប្រទេស (country ratio) | | | ០,១០ | ២០០៧ | ០,៣០ | ០,៥០ |
| • កំរិតមធ្យមថ្នាក់ខេត្ត (provincial average) | | | ០,០៧ | | | |
| • កំរិតកណ្តាលថ្នាក់ខេត្ត (provincial median) | | | ០,០៥ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៥៥. ផលធៀបឆ្មបមធ្យមរបស់ក្រសួងសុខាភិបាលនឹងប្រជាជន ១០.០០០នាក់ តាមទីកន្លែង៖ *(k)* | ✓ | | | | | |
| • ទូទាំងប្រទេស | | | ០,៥៥ | ២០០៧ | ០,៧៥ | ១ |
| • កំរិតមធ្យមថ្នាក់ខេត្ត | | | ០,៦៤ | | | |
| • កំរិតកណ្តាលថ្នាក់ខេត្ត | | | ០,៥៧ | | | |
| ៥៦. ផលធៀបគិលានុបដ្ឋាកមធ្យមរបស់ក្រសួងសុខាភិបាលនឹងប្រជាជន ១០.០០០នាក់ តាមទីកន្លែង៖ *(k)* | ✓ | | | | | |
| • ទូទាំងប្រទេស | | | ១,២១ | ២០០៧ | ១,៥ | ២ |
| • កំរិតមធ្យមថ្នាក់ខេត្ត | | | ១,៣៩ | | | |
| • កំរិតកណ្តាលថ្នាក់ខេត្ត | | | ១,៣០ | | | |
| ៥៧. % នៃមណ្ឌលសុខភាពដែលមានបុគ្គលិកស្របតាមសេចក្តីណែនាំអំពី ស.ស.អ MPA | ✓ | ✓ | ន.ប | | ន.ក | ន.ក |
| ៥៨. ចំនួនមន្ទីរពេទ្យបង្អែកដែលមានបុគ្គលិកស្របតាមសេចក្តីណែនាំអំពី ស.ស.ប CPA | ✓ | | ន.ប | | ន.ក | ន.ក |
| ៥៩. % នៃបុគ្គលិកដែលគ្របដណ្តប់ដោយគម្រោងលើកទឹកចិត្ត | ✓ | | ន.ប | | ន.ក | ន.ក |
| **ប្រពន្ធ័ពត៌មាន** | | | | | | |
| ៦០. % នៃមន្ទីរពេទ្យបង្អែកដែលមានប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល(HMIS)តាមប្រពន្ធ័កំព្យូទ័រ *(l)* | ✓ | | ០ | ២០០៧ | ៧០ | ១០០ |
| ៦១. % របាយការណ៍ស្តីពី HMIS ដែលបានដាក់ជូនទាន់ពេលវេលា៖ | ✓ | | | | | |
| • HC1និងHO2មកស្រុកប្រតិបត្តិ | | | ន.ប | | ន.ក | ន.ក |
| • DO3 មកមន្ទីរសុខាភិបាល | | | ន.ប | | ន.ក | ន.ក |
| • PRO4 មកក្រសួងសុខាភិបាល | | | ៧៣ | ២០០៧ | ១០០ | ១០០ |
| ៦២. % នៃមន្ទីរសុខាភិបាលទទួលពត៌មានត្រលប់ HIS ពីក្រសួង | ✓ | ✓ | ន.ប | | ន.ក | ន.ក |
| ៦៣. % នៃការិយាល័យស្រុកប្រតិបត្តិទទួលពត៌មានត្រលប់ពី HIS ពីមន្ទីរសុខាភិបាលខេត្ត-ក្រុង | | | ន.ប | | ន.ក | ន.ក |
| **អភិបាលកិច្ចប្រព័ន្ធសុខាភិបាល** | | | | | | |
| ៦៤. % នៃមូលនិធិជំនួយសម្រាប់សុខភាពដែលបានដាក់បញ្ចូលក្នុងផែនការរំកិល៣ឆ្នាំ | ✓ | ✓ | ន.ប | | ន.ក | ន.ក |
| ៦៥. % នៃអង្គភាពក្រសួងសុខាភិបាលដែលមានផែនការ ការអភិវឌ្ឍស្ថាប័នជាយុទ្ធសាស្ត្រ | ✓ | | ន.ប | | ន.ក | ន.ក |

| | | | | | | |
|---|---|---|---|---|---|---|
| ៦៦. % នៃគ្រឹះស្ថានឯកជន (ប៉ូលីគ្លីនិក បន្ទប់ពិគ្រោះ ជំងឺ មន្ទីរសម្ភព ឱសថស្ថាន គ្លីនិកព្យាបាលធ្មេញ.... ។ល។ ដែលបានផ្តល់អាជ្ញាប័ណ្ណ ប្រកបអាជីវកម្ម : | ✓ | ✓ | ន.ប | | ន.ក | ន.ក |
| ៦៧. ចំនួនគណៈកម្មការ គ្រប់គ្រងមណ្ឌលសុខភាពដែលដំណើរការ | ✓ | ✓ | ន.ប | | ន.ក | ន.ក |

**ប្រភពសំរាប់ទិន្នន័យគោល:**

*(a)* UN Human Development Report, 2005

*(b)* ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ (NSDP 2006-2010)

*(c)* ការអង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា២០០៥ (CDHS 2005)

*(d)* ការអង្កេតចន្លោះជំរឿននៅកម្ពុជា ២០០៤ (Cambodia Inter-population Survey 2004)

*(e)* Expert Consensus Workshop on Estimation of HIV Prevalence, 2007

*(f)* ការអង្កេតស្តីពីប្រេវ៉ាឡង់នៃជំងឺរបេង ២០០២

*(h)* របាយការណ៍នាយកដ្ឋានថវិកានិងហិរញ្ញវត្ថុ- ក្រសួងសុខាភិបាល

*(i)* របាយការណ៍ស្តីពីមូលនិធិជំនួយឆ្នាំ ២០០៧, នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ- ក្រសួងសុខាភិបាល

*(j)* របាយការណ៍ហិរញ្ញប្បទានសុខាភិបាលប្រចាំឆ្នាំ ២០០៨, នាយកដ្ឋានផែនការនិងពត៌មានសុខាភិបាល

*(k)* របាយការណ៍នាយកដ្ឋានបុគ្គលិក

*(l)* លើកលែងមន្ទីរពេទ្យជាតិដែល HMIS បានដាក់ឱយដំណើរការរួចមកហើយ

ន.ប នឹងបង្កើត

ន.ក នឹងកំណត់

# សន្ទានុក្រម

**ការទទួលខុសត្រូវ**
Accountability

គឺជាការទទួលស្គាល់និង បន្ទុកនៃទទួលខុសត្រូវចំពោះសកម្មភាព ការសំរេចចិត្ត និងគោលនយោបាយ ដោយរាប់បញ្ចូលនូវកាតព្វកិច្ចរាយការណ៍ ពន្យល់ និងឆ្លើយបំភ្លឺចំពោះហេតុបច្ច័យដែលកើតមាន ។

**ការទទួលស្គាល់ជាផ្លូវការ**
Accreditation

គឺបែបបទស្ម័គ្រចិត្តដែលតាមរយៈនេះការទទួលស្គាល់ជាសាធារណៈនូវគុណភាពនៃស្ថាបន័សុខាភិបាលមួយត្រូវបានបង្ហាញ តាមរយៈការវាយតំលៃដោយក្រុមឯករាជ្យលើកំរិតនៃស្នាដៃរបស់អង្គភាពនេះចំពោះបទដ្ឋានគុណភាពដែលអាចទទួលយកបានជាទូទៅ ។ បទដ្ឋានសំរាប់បែបបទនៃការទទួលស្គាល់ជាផ្លូវការនេះ ត្រូវបានកំណត់ក្នុងកំរិតអតិបរមាដែលអាចនឹងសំរេចបានដើម្បីជំរុញឱ្យមានការកែលំអក្នុងរយៈពេលមួយជាកំណត់ ។

**ការតំរៀបតំរង់**
Alignment

បែបបទដែលតាមរយៈនេះគោលនយោបាយ និតិវិធី ប្រពន្ធ័ ការផ្តល់មូលនិធិ វដ្តផែនការនីយកម្ម និងការត្រួតពិនិត្យតាមដាននៃសកម្មភាពរបស់អ្នកផ្តល់ជំនួយត្រូវដាក់ឱ្យស្របតាមគោលនយោបាយ និតិវិធី ប្រពន្ធ័ ការផ្តល់មូលនិធិ វដ្តផែនការនីយកម្មនិងការត្រួតពិនិត្យតាមដានរបស់រដ្ឋាភិបាល ដើម្បីធានាថាអាទិភាពដែលកំណត់ដោយប្រទេសកម្ពុជាក្លាយជាអាទិភាពរបស់ម្ចាស់ជំនួយ ។

**កញ្ចប់ភាគផល**
Benefit package

សំណុំអប្បបរមានៃសេវាដែលផ្តល់ឱ្យអ្នកមានការទទួលរ៉ាប់រងសុខភាពនៅក្នុងក្របខណ្ឌនៃកំរិតប្រាក់បង់ភាគទាន ក៏ដូចជាអ្នកក្រីក្រដែលបានទទួលការគាំពារដោយមូលនិធិសមធម៌ ។

**បន្ទុកជំងឺ**
Burden of diseases

គឺទំងន់នៃការឈឺរបស់បុគ្គល សហគមន៍និងប្រទេសទាំងមូល ។ ការវាស់វែងអំពីបន្ទុកជំងឺអាចរាប់បញ្ចូលទាំងអាយុកាលរំពឹងទុកវែង គុណភាពជីវិតនិងផលប៉ះពាល់លើសេដ្ឋកិច្ចនិងសង្គម ។

**ការចំណាយសំរាប់មនុស្សម្នាក់**
Capitation payment

ចំណាយថេរឱយអ្នកផ្តល់សេវា–គណនាសំរាប់មនុស្សម្នាក់ៗ ដែលបានចុះឈ្មោះក្នុងបញ្ជីធានារ៉ាប់រងសុខភាពសំរាប់រយៈពេលមួយ បរិមាណចំណាយជាក់លាក់ត្រូវបានទូទាត់ជាដំណាក់ៗឱយអ្នកផ្តល់សេវាសំរាប់សំណុំសេវាសុខភាពជាក់លាក់ដោយមិនគិតអំពីបរិមាណ (សេវា) ដែលត្រូវទូទាត់ ។

**ការចំណាយដ៏មហន្តរាយលើសុខភាព**
Catastrophic health expenditures

ស្ថានភាពដែលគ្រួសារចំណាយលើសុខភាពលើសពី៤០%នៃប្រាក់ចំណូលរបស់ខ្លួនបន្ទាប់ពីការចំណាយលើតំរូវការចិញ្ចឹមជីវិត ដូចជាម្ហូបអាហារ ។ ការចំណាយដ៏មហន្តរាយនេះអាចបណ្តាលមកពីការឈឺធ្ងន់ធ្ងរ ឬមួយដោយសារថ្លៃចំណាយខ្ពស់ ប៉ុន្តែមិន (ឈឺ) ញឹកញាប់ ឬមួយថ្លៃចំណាយទាបប៉ុន្តែឈឺញឹកញាប់ពេក ។

**ការធានារ៉ាប់រងសុខភាពតាមសហគមន៍** Community based health insurance

ជាទំរង់ការមីក្រូធានារ៉ាប់រងសុខភាព ដែលគ្រប់គ្រងដោយឯករាជ្យភាពដោយសមាជិកសហគមន៍ ដោយអង្គការដែលមានមូលដ្ឋាននៅក្នុងសហគមន៍ ។

**កិច្ចសន្យា**
Contracting

យន្តការមួយសំរាប់ការផ្តល់សេវាសាធារណៈ: សំដៅឆ្លើយតបទៅនឹងតំរូវការរបស់អ្នកប្រើប្រាស់សេវា ពង្រឹងប្រសិទ្ធភាពការងារ និងលើកកំពស់គុណភាពសេវា ដើម្បីទទួលបាននូវជំនឿទុកចិត្តពីអ្នកប្រើប្រាស់សេវា។ ការអនុវត្តន៍យន្តការកិច្ចសន្យា គឺជាបែបបទដែលក្នុងនេះកិច្ចព្រមព្រៀងជាផ្លូវការត្រូវបានធ្វើឡើងរវាងអ្នកចេញចំណាយជាមួយនឹងក្រុមអ្នកជាវឬបុគ្គលជាអ្នកបញ្ជាទិញសេវា អ្នកធានារ៉ាប់រងដោយបញ្ជាក់ច្បាស់អំពី អត្រា ករណីយកិច្ចនិងទំនាក់ទំនងក្នុងចំណោមភាគីទាំងអស់ តារាងភាគផលនិងលក្ខខណ្ឌពាក់ពន្ធ័ដទៃទៀត។ នៅក្នុង ផ.យ.ស.២ កិច្ចសន្យានេះគ្របដណ្តប់ទាំង "កិច្ចសន្យាផ្ទៃក្នុង" និង "កិច្ចសន្យាក្រៅ" ។

**កិច្ចសន្យាផ្ទៃក្នុង** (Internal contract) សំដៅលើការរៀបចំនិងចាត់ចែងវិធីសាស្រ្តកិច្ចសន្យាដែលក្នុងនេះទាំងអ្នកបញ្ជាទិញសេវានិងអ្នកផ្តល់សេវា គឺជាវិស័យសុខាភិបាលសាធារណៈ។ កិច្ចសន្យាផ្ទៃក្នុង គឺកិច្ចព្រមព្រៀងត្រូវបានធ្វើឡើង រវាងក្រសួងសុខាភិបាល (អ្នកបញ្ជាទិញសេវានិងជាអ្នកចេញចំណាយ) ជាមួយនឹងមន្ទីរសុខាភិបាលខេត្ត-ក្រុង និង/ឬស្រុកប្រតិបត្តិ (ជាអ្នកផ្តល់សេវា)។ មន្ទីរសុខាភិបាលខេត្ត-ក្រុងអាចរៀបចំចាត់ចែងកិច្ចសន្យាផ្ទៃក្នុងជាមួយស្រុកប្រតិបត្តិ ហើយស្រុកប្រតិបត្តិអាចជាមួយ មន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព។

**កិច្ចសន្យាក្រៅ** (External contract) សំដៅលើការរៀបចំនិងចាត់ចែងវិធីសាស្រ្តកិច្ចសន្យាដែលក្នុងនេះទាំងអ្នកបញ្ជាទិញសេវាគឺជាវិស័យសុខាភិបាលសាធារណៈ រីឯនិងអ្នកផ្តល់សេវាគឺជាវិស័យឯកជន។ កិច្ចសន្យាក្រៅ គឺកិច្ចព្រមព្រៀងត្រូវបានធ្វើឡើងរវាងក្រសួងសុខាភិបាល (អ្នកបញ្ជាទិញសេវានិងជាអ្នកចេញចំណាយ)ជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលនិង/ឬឯកជនរកផលកំរៃ (ជាអ្នកផ្តល់សេវា)។

**ថ្លៃចំណាយ**
Cost

ធនធានដែលគិតជារូបិយវត្ថុដែលបានចំណាយនៅក្នុងការអនុវត្តន៍សកម្មភាព

**ចំណាយបន្ថែមកើនតាមកំរិត** (Incremental cost): ថ្លៃចំណាយលើសម្មភាពថ្មី ដែលមួយផ្នែកនៃការចំណាយនេះ បានកើតមានរួចមកហើយ។

**Marginal cost** បរិមាណអាស្រ័យទៅតាមកំរិតលទ្ធផលដែលកើតមាន ដែលនៅពេលនេះតំលៃសរុបបានប្រែប្រួល ប្រសិនបរិមាណនៃលទ្ធផលកើនឡើងឬថយចុះក្នុង១ឯកត្តា។

**ចំណាយកាលានុវត្ត** (Opportunity cost): បរិមាណកំរិតអតិបរមាដែលអាចទទួលបាន នៅពេលណាមួយ ប្រសិនបើនៅពេលនោះទ្រព្យរបស់ឬធនធានត្រូវបានគេលក់បញ្ចេញ ជួលឬយកទៅប្រើប្រាស់ក្នុងជំរើសដ៏មានតំលៃបំផុត។

**គណនាថ្លៃចំណាយ**
Costing

បច្ចេកទេស និងបែបបទនៃការសិក្សាឱយឃើញច្បាស់លាស់ ពីបរិមាណនៃការចំណាយដែលបានកើតមានលើផលិតផលនិងសេវាជាក់ស្តែង។

**វិមជ្ឈការ**
Decentralization

ការផ្ទេរអំណាចពីរដ្ឋាភិបាលកណ្តាលទៅឱយអាជ្ញាធរថ្នាក់ក្រោម។

| | |
|---|---|
| **វិសហមជ្ឈការ**<br>Deconcentration | បែបបទដែលតាមរយៈនេះ មុខងាររដ្ឋបាលនៅក្នុងក្របខណ្ឌឋានានុក្រមនៃរដ្ឋាភិបាលកណ្តាល ត្រូវបានផ្ទេរពីក្រសួងទៅឱយមន្ត្រីប្រតិបត្តិថ្នាក់មូលដ្ឋាន ដោយការផ្ទេរបន្ទុកការងារ ការបង្កើតទីភ្នាក់ងារប្រតិបត្តិថ្នាក់មូលដ្ឋាន ឬការផ្ទេរការទទួលខុសត្រូវទៅឱយអង្គភាពរដ្ឋបាលមូលដ្ឋានដែលជាផ្នែកមួយនៃរចនាសម្ព័ន្ធរដ្ឋាភិបាលកណ្តាល។ |
| **តំរូវការ**<br>Demand | បរិមាណនៃរបស់ដែលអ្នកទិញចង់បាន ហើយមានលទ្ធភាពអាចទិញបាននៅចំពោះមុខថ្លៃខុសៗគ្នា។ |
| **សុខភាពបរិស្ថាន**<br>Environmental Health | សុខភាពបរិស្ថានដោះស្រាយកត្តាបរិស្ថាននានា ដែលអាចប៉ះពាល់ជាសក្តានុពលដល់សុខភាព។ ដំណោះស្រាយនេះតំរង់ឆ្ពោះទៅរកការបង្ការជំងឺ និងការបង្កើតនូវបរិស្ថានមួយគាំទ្រដល់សុខភាព។ |
| **ប្រសិទ្ធផល**<br>Effectiveness | ផល/ហេតុបច្ច័យនៃសកម្មភាព និងលទ្ធផលបញ្ចប់ លទ្ធផលឬភាគផលសំរាប់ប្រជាជន ដែលសំរេចបានក្នុងទំនាក់ទំនងនឹងគោលដៅដែលបានកំណត់។ នេះគឺជាការសំដែងឱយឃើញអំពីផល/ហេតុបច្ច័យគួរឱយសោមនស្សនៃកម្មវិធីអន្តរាគមន៍សេវា នៅក្នុងការកាត់បន្ថយបញ្ហាសុខភាព ឬកែលំអស្ថានភាពសុខភាពដែលមិនគួរជាទីពេញចិត្ត។ |
| **ប្រសិទ្ធភាព**<br>Efficiency | ផល/ហេតុបច្ច័យឬលទ្ធផលបញ្ចប់ដែលសំរេចបាន ក្នុងទំនាក់ទំនងទៅនឹងកិច្ចប្រឹងប្រែងដែលបានចំណាយដោយគិតជាសាច់ប្រាក់ ធនធាន និងពេលវេលា។ |
| **មុខងារសារវន្តនៃសុខភាពសាធារណៈ**<br>Essential public health functions | គឺសំណុំសកម្មភាពជាមូលដ្ឋានដែលដោះស្រាយកត្តាប៉ះពាល់ដល់សុខភាព ការពារសុខភាពប្រជាជននិងព្យាបាលជំងឺ។ សកម្មភាពទាំងនេះនឹងបង្ការព្រមទាំងគ្រប់គ្រងកត្តារួមចំណែកចំបងៗដល់បន្ទុកជំងឺ ដោយប្រើប្រាស់មានប្រសិទ្ធភាពនូវបច្ចេកទេស និតិក្រម រដ្ឋបាលនិងអន្តរាគមន៍ដើម្បីផ្លាស់ប្តូរឥរិយាបទ ឬធ្វើឱយខ្វាចញញើត ដូច្នេះវាផ្តល់នូវអភិក្រមសំរាប់សកម្មភាពអន្តរវិស័យចំពោះសុខភាព។ *(Yach D. Redefining the scope of public health beyond the year 2000. Current Issues in Public Health, 1996, 2:247-252.)* |
| **សមធម៌**<br>Equity | គ្មានភាពខុសគ្នាដាច់ខាតអំពីស្ថានភាពសុខភាពនិងលទ្ធភាពមកទទួលនិងប្រើប្រាស់សេវាថែទាំសុខភាពដោយយោងតាមតំរូវការរវាងក្រុមមនុស្សក្នុងសង្គមដែលមានឬក៏គ្មានផលប្រយោជន៍សង្គមជាមូលដ្ឋានពោលគឺមានស្ថានភាពខុសៗគ្នានៅក្នុងឋានានុក្រមសង្គម។ សេវាសុខភាពត្រូវមានសំរាប់ប្រជាជនទាំងអស់ចូលមកប្រើប្រាស់នៅពេលត្រូវការចាំបាច់ ដោយមិនគិតអំពីលទ្ធភាពដែលអាចបង់ថ្លៃសេវា។ |
| **គោលបំណង**<br>Goal | គោលបំណងគឺជាគោលដៅអភិវឌ្ឍន៍កំរិតខ្ពស់ជាធម្មតា គោលបំណងត្រូវបានបញ្ជាក់ក្នុងន័យទូទៅ (ទូលំទូលាយ) ហើយមានរយៈពេលវែង (៣-៥ឆ្នាំ)។ គោលបំណងគឺជាអ្វីចុងក្រោយដែលស្ថាប័ន/អង្គភាពមួយពុះពារ ដើម្បីសំរេចបានដោយឈរលើមូលដ្ឋាននៃយុទ្ធសាស្ត្រ និងផែនការ។ |

**សុខដុមនីយកម្ម**
Harmonization

បែបបទដើម្បីរៀបចំជាខ្សែសង្វាក់ ឱយមានភាពងាយស្រួល និងសំរបសំរួលរាល់វិធីសាស្ត្រ និងនិតិវិធី របស់ដៃគូអភិវឌ្ឍន៍ ទាំងក្នុងចំណោមអ្នកផ្តល់ជំនួយ ទាំងជាមួយរដ្ឋាភិបាល។មានន័យថាការសំរបសំរួលជំនួយក្រៅប្រទេសឱយទៅតាមនិតិវិធី ស្ថាបន័និងប្រពន្ធ័ជាតិនៅកន្លែងណាដែលអាចធ្វើបាន។

**ហិរញ្ញប្បទានការថែទាំសុខភាព**
Health care financing

មុខងារស្នូលនៃហិរញ្ញប្បទានការថែទាំសុខភាពគឺៈ ប្រមូលប្រាក់ចំណូល ប្រមូលផ្តុំធនធាន និងជាវសេវាៈ

**ប្រមូលប្រាក់ចំណូល**(Collecting revenue) ជាបែបបទដែលប្រពន្ធ័សុខាភិបាលទទួលលុយតាមមធ្យោបាយនានាក្នុងការប្រមូលចំណូលៈដូចជាពន្ធអារករទូទៅ ការធានារ៉ាប់រងសុខភាពសង្គម ការធានារ៉ាប់រងសុខភាពវិសយ័ឯកជន ការចំណាយប្រាក់ហោប៉ៅ ជំនួយឥតសំណងអំណោយមនុស្សធម៌និងកម្ចីពហុភាគី។

**ប្រមូលផ្តុំធនធាន**(Pooling of resources) ជាបែបបទនៃការប្រមូលផ្តុំនិងការគ្រប់គ្រងប្រាក់ចំណូល ដើម្បីធានាថាហានិភយ័នៃចំណាយសំរាប់ការថែទាំសុខភាពត្រូវចេញដោយសមាជិកទាំងអស់នៅក្នុងក្រុម (ធានារ៉ាប់រង)មិនមែនចេញដោយអ្នកបង់ប្រាក់ធានារ៉ាប់រងជាបុគ្គលទេ។

**ជាវសេវា**(Purchasing) សុខភាពគឺជាបែបបទមួយដែលតាមរយៈនេះ អន្តរាគមន៍លើសុខភាពដែលត្រូវការចាំបាច់បំផុតនិងមានប្រសិទ្ធភាពត្រូវបានគេជ្រើសយកនិងផ្តល់ឱយក្នុងលក្ខណៈសក្តិសិទ្ធនិងសមធម៌ហើយអ្នកផ្តល់សេវាទទួលការទូទាត់យ៉ាងសមស្របដើម្បីផ្តល់សេវានិងអន្តរាគមន៍ដែលបានកំណត់។ការជាវសេវាមានសមាសធាតុប្រទាក់ក្រឡាគ្នាបីៈបែងចែកធនធានហិរញ្ញវត្ថុបង្កើតជំរើសសំរាប់ទូទាត់ដល់អ្នកផ្តល់សេវា និងចុះកិច្ចសន្យាជាមួយអ្នកផ្តល់សេវា។

**ពត៌មានសុខាភិបាល**
Health information

ពត៌មានសុខាភិបាលជាបរិមាណក្តីនិងជាគុណភាពក្តី ដែលអាចយកមកប្រើប្រាស់ដោយអ្នកធ្វើសេចក្តីសំរេចចិត្តនិងគ្រូពេទ្យព្យាបាល ដើម្បីយល់ដឹងបានល្អអំពីការប្រព្រឹត្តទៅនៃជំងឺនិងបញ្ហាថែទាំសុខភាពនានានិងដើម្បីបង្ការ ធ្វើរោគវិនិច្ឆយ័ឬព្យាបាលបញ្ហាសុខភាព។ ពត៌មានសុខាភិបាលគប្បីត្រួសត្រាយការរកៀងគរនិងវិភាជន៍ធនធាន ការកំណត់អាទិភាពនៃកម្មវិធីសុខភាព និងការស្រាវជ្រាវ ព្រមទាំងលើកស្ទួយប្រសិទ្ធភាពនិងប្រសិទ្ធផលនៃកម្មវិធីសុខភាព។

**ការធានារ៉ាប់រងសុខភាព**
Health insurance

ការគាំពារផ្នែកហិរញ្ញវត្ថុទល់នឹងការចំណាយលើការថែទាំសុខភាពដែលបណ្តាលមកពីជំងឺ ឬរបួសផ្សេងៗ។ ការកាត់បន្ថយ ឬការលប់បំបាត់គ្រោះហានិភយ័ដែលកើតមានមិនទៀងទាត់ទៅលើការខាតបង់សំរាប់បុគ្គលឬគ្រួសារ។តាមរយៈការប្រមូលផ្តុំគ្នាយ៉ាងច្រើននៃបុគ្គលឬគ្រួសារដែលមានភាពប្រឈមប្រហាក់ប្រហែលគ្នា ហើយត្រូវបានធានាដោយមូលនិធិរួម មូលនិធិនេះនឹងជួយប៉ះប៉ូវការខាតបង់ដែលកើតមាននៅលើសមាជិកណាម្នាក់។

**អាំងស៊ីដង់**
Incidence

ទំហំហានិភយ័នៃស្ថានភាពនៃជំងឺដែលកំពុងកើតមាន នៅអំលុងពេលមួយជាក់លាក់។ អត្រាអាំងស៊ីដង់គឺជាចំនួនករណីថ្មីនៃជំងឺក្នុងអំលុងពេលមួយជាក់លាក់។

**សូចនាករ**
Indicator

គឺជារង្វាស់សំរាប់ពិនិត្យផ្ទៀងផ្ទាត់មើលថាតើគោលដៅត្រូវបានសំរេចដល់កំរិតណា ហើយអាចវាស់វែងវឌ្ឍនភាពនិងការផ្លាស់ប្តូរឆ្ពោះទៅរកការសំរេចនូវលទ្ធផល។ សូចនាករអាចវាស់វែងបរិមាណនិង/ឬគុណភាព ដែលទាក់ទងនឹងទិដ្ឋភាពនៃការថែទាំ ឬបញ្ហាគ្រប់គ្រង/ស្ថាប័ន ទៅតាមពេលវេលាកំណត់ និងអាចបញ្ជាក់អំពីភូមិសាស្ត្រ និងក្រុមគោលដៅចំណុច។

**ការអភិវឌ្ឍន៍ស្ថាបន័**
Institutional Development

សំដៅលើ“បែបបទនៃការប្រព្រឹត្តទៅ”និង“មាតិកា”នៃការផ្លាស់ប្តូរនៅក្នុងស្ថាប័ន។ ពាក្យថា “បែបបទនៃការប្រព្រឹត្តទៅ”បង្ហាញពី“មធ្យោបាយ” ដើម្បីសំរេចបាននូវការផ្លាស់ប្តូរ និងពាក្យថា“មាតិកា”បញ្ជាក់អំពី“អ្វី”ដែលត្រូវសំរេច។

**ការផ្តល់អជ្ញាបណ្ណ**
Licensing

គឺបែបបទជាកាតព្វកិច្ច ដែលតាមរយៈនេះអជ្ញាធររបស់រដ្ឋាភិបាលផ្តល់ការអនុញ្ញាតិដល់អ្នកប្រកបវិជ្ជាជីវៈម្នាក់ៗឬអង្គភាពសុខភាពណាមួយឱ្យប្រតិបត្តិឬចូលរួមពាក់ពន្ធ័ ក្នុងការប្រកបមុខរបរឬវិជ្ជាជីវៈ។

**បេសកកម្ម**
Mission statement

បញ្ជាក់អំពីបំណងប្រាថ្នារបស់ក្រសួងសុខាភិបាល ដែលឆ្លុះបញ្ចាំងពីរដ្ឋធម្មនុញ្ញ និងក្រិត្យនៃព្រះរាជាណាចក្រកម្ពុជា ។

**គណនីសុខាភិបាលជាតិ**
National Health Accounts

ក្របខណ្ឌ័និងវិធីសាស្ត្រសំរាប់វាស់ និងបង្ហាញពត៌មានស្តីអំពីការចំណាយលើសុខភាពសរុបរបស់រដ្ឋ ដោយរាប់បញ្ចូលទាំងមូលនិធិពីប្រភពរដ្ឋនិងឯកជន។ គណនីសុខាភិបាលជាតិតាមដានស្នាមធនធានហិរញ្ញវត្ថុចាប់ពីប្រភពដើម រហូតដល់អ្នកផ្តល់សេវា និងមុខងារ។ វាមានសារៈសំខាន់ដោយសារប្រពន្ធ័សុខាភិបាលស្មុគ្រស្មាញ អ្នកតាក់តែងគោលនយោបាយត្រូវការឧបករណ៍ដើម្បីវិភាគហិរញ្ញប្បទានលើការថែទាំសុខភាពថា តើមានបរិមាណធនធានប៉ុន្មាននិងត្រូវបានប្រើប្រាស់យ៉ាងដូចម្តេចក្នុងប្រពន្ធ័សុខាភិបាល? តើលំនាំអ្វីនៃការបែងចែកធនធានការប្រើប្រាស់និងជំរើសដែលមាន។

**គោលដៅ**
Objective

បង្ហាញអំពីផ្លាស់ប្តូរដែលគិតថាមានសារៈសំខាន់ ក្នុងការដោះស្រាយបញ្ហាដែលបានកំណត់អត្តសញ្ញាណនៅក្នុងអំលុងពេលនៃផែនការ។ គោលដៅគប្បីអធិប្បាយអំពីបញ្ហាចំបងៗដែលត្រូវដោះស្រាយឬស្ថាបភាពដែលត្រូវផ្លាស់ប្តូរ។

**សុខភាពវិជ្ជាជីវៈ**
Occupational health

សុខភាពនិងសុវត្ថិភាពក្នុងពេលបំពេញការងារនៅកន្លែងធ្វើការ។សុខភាពវិជ្ជាជីវៈនិងសុខមាលភាពរបស់អ្នកធ្វើការងារ គឺជាបុរេលក្ខខណ្ឌ័ដ៏សំខាន់សំរាប់ផលិតភាពនិងមានសារៈប្រយោជន៍បំផុតសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចទូទៅប្រកបដោយចិរភាព។

**ការចំណាយប្រាក់ហោប៉ៅ**
Out-of-pocket payment

ការចំណាយចេញពីហោប៉ៅដែលសាធារណៈជនប្រឈមមុខ ដោយអ្នកជំងឺត្រូវទូទាត់ដោយផ្ទាល់ទៅឱ្យអ្នកផ្តល់សេវាដោយគ្មានសំណងមកវិញ។

**គោលនយោបាយ**
Policy

ការព្រមព្រៀង ឬការយល់ស្របគ្នា ក្នុងចំណោមដៃគូពាក់ពន្ធ័ស្តីអំពីបញ្ហាដែលនឹងត្រូវដោះស្រាយ និងស្តីអំពីអភិក្រម ឬយុទ្ធសាស្ត្រត្រូវយកទៅដោះស្រាយបញ្ហាទាំងនោះ។

**គោលនយោបាយសុខាភិបាល** (health policy) សេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាសំរាប់បរិបទទូទៅ ដែលក្នុងនេះការងារសុខាភិបាលនិងការងារពាក់ព័ន្ធនឹងសុខាភិបាលត្រូវបានអភិវឌ្ឍន៍ និងអនុវត្តន៍។

**ទិសដៅគោលនយោបាយសុខាភិបាល**(Policydirection) បញ្ជាក់អំពីវិសាលភាពការងារសំរាប់វិស័យសុខាភិបាលទាំងមូលក្នុងអំលុងពេលពីឆ្នាំ២០០៨-២០១៥ ដើម្បីលើកកំពស់ស្ថានភាពសុខភាពប្រជាជនកម្ពុជា និងមុខងារស្នូលរបស់ប្រពន្ធ័សុខាភិបាលប្រកបដោយចិរភាព។

**ទំរង់ការបុរេបង់ថ្លៃ**
Prepayment scheme
វិធីនៃការទូទាត់ថ្លៃចំណាយលើសេវាថែទាំសុខភាពទុកជាមុន មុនពេលប្រើប្រាស់។ វិធីនេះចេញថ្លៃចំណាយទុកជាមុនលើផលប្រយោជន៍ដែលបានកំណត់សំរាប់ក្រុមប្រជារាស្ត្រ តាមរយៈការទូទាត់ចំណាយតាមដំណាក់កាលនៅក្នុងរូបភាពជាប្រាក់បង់ធានារ៉ាប់រងជាប់ជំពាក់ ឬការបង់ភាគទាន ដោយរាប់បញ្ចូលការបង់វិភាគទានទាំងអស់នោះ ទៅក្នុងមូលនិធិសុខភាពដោយនិយោជិកដែលតំណាងឱយនិយោជិតរបស់ខ្លួន។

**ប្រេវ៉ាឡង់** Prevalence
គឺចំនួនសរុបនៃករណីនៃជំងឺមួយក្នុងក្រុមប្រជាជននៅពេលវេលាកំណត់មួយ។

**វិស័យឯកជន**
Private sector
ផ្នែកសេដ្ឋកិច្ចមួយរបស់ប្រទេសដែលមិនស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋាភិបាល។ ផ្នែកឯកជនក្នុងប្រទេសកម្ពុជាមានដំណើរការខុសគ្នា ដែលអាចសង្ខេបជា ឯកជនយកកំរៃ មិនយកកំរៃនិងផ្នែកក្រៅផ្លូវការ ។

**វិស័យសាធារណៈ**
Public sector
នៅក្នុងផែនការយុទ្ធសាស្ត្រនេះវិស័យសាធារណៈ ទាក់ទងទៅនឹងសេវាដែលត្រូវផ្តល់មូលនិធិនិងគ្រប់គ្រងនៅក្នុងប្រព័ន្ធរាជរដ្ឋាភិបាល ។

**ការធានាគុណភាព/គុណភាព**
Quality assurance/Quality
ជាពាក្យទូទៅប្រើសំដៅលើសកម្មភាពនិងប្រព័ន្ធ សំរាប់ការពិនិត្យតាមដាន និងការកែលំអគុណភាពឱយប្រសើរឡើង។ វាទាក់ទងនឹងការវាស់វែង និងការវាយតំលៃគុណភាព ប៉ុន្តែក៏គ្របដណ្តប់លើសកម្មភាពដទៃទៀត ដើម្បីបង្ការគុណភាពអន់ថយនិងធានាគុណភាពខ្ពស់។

**ការគ្រប់គ្រងប្រកបដោយគុណភាព**(Qualitymanagement) កំរិតនៃភាពល្អឥតខ្ចោះនៃសេវា ឬប្រព័ន្ធដែលឆ្លើយតបទៅនឹងតំរូវការផ្នែកសុខភាពរបស់អ្នកដែលត្រូវការបំផុតដោយចំណាយទាបក្នុងក្របខណ្ឌព្រំដែនកំណត់ សេចក្តីបង្គាប់និង/ឬនិយ័តកម្ម។ មានន័យថាត្រូវពិនិត្យមើលបញ្ហានានាដូចជាសមធម៌ លទ្ធភាពប្រើប្រាស់សេវា ប្រសិទ្ធភាព ភាពត្រឹមត្រូវនិងការឆ្លើយតប។

**ការផ្តល់សេវាប្រកបដោយគុណភាព** (Quality in health services) សំដៅលើគុណភាពនៃសេវាបង្ការនិងថែទាំព្យាបាលដែលអាចវាស់បានដោយសវនកម្មគ្លីនិក។ ការឈានទៅដល់ការបង្ការនិងថែទាំព្យាបាលមានគុណភាពខ្ពស់ គឺត្រូវការជាចម្បងតាន្ទុវព័ត៌មានអំពីការផ្តល់សេវានិងអន្តរាគមន៍ដែលកំពុងមាននិងឧបសគ្គក្នុងការផ្តល់សេវា។ព័ត៌មានស្តីពីចំនួននិងប្រភេទនៃអ្នកផ្តល់សេវា ការយល់ដឹងអំពីការអនុវត្តន៍ជាក់ស្តែង និងឥរិយាបទរបស់អ្នកផ្តល់សេវា និងរបៀបនៃការប្រើប្រាស់សេវារបស់អតិថិជនក៏ត្រូវការចាំបាច់ដែរ ។

**គុណភាពជីវិត**
Quality of life

គឺកំរិតនៃសុខមាលភាពដែលកើតមានចំពោះបុគ្គល ឬក្រុមប្រជាជន។ គុណភាពជីវិតមិនអាចវាស់វែងដោយផ្ទាល់បានទេ ហើយវាមានសមាសភាគពីរៈ ទីមួយគឺទិដ្ឋភាពនៃសរីរាង្គកាយដែលរាប់បញ្ចូលនូវសុខភាព របបអាហារ ការទប់ទល់ប្រឆាំងនឹងការឈឺចាប់និងជំងឺ។ ទីពីរគឺសភាពចិត្តសាស្ត្រដែលរាប់បញ្ចូលនូវ stress កង្វល់ សប្បាយ និងស្ថានភាពអារម្មណ៍វិជ្ជមានឬអវិជ្ជមានដទៃទៀត។

**និយតកម្ម** Regulation

វិធាន បទបញ្ញត្តិឬច្បាប់ដែលធ្វើឱយការប្រតិបត្តិត្រូវបានធានាតាមបទដ្ឋានដែលបានកំណត់។

**ការវិភាជន៍ធនធាន**
Resource allocation

បែបបទដែលតាមនេះ ធនធានដែលមាន/អាចរកបាន ត្រូវបានបែងចែក/ចែកចាយរវាងការប្រើប្រាស់ដ៏ប្រកួតប្រជែងទុកជាមធ្យោបាយមួយក្នុងការសំរេចគោលបំណងពិតប្រាកដមួយ។

**អភិក្រមគ្រប់គ្រងបើកទូលាយទូទាំងវិស័យ**
Sector-wide Approaches

បែបបទនៃការប្រព្រឹត្តទៅដើម្បីបង្កើនភាពជាម្ចាស់ នៅក្នុងការដាក់ចេញនូវគោលនយោបាយដោយអនុញ្ញាតិឱយមានការបន្តចូលរួម រាប់បញ្ចូលទាំងការសន្ទនាក្នុងវិស័យពីសំណាក់ទីភ្នាក់ងារនិងស្ថាប័នទាំងអស់ទាំងសាធារណៈនិងឯកជន។ អភិក្រមនេះនឹងផ្តល់ក្របខណ្ឌការងារមួយមានភាពបត់បែន ដែលក្នុងនេះភាពផ្សេងៗគ្នានៃការរៀបចំចាត់ចែងការផ្តល់មូលនិធិនិងការអនុវត្តន៍អាចនឹងត្រូវបានតំរូវទៅតាមលក្ខខណ្ឌនៅនឹងកន្លែង ដោយផ្អែកលើយុទ្ធសាស្ត្ររួម និងការរៀបចំចាត់ចែងការគ្រប់គ្រងដែលបានឯកភាពគ្នាទៅវិញទៅមក។

**កត្តាសង្គមដែលមានឥទ្ធិពលលើសុខភាព**
Social determinants of health

គឺជា “មូលហេតុនៃមូលហេតុ” នៃជំងឺនិងសុខភាពទ្រុឌទ្រោម។ មូលហេតុទាំងអស់នោះគឺជារចនាសម្ពន្ធ័គ្រឹះនៃឋានានុក្រមសង្គម និងលក្ខខណ្ឌកំណត់ក្នុងសង្គមជាច្រើនទៀត ដែលបង្កើតរចនាសម្ពន្ធ័នេះ សំរាប់មនុស្សធំធាត់ រស់នៅ ធ្វើការ និងអាយុវែង។ *(Commission on the Social Determinants of Health. WHO)*

**ថវិកាកញ្ចប់សំរាប់ការផ្តល់សេវា**
Service delivery grant

មូលនិធិម្ចាស់ជំនួយផ្តល់ឱយថ្នាក់ប្រតិបត្តិ ដើម្បីលើកកំពស់ការផ្តល់សេវា តាមរយៈការបង្កើនស្វយ័តភាពនៃការគ្រប់គ្រងនិងការទទួលខុសត្រូវនៅថ្នាក់ប្រតិបត្តិ។ការវិភាជន៍ធនធានដល់ថវិកាកញ្ចប់សំរាប់ការផ្តល់សេវានិងត្រួតពិនិត្យតាមដានស្នាដៃការងារ នឹងប្រព្រឹត្តទៅតាមបែបបទនៃផែនការប្រតិបត្តិប្រចាំឆ្នាំ។

**ជំនួយសង្គម**
Social assistance

ផលប្រយោជន៍ជាសាច់ប្រាក់ ឬជារបស់របរដែលទទួលហិរញ្ញប្បទានពីរដ្ឋ មិនមែនជាវិភាគទានហើយដែលភាគច្រើនត្រូវបានផ្តល់ឱយដោយឈរលើមូលដ្ឋាននៃមធ្យោបាយដែលអាចមាន ឬ កំរិតប្រាក់ចំណូល។

**ការធានារ៉ាប់រងសុខភាពសង្គម**
Social health insurance

ការធានារ៉ាប់រងសុខភាពគឺជាកាតព្វកិច្ច ហើយត្រូវបានចាត់ទុកថាជាផ្នែកមួយនៃប្រពន្ធ័សន្តិសុខសង្គមដែលផ្តល់មូលនិធិដោយការបង់ភាគទាន និងគ្រប់គ្រងដោយអង្គភាពរដ្ឋស្វយ័ត/ប្រតិពទ្ធ័មានកិត្យានុកូលភាព។

**ការគាំពារសុខភាពសង្គម**
Social health protection

សំណុំគោលនយោបាយនិងកម្មវិធីដែលត្រូវបានបង្កើតឡើង ដើម្បីការពារបុគ្គលទល់គ្រោះអាសន្ន លើសរីរាង្គកាយ ផ្នែកសេដ្ឋកិច្ចនិងសង្គម ដែលបណ្តាលមកពីមានជំងឺ មាតុភាព របួស បាត់បង់សមត្ថភាពការងារនិងស្លាប់។ល។

| | |
|---|---|
| **បណ្ដាញសុវត្ថិភាពសង្គម**<br>Social safety nets | ប្រពន្ធ័មួយដែលអនុញ្ញាតិឱយពលរដ្ឋខ្សត់ខ្សោយផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ច បន្តទទួលសេវាសង្គមតាមរយៈសេវាមិនបង់ថ្លៃ ការថែទាំទំនុកបំរុង ការធានារ៉ាប់រងសង្គមនិងជំនួយសង្គម។ |
| **ភ្នាក់ងារប្រតិបត្តិការពិសេស**<br>Special Operating Agency | គឺជាអង្គភាពមួយរបស់ក្រសួង/ស្ថាប័នដែលត្រូវបានចាត់តាំងឡើង ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនិងប្រសិទ្ធផលនៃការងារ ពង្រឹងការទទួលខុសត្រូវ ជំរុញគំនិតផ្តួចផ្តើម សំដៅពង្រឹងវប្បធម៌នៃការយកចិត្តទុកដាក់ដល់អ្នកប្រើប្រាស់សេវា។ លក្ខខណ្ឌដើម្បីអនុវត្តយន្តការភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវផ្អែកលើចំណុច ៤ ជាមូលដ្ឋានៈ<br>• ផ្តោតការយកចិត្តទុកដាក់លើតំរូវការជាអាទិភាពរបស់អ្នកប្រើប្រាស់សេវា ដោយកំណត់ច្បាស់អំពីប្រភេទ គុណភាព និងតំលៃសេវាដែលត្រូវផ្តល់។<br>• កំណត់ច្បាស់អំពីលទ្ធផលរំពឹងទុកនិងធនធានចាំបាច់នានា<br>• កំណត់ច្បាស់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ភ្នាក់ងារនេះ<br>• កំណត់ច្បាស់អំពីយន្តការនៃការត្រួតពិនិត្យតាមដាន និងវាយតំលៃ |
| **បទដ្ឋាន**<br>Standards | លក្ខខណ្ឌឬកំរិតព្រំដែនដែលត្រូវបានបង្កើតឡើងដើម្បីប្រើប្រាស់ជាវិធានឬមូលដ្ឋានសំរាប់ធ្វើការប្រៀបធៀបក្នុងការវាស់វែង ឬវិនិច្ឆ័យសមត្ថភាព គុណភាព និង/ឬ បរិមាណ។ |
| **មគ្គុទេសភាព**<br>Stewardship | ប្រមូលផ្តុំនៅលើភារកិច្ចក្នុងការកំណត់ចក្ខុវិស័យ និងទិសដៅគោលនយោបាយសុខាភិបាល ការដាក់ឱយប្រើប្រាស់ប្រកបដោយអានុភាពទូទាំងវិស័យសុខាភិបាល (ទាំងវិស័យសុខាភិបាលសាធារណៈនិងឯកជន)តាមរយៈនិយ័តកម្ម ការតស៊ូមតិ ការប្រមូល–វិភាគ និងប្រើប្រាស់ពត៌មាន។ |
| **គោលដៅចំណុច**<br>Target | បញ្ជាក់អំពីកំរិតរំពឹងទុកនៃការសំរេចគោលដៅ នៅក្នុងក្របខណ្ឌពេលវេលាដែលបានកំណត់ ម្យ៉ាងវិញទៀតវាបញ្ជាក់ថាតើការសំរេចបានមានទំហំប៉ុណ្ណា នៅចុងបញ្ចប់នៃរយៈពេលដែលគ្របដណ្តប់ដោយផែនការ។ គោលដៅអាចមានលក្ខណៈច្បាស់លាស់ កាលណាមានបញ្ជាក់គោលដៅចំណុច។ |
| **គុណតំលៃ**<br>Values | តំលៃនិងគោលការណ៍តំណាងអោយឧត្តមគតិរបស់ក្រសួងសុខាភិបាល និងផ្តល់នូវក្រមសីលធម៌និងចរិយាសាស្ត្រដែលណែនាំដល់ការធ្វើសេចក្តីសំរេចចិត្តដើម្បីទទួលនូវជោគជ័យ។ តំលៃនិងគោលការណ៍នេះមានសារៈសំខាន់ក្នុងការប្រាស្រយ័ទាក់ទងបំភ្លឺសំណួរនៃហេតុផលនានាដែលគាំទ្រដល់ការធ្វើសេចក្តីសំរេចចិត្ត ។ |
| **ចក្ខុវិស័យ**<br>Vision | ចក្ខុវិស័យគឺជាឥន្ទៈនៃភាពជាអ្នកដឹកនាំ និងជាការព្រមព្រៀងគ្នាអំពីអនាគត ឬទិសដៅជាយុទ្ធសាស្ត្រដែលផ្តល់ឱយនូវសេចក្តីសង្ឃឹមនិងចលនាវិវត្តន៍។ |
| **ការគ្របដណ្តប់ជាសកល**<br>Universal coverage | លទ្ធភាពមកទទួលយកនូវអន្តរាគមន៍ផ្នែកសុខភាពសំខាន់ៗ របស់មនុស្សគ្រប់រូប ដូចជាការលើកស្ទួយសុខភាព ការបង្ការ ព្យាបាល និងស្តារនិតិសម្បទានៅចំពោះមុខការចំណាយដែលអាចទ្រាំទ្របាន ដូច្នេះអាចសំរេចបាននូវសមធម៌ក្នុងការមកទទួលយកសេវា ។ |

**ការបង់ថ្លៃសេវា**
User charges

ការចំណាយលើរបស់របរនិងសេវា យោងតាមបញ្ជីតំលៃ ឬតារាងតំលៃ។ ប្រពន្ធ័បង់ថ្លៃបែបនេះតាមធម្មតាគឺគ្មានសមធម៌ទេ។ ដោយសារបង្ខំឱយអ្នកជំងឺបង់ថ្លៃសេវា និងធ្វើឱយអ្នកក្រីក្រចំណាយច្រើនជាងអ្នកមាន បើគិតជាសមាមាត្រ។

សន្ទានុក្រមនេះត្រូវបានដកស្រង់និងកែសំរួលចេញពី: ផែនការយុទសាស្រ្តសុខាភិបាល២០០៣-២០០៧ គោលនយោបាយជាតិស្តីពីការកែលំអគុណភាព សៀវភៅធ្វើផែនការ (ក្រសួងសុខាភិបាល) គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាលរបាយការណ៍វាយតំលៃវឌ្ឍនភាពនៃការគ្រប់គ្រងបើកទូលាយទូទាំងវិសយ័ យុទ្ធសាស្រ្តស្តីពីហិរញ្ញប្បទានការថែទាំសុខភាព (WHO/WPRO) ឯកសារនានារបស់អង្គការសុខភាពពិភពលោក និងឯកសារបោះពុម្ពផ្សាយដទៃទៀត។